# ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៨

## ទារកដែលកើតពីការពពោះជំនួស មុនថ្ងៃ ៨ ខែមករា ឆ្នាំ ២០១៨ នៅតែត្រូវអនុញ្ញាតឲ្យបញ្ជូនចេញ

https://www.postkhmer.com/ ដោយ ច័ន្ទនីដា | Publication date 01 April 2018 | 11:35 ICT

**ភ្នំពេញៈ** មន្ត្រីឲ្យដឹងថា កម្ពុជានៅអនុញ្ញាតឲ្យមានការនាំទារកដែលកើតចេញពីការពពោះមុនថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៨ អាចនាំចេញទៅចិញ្ចឹមនៅក្រៅប្រទេសបាននៅឡើយ ចៀសវាងការ «បារម្ភ» ចំពោះចំណាត់ការផ្លូវច្បាប់ ដែលនេះជាការបកស្រាយពីលើសេចក្តីណែនាំថ្មីមួយដែលចេញផ្សាយ កាលពីថ្ងៃទី ២៩ ខែមីនា ថ្មីៗនេះ។

សេចក្តីណែនាំមួយរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) ណែនាំឲ្យអាជ្ញាធរបន្តសុពលភាពនៃគោលការណ៍មួយដែលចេញ កាលពីខែ មិថុនា ឆ្នាំ២០១៧ ទាក់ទងនឹងការពពោះជំនួសដើម្បីអនុវត្តចំពោះករណីទារកកើតមុនថ្ងៃ៨ ខែមករា ឆ្នាំ ២០១៨ បានយកចេញទៅក្រៅប្រទេស ។ លោក ស ខេង ប្រធានNCCT និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានសរសេរសេចក្តីណែនាំចុះថ្ងៃទី២៩ មីនាឲ្យបន្តសុពលភាពនៃការយកទារកដែលកើតមុនថ្ងៃ៨ខែមករា ឆ្នាំ២០១៨ ចេញទៅក្រៅប្រទេស ប៉ុន្តែត្រូវ «ហាមឃាត់ចំពោះករណីថ្មី» ដែលពពោះក្រោយថ្ងៃឱសានវាទនេះ។

លោកស្រី ជូ ប៊ុនអេង អនុប្រធាន NCCT និងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃបានពន្យល់ឲ្យភ្នំពេញប៉ុស្តិ៍បន្ថែមថា ៖ «អ្នកមិនទាន់យកទារកចេញទៅក្រៅប្រទេសបាននៅបន្ត យើងមិនចង់ឲ្យគាត់បារម្ភ។ ទោះបីកូនអាយុ ១ខួប ២ខួបក្តីពួកគេនៅតែអាចនាំយកចេញបាន»។ លោកស្រី ប៊ុនអេង បានឲ្យដឹងកាលពីចុងសប្តាហ៍ថា សេចក្តីព្រាងមួយនេះបានបញ្ចប់ត្រឹមតែ«ថ្នាក់មន្ត្រីបច្ចេកទេស»ប៉ុណ្ណោះ ហើយមានការពិភាក្សាផ្តល់យោបល់ជាច្រើនទៀត ដែលត្រូវធ្វើ ។ ទាក់ទងនឹងគោលការណ៍សុំនាំទារកកើតមុនខែមករាចេញនេះ លោកស្រី ប៊ុនអេង បានឲ្យដឹងថា មានជាង ១០ ករណីដែលមានទារកខ្លះ បានយកចេញទៅហើយ និងខ្លះទៀត នៅកំពុងរៀបចំវីសានៅឡើយ។ ទោះយ៉ាងណា លោកស្រីថា មានការលេចចេញនូវរូបភាពថ្មីគឺស្ត្រីដែលគេជួលឲ្យពពោះ បានចាកចេញពីកម្ពុជា ទៅប្រទេសថៃ ដើម្បីជាកន្លែងរង់ចាំការផ្តល់កំណើតដល់កូនដែលកើតចេញពីកាពពោះជំនួសវិញជាការគេចចេញការចោទប្រកាន់ថាខុសច្បាប់។

លោកស្រីបន្តថា៖«ឥឡូវវាមានរឿងផ្សេងទៀតហើយពីព្រោះគាត់ (ស្ត្រីខ្មែរ)នាំគ្នាចេញទៅថៃ ព្រោះឥឡូវ យើងកំពុងរៀបចំច្បាប់។ ចាំពិនិត្យលទ្ធភាព ពេលច្បាប់ចេញ តើច្បាប់ហ្នឹងមានទិសដៅយ៉ាងម៉េច ចាំគិតតាមហ្នឹងទៀត»។ កន្លងមករដ្ឋាភិបាល បានចាត់ទុកថា ករណីពពោះជំនួស ដោយយកទារកទៅចិញ្ចឹមនៅក្រៅប្រទេស ជាករណី «ខុសច្បាប់» ប៉ុន្តែកម្ពុជានៅមិនទាន់មានច្បាប់ស្តីពីការពពោះជំនួសនោះទេ ហើយច្បាប់មួយនេះកំពុងត្រូវបានរៀបចំដោយក្រសួងយុត្តិធម៌ សហការជាមួយក្រសួងកិច្ចការនារី ដែលកាលដើមខែមីនា ក្រោយជំនួបជាមួយអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្សអង្គការសហប្រជាជាតិលោកស្រី Rhona Smith ខាងក្រសួងយុត្តិធម៌ ឲ្យដឹងថា ពង្រាងច្បាប់មួយនេះបានបញ្ចប់ហើយ ដោយមាន ៩ជំពូក និង ៦២ មាត្រា។

សេចក្តីណែនាំរបស់លោក ស ខេង ក៏ជំរុញឲ្យមានការតាមដានស្វែងរក «អន្តរការី ឬជនដែលប្រើល្បិចឃុបឃិតអូសទាញឲ្យមានការពពោះជំនួស» មកផ្តន្ទាទោសតាមផ្លូវច្បាប់ផងដែរ៕

## រដ្ឋាភិបាលយោធាថៃនឹងបន្ធូរការរឹតបន្តឹងច្បាប់សម្រាប់ពលករខ្មែរក្នុងអំឡុងបុណ្យចូលឆ្នាំ

https://wmc.org.kh 30 មិនា 2018 ហ៊ុល រស្មី

ភ្នំពេញ៖ រដ្ឋាភិបាលយោធាថៃបានផ្តល់ការសម្រួលដល់ពលករខ្មែរ ដែលកំពុងធ្វើការបណ្តោះអាសន្ននៅប្រទេសថៃ ដោយឲ្យពួកគេមានលទ្ធភាពធ្វើដំណើរចេញចូលប្រទេសថៃ នៅមុនបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ហូតដល់

ដំណាច់ខែមេសា។ នេះបើយោងតាមលិខិតជូនដំណឹងរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ។ លិខិតរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃដែល VOA បានទទួលកាលពីយប់ថ្ងៃព្រហស្បតិ៍ បានសរសេរក្នុងន័យដើមថា៖ «ក្នុងអំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរនាពេលខាងមុខនេះ ភាគីកម្ពុជា និងថៃនឹងសហការគ្នាដើម្បីសម្រួលដល់ពលករ ដែលកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) នៅមានសុពលភាព និងពលករដែលកាន់លិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) ដែលមានទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារនៅមានសុពលភាព ព្រមទាំងអ្នកនៅក្នុងបន្ទុក អាចធ្វើដំណើរចេញ-ចូលប្រទេសថៃ-កម្ពុជាបានចាប់ពីថ្ងៃទី៥រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០១៨»។

លិខិតដដែលបានសរសេរបន្តថា៖ «ចំពោះបងប្អូនពលករ កាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) ដែលមានបំណងធ្វើដំណើរត្រឡប់មកកម្ពុជាវិញក្នុងអំឡុងពេលនេះ ត្រូវទៅស្នើសុំលិខិតអនុញ្ញាតពីមន្ទីរការងារថៃក្នុងខេត្ត ដែលខ្លួនធ្វើការ។ ដោយឡែក ចំពោះបងប្អូនពលករ ដែលកាន់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ (TD) ត្រូវទៅស្នើសុំទិដ្ឋាការចេញ-ចូល (Re-Entry Visa) នៅការិយាល័យអន្តោប្រវេសន៍ក្នុងខេត្ត ដែលខ្លួនធ្វើការ ឬនៅច្រកព្រំដែនអន្តរជាតិ ដោយពុំមានបង់កម្រៃសេវាឡើយ»។ លិខិតរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានបញ្ជាក់ឲ្យដឹងបន្តទៀតថា ពលករទាំងអស់ត្រូវឆ្លងកាត់តាមព្រំដែនអន្តរជាតិ ហើយប្រសិនជាត្រឡប់មកកម្ពុជាតាមច្រកណាត្រូវត្រឡប់ទៅថៃវិញតាមច្រកនោះ។ លិខិតបានបន្ថែមថា ពលករកម្ពុជាកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) មិនតម្រូវឲ្យសុំលិខិតធ្វើដំណើរបណ្តោះអាសន្ន (Laissez Passer) ដើម្បីធ្វើដំណើរត្រឡប់មកកម្ពុជាឡើយ ក្នុងអំឡុងពេលភាគីថៃ និងកម្ពុជាបានឯកភាពគ្នានេះ។

កាលពីពាក់កណ្តាលខែមីនា រដ្ឋាភិបាលយោធាថៃបានជូនដំណឹងដល់ពលករកម្ពុជាតាមស្ថានទូតប្រទេសកម្ពុជាប្រចាំនៅប្រទេសថៃ អំពីការកំណត់យកថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៨ ជាឱសានវាទសម្រាប់ពលករខ្មែរ ដើម្បីចុះឈ្មោះបន្តសុពលភាពប័ណ្ណស្នាក់នៅ និងធ្វើការបណ្តោះអាសន្ននៅប្រទេសនេះ មុនពេលអាជ្ញាធរថៃចាត់វិធានការខាងច្បាប់ «យ៉ាងតឹងរឹង»។

យោងតាមលិខិតរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដែលបានលើកឡើងខាងលើនេះ ពលករខ្មែរអាចធ្វើដំណើរចេញចូលប្រទេសថៃបាន តែលិខិតនោះមិនបានបញ្ជាក់ថា ពលករខ្មែរអាចបន្តធ្វើការនៅប្រទេសថៃ ដោយមិនប្រឈមនឹងចំណាត់ការផ្លូវច្បាប់នោះឡើយ។

រដ្ឋាភិបាលយោធាថៃ បានបង្កើនការរឹតបន្តឹងលើភាពស្របច្បាប់របស់ពលករបរទេសដែលកំពុងធ្វើការនៅប្រទេសខ្លួន ក្រោយការធ្វើវិសោធនកម្មច្បាប់ការងារថៃកាលពីឆ្នាំ២០១៧។

លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីនៃអង្គការការពារសិទ្ធិពលករ ហៅកាត់ថាសង់ត្រាល បានប្រាប់ VOA កាលពីពេលកន្លងមកថា រដ្ឋាភិបាលថៃតែងតែធ្វើការពន្យារពេលដល់ពលករកម្ពុជាសម្រាប់ឲ្យពួកគេបានទទួលនូវភាពស្របច្បាប់ធ្វើការងារនៅប្រទេសថៃ។ លោកមានប្រសាសន៍ថា ប្រសិនបើភាគីថៃអនុវត្តទៅតាមច្បាប់ការងារដែលត្រូវបានធ្វើវិសោធនកម្មកាលពីឆ្នាំ២០១៧ ឬហៅថា ច្បាប់ការងារថៃថ្មីនោះ នោះកម្មករដែលធ្វើការមិនតាមប្រភេទការងារដែលត្រូវបានអនុញ្ញាត ឬក៏ពុំមានឯកសារត្រឹមត្រូវ អាចប្រឈមនឹងការបណ្តេញចេញ ផាកពិន័យ និងជាប់ពន្ធនាគារមិនក្រោមពីប្រាំឆ្នាំទេ។

ការបង្ក្រាបរបស់រដ្ឋាភិបាលថៃលើពលករខ្មែរធ្លាប់បានធ្វើឡើងជាទ្រង់ទ្រាយធំ កាលពីបួនឆ្នាំមុន ពោលគឺកាលពីខែមិថុនាឆ្នាំ២០១៤ដែល ពលករខ្មែរជាង១៧ម៉ឺននាក់ត្រូវបានបង្ខំចិត្តចាកចេញពីប្រទេសថៃ ក្រោយពីរបបយោធាថៃ

បង្ក្រាបលើពលករខុសច្បាប់ក្នុងប្រទេសខ្លួន។ របាយការណ៍មួយរបស់អង្គការការពារសិទ្ធិពលករបង្ហាញថា យ៉ាងហោចណាស់មានពលករខ្មែរ១លាននាក់ធ្វើការនៅក្នុងប្រទេសថៃ ទាំងស្របច្បាប់ និងខុសច្បាប់៕

## ថៅកែ និងពលករបរទេស មានពេលដល់ចុងខែមេសា ដើម្បីសុំពន្យារសុពលភាពបណ្ណការងារជនបរទេស

https://wmc.org.kh/ ថ្ងៃសៅរ៍ ទី៣១ ខែមីនា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ ក្រសួងការងារកម្ពុជា កាលពីថ្ងៃទី២៩ ខែមីនា បានចេញសេចក្ដីជូនដំណឹង ដោយបញ្ជាក់ថា ក្រុមថៅកែ និងពលករបរទេស ដែលកំពុងរកស៊ីនៅកម្ពុជា មានពេលរហូតដល់ចុងខែមេសា ក្នុងការមកបំពេញបែបបទ សុំពន្យារសុពលភាពបណ្ណ ឬ សៀវភៅការងារជនបរទេស។ ករណីដែលជនបរទេស ធ្វើការនៅកម្ពុជា ដោយគ្មានច្បាប់ ពួកគេប្រឈម ការផាកពិន័យជាប្រាក់ ជាប់ពន្ធនាគារ និងបណ្ដេញចេញពីកម្ពុជា។

ក្រសួងការងារកម្ពុជា ធ្លាប់បានចេញសេចក្ដីជូនដំណឹងម្ដងរួចមកហើយ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ដោយកំណត់យកដំណាច់ខែមីនា ឆ្នាំ២០១៨ ជាឱសានទក្នុងការពន្យារសុពលភាពបណ្ណ ឬ សៀវភៅការងារជនបរទេស ។ ក៏ប៉ុន្ដែក្រសួងការងារបានសម្រេចពន្យារតទៅមុខទៀត បន្ទាប់ពី ក្រសួងសង្កេតឃើញថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសមួយចំនួន នៅមិនទាន់បានស្នើសុំពន្យារសុពលភាពបណ្ណ ឬសៀវភៅការងារជានបរទេសតាមសេចក្ដីជូនដំណឹងរបស់ក្រសួងការងារនៅឡើយ។ ដើម្បីបញ្ចៀសការផាកពិន័យតាមអត្រាប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ៤ម៉ឺនរៀល ក្រសួងការងារ ក៏សម្រេចពន្យារពេលសម្រាប់ស្នើសុំបន្តសុពលភាពបណ្ណ ឬសៀវភៅការងារជនបរទេស រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។ ក្រសួងការងារបង្ហាញក្ដីសង្ឃឹមថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសដែលប្រកបមុខរបរណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា នឹងប្រញាប់មកស្នើសុំពន្យារសុពលភាពបណ្ណ ឬសៀវភៅការងារជនបរទេស ឲ្យបានមុនថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។ ក្រសួងបញ្ជាក់ថា ក្នុងករណីដែលជនបរទេសទាំងថៅកែ និងពលករ ខកខានការសុំពន្យារសុពលភាពនេះ ក្រសួងនឹងចាត់វិធានការផាកពិន័យ តាមទោសប្បញ្ញត្តិក្នុងជំពូក ១៦ នៃច្បាប់ស្ដីពីការងារ និងបទប្បញ្ញត្តិជាធរមាន។

ជនបរទេស ដែលកំពុងធ្វើការងារនៅប្រទេសកម្ពុជា មានប្រមាណជាង ១៦ម៉ឺននាក់ ក៏ប៉ុន្ដែគឺមានជនបរទេសប្រមាណតែ ៥ម៉ឺន ៧ពាន់នាក់ ប៉ុណ្ណោះ ដែលមានប័ណ្ណការងារ ឬសៀវភៅការងារជនបរទេសស្របទៅតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

សម្ដេច ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានប្រសាសន៍ ក្នុងឱកាសពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារបន្ត កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ថា កម្ពុជាបានបាត់បង់ប្រាក់ចំណូលក្នុងមួយឆ្នាំៗ ជាង ២០លានដុល្លារ ព្រោះតែជនបរទេសទាំងថៅកែ និងពលករ មួយចំនួនមិនបានបង់ពន្ធជូនរដ្ឋ។ ក្រៅតែពីរដ្ឋត្រូវបាត់បង់ចំណូលជាថវិកាជាតិជនបរទេសខុសច្បាប់ទាំងនោះ ក៏បានធ្វើឲ្យពលរដ្ឋខ្មែរបាត់ឱកាសការងារផងដែរ ។ ព្រោះមើលឃើញដូចនេះ សម្ដេច ស ខេង បានថ្លែងដោយសង្កត់ធ្ងន់ៗថា រាជរដ្ឋាភិបាលកម្ពុជា នឹងមិនអនុញ្ញាតឲ្យមានជនបរទេសធ្វើការនៅកម្ពុជា ដោយមិនស្របច្បាប់ទៀតនោះទេ។

ជុំវិញរឿងនេះ លោកនាយឧត្ដមសេនីយ៍ សុខ ផល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ បានប្រាប់អ្នកសារព័ត៌មានកាលពីចុងខែកុម្ភៈ ដែរថា ប្រសិនបើជនបរទេសទាំងថៅកែ និងពលករ រឹងរូសមិនព្រមអនុវត្ត តាមអ្វីដែលជាច្បាប់របស់កម្ពុជា ពួកគេនឹងត្រូវបានបង្ខំឲ្យបង់ការផាកពិន័យ ឬក៏ត្រូវប្ដឹងឡើងតុលាការ ចាប់ដាក់ពន្ធនាគារ មុនបណ្ដេញចេញពីកម្ពុជា។ ជនបរទេសម្នាក់ៗ ត្រូវបង់ពន្ធជូនរដ្ឋនៅដំណាច់ឆ្នាំនីមួយៗ នូវទឹកប្រាក់ ១០០ដុល្លារ។ ក៏ប៉ុន្ដែក្នុងករណីជនបរទេស ទាំងថៅកែ និងពលករ មិនបានគោរពតាមច្បាប់នេះ ពួកគេនឹងត្រូវអគ្គ

នាយកដ្ឋានអន្តោប្រវេសន៍ សហការគ្នាជាមួយក្រសួងការងារ ធ្វើការផាកពិន័យជាទឹកប្រាក់បន្ថែមពីលើប្រាក់ពន្ធនេះ ចំនួន ១២៥ដុល្លារទៀត៕

## សមត្ថកិច្ចថៃ,និងចាប់បញ្ជូនពលករខុសច្បាប់អោយវិលត្រឡប់ទៅស្រុកកំណើតវិញ

http://www.pheaktraprak.com/ April 1, 2018

នៅដើមខែមេសានេះសមត្ថកិច្ចថៃនិងធ្វើការចាប់បញ្ជូនពលករដែលខុសច្បាប់អោយវិលត្រឡប់ទៅស្រុកកំណើតវិញ។ ចាប់ពីថ្ងៃអាទិត្យ ទី01 ខែមេសា ឆ្នាំ2018 នេះតទៅពលករខុសច្បាប់ដែលកំពុងធ្វើការស្នាក់នៅប្រទេសថៃ និងត្រូវសមត្ថកិច្ចចុះអនុវត្តច្បាប់ចាប់បញ្ជូនអោយវិលត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ តាម និតិវិធីច្បាប់គ្រប់គ្រងពលករបរទេសរបស់ថៃ។ ដូច្នេះបើសិនជាបងប្អូនពលករដែលកំពុងស្ថិតក្នុងស្ថានភាពខុសច្បាប់ ហើយមានបំណងចង់វិលត្រឡប់ចូលមកធ្វើការនៅប្រទេសថៃម្តងទៀត សូមបងប្អូនចូលមកតាមរយៈ MOU ដើម្បីឲ្យត្រឹមត្រូវ និងស្របច្បាប់តាមលក្ខខណ្ឌរបស់ប្រទេសថៃ។

## ពលករភូមានិងខ្មែរ,បើកឆាកប្រយុទ្ធគ្នា មានមនុស្សចំនួន 09នាក់ រងរបួសធ្ងន់

http://www.pheaktraprak.com/ April 2, 2018

ករណីអំពើហិង្សានេះបានកើតឡើងកាលពីវេលាម៉ោង08យប់ ថ្ងៃអាទិត្យ ទី01 ខែមេសា ឆ្នាំ2018 នៅត្រង់ចំណុចកន្លែងស្នាក់នៅរបស់កម្មករសំណង់មួយកន្លែងស្ថិតភូមិ(ម៉ូនឹង)សង្កាត់ផានថង ស្រុកផានថង ខេត្តឈុនបុរី ប្រទេសថៃ ។ យោងតាមរបាយការណ៍ពីកន្លែងកើតហេតុបានប្រាប់ឲ្យដឹងថា ករណីបង្កអំពើហិង្សាដាក់គ្នានេះបណ្តាលអោយមានពលករសញ្ជាតិខ្មែរចំនួន 04នាក់ និងពលករសញ្ជាតិភូមាចំនួន 05នាក់រងរបួសធ្ងន់ទាំងសង់ខាង ហើយត្រូវបានភ្នាក់ងារសង្គ្រោះស្រុកផានថង បញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យផានថង ខេត្តឈុនបុរី ។ ប្រភពបឋមពីសាក្សីដែលឃើញហេតុការណ៍នៅកន្លែងកើតហេតុរៀបរាប់អោយដឹងថា នៅមុនពេលកើតហេតុគេឃើញពលករទាំងពីរក្រុមអង្គុយផឹកស៊ីជុំគ្នា ស្រាប់តែមួយសន្ទុះក្រោយមកកើតមានរឿងវាយតប់គ្នា ហើយគេឃើញមានមនុស្សរងរបួសត្រូវគេកាប់ត្រូវក្បាលហើយនិងដៃ និងមានខ្លះទៀតហើមមុខហើមមាត់ ។

ក្រោយពេលកើតកម្លាំងសមត្ថកិច្ចតម្រួតស្រុកផានថងបានចុះធ្វើអន្តរាគមន៍ដល់កន្លែងកើត ក្នុងការត្រួតពិនិត្យនៅបរិវេណកន្លែងកើតហេតុសមត្ថកិច្ចបានប្រទះឃើញដាវសោមួយចំនួនមួយដើម សមត្ថកិច្ចបានយកទៅរក្សាទុកជាវត្ថុតាំង និងធ្វើការសាកសួរ ជនរងគ្រោះទាំងសង់ខាងដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ចំណែកឯមូលហេតុដែលបង្កអោយកើតអំពើហឹង្សានេះ គេសន្និដ្ឋានថាប្រហែលជាមកពីស្រវឹងស្រាហើយនិយាយស្តាប់គ្នាមិនបានទើបកើតរឿង។

## អាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែររួចទោស៣នាក់តាមច្រកអន្តរជាតិដាំ

http://www.rasmeinews.com/ March 30, 2018, 8:10 PM

*ដោយៈអូរស្មាច់/ឧត្តរមានជ័យៈ* អាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែរដែលរួចផុតទោសចំនួន៣នាក់តាមច្រកអន្តរជាតិដាំសាងាំស្រុកអន្លង់វែងខេត្តឧត្តរមានជ័យកាលពីវេលាម៉ោង៣និង២០នាទីរសៀលថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨។ សមត្ថកិច្ចប្រចាំច្រកអន្តរជាតិដាំបានឱ្យដឹងថា ពលរដ្ឋខ្មែរទាំ៣នាក់ត្រូវបានអាជ្ញាធរថៃបញ្ជូនមានឈ្មោះ ១.ឈ្មោះ ស៊ុំ ព្រែក ភេទប្រុស អាយុ២៦ឆ្នាំ រស់នៅភូមិអូរចិញ្ចៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ២.ឈ្មោះគង់វិភេទប្រុសអាយុ៣៨ឆ្នាំរស់នៅភូមិមរតកតេជោឃុំកណ្តួតស្រុកជាំក្សាន្តខេត្តព្រះវិហារ៣.ឈ្មោះមឿនទិត្យភេទប្រុសអាយុ៣៧រស់នៅភូមិមរតកតេជោឃុំកណ្តួតស្រុកជាំក្សាន្តខេត្តព្រះវិហា។ហើយអ្នកទាំង៣នាក់ត្រូវបានចាប់ខ្លួននៅថ្ងៃទី៤.ខែមករា

.ឆ្នាំ២០១៧ ឆ្លងព្រំដែនចូលកាប់ឈើគ្រញូងខុសច្បាប់ប្រកតាសីមខេត្តព្រះវិហារ ជាប់គុកនៅ ខេត្តស៊ីសាកេត ប្រទេសថៃ៕S/

## ៣ខែឆ្នាំ២០១៨, ពលករខ្មែរជិត១ម៉ឺននាក់ ត្រូវភាគីថៃបញ្ជូនមកកម្ពុជា ដោយសារស្នាក់នៅខុសច្បាប់

http://freshnewsasia.com/ 2018-03-30

**(បន្ទាយមានជ័យ)៖** យោយតាមរបាយការណ៍របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំង ការជួញដូរមនុស្សថ្នាក់ខេត្ត (គ-ឌ-ប-ជ) បានឲ្យដឹងថា នៅត្រីមាសទី១ ឆ្នាំ២០១៨នេះ មានពលករខ្មែរចំណាកស្រុក ខុសច្បាប់ចំនួន៩៣៥នាក់ ត្រូវបានភាគីថៃ ចាប់បញ្ជូនមកកម្ពុជាវិញ។ បើប្រៀបធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៧កន្លងទៅ មានចំនួន១៥៦៤៥នាក់ មានការថយចុះចំនួន៥៧១០នាក់។

លោកស្រី ប៉ុក ណាឌី អភិបាលរងខេត្ត បានថ្លែងថា គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ខេត្ត បានសម្រេចនូវលទ្ធផលលើការធ្វើសមាហរណកម្ម និងតាមដានបានទទួល សាវតាជនរងគ្រោះដោយអំពើជួញដូរមនុស្សមុនពេលធ្វើមាតុភូមិនិវត្តន៍ ចំនួន៨មាក់ (ស្រីម្នាក់, កុមារី ២នាក់, កុមារា៥នាក់) ពីនាយដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃប្រទេសថៃ ដើម្បីឲ្យមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ធ្វើការស្វែងរកគ្រួសាររបស់ពួក មុនពេលធ្វើមាតុភូមិនិវត្តន៍ត្រឡប់មកប្រទេសកំណើតវិញ។ ក្នុងនោះក្រុមការងារ បានសម្ភាសន៍ជនទេសន្តោប្រវេសន៍ (ពលករខ្មែរ) ដែលអាជ្ញាធរថៃ បញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ មានពលករសរុបចំនួន៩៩៣៥នាក់ បើប្រៀបធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៧ ចំនួន១៥៦៤៥នាក់ គឺមានការថយចុះចំនួន ៥៧១០នាក់។

ទន្ទឹមនឹងនេះលោកស្រី ប៉ុក ណាឌី បានបន្តថា ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទពិសេសទៅលើស្ត្រី និងកុមារ គឺជាប្រធានបទដ៏សំខាន់ដែលត្រូវបាន បណ្តាប្រទេសក្នុងតំបន់ និងនៅលើពិភពលោក មានការចាប់អារម្មណ៍ជាទីបំផុត ព្រមទាំងបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងព្រោះវានាំមកនូវផលប៉ះពាល់ និងគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ ដល់មនុស្សជាតិ និងធ្វើឲ្យប្រែប្រួលយ៉ាងធំផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម។ លោកស្រីអភិបាលរងខេត្ត ក៏បានថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែង យកចិត្តទុកដាក់ខ្ពស់លើបញ្ហាទាំងអស់នេះ ក្នុងនោះអាជ្ញាធរពាក់ព័ន្ធ ជាពិសេសកម្លាំងសមត្ថកិច្ចនៅតាមបន្ទាត់ព្រំដែន ត្រូវតែពង្រឹងការយកចិត្តទុកដាក់បន្ថែមទៀតឲ្យបានម៉ឺងម៉ាត់ក្នុងការទប់ស្កាត់រាល់សកម្មភាពការ ជួញដូរមនុស្ស តាមរយៈមេខ្យល់ដែលបានដឹកនាំពលករកម្ពុជា ទៅធ្វើការដោយខុសច្បាប់ដែលជាកត្តាប្រឈមទៅអំពើជួញដូរមនុស្ស ពិសេសលើស្ត្រី និងកុមារផងដែរ៕

## ឧត្តមសេនីយ៍ឯក ខេង លីដា អញ្ជើញបិទវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងការរំលោភបំពានលើអនីតិជន

http://cambodiapolice.com/ 12:13 pm 2 មេសា 2018 106

ភ្នំពេញ ៖ នៅព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨នេះ ឯកឧត្តម ឧត្តមសេនីយ៍ឯក ខេង លីដា អនុប្រធានាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌ បានអញ្ជើញជាអធិបតីក្នុងពិធីបិទវគ្គបណ្តុះ បណ្តាលស្តីពីការប្រយុទ្ធប្រឆាំងការរំលោភបំពានលើអនីតិជន ក្រោមកិច្ចសហការជាមួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ(DCI) ក្រសួងមហាផ្ទៃ នៃសាធារណរដ្ឋបារាំង ដោយមាន ការចូលរួមពីលោកវរសេនីយ៍ត្រី OLIVIER LEFERBVRE អនុព័ន្ធ សន្តិសុខផ្ទៃក្នុង អមស្ថានទូតបារាំង ប្រចាំនៅប្រទេសស វៀតណាម ។

ក្នុងពិធីបិទវគ្គបណ្តុះបណ្តាលនេះ ឯកឧត្តម ឧត្តមសេនីយ៍ឯក ខេង លីដា អនុប្រធានាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ បានមានប្រសាសន៍ផ្តាំផ្ញើដល់សិក្ខាមដែលបានបញ្ចប់វគ្គថា ក្នុង នាមយើងជាមន្ត្រីនគរបាលយុត្តិធម៌ ហើយបានរៀនបញ្ចប់វគ្គ មិនត្រូវយកចំណេះជំនាញទៅអនុវត្តឲ្យផ្ទុយពីក្រមសីលធម៌ វិជ្ជាជីវៈនោះទេ បញ្ហាសំខាន់ក្នុងការបំពេញភារកិច្ច ត្រូវមាន សច្ចៈធម៌ ត្រូវមានគុណធម៌ បញ្ហាយុត្តិធម៌នេះ មិនមែនយុត្តិធម៌ សម្រាប់តែជនរងគ្រោះនោះទេ ត្រូវមានយុត្តិធម៌ទាំងជនល្មើស អ្នកដែលត្រូវផ្តន្ទាទោសក្នុងកម្រិតណា ត្រូវកត់ត្រាឲ្យបាន ច្បាស់លាស់ ជួនកាលជនល្មើសខ្លះប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ប៉ុន្តែយើងកសាងសំណុំរឿងមិនត្រឹមត្រូវមិនយុត្តិធម៌ វាធ្វើឲ្យ ជនល្មើសធ្ងន់ធ្ងរក្លាយទៅជាជនល្មើសតិចតួច ជួនកាលជន ល្មើសមានទោសតិចតួច តែយើងកសាងសំណុំរឿងមិនត្រឹម ត្រូវ វាក្លាយទៅជាជនល្មើសមានទោសធ្ងន់ធ្ងរ ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក បានណែនាំដល់សិក្ខាកាមទៀតថា ឆ្លងតាមវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមទាំងអស់ត្រូវយក ចំណេះជំនាញបទពិសោធន៍ទៅអនុវត្តឲ្យមានប្រសិទ្ធភាព ដើម្បីឲ្យក្លាយទៅជាគ្រូបង្គោលមានជំនាញពិតប្រាកដ ហើយ ចេះចែករំលែកចំណេះជំនាញនិងបទពិសោធន៍ទាំងនេះ ដល់ សហការី និងមិត្តភក្តិរួមការងារផងដែរ ។ ជាពិសេសត្រូវមាន ការទុកចិត្តគ្នា សាមគ្គីភាពគ្នា ទើបធ្វើការអ្វីក៏បានជោគជ័យ ហើយត្រូវធ្វើការជាក្រុម បានន័យថា យើងបានទុកចិត្តគ្នា ទៅវិញទៅមក និងចេះសហការសាមគ្គីគ្នា ។

ក្នុងឱកាសនេះដែរ លោកវរសេនីយ៍ត្រី OLIVIER LEFERBVRE អនុព័ន្ធសន្តិសុខផ្ទៃក្នុង អមស្ថានទូតបារាំងប្រចាំនៅប្រទេស វៀតណាមបានមានប្រសាសន៍ថា នៅក្នុងវគ្គបណ្តុះបណ្តាល នេះ បានបង្រៀនអំពីមធ្យោបាយផ្សេងៗ ហើយបានបង្រៀន អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូររំលោភបំពានផ្លូវភេទលើអនីតិជនផងដែរ ។ លោកវរសេនីយ៍ត្រី OLIVIER LEFERBVRE បានបន្តទៀតថា បើតាមការចាំបាននៅក្នុងរបាយការណ៍ចុងក្រោយបំផុតរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកការកេងប្រវ័ញ្ចផ្លូវភេទលើ កុមារនោះ គឺអ្នករួមភេទជាមួយកុមារនោះមានប្រមានជា ៧៥០០០០ នាក់ តែងតែប្រើប្រាស់អ៊ិនធើណេតជាប្រចាំ ហើយ មានគេហទំព័រអ៊ិនធើណេតលើសពី៤លាននៅលើពិភពលោក ដែលពួកគេបានចែករំលែករូបភាពអាសអាភាសរបស់កុមារ ។ នៅពេលថ្មីៗនេះ មានរូបភាពអាសអាភាសរបស់កុមារ២០០រូបត្រូវបានគេបង្ហោះនៅលើអ៊ិនធើណេត។ ដោយសារតែបញ្ហា ទាំងអស់នេះហើយ ទើបធ្វើឲ្យមានទេសចរផ្លូវភេទក្លាយទៅជា ទេសចរផ្លូវភេទលើពិភពលោក រហូតដល់ក្លាយទៅជាការជួញ ដូរនៅលើរាង្គកាយរបស់មនុស្ស ។ ប្រទេសកម្ពុជា ក៏ដូចជា ប្រទេសផ្សេងៗទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺមិនបានគេច ផុតអំពីបញ្ហាឧក្រិដ្ឋកម្មនេះទេ ហើយជនជាតិលោកខាងលិច ជាច្រើននាក់បានមកប្រទេសកម្ពុជា មិនមែនមកទស្សនា ប្រាសាទអង្គរវត្តនោះដែរ ដូច្នេះក្នុងនាមសិក្ខាម ដែលបាន ហាត់រៀនបញ្ចប់វគ្គ ត្រូវទទួលការងារមួយដ៏លំបាក ហើយ តឹងរឹងបំផុត ព្រោះថា ការស៊ើបអង្កេត ស្រាវជ្រាវស្វែងរកបទល្មើសជនល្មើសជួញដូរ រំលោភបំពានផ្លូវភេទលើកុមារនេះ ជាភារកិច្ចរបស់កម្លាំងនគរបាលយុត្តិធម៌ ៕

## ថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៨

## ពលករខ្មែរធ្វើការដោយខុសច្បាប់នឹងត្រូវបណ្តេញចេញពីប្រទេសថៃ

https://wmc.org.kh ថ្ងៃចន្ទ ទី២ ខែមេសា ឆ្នាំ២០១៨ ធូ វីរៈ

ភ្នំពេញ៖ យោងតាមកាសែតថៃ Bangkok Post ចុះផ្សាយនៅថ្ងៃ ចន្ទ ទី ២ ខែ មេសានេះ ថា ពលកបរទេស ៦ម៉ឺន នាក់ ធ្វើការងារដោយខុសច្បាប់នឹងនិរទេសចេញពីប្រទេសថៃ ហើយក្នុងចំណោមនោះក៏មានពលករកម្ពុជាផងដែរ។ ការបន្តសុពលភាពប័ណ្ណស្នាក់នៅ និងធ្វើការបណ្តោះអាសន្ន ឬ ប័ណ្ណពណ៌ស៊ីជម្ពូ និងលិខិតទំនាក់ទំនងរវាងថៅកែនិងពលករនៅប្រទេសថៃ បានបិទបញ្ចប់ហើយនៅ ថ្ងៃទី១ ខែ មេសា ឆ្នាំ ២០១៨។ កាលពីសប្តាហ៍មុនស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃបានអំពាវនាវដល់ពលករខ្មែរទាំងអស់ទៅ បន្តសុពលភាពប័ណ្ណស្នាក់នៅនិងធ្វើការបណ្តោះអាសន្ននៅការិយាល័យច្រកចេញចូលតែមួយស្របពេលអាជ្ញាធរថៃចាត់វិធានការយ៉ាងតឹងរឹងតាមច្បាប់ ចំពោះពលករបរទេសទាំង

អស់ រួមទាំងពលករខ្មែរដែលស្នាក់នៅនិងធ្វើការដោយខុសច្បាប់នៅប្រទេសថៃ។ កាសែតBangkok Post ឲ្យដឹងថា ពលករចំណាក់ស្រុកបរទេសជិត២លាននាក់បានទៅបន្តសុពលភាពប័ណ្ណស៊ីជម្ពូ ឬ ប័ណ្ណស្នាក់នៅនិងធ្វើការបណ្តោះអាសន្ននិងលិខិតទំនាក់ទំនងរវាងថៅកែនិងពលករនៅប្រទេសថៃ។ ក្នុងចំណោមនោះពលករចំណាកស្រុកខុសច្បាប់មកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ៦ ម៉ឺន នាក់នឹងត្រូវ បណ្តេញចេញពីប្រទេសថៃដោយសារខកខានមិនមកដាក់ពាក្យស្នើសុំប័ណ្ណពណ៌ស៊ីជម្ពូនិងប័ណ្ណស្នាក់នៅ។ ពលករបរទេសជាង ៩ សែននាក់ បានបញ្ចប់នីតិវិធី និងផ្តល់លិខិតអនុញ្ញាតការងារបណ្តោះអាសន្ន និងទទួលស្គាល់ឯកសារពណ៌ជម្ពូ និងពលករបរទេសជាង១លាននាក់ កំពុងផ្ទៀតផ្ទាត់ឯកសារ។

តាមច្បាប់ថ្មីប្រទេសថៃ ពលករអន្តោប្រវេសន៍ ខកខានមិនបានធ្វើបែបបទស្នាក់នៅនិងធ្វើការត្រូវពិន័យជាប្រាក់ពី៥.០០០បាត ទៅ៥០.០០០ម៉ឺនបាត។សម្រាប់កម្មករនិយោជិតពិន័យជាប្រាក់ ១ ម៉ឺនបាត ទៅ ១ សែនបាត។ បទល្មើសដែលកើតឡើងច្រំដែលរបស់និយោជកនឹងត្រូវពិន័យជាប្រាក់២សែនបាតក្នុងមួយករណីហើយត្រូវផ្តន្ទាទោសជិត១ឆ្នាំនិងបន្ថែមពីនេះក្រុមហ៊ុននេះត្រូវហាមមិនឲ្យជ្រើសរើសពលករបរទេសរយៈពេល៣ឆ្នាំ។ យោងតាមរបាយការណ៍ក្រសួងការងារកម្ពុជា ពលករចំណាក់ស្រុកខ្មែរបម្រើការងារនៅប្រទេសថៃ ១ លាន ៥ ម៉ឺននាក់។ បើយោងតាមរបាយការណ៍ប្រចាំឆ្នាំ២០១៧របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការណ៍អន្តរជាតិបង្ហាញថា យ៉ាងតិចពលករខ្មែរជិត ១ ពាន់នាក់ ត្រូវបាននិរទេសពីប្រទេសថៃ មកកម្ពុជាតាមច្រកអន្តរជាតិប៉ោយប៉ែតខេត្តបន្ទាយមានជ័យ៕

## មន្ត្រីថាឈប់ដាក់ទានដល់អ្នកសុំទានតាមផ្លូវទើបអាចជួយពួកគាត់បាន

http://www.rasmeinews.com/ April 2, 2018, 4:43 PM ដោយៈ មេសា

ភ្នំពេញៈ លោក ឈួរ សុបញ្ញា ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម នៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានពន្យល់អំពីមូលហេតុដែលត្រូវឈប់ដាក់ទានដល់អ្នកសុំទានថា ” យើងតែងតែគិតថា ការដាក់ទានគឺជាទង្វើសប្បុរស ជាការអាណិតអាសូរ ប៉ុន្តែធ្វើបែបនោះ គឺជាការចងជើងអ្នកសុំទានទាំងនោះទៅវិញទេ ព្រោះថា ដ៏រាបណា សុំទានបានលុយ ពួកគេ នឹងនៅតែបន្តសុំទានទៀត មិនទទួលយកសេវាដែលផ្តល់ឱ្យដោយរដ្ឋាភិបាល និង អង្គការដៃគូនានា ដើម្បីឱ្យរួចផុតពីការសុំទានឡើយ ចំណែកកុមារវិញ គឺត្រូវបានគេបង្ខំ ឱ្យដើរសុំទាន មិនបានរៀនសូត្រ តើអនាគតរបស់ពួកគេទៅជាយ៉ាងណា ? ” ។ លោក ឈួរ សុបញ្ញា ថ្លែងយ៉ាងដូច្នេះ នាឱកាសរៀបចំកិច្ចពិភាក្សាបញ្ជ្រាបការយល់ដឹងអំពីការសុំទាននៅតាមផ្លូវ ដែលរៀបចំនៅឯសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច កាលពីរសៀលថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៨ ។ កន្លងក្រសួងស្ថាប័នពាក់ព័ន្ធបានខិតខំរៀបចំយន្តការជាច្រើនក្នុងការជួយដល់កុមារជនក្រីក្រដែលជាអ្នកសុំទានទាំងឡាយ ឱ្យរួចផុតពីភាពជាអ្នកសុំទាន ។ ប៉ុន្តែត្រូវបានគេមើលឃើញថា យន្តការទាំងនោះមិនសូវមានប្រសិទ្ធភាពឡើយ ដោយហេតុថា អ្នកសុំទាន នឹងមិនទទួលយកសេវាដែលរៀបចំឱ្យឡើយ ដោយសារពួកគេនៅតែរកលុយបានពីការសុំទាន ។ ដោយហេតុនេះ មានតែសាធារណជនគ្រប់រូបឈប់ដាក់ទានដល់អ្នកសុំទាន ទើបជាការអាចជួយឃិតយោងពួកអ្នកសុំទានទាំងនោះ ឱ្យរួចផុតពីឱនភាព ភាពជាជនរងគ្រោះ និង ភាពពីត្រូវការគេកេប្រវញ្ចន៍ទៅបាន ៕

## ថៃព្រមានចាត់វិធានការលើថៅកែដែលមិនបានចុះបញ្ជីពលករបរទេស

http://kleykley.sabay.com.kh/ ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៨ ម៉ោង 15:54

ក្រសួងការងារថៃ បានព្រមានកាលពីថ្ងៃទី០១ មេសាថា អាជ្ញាធរនឹងចាត់វិធានការលើថៅកែដែលខកខានមិនបានចុះបញ្ជីពលករបរទេស។ ការព្រមាននេះ បានធ្វើឡើងក្នុងពេលដែលពលករបរទេសប្រមាណ ៦ម៉ឺននាក់ នៅមិនទាន់បានចុះបញ្ជីរួចរាល់ បន្ទាប់ពីថ្ងៃចុះឈ្មោះ ត្រូវបានបញ្ចប់កាលពីថ្ងៃ៣១ មីនា ឆ្នាំ២០១៨។ ក្រោយពីបិទការចុះឈ្មោះ ទិន្នន័យផ្លូវការ បានបង្ហាញថា ពលករចំនួនជាង ១,៣លាននាក់ មកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា បានចុះឈ្មោះរួចរាល់ដោយស្របច្បាប់ដើម្បីធ្វើការក្នុងប្រទេសថៃ។ លោក Adul Saengsingkaew រដ្ឋមន្ត្រីក្រសួងការងារថៃ

បាននិយាយនៅសន្និសីទកាសែតថា ពលករដែលមិនទាន់បានចុះបញ្ជីឈ្មោះ ត្រូវតែត្រឡប់ទៅកាន់ប្រទេសរបស់ខ្លួនវិញ។ គូសបញ្ជាក់ថា ច្បាប់ប្រទេសថៃថ្មីស្តីពីពលករបរទេស នឹងធ្វើការពិន័យជាសាច់ប្រាក់ចាប់ពីជាង១២ម៉ឺនដុល្លារ ដល់២៥ម៉ឺនដុល្លារចំពោះពលករបរទេសខុសច្បាប់ម្នាក់ៗក្នុងប្រទេសថៃ ដោយប្រាក់ទាំងនោះនឹងត្រូវបង់ដោយក្រុមថៅកែ។ រីឯពលករវិញ អាចប្រឈមមុខនឹងការជាប់គុកចំនួន៥ឆ្នាំ ឬពិន័យជាសាច់ប្រាក់ពី ៦៤ដុល្លារដល់ជាង៣២០០ ដុល្លារ ឬទាំងពីរតែម្តង (ជាប់គុកផង បង់ប្រាក់ពិន័យផង)៕ ប្រភព៖ Bangkokpost ប្រែសម្រួល៖ អ៊ឹម ម៉េងស៊ាង

## ក្រសួងមហាផ្ទៃ ដាក់កំហិតសមត្ថកិច្ចទប់ស្កាត់ការលួចបង្កើតច្រករបៀងខុសច្បាប់

http://bayontv.com.kh/ 02/04/2018

កោះកុង ៖ មន្ត្រីជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ បានដាក់កំហិតយ៉ាងម៉ឺងម៉ាត់មួយដល់កម្លាំងនគរបាលទីបញ្ជាការស្រាលប្រចាំទិសខេត្តកោះកុង ចាំបាច់អនុវត្តពិនិត្យ និងទប់ស្កាត់ឱ្យខាងតែបានចំពោះសកម្មភាពលួចលាក់បង្កើតច្រករបៀងខុសច្បាប់ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ។ កងកម្លាំងនគរបាលការពារវរៈព្រំដែនប្រចាំទិសកោះកុង ត្រូវបានដាក់កំហិតឲ្យទប់ស្កាត់ការលួចបង្កើតច្រករបៀង ខុសច្បាប់ ពីព្រោះបញ្ហាច្រករបៀងងាយបង្កភាពមិនប្រក្រតីតាមខ្សែបន្ទាត់ព្រំដែន បាត់បង់ចំណូលថវិកាជាតិ និងបូរណភាពទឹកដី អធិបតេយ្យភាពជាតិ និងករណីខ្លះទំនួលខុសត្រូវលើការបំពេញភារកិច្ច។ ប្រសិនបើកងកម្លាំងសមត្ថកិច្ច ឬ អាជ្ញាធរណាមួយ ហ៊ានលួចបើកច្រករបៀងដោយគ្មានការអនុញ្ញាត នឹងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ នេះបើតាមការបញ្ជាក់របស់ឯកឧត្តម អ៊ុក គឹមលេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អំឡុងពេលចុះសំណេះសំណាលជាមួយកងកម្លាំងនគរបាលវរៈការពារព្រំដែនគោកលេខ២៦៩ និងវរៈព្រំដែនទឹកលេខ៨២៧ កាលពីចុងសប្តាហ៍ មុននេះ។

ឯកឧត្តម បានក្រើនរំឭកថា ការលួចបង្កើតច្រករបៀងគ្មានការអនុញ្ញាតត្រឹមត្រូវ គឺអាចនឹងបាត់បង់ទឹកដី ព្រោះច្រករបៀងខ្លះ មិនឈរលើទឹកដីព្រំដែនពិតប្រាកដនោះទេ។ ចំណុចទាំងនេះហើយ ដែលធ្វើឱ្យកម្លាំងនគរបាលជាតិលំបាក នឹងដឹងអំពីភូមិសាស្ត្រទឹកដីរបស់ខ្លួនច្បាស់លាស់។ ដូច្នេះ កុំគិតតែប្រយោជន៍បុគ្គល ធ្វើបាត់ទឹកដីរបស់ខ្លួនឲ្យសោះ។ ឯកឧត្តម បានបញ្ជាក់ថា ប្រសិនបើកម្លាំងនគរបាល ឬអាជ្ញាធរណាមួយ ហ៊ានលួចលាក់បង្កើតច្រករបៀងខុសច្បាប់គ្មានការអនុញ្ញាត ហើយកើតមានបទល្មើសតាមខ្សែបន្ទាត់ព្រំដែន នឹងទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួនចំពោះមុខច្បាប់ជាធរមាន។ ឧត្តមសេនីយ៍ សំឃិត វៀន ស្នងការនគរបាលខេត្តកោះកុង បានឲ្យដឹងថា មូលដ្ឋានខេត្តកោះកុង គឺមានតែច្រក ព្រំដែនអន្តរជាតិចាំយាមមួយប៉ុណ្ណោះ។ កន្លងទៅ ក៏មានច្រករបៀងគីរីវង្សផងដែរ ប៉ុន្តែត្រូវបានរដ្ឋាភិបាលសម្រេចបិទជា ស្ថាពរហើយ នៅដើមឆ្នាំ២០១៨នេះ ចៀសវាងកើតមានបញ្ហាខុសប្រក្រតី។ ច្រករបៀងគីរីវង្ស មានលក្ខណៈខុសពីច្រករបៀងតាមបណ្តាខេត្តដ៏ទៃទៀត ព្រោះវាពុំមែនជាច្រកសម្រាប់នាំចេញនាំចូលទំនិញពាណិជ្ជកម្មនោះទេ។ ទោះយ៉ាងណា លោកនឹងខិតខំអនុវត្តតួនាទីភារកិច្ចការពារ និងពង្រឹងសន្តិសុខសណ្តាប់ធ្នាប់តាមខ្សែក្រវ៉ាត់ព្រំដែនឱ្យបានល្អប្រសើរ។

កាលពីចុងខែតុលា ឆ្នាំ២០១៧ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជា ឱ្យបិទច្រករបៀងខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនទាំងអស់នៅទូទាំងប្រទេស ដោយសារតែការបង្កបញ្ហាច្រើនជាងការ ទទួលបានផលចំណេញ៕

## ថ្ងៃទី២ ខែ៤ ឆ្នាំ២០១៨ យើងឃើញថាប្រជាជនខ្មែររាប់ ម៉ឺននាក់បានចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ គឺពិតជាលំបាកណាស់សំរាប់ពួកគាត់ ដែលត្រូវចំណាកស្រុកឃ្លាតពីរ បងប្អូន ម៉ែឪ

http://www.khmers.news/ April 2, 2018 By mong kol

ថ្ងៃទី២ ខែ៤ ឆ្នាំ២០១៨ យើងឃើញថាប្រជាជនខ្មែររាប់ មឺុននាក់បានចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ គឺពិតជាលំបាកណាស់សំរាប់ពួកគាត់ ដែលត្រូវចំណាកស្រុកឃ្លាតពីរ បងប្អូន ម៉ែឪ ហើយទៅនៅប្រទេសគេ តែសូមសសើរពួកគាត់ ទោះដឹងថាពិបាកតែពួកគាត់នៅតែតស៊ូជំនាស់គ្រប់បែបយ៉ាងក៏ដើម្បីបានប្រាក់ខែខ្ពស់ និងដើម្បីផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ ។

## ការកំណត់ពេល ឲ្យពលករកម្ពុជា ធ្វើប័ណ្ណរបស់ថៃ មិនបានធ្វើឲ្យមានការវិលមកស្រុកច្រើនទេ

https://www.postkhmer.com/ យន់ ស៊ីនាត and Daphne Chen | Publication date 03 April 2018 | 13:50 ICT

**ភ្នំពេញៈ** អង្គការក្រៅរដ្ឋាភិបាលបាននិយាយថា កាលបរិច្ឆេទឲ្យពលករចំណាកស្រុកធ្វើការនៅថៃទៅចុះបញ្ជីយកប័ណ្ណបណ្ដោះអាសន្នដែលបានអនុម័ត កាលពីថ្ងៃសៅរ៍ មិនបានធ្វើឲ្យមានអ្នកវិលមកកម្ពុជាវិញច្រើនទេ ប៉ុន្តែក្រុមអ្នកសង្កេតការណ៍នៅតែមិនប្រាកដថា តើនឹងមានការបង្ក្រាបលើអ្នកមិនទាន់មានប័ណ្ណឬយ៉ាងណា។

លោក Barry Jessen អ្នកគ្រប់គ្រងជាន់ខ្ពស់អង្គការ Samaritan's Purse ដែលធ្វើការនៅព្រំដែន កម្ពុជា-ថៃ បានថ្លែងថា ពលករកម្ពុជាភាគច្រើនដែលវិលមកកម្ពុជាវិញសុទ្ធតែថាមកចូលឆ្នាំខ្មែរ។ លោកJessen បន្តថា៖ «គ្មាននរណាម្នាក់ថា ត្រឡប់មកវិញ ដោយសារការកំណត់ឲ្យចុះបញ្ជីយកប័ណ្ណការងារស៊ីជម្ពូនោះទេ ហើយរហូតមកទល់ពេលនេះ ដូចជា មិនឃើញមានការបង្ក្រាបធំដុំទេ»។ ពលករដែលបានចុះបញ្ជីយក «ប័ណ្ណស៊ីជម្ពូ» ដែលថៃ កំណត់ត្រឹមថ្ងៃទី ៣១ ខែមីនានោះ ឥឡូវនេះពួកគេមានពេលដល់ខែ មិថុនា ដើម្បីចុះបញ្ជីយកប័ណ្ណនោះ ដើម្បីធ្វើការស្របច្បាប់។ ចំពោះអ្នកមិនបានធ្វើតាមកំណត់ ពួកគេត្រូវវិលមកកម្ពុជាវិញ ហើយពេលត្រឡប់ទៅវិញត្រូវធ្វើឲ្យស្របតាមផ្លូវច្បាប់។

តាមរយៈសារមួយ អ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ បានថ្លែងថា ក្រុមមន្ត្រីកំពុងធ្វើការលើរឿងនេះ «ក្នុងស្មារតីសហការយ៉ាងខ្លាំងក្លា» មួយជាមួយ ថៃ ដើម្បីដំណើរការឯកសារឲ្យស្របច្បាប់សម្រាប់ពលករដែលកាន់ប័ណ្ណស៊ីជម្ពូ។ មិនទាន់ច្បាស់ទេថា មានពលករប៉ុន្មាននាក់មិនធ្វើឲ្យទាន់ថ្ងៃកំណត់នោះ ប៉ុន្តែតាមកាសែត បាងកក ប៉ុស្ដិ៍ ថាមានប្រមាណ ៦ ម៉ឺននាក់។ ប៉ុន្តែក្រុមការពារពលករចំណាកស្រុកមានមូលដ្ឋាននៅទីក្រុង បាងកក បារម្ភថា ចំនួននេះអាចមានច្រើនម៉ឺននាក់បន្ថែមទៀត ដោយសារការពន្យារពេល នៅឯច្រកចេញចូលតែមួយ។

លោក Adisorn Kerdmongkhol អ្នកសម្របសម្រួលក្រុមការងារនោះបានអំពាវនាវឱ្យថៃ ពន្យារពេល ៣ ខែទៀត ដោយលោកថា ការិយាល័យច្រកចេញចូលតែមួយជាច្រើនចុះឈ្មោះបានតែ ៣០០០ នាក់ ក្នុងមួយថ្ងៃ ដូច្នេះហើយធ្វើឱ្យពលករជាច្រើនទៀតត្រូវរង់ចាំ ៣ ថ្ងៃ ឬ ច្រើនជាងនេះ។ លោក ថ្លែងថា៖ «ការបង្ក្រាបពលករចំណាកស្រុកដែលគ្មានឯកសារនៅដំណាក់កាលនេះ គឺគ្រាន់តែពង្រឹងភាពមិនស្មោះត្រង់របស់ ថៃ ក្នុងការទប់ស្កាត់ការជួញដូរមនុស្សប៉ុណ្ណោះ»។

លោក Reuben Lim អ្នកនាំពាក្យអង្គការ International Organization for Migration នៅថៃ បាននិយាយថា វានៅមិនទាន់ច្បាស់ទេថាតើពេលណាទើបថៃអនុវត្តការបង្ក្រាបនៅពេលហួសថ្ងៃកំណត់នេះ។

លោក យុន ថារ៉ូ មន្ត្រីកម្មវិធីរបស់អង្គការ Solidarity Center បានថ្លែងថា កង្វះភាពច្បាស់លាស់លើការអនុវត្តអាចធ្វើឱ្យប៉ះពាល់ដល់កម្មករ។ លោកថា៖ «ការបារម្ភធំរបស់យើងគឺពលករនេសាទដែលពួកគេត្រូវចេញទៅនេសាទនៅក្នុងសមុទ្ររយៈពេលពីមួយសប្ដាហ៍ទៅមួយខែ»៕INS

## ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៨

## ស្នងការនគរបាលខេត្តអានយ៉ាងនិងស្នងការនគរបាលខេត្តតាកែវ បង្កើនកិច្ចសហប្រតិបត្តិការរួមគ្នាទប់ស្កាត់បទល្មើសនៅតាមបន្ទាត់ព្រំដែន

http://www.cen.com.kh/ April 3, 2018

តាកែវ ៖ ឆ្លងកាត់និងជំនួបការងារបង្ការនិងទប់ស្កាត់បទល្មើសដែលកើតមានឡើងនៅតាមបន្ទាប់ព្រំដែនកម្ពុជាវៀតណាម អានយ៉ាង តាកែវ លោក ឡេ យ៉ាំងទៀង ស្នងការរងនគរបាលខេត្តអានយ៉ាន បានស្នើសុំអោយឯកឧត្តមឧត្តមសេនីយ៍ទោ សុខ សំណាង ស្នងការនគរបាលខេត្តតាកែវ បន្តកិច្ចសហប្រតិបត្តិការអោយកាន់តែខ្លាំងក្លា រួមគ្នាទប់ស្កាត់បទល្មើសសេដ្ឋកិច្ច និងរក្សាសន្តិសុខសណ្ដាប់ធ្នាប់ ជាពិសេសការជួញដូរគ្រឿងញៀនខុសច្បាប់ប្រភេទកញ្ឆា នៅតាមបន្ទាត់ព្រំដែនរវាងខេត្តទាំងពីរ ។ ការស្នើសុំនេះគឺបានកើតឡើងក្នុងពេលដែលប្រតិភូនៃស្នងការដ្ឋាននគរបាលខេត្តអានយ៉ាង បានធ្វើដំណើរទស្សនកិច្ចនៅខេត្តតាកែវ ក្នុងឱកាសដែលលោក ឡេ យ៉ាំងទៀង អញ្ជើញជួបនិងជូនពរឆ្នាំថ្មីប្រពៃណីជាតិ ខ្មែរ នៅស្នងការដ្ឋាននគរបាលខេត្តតាកែវ នាពីថ្ងៃទី ០៣ មេសា ២០១៨ ។

លោកស្នងការរងនគរបាលខេត្តអានយ៉ាងបានបន្តថា បច្ចុប្បន្ននេះបទល្មើសជាច្រើនដែលកើតមានឡើងនៅតាមបន្ទាត់ព្រំដែន គឺសមត្ថកិច្ចយើងរួមជាមួយនិង សមត្ថកិច្ចខេត្តតាកែវ បានសហការគ្នាធ្វើការបង្រ្កាបបានជាច្រើនករណីមកហើយ ដូច្នេះដើម្បីជានា និងរក្សាអោយបានសុវត្ថិភាពសន្តិសុខសណ្តាប់ធ្នាប់ រវាងស្រុកនៅជាប់ព្រំដែនខេត្តអានយ៉ាង និងខេត្តតាកែវ យើងត្រូវតែធ្វើការផ្លាស់ប្តូរក៏ដូចជាការផ្តល់នៅព័ត៌មានអោយគ្នាទៅវិញទៅមក អោយបានរហ័សនិងទាន់ពេលវេលាចំពោះមុខសញ្ញា ឆ្លងដែនខុសច្បាប់ រួមមាន មុខសញ្ញាគេរវកម្ម មុខសញ្ញាព្រហ្មទណ្ឌ មុខសញ្ញាជួញដូរមនុស្ស សេដ្ឋកិច្ច និងមុខសញ្ញាផ្សេងៗទៀត ។

ជាកិច្ចឆ្លើយតបឯកឧត្តមឧត្តមសេនីយ៍ទោ សុខ សំណាង ស្នងការនគរបាលខេត្តតាកែវ បានឯកភាពបន្តរក្សាសាម្គីភាព មិត្តភាព នូវកិច្ចសហប្រតិបត្តិការនេះអោយកាន់តែមានចំណងមិត្តភាពកាន់តែរឹងមាំថែមទៀត ហើយលោកនិងខិតខំបន្តសហការគ្នាអោយកាន់តែមានភាពរឹងមាំថែមទៀត រវាងកំលាំងនគរបាលនៃខេត្តទាំងពីរខេត្តតាកែវ ខេត្តអានយ៉ាង ក្នុងការបង្រ្កាបបទល្មើសសេដ្ឋកិច្ច និងបទល្មើសផ្សេងៗទៀត នៅតាមខ្សែបន្ទាត់ព្រំដែន ដោយឈរលើគោលការណ៍ច្បាប់នៃប្រទេសទាំងពីរ កម្ពុជា វៀតណាម ៕ តាកែវ

## ពលករកម្ពុជា,ចំនួនរាប់រយនាក់ កំពុងសម្រុកធ្វើដំណើរទៅលេងស្រុកកំណើតតាមរយៈច្រកទ្វារអន្តរជាតិ(បានទ្បែម)

http://www.pheaktraprak.com/ April 4, 2018

ពលករកម្ពុជាចំនួនរាប់រយនាក់ កំពុងសម្រុកធ្វើដំណើរវិលត្រឡប់ទៅលេងស្រុកកំណើតតាម រយៈច្រកទ្វារអន្តរជាតិបានទ្បែម ខេត្តចាន់បុរី យ៉ាងច្រើនកុះករ។ នេះជាទិដ្ឋភាពបងប្អូនពលករកម្ពុជាធ្វើការនៅប្រទេសថៃចំនួនរាប់រយនាក់ កំពុងធ្វើដំណើរមកពីខេត្តផ្សេងៗក្នុងប្រទេសថៃ ដើម្បីឆ្លងដែនបន្តទៅជួបជុំក្រុមគ្រួសារឪពុកម្តាយបងប្អូននៅឯស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរខាងមុខនេះតាមរយៈច្រកទ្វារអន្តរជាតិបានទ្បែម ខេត្តចាន់បុរី កាលពីថ្ងៃអង្គារទី03 ខែមេសា ឆ្នាំ2018 ម្សិលមិញនេះ។ ទិដ្ឋភាពថ្ងៃ:03-04-2018

## បុរសពលករខ្មែរម្នាក់,យកកាំបិតចាក់កខ្លួនឯងព្រោះតែនឹកផ្ទះ.!

http://www.pheaktraprak.com/ April 3, 2018

មានករណីបុរសពលករខ្មែរម្នាក់ យកកាំបិតចាក់កខ្លួនឯង រងរបួសធ្ងន់ មូលហេតុព្រោះតែនឹកផ្ទះ តែថៅកែមិនអោយឈប់សម្រាក់។ ករណីពលករខ្មែរយកកាំបិតចាក់កខ្លួនឯងរបួសនេះបានកើតឡើងកាលពីវេលាម៉ោង10យប់ ថ្ងៃអាទិត្យទី01 ខែមេសា ឆ្នាំ2018 នៅត្រង់ចំណុចក្បែររបងផ្ទះ(បានសួនមីស៊ី) លេខ183/8 ស្ថិតនៅក្នុងភូមិ(ម៉ូស៊ី) សង្កាត់ស៊ូស៊ាក់ ស្រុកស៊ីរាចធា ខេត្តឈុនបុរី ប្រទេសថៃ ។ ជនរងគ្រោះមានឈ្មោះ ផាន់ណា ភេទប្រុស អាយុ 25ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាកម្មករធ្វើការនៅក្នុងភូមិឃុំកើតហេតុ ។ ប្រភពពីកន្លែងកើតហេតុបានឲ្យដឹងថា ជនរងគ្រោះបានត្រូវកាំបិតចុងស្រួចចាក់ចំកបណ្តាលអោយរងរបួសប្រវែងមួយសង់ទីម៉ែត ឈាមហូសោចដោគខ្លួនទាំងស្ថានភាពដេកស្រែក អ៊ូយ អ៊ូយ.! ដោយការឈឺចាប់ ។

តាមការសាកសួរបឋម ជនរងគ្រោះបានរាប់រៀបទាំងទឹកភ្នែកថា បញ្ហានេះកើតឡើងដោយសាររឿងសុំថៅកែឈប់សម្រាកទៅលេងផ្ទះ តែថៅកែមិនយល់ព្រមអោយឈប់ ទើបធ្វើអោយគាត់ពិបាកចិត្តរហូតដល់យកកាំបិតមកចាក់កខ្លួនបណ្តាលអោយរងរបួសតែម្តង ក្រោយពេលកើតហេតុបុរសរងគ្រោះត្រូវបាន ភ្នាក់ងារសង្គ្រោះស្រុកស៊ីរាចធាបញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យឱអ៊ូជុម។ ក្នុងករណីនេះដែរសមត្ថកិច្ចតម្រួតស្រុកស៊ីរាចធាកំពុងធ្វើការអញ្ជើញថៅកែថៃខាងលើ អោយចូលមកបំភ្លឺក្នុងរឿងនេះនិងចាត់វិធានការដោះស្រាយអោយពលកររងគ្រោះខាងលើបានវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ។

# តុលាការគូវ៉ែតកាត់ទោសប្រហារជីវិតប្ដីប្រពន្ធចំពោះការសម្លាប់អ្នកបំរើជនជាតិហ្វីលីពីន

http://www.rasmeinews.com/ April 2, 2018, 10:40 AM

ប្រភពព័ត៌មានពីតុលាការបាននិយាយថា តុលាការនៃប្រទេសគូវ៉ែត កាលពីថ្ងៃអាទិត្យទី០១មេសាបានកាត់ទោសកំបាំងមុខ ដោយប្រហារជីវិត បុរសលីបង់ម្នាក់ និងប្រពន្ធជនជាតិស៊ីរីរបស់គាត់ដោយព្យួរក ចំពោះការសម្លាប់ អ្នកបំរើជនជាតិហ្វីលីពីនម្នាក់ ។ តុលាការនេះ បានចេញការសម្រេចដាក់ទោសនៅក្នុងសវនាការលើកដំបូងក្នុងករណីរបស់អ្នកបំរើឈ្មោះJoanna Demafelis អាយុ២៩ឆ្នាំនេះ ដែលសាកសពរបស់នាង ត្រូវបានគេរកឃើញនៅក្នុងទូទឹកកក នៅប្រទេសគូវ៉ែត កាលពីដើមឆ្នាំនេះ។

ប្រភពព័ត៌មាននេះ បាននិយាយប្រាប់សារព័ត៌មានAFP ការកាត់ទោសនេះនៅតែអាចប្ដឹងឧទ្ធរណ៍បានប្រសិនបើប្ដីប្រពន្ធនេះ ត្រឡប់ទៅប្រទេសគូវ៉ែតវិញ។ ឯកអគ្គរដ្ឋទូតហ្វីលីពីន លោក Renato Pedro Villa បានបដិសេធមិនធ្វើអត្ថាធិប្បាយលើសាលក្រមនេះទេដោយបានប្រាប់ សារព័ត៌មានAFP ថាប្រទេសរបស់លោកនឹងរង់ចាំមើលការអនុវត្តទោស លើជនល្មើសប្ដីប្រពន្ធនេះ។ ប្ដីប្រពន្ធនេះត្រូវបានចាប់ខ្លួនកាលពីខែកុម្ភៈនៅប្រទេសស៊ីរី បន្ទាប់ពីមានការតាមចាប់ខ្លួនដោយប៉ូលិសអន្តរជាតិ។ ក្រុមអាជ្ញាធរស៊ីរីបានប្រគល់ប្ដីឈ្មោះ Nader Essam Assaf នេះ ទៅឱ្យក្រុមអាជ្ញាធរលីបង់ខណៈដែលប្រពន្ធជនជាតិស៊ីរីរបស់គាត់ស្ថិតនៅក្រោមការឃុំឃាំងនៅទីក្រុងដាម៉ាស ប្រទេសស៊ីរី៕ ដោយៈសុខា

# អឺរ៉ុបត្រួតពិនិត្យឧស្សាហកម្មនេសាទថៃ ខណៈពលករបារម្ភពីការប៉ះពាល់ការងារ

https://www.postkhmer.com/ យន់ ស៊ីនាត and Erin Handley | Publication date 04 April 2018 | 14:12 ICT

ភ្នំពេញៈ អ្នកត្រួតពិនិត្យនៃសហភាពអឺរ៉ុបនៅថ្ងៃពុធទី ៤ ខែមេសានេះ បានចុះមកត្រួតពិនិត្យឧស្សាហកម្មនេសាទនៅប្រទេសថៃ ដែលជាផ្នែកមួយនៃកិច្ចប្រឹងប្រែង ដើម្បីការពារពលករដែលមានទាំងជនជាតិខ្មែរផង ពីការរំលោភបំពានដោយនិយោជក ប៉ុន្តែក៏បានធ្វើឲ្យមានការបារម្ភពីផលប៉ះពាល់លើការងារពួកគេផងដែរ។ ការត្រួតពិនិត្យនេះបានណាត់យកកំពង់ផែ (PIPO) ដែលលទ្ធផលអាចធ្វើឱ្យសហភាពអឺរ៉ុបដកកាតព្រមាន«កាតលឿង»ក្នុងឆ្នាំ២០១៥របស់ខ្លួនចេញពីឧស្សាហកម្មនេះឬក៏ត្រូវហាមឃាត់ការនាំចូលផលិតផលនេសាទនេះ។

តាមកាសែតបាងកក ប៉ុស្ដិ៍ ដែលបានដកស្រង់សម្ដីឧបនាយករដ្ឋមន្ត្រីថៃ លោក Chatchai Sarikulya នៅមុនការចុះត្រួតពិនិត្យដោយលោកមានសុទិដ្ឋិនិយម លើកិច្ចការនេះនិងថា ថៃ បានចុះបញ្ជីពលករនេសាទបាន ១ លាននាក់ដែលមានទាំងពលករកម្ពុជា ច្រើនម៉ឺននាក់ផងដែរ។ លោកថាៈ «ថៃ លែងមានពលករចំណាកស្រុកខុសច្បាប់ធ្វើការទាក់ទងនឹងឧស្សាហកម្មនេសាទទៀតហើយ ខណៈដែលយើងបានចុះបញ្ជីពួកគេរួចរាល់នោះ»។ ប៉ុន្តែបើតាមរបាយការណ៍ចេញដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស Human Rights Watch នៅដើមឆ្នាំនេះបានរកឃើញថាការចុះធ្វើអធិការកិច្ចពលកម្មថៃភាគច្រើនគឺបំផ្លើស ដើម្បីបានទទួលការបញ្ជាទិញពីអន្តរជាតិ ខណៈពួកគេកម្រធ្វើសម្ភាសន៍ផ្ទាល់ជាមួយពលករនេសាទ។

លោក Brad Adams នាយកអង្គការឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការ HRW ប្រចាំតំបន់អាស៊ីបានថ្លែងតាមអ៊ីមែលថាៈ«អធិការកិច្ចរបស់សហភាពអឺរ៉ុប ត្រូវតែធ្វើឲ្យបានតឹងរ៉ឹងជាមួយថៃហើយសូមកុំចាញ់ការបោកបញ្ឆោតទាំងនេះដើម្បីបង្វែរការយកចិត្តទុកដាក់លើចម្ងល់ជាច្រើនទាក់ទងនឹងការដោះស្រាយបញ្ហានៃការរំលោភបំពានកម្មករនេសាទ។

លោក ឃុន ថារ៉ូ មន្ត្រីកម្មវិធីអង្គការ Solidarity Center បានយល់ស្របថា បញ្ហាជាច្រើននៅតែមានរួមទាំងពលកម្មកុមារនិងការរឹតត្បិតលើពលករចំណាកស្រុក ខណៈម្ចាស់ទូកនិងនិយោជកជាច្រើនមានមុខតំណែងខ្ពស់នៅក្នុងរដ្ឋាភិបាលថៃ ដែលវាពិបាកសម្រាប់ពលករនេសាទទទួលបានយុត្តិធម៌ពេលពួកគេស្វែងរកសំណងតាមផ្លូវតុលាការ។ ប៉ុន្តែអ្នកនេសាទខ្មែរម្នាក់ឈ្មោះ ចេង ណាល់ អាយុ ៣១ ឆ្នាំ ដែលបានធ្វើការក្នុងឧស្សាហកម្មនេះ ១០ ឆ្នាំ បានថ្លែងថា មានការរីកចម្រើនគួរឲ្យកត់សម្គាល់តែគាត់បារម្ភពីបាត់បង់ការងារប្រសិនបើសហភាពអឺរ៉ុប ហាមនាំចូលផលិតផលនេសាទ។

លោក ណាល់ ថា គាត់បានទទួលឯកសារស្របច្បាប់កាលពីឆ្នាំមុនបន្ទាប់ពីបានបង់ប្រាក់២ម៉ឺនបាត (៦៤១ ដុល្លារ) ហើយប្រាក់ពាក់កណ្តាលត្រូវបង់ដោយនិយោជករបស់គាត់។

ប្រតិភូសហភាពអឺរ៉ុប នៅប្រទេសថៃ មិនបានឆ្លើយតបទៅនឹងសំណើសុំការបំភ្លឺទេ។ លោក ហេងសួរ អ្នកនាំពាក្យក្រសួងការងារកម្ពុជាបានថ្លែងថា បញ្ហានេះគឺសម្រាប់សហគមន៍អឺរ៉ុបនិងថៃ ដោះស្រាយ ប៉ុន្តែលោកថារដ្ឋាភិបាលថៃបានធ្វើកំណែទម្រង់ជាច្រើន និងតាំងចិត្តសហការស្មោះត្រង់ជាមួយកម្ពុជា៕ NS

## ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១៨

## ពលករចេញចូលហូរហែ ទោះបីជិតចូលឆ្នាំខ្មែរក៏ដោយ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៨ម៉ោង ២៣:៥២ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរទៅមកទឹកដីថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត-ខ្លងលឹក ជាហូរហែបើទោះពេលនេះ កៀកនឹងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិទៅហើយក្តី។ ការវិលត្រលប់របស់បងប្អូនពលករខ្មែរពីដីថៃ ដើម្បីជួបជុំសាច់ញាតិនៅតាមភូមិកំណើតតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែពេលនេះចាប់ផ្តើមមានជាហូរហែ ប៉ុន្តែបើប្រៀបធៀបទៅនឹងឆ្នាំមុនក៏មិនខុសគ្នាប៉ុន្មាននោះទេ គឺមានតិចជាងច្រកទ្វារអន្តរជាតិដូង ក្នុងស្រុកកំរៀងខេត្តបាត់ដំបង។

ថ្វីដ្បិតតែពលករវិលត្រលប់ពីថៃមិនច្រើនតែឆ្នាំនេះវាប្លែកខុសពីបណ្តា ឆ្នាំមុនៗត្រង់ថា ពលករវិលត្រលប់ឆ្នាំនេះភាគច្រើនជាលក្ខណៈគ្រួសារ គឺពលករដែលវិលពីភូមិសាស្ត្រ តាមស្រុកក្នុងខេត្តជាប់ព្រំដែនដូចជា ទៅស៊ីឈ្នួលធ្វើចម្ការ កាប់អំពៅ និងដាំដំណាំឲ្យជនជាតិថៃជាដើម។ ជួបសម្ភាសជាមួយបុរសម្នាក់ក្នុងចំណោមពលករជាច្រើនមានកូនប្រុសស្រីតាមជាប់ជាមួយផងនិយាយថា គាត់មកពីស៊ីឈ្នួលកាប់អំពៅនៅខេត្តស្រះកែវ គាត់ និងពលករផ្សេងៗជាអ្នកខេត្តសៀមរាប។

បើទោះជាបែបនេះក្តីពលករហូរចូទៅធ្វើការលើទឹកដីថៃក្នុងមួយថ្ងៃៗតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតក៏មានជាច្រើនដូចគ្នា។ តំណាងក្រុមហ៊ុននាំពលករទៅធ្វើការលើដីថៃមួយ បានប្រាប់ កោះសន្តិភាព នៅថ្ងៃទី៥ មេសា នេះថា ពលករតាមរយៈក្រុមហ៊ុនរបស់គាត់ចេញទៅថៃថ្ងៃនេះមានចំនួន២៩០នាក់៕

## អង្គការ IOM X ចាក់ផ្សាយរឿងអប់រំស្ត្រីទាក់ទងនឹងអាពាហ៍ពិពាហ៍ទៅរស់នៅបរទេស

https://thmeythmey.com/ 05, Apr 2018 , 2:56 pm

ដោយ: ថាន រស្មី ភ្នំពេញ៖ អង្គការ IOM X ក្រោមកិច្ចសហការជាមួយ មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC) ចាប់ផ្តើមយុទ្ធនាការចាក់ផ្សាយរឿងអប់រំតាមវិទ្យុ និងបញ្ចាំងតាមទូរទស្សន៍ សំដៅធ្វើយ៉ាងឲ្យប្រជាពលរដ្ឋមានការប្រុងប្រយ័ត្នខ្ពស់ មុនសម្រេចចិត្តរៀបការចេញទៅរស់នៅបរទេស ក្នុងនោះមានប្រទេសចិន ជាដើម។

ដោយមើលឃើញថា ស្ត្រីដែលរៀបការទៅរស់នៅក្រៅប្រទេសជាមួយប្តីបរទេស តែងប្រឈមលើការជួញដូរផ្លូវភេទ និងកម្លាំងពលកម្មនោះ អង្គការ IOM X រួមជាមួយមណ្ឌលព័ត៌មានស្ត្រី (WMC) បានផលិតខ្សែរឿងអប់រំ ដែលមានចំណងជើងថា «ចំណាកស្រុកដោយជោគជ័យ» ដើម្បីចាក់ផ្សាយនៅតាមស្ថានីទូរទស្សន៍ និងវិទ្យុ ចំនួន៤លើកពេញមួយខែមេសា នេះ។ រឿងអប់រំ«ចំណាកស្រុកដោយជោគជ័យ» នេះ ក៏មានការចូលរួមពី គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (NCCT) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC) រួមជាមួយអង្គការជាតិ និងអន្តរជាតិជាច្រើនទៀតផងដែរ។

វិទ្យុដែលចាក់ផ្សាយរឿងអប់រំនេះ មានវិទ្យុស្ត្រីកម្ពុជា FM102 និងវិទ្យុវាយោ រីឯខ្សែរឿងរ្ស តែវចាក់បញ្ចាំងនៅទូរទស្សន៍ PNN នៅល្ងាចថ្ងៃទី៥ និងទី៦ខែមេសា និងទូរទស្សន៍ MyTV នៅព្រឹកថ្ងៃទី៧ និងទី៨ ខែមេសា។ បន្ថែមលើនេះ ក្រុមការងាររបស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា នឹងធ្វើដំណើរចុះទៅភូមិ តាអុង ឃុំតាអុង ស្រុកចំការលើ ខេត្តកំពង់ចាម ចាប់ពីថ្ងៃទី២៣ ដល់២៦ ខែមេសា ជូនដល់ប្រជាពលរដ្ឋទស្សនាដល់មូលដ្ឋាន។ អង្គការ IOM X គឺជាយុទ្ធនាការ

របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) និងទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ (USAID) ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច៕

## ពលរដ្ឋខ្មែរនៅអាមេរិក ៤៣នាក់ ដែលប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរខុសច្បាប់អាមេរិកនិងជាប់ពន្ធនាគារ ត្រូវបញ្ជូនមកកម្ពុជាវិញ

http://www.cen.com.kh/ April 5, 2018

ភ្នំពេញ ៖ ដោយអនុវត្តន៍តាមការចុះកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអាមេរិក បញ្ជូន និង ទទួល យកពលរដ្ឋខ្មែរ ពីសហរដ្ឋអាមេរិក ឲ្យត្រឡប់មកកម្ពុជាវិញនោះ ពលរដ្ឋខ្មែររស់នៅសហរដ្ឋអាមេរិក ចំនួន៤៣នាក់ (ស្ត្រី៣នាក់) បានទៅរស់នៅសហរដ្ឋអាមេរិក តាំងពីមុនឆ្នាំ១៩៩៤ ហើយបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរខុសច្បាប់អាមេរិក រហូតដល់ជាប់ពន្ធនាគារ នៅអាមេរិក បានបញ្ជូនមកដល់ប្រទេសកម្ពុជាវិញហើយ នៅវេលាម៉ោងព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨នេះ តាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ។

លោក កែវ វណ្ណថន អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ បានឲ្យដឹងថា ពលរដ្ឋដែលបញ្ជូនមកកម្ពុជាវិញនេះ ពួកគាត់បានទៅរស់នៅសហរដ្ឋអាមេរិក តាំងពីមុនឆ្នាំ១៩៩៤ ហើយក៏បានប្រព្រឹត្តល្មើសធ្ងន់ធ្ងរ រហូតដល់ជាប់ពន្ធនាគារនៅអាមេរិក។ ក្រោយពេលជាប់ពន្ធនាគាររួចនេះហើយ ពួកគាត់ត្រូវបានអាមេរិកសម្រេចបញ្ជូនឲ្យត្រឡប់មកកម្ពុជាវិញ។

សូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអាមេរិក បានចុះកិច្ចព្រមព្រៀងបញ្ជូន និងទទួលយកពលរដ្ឋខ្មែរពីសហរដ្ឋអាមេរិកឲ្យត្រឡប់មកកម្ពុជាវិញ ចាប់តាំងពីឆ្នាំ២០០២។ កិច្ចព្រមព្រៀងនេះ រដ្ឋាភិបាលសហរដ្ឋអាមេរិក នឹងបញ្ជូនពលរដ្ឋខ្មែរណា ដែលប្រព្រឹត្តបទល្មើសឲ្យត្រឡប់មកមាតុភូមិវិញ ក្រោយពេលអនុវត្តន៍ទោសរួចរាល់។ ប៉ុន្តែកាលពីចុងឆ្នាំ២០១៧ ការបញ្ជូនពលរដ្ឋខ្មែរពីអាមេរិកត្រូវបានខកខាន ដោយសារតែសហរដ្ឋអាមេរិក មិនព្រមតាមសំណើកម្ពុជា ដែលស្នើឱ្យកែប្រែលក្ខខណ្ឌ មួយចំនួន នៅក្នុងកិច្ចព្រមព្រៀងនេះ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត។ សហរដ្ឋអាមេរិក បានសម្រេចផ្អាកទិដ្ឋាការ ដល់មន្ត្រីជាន់ខ្ពស់ក្រសួងការបរទេស និងសាច់ញាតិរបស់ពួកគេ ដែលរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថា ដោយសារតែការសើរើកិច្ចព្រមព្រៀងនេះ។ ជាមួយគ្នានេះកម្ពុជាក៏បានសម្រេចផ្អាកកិច្ចសហប្រតិបត្តិការកម្ពុជា-អាមេរិក ក្នុងការរុករកអដ្ឋិធាតុទាហានអាមេរិកដែលបាត់ខ្លួននៅកម្ពុជា ក្នុងសម័យសង្គ្រាមផងដែរ៕ ដោយ ៖ បញ្ញាស័ក្តិ

## ក្រសួងការងារ៖ពលករខ្មែរនៅថៃតិចតួចខកខានមិនបានបន្តសុពលភាពប័ណ្ណពណ៌ស៊ីជម្ពូ

https://wmc.org.kh/ ថ្ងៃព្រហស្បតិ៍ ទី៥ ខែមេសា ឆ្នាំ២០១៨ធូ វីរៈ

ភ្នំពេញ៖ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យដឹងថា ពលករខ្មែរមានចំនួនតិចតួចដែលបានខកខានមិនបានបន្តសុពលភាពប័ណ្ណស្នាក់នៅនិងធ្វើការបណ្ដោះអាសន្ន ឬ ប័ណ្ណពណ៌ស៊ីជម្ពូ និងលិខិតទំនាក់ទំនងរវាងថៅកែ និង ពលករ ខណៈដែលអាជ្ញាធរថៃព្រមានពីការបណ្ដេញចេញពលករបរទេសខុសច្បាប់។

នៅសប្តាហ៍មុនស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃបានអំពាវនាវដល់ពលករខ្មែរទាំងអស់ ប្រញាប់ទៅបន្តសុពលភាពប័ណ្ណស្នាក់នៅ និងធ្វើការបណ្ដោះអាសន្ន ឬ ប័ណ្ណពណ៌ស៊ីជម្ពូ និងលិខិតទំនាក់ទំនងរវាងថៅកែ និង ពលករ នៅការិយាល័យច្រកចេញចូលតែមួយ ដើម្បីបំពេញបែបបទជាពលករស្របច្បាប់ជាមួយគណៈកម្មការផ្តល់ភាពស្របច្បាប់កម្ពុជានៅប្រទេសថៃ។ ជាមួយគ្នានេះ ការបន្តសុពលភាពប័ណ្ណស្នាក់នៅ និងប័ណ្ណពណ៌ស៊ីជម្ពូ រួមទាំងលិខិតទំនាក់ទំនងរវាងថៅកែនិងពលករ បានផុតសុពលភាពហើយ កាលពីដើមខែ មេសានេះ។ កាសែតថៃ Bangkok Post បានចុះផ្សាយថា ពលករចំណាកស្រុកបរទេស ដូចជាពលករកម្ពុជា មីយ៉ាន់ម៉ា ឡាវ ប្រមាណ ៦ ម៉ឺននាក់ កំពុងធ្វើការងារ

និងស្នាក់នៅដោយខុសច្បាប់ ព្រោះពលករទាំងនោះ ខកខានមិនបន្តសុពលភាពប័ណ្ណស្នាក់នៅនិង ប័ណ្ណពណ៌ស៊ីជម្ពូនៅក្រសួងការងារថៃ ហើយពលករបរទេសទាំងនោះ នឹងប្រឈមការបណ្តេញចេញពីប្រទេសថៃ។

ទាក់ទិនករណីនេះ លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យដឹងថា ក្នុងចំណោមពលករមិនទាន់ស្របច្បាប់ប្រមាណ ៤០ ម៉ឺន នាក់ គឺ ពលករខ្មែរមានចំនួនតិចតួចទេ ដែលមិនទាន់បានមកបន្តសុពលភាពប័ណ្ណស្នាក់នៅនិងប័ណ្ណពណ៌ស៊ីជម្ពូ។ លោក ហេង សួរ៖ «បើធៀបជាមួយនឹងចំនួន៤០ម៉ឺននាក់ដែលមិនមានប័ណ្ណពណ៌ស៊ីជម្ពូ ឥឡូវនេះយើងមានពលករតិចតួចតែប៉ុណ្ណោះមិនទាន់បានទៅពន្យាប័ណ្ណពណ៌ស៊ីជម្ពូនេះ។ អញ្ចឹងយើងបានដោះស្រាយបញ្ហាជូនបងប្អូនបានប្រមាណ៩៦ភាគរយរួចទៅហើយ។» លោក ហេង សួរ ជឿថា ពលករខ្មែរដែលខកខានទាំងនោះអាចនឹងទៅបន្តសុពភាពប័ណ្ណពណ៌ស៊ីជម្ពូនៅ ក្រោយពេលពិធីបុណ្យចូលឆ្នាំខ្មែរ។ ទោះបីយ៉ាងណា លោកព្រមានថា អាជ្ញាធរថៃនឹងចាប់ផ្តើមរឹតបន្តឹងលើពលករចំណាកស្រុកខុសច្បាប់យ៉ាងយូរនៅដើមខែ មិថុនា ខាងមុននេះ។ លោក ហេង សួរ៖ «សម្រាប់ភាគីថៃគឺយូរនៅថ្ងៃទី ៣០ ខែ មិថុនា គាត់នឹងមានវិធានការសម្រាប់អ្នកដែលមិនមានឯកសារ ជាពិសេសមិនមានប័ណ្ណពណ៌ស៊ីជម្ពូ និងតែម្តង។ ប៉ុន្តែក៏មិនមែនមានន័យថាបិទសម្រាប់បងប្អូនមិនមានប័ណ្ណពណ៌ស៊ីជម្ពូត្រឡប់មកប្រទេសកំណើតបានទេ។ អញ្ចឹងប្អូនអាចត្រឡប់មកវិញរៀបចំឯកសារពីកម្ពុជាចូលទៅប្រទេសថៃវិញបាន។»

កាលពីអំឡុងខែ កុម្ភៈ កម្ពុជា-ថៃ ប្តេជ្ញាដោះស្រាយបញ្ហាពលករខ្មែរឲ្យក្លាយជាពលករស្របច្បាប់និងបញ្ចប់ការផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរនៅចុងខែ មិថុនា ឆ្នាំនេះ។ តាមច្បាប់ថ្មីរបស់ប្រទេសថៃ ពលករអន្តោប្រវេសន៍ ខកខានមិនបានធ្វើបែបបទស្នាក់នៅត្រូវ ពិន័យជាប្រាក់ពី ៥.០០០ បាត ទៅ ៥០.០០០ បាត។ សម្រាប់កម្មករ និយោជិតត្រូវពិន័យជាប្រាក់ចាប់ពី ១ ម៉ឺនបាត ទៅ ១ សែនបាត។ បទល្មើសដែលកើតឡើងច្រំដែលៗរបស់និយោជកត្រូវពិន័យប្រាក់ ២ សែនបាត ក្នុងមួយករណី ហើយផ្តន្ទាទោសពន្ធនាគារ ជិត ១ឆ្នាំ។ បន្ថែមពីនេះក្រុមហ៊ុនត្រូវហាមមិនឲ្យជ្រើសរើសពលករបរទេសរយៈពេល៣ឆ្នាំ។

យោងតាមរបាយការណ៍ក្រសួងការងារកម្ពុជា ពលករចំណាក់ស្រុកខ្មែរបម្រើការងារនៅប្រទេសថៃ ១ លាន ៥ ម៉ឺននាក់។ បើយោងតាមរបាយការណ៍ប្រចាំឆ្នាំ២០១៧របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការណ៍អន្តរជាតិបង្ហាញថាយ៉ាងតិចពលករខ្មែរជិត១៣ន់នាក់ត្រូវបាននិរទេសពីប្រទេសថៃមកកម្ពុជាតាមច្រកអន្តរជាតិប៉ោយប៉ែតខេត្តបន្ទាយមានជ័យ៕

## ពលករខុសច្បាប់បញ្ជូនតាមរថយន្តទ្រុងចេញពីថៃមានការខុសពីឆ្នាំមុនៗ(មានវីដេអូ)

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៨ម៉ោង ០៩:៥០ម៉ឺត សារុន

ខេត្តបន្ទាយមានជ័យ ៖ នៅជិតចូលឆ្នាំថ្មី ខាងមុខនេះពលករខុសច្បាប់ដែលភាគីថៃបញ្ជូនតាមរថយន្តទ្រុងតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សម្រាប់មុនពិធីបុណ្យជាតិធំៗ ពិសេសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដែលនឹងខិតជិតចូលមកដល់នៅសល់តែជាង១០ថ្ងៃទៀតនេះ បើប្រៀបធៀបទៅនឹងកៀកពិធីបុណ្យចូលឆ្នាំថ្មីឆ្នាំមុនៗ គឺខុសគ្នាខ្លាំង នេះបើតាមការឲ្យដឹងពីសមត្ថកិច្ច និងមន្ត្រីបម្រើការងារនៅទីតាំងទទួលពលករបញ្ជូនពីថៃក្នុងក្រុងប៉ោយប៉ែត ។

លោកឱក សំណុក អនុប្រធានការិយាល័យប្រឆាំងការជួញដូរ និងការពារអនិតិជននៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យបានប្រាប់ឲ្យកោះសន្តិភាពដឹងថា កាលពីខែមុនៗចុងឆ្នាំ២០១៧ និងដើមឆ្នាំ២០១៨ ពលករបញ្ជូនពីថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ថ្ងៃខ្លះត្រឹមតែ៥០ទៅ៦០នាក់ ថ្ងៃខ្លះគ្មាន និងថ្ងៃខ្លះជិត១០០នាក់ ។ លោកបន្តថា ទើបរយៈពេលដើមខែមេសា ២០១៨នេះ ពលករបញ្ជូនត្រឡប់មកថ្ងៃខ្លះកើនដល់៣១០នាក់ ថ្ងៃខ្លះត្រឹមជាង២០០នាក់ ។ លោកថា ពេលនេះកាលពីថ្ងៃខែឆ្នាំមុន ជិតពិធីបុណ្យជាតិដូចគ្នា ពលករបញ្ជូនត្រឡប់ក្នុង១ថ្ងៃៗមិនក្រោម៣០០នាក់ឡើយ ហើយថ្ងៃខ្លះរហូតជាង៥០០នាក់ក៏មានដែរ ៕

## តម្រួតស្រះកែវចាប់រថយន្តឈ្នួល,ដឹកពលករកម្ពុជាបំរុងចេញផ្លូវកាត់

http://www.pheaktraprak.com/ April 6, 2018

កាលពីថ្ងៃព្រហស្បតិ៍ ទី05 ខែមេសា ឆ្នាំ2018 ម្សិលមិញនេះ កម្លាំងសមត្ថកិច្ចតម្រួតប៉ុស្តិ៍(ណងម៉ាកហ្វាយ) ស្រុកវ៉ាតណាខន ខេត្តស្រះកែវ ប្រទេសថៃ បានធ្វើការឃាត់រថយន្តតូយ៉ូតាតូរីស ពណ៌សមួយគ្រឿង បន្ទាប់ពីសម្ថកិច្ចប្រទះឃើញរថយន្តខាងលើគួរឲ្យសង្ស័យ ។ យោងតាមរបាយការណ៍របស់សមត្ថកិច្ចបានឲ្យដឹងថារថយន្តតូរីសស៊ីឈ្នួលខាងលើបានស៊ីឈ្នួលដឹកពលករកម្ពុជាចំនួន 11នាក់ ក្នុងរដូវបុណ្យចូលឆ្នាំថ្មី ដោយយកតម្លៃឈ្នួលថ្លៃជាងរថយន្តឈ្នួលប្រចាំ ដោយមានការទំនាក់ទំនងជួលពីពលករកម្ពុជាម្នាក់ ក្នុងការត្រួតពិនិត្យឯសាររបស់ពលករកម្ពុជាទាំងអស់ មានឯកសារលិខិតឆ្លងដែនធ្វើដំណើរត្រឹមត្រូវ  ជាធម្មតាពលករមានលិខិតធ្វើដំណើរត្រូវចេញទៅប្រទេសកម្ពុជាតាមរយៈច្រកព្រំដែនអន្តរជាតិប៉ុណ្ណោះ ដោយមិនអាចចេញតាមច្រកព្រំដែនធម្មជាតិបានដាច់ខាត ក៏ប៉ុន្តែរថយន្តខាងលើបែរជាដឹកពលករទាំងអស់សំម្តៅទៅតាមច្រកព្រំដែនធម្មជាតិ ស្រុកតាបផាយ៉ា ដោយអាងថាពលករចង់ធ្វើដំណើរចេញតាមច្រកស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កម្លាំងសមត្ថកិច្ចថៃ ចឹងធ្វើការផាកពិន័យអ្នកបើកបររថយន្តខាងលើចំនួនទឹកប្រាក់ 400 បាត រួចអោយរថយន្តខាងលើដឹកពលករទាំងអស់ទៅចុះនៅច្រកព្រំដែនអន្តរាជាតិ( ខ្លងលឹក-ប៉ោយប៉ែត )។

## ជប៉ុនកំពុងសម្លឹងឃើញយុវវ័យកម្ពុជា ខណៈប្រទេសនេះជួបវិបត្តិកម្លាំងពលកម្ម

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៨ ម៉ោង ១០:៥៨ សុវណ្ណណៃត

រាជធានីភ្នំពេញ ៖ រដ្ឋាភិបាលប្រទេសជប៉ុនបានបង្ហាញពីហានិភ័យនៃការធ្លាក់ចុះធនធានមនុស្សពេញវ័យ ខណៈកំណើនមនុស្សវ័យចាស់កាន់តែច្រើន ដែលធ្វើឲ្យប្រទេសនេះបាត់បង់កម្លាំងពលកម្មនៅក្នុងវិស័យការងារ ដូចនេះ ហើយត្រូវការប្រើប្រាស់ការងារដោយស្វ័យប្រវត្តិ តែទោះជាយ៉ាងណា នៅក្នុងវិស័យការងារក៏ត្រូវការធនធានមនុស្សសម្រាប់ធ្វើការដែរ។ ដោយសារតែវិបត្តិធនធានមនុស្សពេញវ័យសម្រាប់បម្រើការងារថយចុះ ធ្វើឲ្យប្រទេសនេះស្វែងរកកម្លាំងពលកម្មពីបណ្តាប្រទេសខាងក្រៅ ដើម្បីយកទៅបំពេញការងារតាមបណ្តាសហគ្រាសផ្សេងៗ ។ ក្នុងនោះដែរ កម្ពុជាជាគោលដៅសំខាន់មួយសម្រាប់ជប៉ុន ក្នុងការបណ្តុះបណ្តាលពលករយកទៅធ្វើការ ។

បើតាមលោក Takeshi Kurada នាយកប្រតិបត្តិក្រុមហ៊ុនរីណៃត ជប៉ុន គ្រុប អាយអុិនស៊ី បានឲ្យដឹងកាលពីថ្ងៃទី៥ មេសា ថា បច្ចុប្បន្ននេះ ប្រទេសជប៉ុនកំពុងជួបវិបត្តិសម្បូរមនុស្សចាស់ និងខ្វះមនុស្សពេញវ័យធ្វើការ ដែលធ្វើឲ្យប្រទេសជប៉ុនបាត់បង់កម្លាំងការងារច្រើនសម្រាប់បម្រើការនៅតាមសហគ្រាស និងរោងចក្រនានា ។ លោកនិយាយថា ៖« ការដែលយើងសម្រេចមកកម្ពុជា ហើយស្វែងរកកម្លាំងពលកម្មពីកម្ពុជាទៅធ្វើការនៅប្រទេសជប៉ុន ដោយសារតែយើងគិតថា ទំនាក់ទំនងរវាងជប៉ុននិងកម្ពុជា មានភាពស្និទ្ធស្នាលនឹងគ្នា ហើយកម្ពុជាមានមនុស្សពេញវ័យបម្រើការងារក៏ច្រើន ។ ដូចនេះហើយទើបយើងបានសហការជាមួយបណ្តាស្ថាប័ននានានៅជប៉ុន សម្រេចបណ្តុះបណ្តាលសិក្ខាកាមកម្ពុជាតែម្តង » ។ លោកបន្តថា ការងារបច្ចុប្បន្ននៅក្នុងប្រទេសជប៉ុន ដែលគ្រោងនឹងបញ្ជូនសិក្ខាកាមពីកម្ពុជា ភាគច្រើនជាការងារក្នុងវិស័យយានយន្ត ដូចជា តាមបណ្តាសហគ្រាសថែទាំយានយន្ត និងការងារដំឡើងរថយន្តនៅតាមរោងចក្រនានា ។ ក្រៅពីអត្ថប្រយោជន៍ដែលទទួលបានប្រាក់បៀវត្សរ៍ប្រចាំខែហើយ ពលករកម្ពុជាដែលទៅធ្វើការនៅជប៉ុន ក៏នឹងអាចទទួលបានជំនាញមុនពេលចេញទៅធ្វើការ និងបទពិសោធន៍ជំនាញ ក្រោយពេលទៅធ្វើការនៅប្រទេសជប៉ុន ។

លោកបន្ថែមទៀតថា ដើម្បីសម្រួលដល់ការខ្វះខាតរបស់ពលករកម្ពុជា ភាគីជប៉ុនក៏បានសហការជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ផ្តល់កម្ចី ដែលពលកររូបណាខ្វះខាតហិរញ្ញវត្ថុសម្រាប់ធ្វើដំណើរ ។ ដូចនេះ នៅពេលពួកគេធ្វើការបានចំណូលអាចសងត្រឡប់ទៅគ្រឹះស្ថាននោះវិញតាមលទ្ធភាព ។ លោក Mitsugu Takeuchi ប្រធានសមាគមថែទាំរថយន្តប្រទេសជប៉ុន បានឲ្យដឹងថា ជប៉ុនគ្រោងនឹងបណ្តុះបណ្តាលធនធានមនុស្សកម្ពុជាឲ្យបាន១ពាន់

នាក់នៅក្នុងឆ្នាំ២០២០ ។ មិនតែប៉ុណ្ណោះ ជប៉ុនក៏គ្រោងនឹងបណ្តុះបណ្តាលគ្រូបង្គោលជនជាតិខ្មែរផងដែរ ដើម្បីឲ្យគ្រូបង្គោលទាំងនោះទៅបណ្តុះបណ្តាលបន្តដល់ធនធានមនុស្សក្នុងវិស័យយានយន្តកម្ពុជា ។ លោកនិយាយថា ៖« ក្នុងនាមជាប្រធានសមាគមថែទាំរថយន្តនៅប្រទេសជប៉ុន យើងបានស្នើឲ្យសមាជិក ដែលជាម្ចាស់រោងចក្រដំឡើងរថយន្ត និងសហគ្រាសថែទាំរថយន្តនានាទទួលយកពលករកម្ពុជាទៅធ្វើការឲ្យបានច្រើនតាមលទ្ធភាព ហើយយើងក៏ជឿថាសមាជិកទាំងអស់ក៏កំពុងត្រូវការកម្លាំងពលកម្មសម្រាប់បម្រើការងារនៅក្នុងសហគ្រាសរបស់ខ្លួនដែរ ស្របពេលកម្លាំងពលកម្មជប៉ុនកំពុងថយចុះ » ។

លោក ពេជ សោភ័ន រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍ថា កម្ពុជាជាប្រទេសដែលមានប្រជាពលរដ្ឋវ័យក្មេង និងឈានដល់អាយុចូលធ្វើការច្រើន ។ ជាក់ស្តែង បច្ចុប្បន្ននេះ កំណើនមនុស្សពេញវ័យធ្វើការមានប្រមាណ៣០ម៉ឺននាក់ក្នុង១ឆ្នាំ ។ ដូចនេះ ការស្វែងរកពលករកម្ពុជាទៅធ្វើការនៅប្រទេសជប៉ុន គឺជារឿងមួយល្អប្រសើរ ។ លោកថា ៖« កម្ពុជា ជាប្រទេសមួយដែលមានសក្តានុពលខ្ពស់ ដូចនេះហើយទើបប្រទេសជាច្រើនទៀតបានចូលមកវិនិយោគ បង្កើតការងារជាបន្តបន្ទាប់ដល់ពលរដ្ឋ ហើយការវិនិយោគរបស់ពួកគេ ក៏មានភាពងាយស្រួលក្នុងការស្វែងរកកម្លាំងពលកម្មផងដែរ » ។ លោកបន្តថា ការផ្តល់ឱកាសការងារដល់យុវជនកម្ពុជារបស់ភាគីជប៉ុន គឺជាការបង្ហាញពីចំណងមិត្តភាពរវាងប្រទេសទាំងពីរកាន់តែមានភាពស្អិតរមួត និងខិតជិតគ្នា ។ ក្រៅពីឱកាសការងារទទួលបានប្រាក់ចំណូល ពលករកម្ពុជាក៏អាចទទួលបានជំនាញមួយសម្រាប់ជីវិតរបស់ខ្លួនផ្ទាល់ ។ មិនតែប៉ុណ្ណោះ ពលករដែលត្រឡប់មកពីធ្វើការនៅប្រទេសជប៉ុនវិញ ក៏អភិវឌ្ឍន៍ប្រទេស និងពង្រឹងបច្ចេកទេសក្នុងវិស័យយានយន្តកម្ពុជាកាន់តែរឹងមាំផងដែរ ។

គួរបញ្ជាក់ថា គិតរហូតមកដល់បច្ចុប្បន្ននេះ កម្ពុជាបានបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ចំនួន១,២លាននាក់ និងបានផ្ញើប្រាក់ត្រឡប់មកក្នុងស្រុកវិញ មានប្រមាណ២ពាន់លានដុល្លារអាមេរិកក្នុង១ឆ្នាំ ៕

## ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១៨

## ពលករខ្មែរ Share រឿងប៉ូលិសព្រំដែនយកប្រាក់ពីពលករ

http://www.pheaktraprak.com/ April 6, 2018

ពលករកម្ពុជាធ្វើការនៅប្រទេសថៃនាំគ្នាស៊ែរ ភ្លុកទឹកភ្លុកដី រឿងអាជ្ញាធរប្រចាំច្រកទ្វារព្រំដែនអន្តរជាតិបានទ្បើមយកប្រាក់ពីពលករម្នាក់100បាត។ កាលពីថ្ងៃសុក្រ ទី06 ខែមេសា ឆ្នាំ2018 ម្ចាស់អាខោនហ្វេសប៊ុកឈ្មោះ chanthy nom បានបង្ហោះរូបភាពពលករកម្ពុជាជាច្រើននាក់កំពុងរងចាំចាយប្រាក់ចំនួន100បាត ទៅអោយប៉ូលិសខ្មែរនៅច្រកព្រំដែនស្ទើរតែបាក់ស្ពាន។ បន្ទាប់ពីបានបង្ហោះនៅលើបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុកធ្វើឲ្យពលករកម្ពុជាមួយចំនួនធំចូលមកComment រិះគន់យ៉ាងចាស់ដៃព្រមទាំងនាំគ្នាស៊ែរបន្តផងដែរ។ ហើយការពិតយ៉ាងណានោះ គេនៅមិនទាន់ដឹងច្បាស់នៅឡើយទេ ព្រោះមិនទាន់មានការបកស្រាយពីខាងសមត្ថកិច្ចប្រចាំព្រំដែន ខាងលើនៅឡើយ។

## មេប៉ូលិសអន្តោប្រវេសន៍ថា គ្មានការយកលុយពីពលករមកពីថៃទេ

http://kleykley.sabay.com.kh/ សៅរ៍, 7 មេសា 2018 14:14

ឧត្តមសេនីយ៍ត្រី សៅ ប៊ុនរិទ្ធ ប្រធានប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ច្រកទ្វារព្រំដែនអន្តរជាតិដូង បានឲ្យដឹងថាគ្មានករណីយកប្រាក់ពីពលករខ្មែរដែលចាកចេញពីថៃ មកលេងស្រុកកំណើតនោះទេ។ លោកថា តាមគោលការណ៍ថ្នាក់លើគឺមិនឲ្យសមត្ថកិច្ចនៅច្រកទ្វារព្រំដែនយកប្រាក់ពីពលករខ្មែរនោះឡើយ បើប៉ូលិសណាយកប្រាក់ពីពលករខ្មែរត្រូវកត់អត្តលេខ និងមើលឈ្មោះ ដើម្បីចាត់វិធានការ។

ចំណែក នាយឧត្តមសេនីយ៍ សុខ ផល អគ្គនាយកដ្ឋានអន្តោប្រវេសន៍បានបញ្ជាក់ថា លោកបានចាត់ឲ្យមន្ត្រីជំនាញចុះពិនិត្យមើលករណីនេះហើយ។ ប៉ុន្តែលទ្ធផលយ៉ាងណា លោកមិនបានបញ្ជាក់នោះទេ។

សូមជម្រាបថា ការចាត់ឲ្យមន្រ្តីជំនាញចុះពិនិត្យមើលករណីយកប្រាក់ពីពលករខ្មែរនេះ បន្ទាប់ពីមានព័ត៌មានលេចឮថា ប៉ូលិសបានយកលុយពួកគាត់ ពេលឆ្លងដែនពីថៃ ចូលមកទឹកដីកម្ពុជា។ ពលករខ្មែរដែលចេញតាមច្រកអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង បានចោទប្រកាន់សមត្ថកិច្ចទាំងភាគីថៃ និងកម្ពុជា ថាបានទារប្រាក់ពួកគាត់ម្នាក់ជិត ៤ម៉ឺនរៀល។ ពលករខ្មែរធ្វើការនៅក្នុងប្រទេសថៃរាប់ពាន់នាក់ បាននាំគ្នាធ្វើដំណើរសម្រុកចាកចេញពីប្រទេសថៃតាមច្រកទ្វារព្រំដែនអន្តជាតិដូង ជាប់នឹងច្រកបានឡែម ស្រុកប៉ុងណាំរ៉ុង ខេត្តច័ន្ទបុរី ប្រទេសថៃ ដើម្បីទៅលេងស្រុកកំណើត ក្នុងឱកាសថ្ងៃបុណ្យចូលឆ្នាំខ្មែរ ខាងមុខនេះ។ ក្រៅពីច្រកទ្វារព្រំដែនអន្តជាតិដូង ពលករខ្មែរជាច្រើននាក់ ក៏បានដំណើរចាកចេញពីប្រទេសថៃចូលមកកម្ពុជាតាមច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាប់នឹងច្រកខ្លងឡឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃផងដែរ៕ អត្ថបទ៖ សោភា

## លោក សៅប៊ុនរិទ្ធ មានអំណាច បញ្ជាឲ្យកូនចៅ ប្រមូលលុយ ពលករឆ្លងដែនពីប្រទេសថៃ មកលេងស្រុកកំណើត តាមរបៀបពុករលួយ ?

http://www.arey-news.com/ ( ថ្ងៃទី 09 April 2018 ម៉ោង 8:51 am )

ខេត្តបាត់ដំបង ៖ លោក សៅ ប៊ុនណារិទ្ធ ប្រធានការិយាល័យនគរបាលអន្តោប្រវេសន៍ច្រកអន្តរជាតិដូង បាននឹងកំពុង ធ្វើអោយអំពើពុករលួយ បែបអបាយមុខនេះ ប៉ះពាល់ដល់អារម្មណ៍ពលករខ្មែរ និងជះឥទ្ធិពលដ៏អាក្រក់ដល់ថ្នាក់លើ ខណៈបុគ្គលរូបនេះគិតផលប្រយោជន៍បុគ្គលធំជាងលើកកម្ពស់កិត្តិ យស អង្គភាព និងស្វែងយល់ យន្តការនយោបាយ រដ្ឋាភិបាលបាននិងកំពុង គិតគូរពីពលករខ្មែរនោះ..? ពលករខ្មែរធ្វើការងារនៅ ប្រទេសថៃសម្រុកចាកចេញមកកាន់ស្រុក កំណើតដ៏ច្រើន នៅថ្ងៃទី៦មេសាឆ្នាំ២០១៨ តាមច្រអន្តរជាតិដូង ហាក់ច្រើនជាសព្វដង ក៏ដូចជាឆ្នាំមុន។ យ៉ាងតិចក្នុង១ថ្ងៃមាន ពលករ ខ្មែររាប់ពាន់នាក់ បានឆ្លងតាមច្រកដូង។ ក្នុងនោះពួកគាត់ ប្រឈមនិងការចំណាយប្រាក់ក្នុងម្នាក់៣០០បាតជិតស្មើនិង៤០០០០រៀលទៅអោយសមត្ថកិច្ច ភាគីថៃ និងនគរបាលអន្តោប្រវេសន៍ ច្រកអន្តរជាតិដូង។ នារដូវបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ខ្មែរយើងដែលនឹង ឈានជិតមកដល់ នាពេលដ៏ខ្លីខាងមុខនេះ ខាងរដ្ឋាភិបាលប្រទេសថៃដែលមានទំនាក់ទំនងដ៏ល្អជាមួយរដ្ឋាភិបាលកម្ពុជា គឺបានអោយតាមបណ្តាក្រុមហ៊ុន សហគ្រាសតូច-ធំក្នុង ប្រទេសនេះត្រូវអនុញ្ញាតអោយបុគ្គលិកកម្មករពលករជនជាតិបរទេស ពិសេស ពលករខ្មែរបានឈប់ សម្រាកពីការងារមួយរយៈ ដើម្បីមកលេងស្រុកកំណើត ជួបជុំបងប្អូនក្រុមគ្រួសារ ដើម្បីសប្បាយរីករាយ នារដូវចូលឆ្នាំថ្មីនេះ។ ក្នុងនោះ មានពលខ្មែររាប់ម៉ឺននាក់បានចាក ចេញពីប្រទេសថៃ តាមច្រកមួយចំនួនទាំងច្រកអន្តរជាតិនិងច្រកទ្វេរភាគីច្រករបៀងខេត្តបាត់ដំបង ខេត្ត បន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិនជាដើម ក្នុងមួយថ្ងៃៗរាប់ពាន់នាក់។ ប៉ុន្តែអ្វីដែលមិនគួរកើតត្រង់ថា មេនគរបាលអន្តោរប្រវេសន៍ច្រកអន្តរជាតិ ដូង ស្ថិតក្នុងស្រុកកំរៀង ខេត្តបាត់ដំបង ឆក់ឱកាសអោយមន្ត្រីរបស់ខ្លួន យកលុយពីពលករខ្មែរ ផ្ទុយពីគោលការណ៍លើកទឹកចិត្តពីប្រមុខរាជរដ្ឋាភិបាលទៅលើពលករ កម្មករ កម្មការិនី ក្នុងក្របខណ្ឌទូទាំងប្រទេសនោះ៕

## ពលករកម្ពុជាចំនួនរាប់ពាន់នាក់,នាំគ្នាធ្វើដំណើរទៅលេងស្រុកកំណើតតាមរយៈច្រកឡែម

http://www.pheaktraprak.com/ April 8, 2018

ពលករកម្ពុជាធ្វើការនៅក្នុងប្រទេសថៃចំនួនរាប់ពាន់នាក់ កំពុងធ្វើដំណើរវិលត្រឡប់ទៅលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។ នៅថ្ងៃអាទិត្យ ទី08 ខែមេសា ឆ្នាំ2018 ម្សិលមិញនេះ ពលករកម្ពុជាធ្វើការនៅតាមបណ្តាលខេត្តផ្សេងៗនៅក្នុងប្រទេសថៃដូចជា ខេត្តសាមុតប្រាកាន, ខេត្តឈុនបុរី, ខេត្តរ៉ាក់យ៉ង, ខេត្តចាន់បុរី និងទីក្រុងបាងកក ចំនួនរាប់ពាន់នាក់ បាននាំគ្នា ធ្វើដំណើរវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួននៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ តាមរយៈច្រកទ្វារព្រំដែនអន្តជាតិ(បានឡែម) ស្រុកប៉ោងណាមរ៉ន់ ខេត្តចាន់បុរី ប្រទេសថៃ យ៉ាងច្រើនកុះករ ។ ដោយពលករដែលធ្វើដំណើរភាគច្រើនគឺមានប័ត្រស៊ីជម្ពូនិងលិខិតឆ្លងដែនធ្វើការយ៉ាងត្រឹមត្រូវ លើសពី

នេះទៅទៀតក្រុមការងារទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ បានទៅប្រចាំការិយាល័យចល័តប្រចាំច្រកទ្វារព្រំដែនអន្តរជាតិ(បានទ្បែម) ដើម្បីជួយអន្តរាគមន៍ជួយសម្រួល និងណែនាំរឿងឯកសារ និងសំណុំបែបបទ ដល់បងប្អូនពលករកម្ពុជាដែលត្រូវធ្វើដំណើរមកពីខេត្តផ្សេងៗនៃប្រទេសថៃ ដើម្បីអោយគាត់បានធ្វើដំណើរចេញចូលប្រកប់ដោយសុវត្ថិភាពគ្រប់គ្នា នៅក្នុងធ្វើដំណើរវិលត្រឡប់ទៅលេងស្រុកកំណើតដើម្បីជួបជុំក្រុមគ្រួសារបងប្អូននាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរខាងនេះ។ ដោយបើកអោយពលករធ្វើដំណើរទៅលេងផ្ទះចាប់តាំងពីថ្ងៃទី05 ខែមេសា ឆ្នាំ2018 រហូតដល់ថ្ងៃទី30 ខែមេសា ឆ្នាំ2018 ។

## បុណ្យចូលឆ្នាំ៖ អាជ្ញាធរថាពលករខ្មែរសម្រុកមកស្រុកកំណើតច្រើនជាងរាល់ឆ្នាំ

http://km.rfi.fr/ ដោយ អេង គីមហុង 08/04/2018

នៅបាំងតែមួយសប្តាហ៍ទៀតទេ ពិធីបុណ្យចូលឆ្នាំខ្មែរនឹងចូលមកដល់។ នៅអំឡុងពេលនេះ អាជ្ញាធរក្រុងប៉ោយប៉ែត បានកត់សម្គាល់ថា ពលករខ្មែរធ្វើការនៅថៃ បានសម្រុកវិលមកស្រុកកំណើតច្រើនជាងឆ្នាំមុន។ ចំណែកមន្ត្រីសង្គមស៊ីវិលវិញមើលឃើញថា ពលករខ្មែរបានចំណាយលុយឱ្យមន្ត្រីច្រកព្រំដែនជាច្រើនដំណាក់ ទម្រាំបានទៅដល់ផ្ទះ។ ជាទូទៅការធ្វើដំណើរចេញចូលរកការងារធ្វើនៅប្រទេសថៃ ត្រូវបែងចែកជាបីដំណាក់កាលដោយរួមមាន៖ ដំណើរចេញព្រឹកវិលល្ងាច មួយសប្តាហ៍ត្រឡប់មកម្តង និងចុងក្រោយ មួយឆ្នាំត្រឡប់មកម្តងក្នុងឱកាសបុណ្យទាន។ ដូច្នេះទាំងអាជ្ញាធរ និងមន្ត្រីអង្គការសង្គមស៊ីវិលកត់សម្គាល់ស្រដៀងគ្នាថា ដំណើរចូលស្រុកមួយឆ្នាំ ត្រឡប់មកលេងស្រុកម្តងៗ កំពុងចរាចរយ៉ាងខ្លាំងនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត។

អភិបាលក្រុងប៉ោយប៉ែត លោក សាន ស៊ានហូ បានអះអាងប្រាប់វិទ្យុបារាំងអន្តរជាតិ នៅថ្ងៃអាទិត្យនេះថា ក្រៅពីប្រើប្រាស់មធ្យោបាយរថយន្ត ពលករខ្មែរធ្វើការនៅថៃ គួរងាកមកជិះរថភ្លើងដោយឥតគិតថ្លៃ ចាប់ពីថ្ងៃទី៤ មេសា ដល់ថ្ងៃទី៣១ ខែកក្កដាខាងមុខនេះ។ រថភ្លើងថ្មីនេះត្រូវបានដាក់ឱ្យដំណើរការដោយក្រសួងសាធារណៈការ និងដឹកជញ្ជូនមុនពិធីបុណ្យចូលឆ្នាំខ្មែរកាលពីថ្ងៃទី៤ ខែមេសា។ ទោះជាមានមធ្យោបាយធ្វើដំណើរថ្មីដោយឥតគិតថ្លៃយ៉ាងណាក៏ដោយ តែរូបភាពនៃការដំឡើងថ្លៃរថយន្តឈ្នួល ឬការទារប្រាក់ពីពលករខ្មែរពីសំណាក់អាជ្ញាធរខ្មែរមួយចំនួន និងពីខាងអាជ្ញាធរថៃនៅតែកើតមានដដែល ដែលបញ្ហានេះធ្វើឱ្យពលករចំណាយប្រាក់អស់ច្រើនមុនមកដល់ស្រុកកំណើត។ នេះបើតាមការអះអាងរបស់លោក ស៊ុម ចាន់គា មន្ត្រីអង្គការអាដហុកប្រចាំនៅខេត្តបន្ទាយមានជ័យ។ តែបើតាមអាជ្ញាធរខ្លួនបានចំណាយ និងជួយសម្រួលដល់ពលករអស់លទ្ធភាពហើយ។ ចំពោះការទាមទារឬក៏ដំឡើងសេវាណាមួយវាជារឿងចៀសមិនផុតទេនៅក្នុងប្រទេសដែលកាន់របបទីផ្សារសេរីនោះ។ នេះបើតាមលោកសាន ស៊ានហូ។

បើតាមរដ្ឋាភិបាលកម្ពុជា បច្ចុប្បន្នពលករកម្ពុជាចំនួន៦៣ម៉ឺននាក់ មានប័ណ្ណស្នាក់នៅពណ៌ស៊ីជម្ពូបណ្តោះអាសន្ន។ ក្នុងចំណោម៦៣ម៉ឺននាក់នេះអាជ្ញាធរបានធ្វើលិខិតឆ្លងដែន ឬលិខិតធ្វើដំណើរជូនដល់ពលករចំនួន៤៣ម៉ឺននាក់រួចរាល់ហើយ។ ចំនួនសល់ពីនេះ ប្រមាណ១៩ម៉ឺននាក់ផ្សេងទៀត អាជ្ញាធរកម្ពុជាកំពុងធ្វើលិខិតឆ្លងដែន ឬលិខិតធ្វើដំណើរជូន។ នេះបើតាមលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ៕

# ពលរដ្ឋ និងសង្គមស៊ីវិលថា កម្ពុជាអាចនឹងខ្វះកម្លាំងពលកម្ម ប្រសិនបើលំហូរចំណាកស្រុក នៅតែកើតមានឡើង ដោយគ្មានវិធានការទប់ស្កាត់

https://www.rfa.org/ ដោយ សន ចាន់រដ្ឋា 2018-04-07

ពលរដ្ឋនៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម និង សង្គមស៊ីវិលផង លើកឡើងថាកម្ពុជា អាចនឹងប្រឈមកង្វះកម្លាំងពលកម្មក្នុងស្រុក ពិសេសកង្វះកម្លាំងបម្រើការងារនៅតាមមូលដ្ឋានក្នុងវិស័យកសិកម្មនៅពេលខាងមុខ។ ការលើកឡើងនេះ ដោយសារពួកគេកត់សម្គាល់ថា ចលនាចំណាកស្រុករបស់ពលរដ្ឋនៅតាមមូលដ្ឋានកើតមានកាន់តែច្រើន រីឯវិធានការដោះស្រាយរបស់រដ្ឋនៅពុំទាន់មានប្រសិទ្ធភាពនៅឡើយ។

ពលរដ្ឋ និងសង្គមស៊ីវិលយល់ថា មានកត្តាមួយចំនួន ដែលអាចរក្សាធនធានមនុស្ស ឬកម្លាំងពលកម្ម មិនឱ្យចំណាកស្រុកបន្តទៀត គឺបេបលោក ហ៊ុន សែន ធ្វើយ៉ាងណាដោះស្រាយបញ្ហាប្រឈមរបស់កសិករដូចជា ដោះស្រាយបញ្ហាតម្លៃកសិផលជាដើម។ លើសពីនេះ ខិតខំទាក់ទាញវិនិយោគបរទេសឱ្យបានច្រើន ដែលអាចបង្កើតការងារក្នុងស្រុកដល់ពលរដ្ឋបន្ថែមទៀត។ របបលោក ហ៊ុន សែន គប្បី ដោះស្រាយបញ្ហាដីធ្លីនៅតំបន់ដែលមានជម្លោះ និង ចាត់វិធានការចំពោះបទល្មើសផ្សេងៗ ដូចជាបទល្មើសនេសាទ បទល្មើសព្រៃឈើ និងសត្វព្រៃ។ មិនតែប៉ុណ្ណោះ រដ្ឋគប្បីខិតខំបណ្តុះបណ្តាលជំនាញផ្សេងៗ ដល់កសិករ។

កសិករនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ លោក កម ស្រស់ មានប្រសាសន៍ថា ការចំណាកស្រុកនៅមូលដ្ឋានរបស់លោកកើតឡើងដោយសារបញ្ហាជីវភាពរបស់ពលរដ្ឋមួយចំនួនជួបការលំបាក ដូចជា ការជំពាក់បំណុលធនាគារ រីឯតម្លៃកសិផលកសិកម្ម និងកសិ-ឧស្សាហកម្ម ធ្លាក់ចុះយ៉ាងកំហុក។ ជាក់ស្តែង តម្លៃម្រេចនៅឆ្នាំនេះ ធ្លាក់មកនៅមួយម៉ឺនរៀល (១០.០០០) ក្នុងមួយគីឡូក្រាម។ ស្របពេលតម្លៃម្រេចកាលពីឆ្នាំមុនៗ កសិករអាចលក់បានចន្លោះពី ២ម៉ឺនរៀលទៅជាង ៤ម៉ឺនរៀលក្នុងមួយគីឡូក្រាម។ រីឯតម្លៃជ័រកៅស៊ូវិញ កសិករនៅខេត្តត្បូងឃ្មុំធ្លាប់លក់បានក្នុងពីបួនពាន់រៀល (៤.០០០) ឡើងទៅក្នុងមួយគីឡូក្រាម បែរជាធ្លាក់មកនៅជាងមួយពាន់រៀល ក្នុងមួយគីឡូក្រាមនៅឆ្នាំ២០១៨៖ «សុំឱ្យរាជរដ្ឋាភិបាលជួយ ចំពោះក្រុមហ៊ុនដែលប៉ះពាល់ដីពលរដ្ឋប៉ុន្មានឱ្យរដ្ឋាភិបាលចែកជូនពលរដ្ឋ ដើម្បីឱ្យពលរដ្ឋមានការងារធ្វើ។ ដំឡើងប្រាក់ខែ ក៏ដូចជាជួយឱ្យមានទីផ្សារ ដូចជាដំឡូងមី ឱ្យមានតម្លៃ ៤រយរៀល ហើយជ័រកៅស៊ូមានតម្លៃបីបួនពាន់រៀលអីចឹង»។

ស្រដៀងគ្នានេះ កសិករនៅឃុំត្រពាំងព្រីងស្រុកតំបែរ លោក សែម ចំណាន លើកឡើងថា ពួកគាត់បារម្ភចំពោះស្ថានភាពចំណាកស្រុក ក្នុងមូលដ្ឋានរបស់ខ្លួន។ លោកបន្តថា ពលរដ្ឋមួយចំនួនចាកចេញពីភូមិកំណើតទៅរកការងារធ្វើនៅតាមបណ្តាខេត្តផ្សេងៗ ក្នុងប្រទេសកម្ពុជា ប៉ុន្តែអ្នកភូមិមួយចំនួនទៀត នាំគ្នាទៅរកការងារធ្វើនៅក្រៅប្រទេស ពិសេសប្រទេសថៃ និងប្រទេសម៉ាឡេស៊ី ដោយខ្លះទៅស្របច្បាប់ និងខ្លះទៀត ចេញទៅដោយប្រថុយប្រថានតែម្តង។ លោក សែម ចំណាន បារម្ភថា ប្រសិនបើលំហូរចំណាកស្រុកនៅតែកើតមានឡើងឥតឈប់ឈរដូចពេលបច្ចុប្បន្ន ថ្ងៃអនាគតប្រទេសកម្ពុជា នឹងខ្វះកម្លាំងពលកម្ម ពិសេសខ្វះកម្លាំងមនុស្សសម្រាប់បម្រើការងារក្នុងវិស័យកម្មនៅតាមមូលដ្ឋានតែម្តង៖ «នៅស្រុកខ្ញុំមុនវាមានការងារច្រើនដូចជាធ្វើស្រែវស្សាស្រែប្រាំង ហើយមួយទៀតយើងប្រកបមុខរបរដូចជាស៊ីឈ្នួលអ្នកក្នុងស្រុក»។ ពលរដ្ឋនៅឃុំត្រពាំងព្រីង មានចំនួនជាងបីពាន់គ្រួសារ (៣.៥៨៣) ហើយភាគច្រើនពួកគាត់មានមុខរបរធ្វើស្រែ និងចម្ការ។ ក្នុងចំណោមពលរដ្ឋទាំងនេះ គឺមានប្រមាណ ៨០ភាគរយ ជំពាក់បំណុលធនាគារ។

ចំណែកពលរដ្ឋនៅស្រុកព្រៃឈរ ខេត្តកំពង់ចាម លោក វ៉ែន រ៉ាន់ មើលឃើញថា ចំនួនពលរដ្ឋដែលរស់ពឹងអាស្រ័យលើផលនេសាទលក្ខណៈគ្រួសារនៅតំបន់បឹងធំ ក៏ចាប់ផ្តើមចាកចោលស្រុកកំណើតជាបន្តបន្ទាប់ ដើម្បីស្វែងរកការងារធ្វើនៅតាមបណ្តាខេត្តផ្សេងៗ ឬទៅរាជធានីភ្នំពេញ។ លោកសង្កេតឃើញថា ក្នុងភូមិរបស់លោក មិនមានអ្នកចំណាកស្រុកទៅក្រៅប្រទេសទេ ប៉ុន្តែភូមិផ្សេង គឺមានអ្នកចំណាកស្រុកទៅក្រៅប្រទេស។ លោកបន្តថា មូលហេតុចំ

ណាកស្រុក ដោយសារទិន្នផលត្រីក្នុងបឹងកាន់តែថយចុះ ហើយបទល្មើសនៅតែកើតមាន៖ «សំណូមពរដែលដល់រាជរដ្ឋាភិបាលកម្ពុជា គាត់គួរតែធ្វើអ្វីមួយ ដូចជាឧទាហរណ៍ដាក់ស្តែងបទល្មើសនេសាទ គាត់គួរធ្វើម៉េច បំបាត់អាបទល្មើសហ្នឹងឱ្យអស់ ដើម្បីឱ្យត្រីកើនឡើងវិញសម្រាប់ប្រជាពលរដ្ឋគាត់រក»។

របាយការណ៍បូកសរុបការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលចេញផ្សាយកាលពីខែមីនា ឆ្នាំ២០១៨ បង្ហាញថា ក្រសួងបានផ្តល់សេវាជួយស្វែងរកការងារធ្វើនៅក្រៅប្រទេសជូនពលករខ្មែរមានចំនួនជាងមួយលានពីរសែននាក់(១.២០០.០០០)។ ប្រទេសទាំងនោះរួមមានប្រទេសថៃមានចំនួនជាង ១លាននាក់ (១.០៥៦.៣៥៨) ប្រទេសកូរ៉េខាងត្បូងជាងបួនម៉ឺននាក់ (៤៤.២២៩) ប្រទេសម៉ាឡេស៊ី ប្រមាណបីម៉ឺននាក់ (៣០.០០០) ប្រទេសជប៉ុន មានចំនួនប្រាំមួយពាន់នាក់ (៦.០០០) ប្រទេសសិង្ហបុរីជិត ៥រយនាក់ (៤៨៧) ព្រមទាំងរដ្ឋបាលពិសេសក្រុងហុងកុងជាង ដប់នាក់ (១៥) ។ ចំនួនទាំងនេះ នៅមិនទាន់រាប់បញ្ចូលចំនួនពលករ ដែលចាញ់បោកមេខ្យល់ ឬទៅធ្វើការងារនៅក្រៅប្រទេសដោយខុសច្បាប់នៅឡើយទេ។

កាលពីខែធ្នូ ឆ្នាំ២០១៧ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងថា ការចំណាកស្រុកទៅធ្វើការងារនៅក្រៅប្រទេស គឺពុំមែនមានតែប្រទេសកម្ពុជានោះឡើយ ហើយទីផ្សារកម្លាំងពលកម្មរបស់កម្ពុជា ត្រូវប្រកួតប្រជែងជាមួយទីផ្សារក្នុងតំបន់ថៃមទៀត៖ «យើងហ្នឹងបន្តពង្រីកជាមួយហ្នឹងទីផ្សារការងារ របស់យើងនៅក្រៅប្រទេស។ ជាមួយហ្នឹងការប្រកួតប្រជែងជាមួយកម្មករនៃប្រទេសដទៃ»។ យ៉ាងនេះក្តី លោក ហ៊ុន សែន ប្តេជ្ញាថានឹងខិតខំពង្រីកទីផ្សារការងារក្នុងស្រុកឱ្យបានច្រើនបន្ថែមទៀត។ ជាមួយគ្នានេះ នៅឆ្នាំ២០១៨ របបលោក ហ៊ុន សែន សម្រេចដំឡើងប្រាក់ខែគោលជូនកម្មករ ពី ១៥៣ដុល្លារសហរដ្ឋអាមេរិក ទៅ ១៧០ដុល្លារសហរដ្ឋអាមេរិក។

របាយការណ៍របស់ក្រសួងការងារ ដដែលកំណត់ទិសដៅសម្រាប់ឆ្នាំ២០១៨ គឺមាន ៩ចំណុច ក្នុងនោះ មាននិយាយអំពីការពង្រឹងគុណភាពកម្មវិធីអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ទាំងរយៈពេលខ្លី និងវែង ដើម្បីឱ្យស្របតាមតម្រូវការទីផ្សារការងានៅពេលបច្ចុប្បន្ន និងថ្ងៃអនាគត ឱ្យបានទូលំទូលាយ។ បន្ថែមពីនេះ លើកកម្ពស់ការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ព្រមទាំងជំរុញកិច្ចសហការជាមួយប្រទេសជាដៃគូ ក្នុងការប្រើប្រាស់កម្លាំងពលកម្ម។

កន្លងមក គេសង្កេតឃើញថា មានពលករមួយចំនួនត្រូវជួបបញ្ហាប្រឈមផ្សេងៗ ដូចជាមិនអាចទ្រាំទ្រនឹងការងារបាន ហើយមានពលករខ្លះទៀត ត្រូវជួបគ្រោះថ្នាក់ការងារបណ្តាលឱ្យបាត់បង់ជីវិតនៅស្រុកគេ។ ការធ្វើទារុណកម្ម ឬការរំលោភបំពានកម្លាំងពលកម្ម ពីសំណាក់ថៅកែ ឬម្ចាស់ផ្ទះដែលខ្លួនបម្រើ ពិសេសពលករដែលទៅធ្វើការងារនៅក្រៅប្រទេសដោយខុសច្បាប់។

សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសកម្ពុជា ដែលបានចេញផ្សាយជាបន្តបន្ទាប់ក្នុងរយៈពេលបីខែដើមឆ្នាំ២០១៨ ឱ្យដឹងថា មានពលករជិតមួយរយនាក់ហើយ ដែលបានជួយសង្គ្រោះពីក្រៅប្រទេស ដូចជាប្រទេសប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី សិង្ហបុរី ប្រទេសឡាវ ជាដើម និងបានបញ្ជូនពួកគេត្រឡប់ទៅស្រុកកំណើតវិញ។ ការជួយសង្គ្រោះពលករទាំងនោះ ដោយសារពួកគាត់ចាញ់បោកមេខ្យល់នាំទៅធ្វើការងារ និងឆ្លងដែនដោយខុសច្បាប់ ហើយខ្លះមិនអាចទ្រាំទ្រការងារលំបាកនៅក្រៅប្រទេសបានផងដែរ។

មន្ត្រីផ្នែកអង្កេតសមាគមការពារសិទ្ធិមនុស្ស អាដហុក (ADHOC) ខេត្តត្បូងឃ្មុំ លោក ឡេង សេងហាន មានប្រសាសន៍ថា ប្រទេសក្នុងតំបន់អាស៊ាន ដូចជាប្រទេសថៃជាដើមនោះ ការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ភាគច្រើនជាប្រភេទកម្មករជំនាញ មិនមែនភាគច្រើនជាប្រភេទកម្មករប្រើកម្លាំង ឬជាពលករបម្រើការងារតាមផ្ទះដូចកម្ពុជាទេ។ លោកថា ការចំណាកស្រុកទៅធ្វើការងារនៅក្រៅប្រទេស ក៏មានចំណុចវិជ្ជមានដែរ ដូចជាទទួលបានប្រាក់ខែខ្ពស់

និងមានប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ ប្រសិនបើការចំណាកស្រុកនោះធ្វើឡើងដោយស្របច្បាប់ និងមានការយកចិត្តទុកដាក់ខ្ពស់ពីក្រុមហ៊ុន ព្រមទាំងរាជរដ្ឋាភិបាល។

ប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា លោក ថេង សាវឿន មានប្រសាសន៍ថា នៅក្នុងសម័យសកលភាវូបនីយកម្ម និងស្ថិតនៅក្នុងបរិបទសេដ្ឋកិច្ចទីផ្សារសេរីផង ប្រសិនបើប្រទេសមួយមិនមានយន្តការគ្រប់គ្រងកម្លាំងពលកម្មច្បាស់លាស់ ប្រទេសដទៃនឹងស្រូបយកកម្លាំងពលកម្មពីប្រទេសនោះជាក់ជាមិនខាន។ លោកមើលឃើញថា ការវិនិយោគលើប្រព័ន្ធបច្ចេកវិទ្យា និងធនធានមនុស្ស នៅមិនទាន់ចំទិសដៅនៅឡើយ៖ «បញ្ហាចំបង គឺវិស័យកសិកម្ម និងវិស័យផលិតផល ពីប្រទេសកម្ពុជា ពិសេសកម្លាំងពលកម្មពីប្រទេសកម្ពុជា គឺកាន់តែថយចុះទៅៗ នៅក្នុងស្រុក ហើយវាកាន់តែកើនឡើងនៃលំហូរចំណាកស្រុក»។ លោក ថេង សាវឿន យល់ថា រដ្ឋគប្បីរៀបចំប្រព័ន្ធអប់រំមួយ ដោយផ្ដោតទៅលើការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដើម្បីឆ្លើយតបបញ្ហាប្រឈម ដែលកំពុងកើតមានឡើង។ លើសពីនេះ រដ្ឋគប្បីលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងវិស័យអភិវឌ្ឍន៍សហគមន៍ឱ្យបានច្រើន ទាំងវិស័យកសិកម្ម កសិ-ឧស្សាហកម្ម។ ជាងនេះទៀត ត្រូវពង្រីកអ្នកមានចំណេះជំនាញទៅតាមទីជនបទឱ្យបានច្រើន តាមរយៈផ្ដល់កញ្ចប់ថវិកាលើកទឹកចិត្ត និងការអភិវឌ្ឍន៍ដល់ពួកគាត់។ រដ្ឋត្រូវរៀបចំ និងស្ដាឡើងវិញ នូវប្រព័ន្ធធារាសាស្ត្រជូនកសិករឱ្យបានត្រឹមត្រូវ៕

## ពលករខ្មែរធ្វើការនៅកោះមួយនៅថៃខកចិត្តដែលមិនបាននៅលេងបុណ្យចូលឆ្នាំនៅខ្មែរ

https://www.rfa.org/ ដោយ តាំង សារ៉ាដា 2018-04-08

ពលករខ្មែរជាច្រើននាក់ ដែលធ្វើការងារនៅលើកោះមួយក្នុងប្រទេសថៃ សម្ដែងការសោកស្ដាយយ៉ាងខ្លាំង ព្រោះមិនបានត្រឡប់ទៅលេងស្រុកកំណើតដូចពលរដ្ឋដទៃ ដោយសារពួកគេរវល់បំពេញការងារ ដែលធ្វើឲ្យពុំមានឱកាសបានទៅលេងស្រុកកំណើតក្នុងរដូវបុណ្យប្រពៃណីរបស់ជាតិ។ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំ២០១៨នេះ មានរយៈពេល៣ថ្ងៃ គឺចាប់ពីថ្ងៃសៅរ៍ ទី១៤ ដល់ថ្ងៃចន្ទទី១៦ ខែមេសា។ តើមូលហេតុអ្វីបានជាពលករទាំងនោះនៅតែបំពេញការងារដោយមិនព្រមត្រឡប់លេងបុណ្យចូលឆ្នាំនៅស្រុកកំណើត? ក្រុមពលករខ្មែរដែលមិនបានទៅលេងបុណ្យចូលឆ្នាំខ្មែរនៅស្រុកកំណើតនោះ ធ្វើការនៅលើតូចកោះមួយក្នុងខេត្តឈុនបូរី (Chunbori)របស់ថៃ។ ពលករប្រុសស្រីទាំងអស់នោះភាគច្រើនរស់នៅធ្វើការដូចលលកញីឈ្មោល ដែលជាប្ដីប្រពន្ធមកពីស្រុកខ្មែរ ហើយមានវ័យប្រមាណ៣០ប្លាយដូចគ្នា។ ក្នុងនោះអ្នកខ្លះមានកូនមួយនិងខ្លះមានកូនហើយ តែពួកគាត់មិនបានយកកូនទៅនៅជាមួយទេ ដោយទុកកូនឲ្យម្ដាយជួយមើលនៅឯស្រុកកំណើត។

អង្គុយក្រោមដើមឈើខាងមុខបន្ទប់ស្នាក់នៅរបស់អ្នកទេសចរណ៍ សម្បុរស្រអែម លោក នី ភិរម្យ រៀបរាប់ថា លោកមានស្រុកកំណើតនៅខេត្តកំពង់ចាម គឺបានទៅធ្វើការនៅប្រទេសថៃជិត ១០ឆ្នាំ ក្នុងនោះលោកឆ្លក់រសជាតិការគ្រប់បែបយ៉ាង មានទាំងការងារសំណង់ និងការងាររត់តុជាដើម។ បុរសវ័យ ៣២ឆ្នាំរូបនេះ ថ្លែងក្នុងទឹកមុខញញឹមញញែមថា លោកមានកូន២ តែទុកឲ្យម្ដាយមើលថែនៅឯខេត្តកំពង់ចាម ដោយមិនបានយកទៅតាមជាមួយទេ ហើយសព្វថ្ងៃលោកធ្វើការជាអ្នករត់តុបម្រើភ្ញៀវនៅលើកោះជាមួយប្រពន្ធ តែប្រពន្ធមានភារកិច្ចអង្គុយចាំយកប្រាក់ពីភ្ញៀវចូលបន្ទប់ទឹក។ ពលករ នី ភិរម្យ បន្ថែមថា លោកធ្វើការនៅលើកោះនេះជាង២ឆ្នាំហើយ ដោយបានប្រាក់ឈ្នួលមួយថ្ងៃ ៣៥០បាត ស្មើនឹងប្រមាណ ៤ម៉ឺន ៥ពាន់(៤៥,០០០)រៀល។ លោកថា ការងារនៅលើកោះនេះកាក់កបជាងការងារកន្លងមក ប៉ុន្តែក៏ជួបការលំបាកមួយចំនួនដែរ ព្រោះថ្ងៃខ្លះមានមនុស្សមកលេងលើកោះច្រើន ហើយលោកនិងប្រពន្ធស្ទើរតែមិនបានសម្រាកនោះទេ៖ «ខ្ញុំធ្វើការច្រើនមុខធ្វើម្ហូបផង រត់តុផង បើថាចូលម៉ោង៧ព្រឹក បើមានភ្ញៀវច្រើនខ្ញុំសម្រាកម៉ោង៧ទៅម៉ោង៨យប់ ប៉ុន្តែការងារនឹងខ្ញុំជួយគេ បើតាមធម្មតាគេឲ្យសម្រាកម៉ោង៥ល្ងាច តែពេលយើងជួយគេទៅជួលកាលគេឲ្យប្រាក់បន្ថែមខ្លះដែរ។ យើងនៅនេះធ្វើការរហូតមែនប៉ុន្តែនៅនេះសល់លុយច្រើនជាងនៅស្រុកខ្មែរ»។ ពលកររូបនេះបន្ថែមទៀតថា បើទោះបីជាការងារនេះមមាញឹកយ៉ាងណាក៏ដោយ ក៏ប៉ុន្តែ លោកសប្បាយចិត្តព្រោះធ្វើការ

បានប្រាក់ផ្ញើទៅឲ្យម្ដាយរាល់ខែ ហើយប្រសើរជាងធ្វើការនៅក្នុងស្រុកដែលធ្វើការមិនសល់ប្រាក់ ហើយថែមទាំងជំពាក់គេវាន់ករទៀតផង។

យ៉ាងណាក៏ដោយចុះ លោក នី ភិរម្យ អះអាងថា លោកនឹកស្រុកកំណើតណាស់ហើយលោកចង់ទៅលែងបុណ្យចូលឆ្នាំប្រពៃណីខ្មែរដែរ ប៉ុន្តែឆ្នាំនេះ ថៅកែមិនអនុញ្ញាតឲ្យលោក និងប្រពន្ធបានទៅលេងស្រុកកំណើតទេ ព្រោះនៅកន្លែងធ្វើការមានភ្ញៀវទេសចរណ៍មកលេងនៅលើកោះច្រើន ដែលត្រូវការពលករជាច្រើននាក់ដើម្បីជួយបម្រើភ្ញៀវ៖ «ខ្ញុំនឹកផ្ទះថ្ងៃខ្លះដេកយំក៏មានដែរ ហើយនឹកមិនដឹងធ្វើយ៉ាងមិចបើយើងគ្មានជម្រើស ព្រោះចូលឆ្នាំលក់ដាច់ខ្លាំង បើចិត្តខ្ញុំចង់ទៅលែងចូលឆ្នាំណាស់ទៅហើយ ប៉ុន្តែយើងក៏ត្រូវគិតម្យ៉ាងថា គេក៏លក់ដាច់នៅពេលនឹងដែរ ហើយខ្ញុំក៏លំបាកចិត្តរឿងនឹងមិនគិតទៅខាងណាខាងណីទេ ហើយម្យ៉ាងធ្វើការវាសំខាន់ជាងបានប្រាក់បន្ថែមផង»។ នៅលើកោះដែលពលករខ្មែរធ្វើការនេះ គឺមានចម្ងាយប្រមាណ១២គីឡូម៉ែត្រពីដីគោក និងចម្ងាយប្រមាណ១០០គីឡូម៉ែត្រ ពីទីក្រុងបាងកក ហើយមានពលករខ្មែរធ្វើការប្រមាណ២០០នាក់ ក្នុងនោះភាគច្រើនធ្វើការសំណង់។

ចំណែកឯពលករខ្មែរដែលធ្វើការផ្ទះសំណាក់នៅជាប់ឆ្នេរនៅលើកោះមួយនេះ មានទាំងអស់៧នាក់ ដោយអ្នកខ្លះធ្វើការផ្នែករៀបចំបន្ទប់ផ្ទះសំណាក់ ខ្លះបម្រើភ្ញៀវផ្នែកខាងរត់តុ និងខ្លះទៀតចាំយកប្រាក់ពីភ្ញៀវចូលបន្ទប់ទឹក។ ទន្ទឹមគ្នានេះ នៅរដូវបុណ្យចូលឆ្នាំប្រពៃណីខ្មែរឆ្នាំនេះ ពួកគាត់មិនបានទៅលេងស្រុកកំណើតដូចពលករធ្វើការនៅកន្លែងផ្សេងនោះទេ។

ពលការិនីម្នាក់ជាភរិយារបស់លោក នី ភិរម្យ មានប្រសាសន៍ថា អ្នកស្រីនិងស្វាមីមិនបានទៅលេងបុណ្យចូលឆ្នាំខ្មែរ ជួបជុំបងប្អូននៅស្រុកកំណើតទេ ព្រោះជាប់រវល់ធ្វើការឲ្យឲ្យថៅកែជនជាតិថៃ ដើម្បីបានប្រាក់យកទៅចិញ្ចឹមកូននិងម្ដាយនៅខេត្តកំពង់ចាម។ ស្ត្រីវ័យ៣០ឆ្នាំប្លាយរូបនេះ រៀបរាប់ទៀតថា ប្រសិនបើអ្នកស្រីទៅលេងស្រុកនៅថ្ងៃបុណ្យសំខាន់នោះ គឺអ្នកស្រីអាចប្រឈមនឹងថៅកែបញ្ឈប់ពីការងារ ហើយម្យ៉ាងធ្វើការនៅអំឡុងពេលនេះ ក៏ធ្វើឲ្យអ្នកស្រីអាចរកបានប្រាក់បន្ថែមបានច្រើនជាងប្រាក់ឈ្នួលសព្វមួយដងដែរ ដូច្នេះទើបអ្នកស្រីសម្រេចចិត្តមិនបានទៅជួបជុំសាច់ញាតិក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ៖ «ព្រោះអីថៅកែគាត់អត់មានអ្នកជួយធ្វើការងារគាត់អ៊ីចឹង ហើយយើងមកជួយគាត់ព្រោះខ្ញុំធ្លាប់នៅជាមួយគាត់ ហើយគាត់ក៏ចិត្តល្អដែរ។ ខ្ញុំនឹកឃើញពេលបុណ្យទានគេទៅជួបប្អូនគេសប្បាយ តែខ្ញុំមិនដឹងធ្វើមិច បើយើងក្រហើយគ្មានជម្រើសក្រៅពីការងារនៅស្រុកថៃ»។

រីឯពលករម្នាក់ទៀត ដែលមានស្រុកកំណើតមកពីខេត្តបន្ទាយមានជ័យ ឯណោះវិញ លោក ស្តើង វ៉ាណ ឈរនៅមាត់សមុទ្រយកជើងឆ្កើះខ្សាច់បណ្ដើររៀបរាប់បណ្ដើរថា លោកធ្វើការងារផ្នែកខាងរត់តុនៅលើកោះមួយនេះជាមួយប្រពន្ធជាង ៤ឆ្នាំហើយ ប៉ុន្តែពុំដែលបានទៅលេងបុណ្យចូលឆ្នាំខ្មែរនៅស្រុកកំណើតម្ដងណានោះទេ។ បុរសវ័យ ៣០ឆ្នាំប្លាយរូបនេះបន្ថែមទៀតថា អំឡុងពេលបុណ្យឆ្នាំនេះ នៅពេលឃើញភ្ញៀវមកលេងនៅលើកោះ ហើយមុជទឹកលែងជាមួយសាច់ញាតិរបស់គេម្ដងៗ ធ្វើឲ្យលោកនឹកស្រមៃដល់ប្រពន្ធនិងកូន ថាប្រសិនបើបាននៅជួបជុំគ្នាមិនដឹងសប្បាយយ៉ាងណាទេ ប៉ុន្តែលោកថាបានត្រឹមតែក្ដីស្រមៃប៉ុណ្ណោះ ចំណែកឯការពិត គឺទាំងលោកនិងប្រពន្ធបានត្រឹមតែអោបសម្រក់ទឹកភ្នែក ដោយមិនបានទៅចូលរួមលេងសប្បាយជាមួយសាច់ញាតិនៅស្រុកកំណើតឡើយ៖ «ព្រោះថាវាស្រួលលុយកាក់ក្នុងមួយអាទិត្យដឹងតែគេបើកលុយ ហើយបើយើងចេញពីកន្លែងនេះទៅក៏ធ្វើការដូចតែគ្នា ដូច្នេះខ្ញុំសម្រេចចិត្តថា ស៊ូទ្រាំអត់ ទោះបើគេជេរស្ដីតិចតួចក៏ចេះតែទ្រាំទៅ ព្រោះគេបើកលុយវាស្រួលដែរ ព្រោះខ្ញុំធ្លាប់ដើរមកច្រើនហើយកន្លែងខ្លះគេបោកខ្ញុំហើយកន្លែងនេះស្រួលក៏ចេះតែទ្រាំទៅ។ ប៉ុន្តែឆ្នាំក្រោយនេះខ្ញុំអត់ធ្វើការទេ គឺខ្ញុំសុំគាត់ទៅលេងចូលឆ្នាំម្ដងហើយ ដើម្បីជួបជុំឪពុកម្ដាយនិងជួបកូន ឲ្យបានជួបជុំគ្នាលេងពេលចូលឆ្នាំ ព្រោះខ្ញុំខានបានចូលឆ្នាំច្រើនដងហើយ»។ សព្វថ្ងៃពលករខ្មែរដែលធ្វើការងារនៅប្រទេសថៃ មានប្រហែលជា ១លាននាក់ ហើយក្នុងចំណោមនោះអាចមានពលកររាប់ម៉ឺននាក់ ដែលមិនបានទៅលេងបុណ្យចូលឆ្នាំប្រពៃណីខ្មែរនៅឯស្រុកកំណើត។

ទោះជាយ៉ាងនេះក្តី ក្រុមពលករដែលធ្វើការនៅលើកោះមួយក្នុងខេត្តឈុនបុរី ឲ្យដឹងថា ក្រោយបុណ្យចូលឆ្នាំរួចហើយ គឺចាប់ពីថ្ងៃទី១៨ មេសាទៅ ថៅកែបានអនុញ្ញាតឲ្យពួកគាត់ទៅស្រុកខ្មែររយៈពេល១០ថ្ងៃ ហើយពួកគាត់ថានឹងត្រឡប់ទៅធ្វើការនៅលើកោះដូចដើមវិញ ដើម្បីសន្សំប្រាក់សម្រាប់ដោះស្រាយជីវភាពគ្រួសារនៅថ្ងៃអនាគតបន្តទៀត៕

## របាយការណ៍ផ្តល់សំឡេងឲ្យម្តាយដែលបាត់បង់កូន ដោយសារគេយកទៅចិញ្ចឹមនៅបរទេស

https://www.postkhmer.com/ Erin Handley and គង់ មេត្តា | Publication date 09 April 2018 | 12:13 ICT

**កំពត:** អ្នកស្រី គីម ប៊ុនណាត បានវិលត្រឡប់មកផ្ទះវិញ បន្ទាប់ពីអ្នកស្រីបានទៅមើលម្តាយរបស់អ្នកស្រីឈឺនៅខេត្តកំពត ដែលពេលនោះអ្នកស្រីមិនឃើញកូនប្រុសរបស់អ្នកស្រីទេ។ អ្នកស្រី ប៊ុនណាត ផ្តល់កំណើតកូនដំបូងរបស់អ្នកស្រីនៅក្នុងឆ្នាំ ២០០១។ អ្នកស្រីរៀបរាប់ថាអ្នកស្រីមិនដឹងថា កាលនោះហេតុអ្វីបានជាស្វាមីរបស់អ្នកស្រីយកកូនប្រុសអាយុទើបបាន ៩ ខែដែលកំពុងមានជំងឺធ្ងន់ធ្ងរទៅដាក់នៅមណ្ឌលកុមារកំព្រាទេ។ នៅទីនោះគេបានប្រាប់អ្នកស្រី ប៊ុនណាត ថាគេនឹងជួយសម្រួលឲ្យកូនប្រុសរបស់អ្នកស្រីបានទៅព្យាបាលនៅក្រៅប្រទេស។ ក្រោយមកអ្នកស្រីបានលែងលះស្វាមី។ អ្នកស្រីបានទៅសួរសុខទុក្ខកូនប្រុសរបស់អ្នកស្រីរៀងរាល់ថ្ងៃអាទិត្យ ជាថ្ងៃដែលអ្នកស្រីឈប់សម្រាកពីការងាររោងចក្រ។ មិនយូរប៉ុន្មានកូនប្រុសរបស់អ្នកស្រីត្រូវបានគ្រួសារមួយសុំយកទៅចិញ្ចឹមនៅឯ សហរដ្ឋអាមេរិកហើយចាប់តាំងពីពេលនោះមក អ្នកស្រីមិនដែលបានជួបមុខកូនប្រុសរបស់អ្នកស្រីទៀតទេ។ អ្នកស្រីនិយាយបណ្តើរយកដៃជូតទឹកភ្នែកបណ្តើរថា៖ «ខ្ញុំព្រួយបារម្ភថា កូនប្រុសខ្ញុំ គិតថាខ្ញុំបោះបង់គាត់ចោល»។ ខណៈដែលថ្ងៃប្រារព្ធខួបកំណើតអាយុ ១៨ ឆ្នាំរបស់កូនប្រុសអ្នកស្រីខិតជិតចូលមកដល់អ្នកស្រី ប៊ុនណាត បានបង្ហាញរូបថតរបស់កូនប្រុសអ្នកស្រីដែលមើលទៅមានលក្ខណៈជាកុមារជនជាតិអាមេរិក កំពុងផ្លុំទៀននំខួបកំណើត និងញញឹមពព្រាយអមដោយសម្លៀកបំពាក់កីឡាយ៉ាងស្អាត។ ករណីរបស់អ្នកស្រី ប៊ុនណាត គឺជាករណីមួយក្នុងចំណោមករណីរបស់ស្ត្រី ៣ នាក់ដែលត្រូវបានគូសបញ្ជាក់នៅក្នុងរបាយការណ៍ថ្មីមួយរបស់អង្គការសិទ្ធិមនុស្សលីកាដូដែលស៊ើបអង្កេតលើករណី «កុមារដែលត្រូវបានគេលួច» នៅក្នុងប្រទេសកម្ពុជា។ ស្ត្រីទាំងនោះគឺជាជនរងគ្រោះនៃការបោកបញ្ឆោតពីមណ្ឌលកុមារកំព្រាមួយចំនួនដែលធ្វើអាជីវកម្មលើភាពក្រីក្ររបស់ពួកគេ ហើយនៅក្នុងករណីជាច្រើនទៀតគេបានប្រឌិតឯកសារក្លែងក្លាយឡើង ដើម្បីទទួលយកកុមារនោះទៅចិញ្ចឹមដោយគ្មានការយល់ព្រមពីឪពុកម្តាយ។

កាលៈទេសៈដ៏គួរឱ្យរន្ធត់បែបនេះត្រូវបានគេមើលឃើញថា កុមារត្រូវបានគេបញ្ជូនចេញពីម្តាយរបស់ពួកគេហើយរបាយការណ៍ក៏បានជំរុញឲ្យរដ្ឋាភិបាល និងអ្នកដែលពាក់ព័ន្ធធ្វើការសុំទោសដល់គ្រប់គ្នាដែលរងគ្រោះពីដំណើរការសុំកូនបែបក្លែងបន្លំនេះកាលពីអតីតកាល ដើម្បីជានាកុំឱ្យមានការសុំកូនអន្តរប្រទេសជាថ្មីម្តងទៀតនៅថ្ងៃអនាគត។

តាមការប៉ាន់ស្មានរបស់រដ្ឋាភិបាលបានឲ្យដឹងថាចន្លោះពីឆ្នាំ ១៩៨៧ ដល់ ២០០៩ មានកុមារចំនួន ៣៦៩៦ នាក់ត្រូវបានគេនាំយកចេញពីប្រទេសកម្ពុជា ដើម្បីយកទៅចិញ្ចឹម នៅពេលដែលប្រទេសកម្ពុជាបានហាមឃាត់ការសុំកូនក្លែងបន្លំបែបនេះក្រោយពីមានការចោទប្រកាន់ថា មានករណីជួញដូរមនុស្សនិងករណីលក់កុមារកើតឡើង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ របាយការណ៍នោះបានគូសបញ្ជាក់ថា តួលេខនេះអាចមានច្រើនជាងនេះដោយសារតែការកត់ត្រាទិន្នន័យមិនទាន់មានប្រព័ន្ធច្បាស់លាស់ ហើយការសុំកូនមួយចំនួនមិនត្រូវបានធ្វើឡើងតាមរយៈក្រសួងសង្គមកិច្ចនោះទេ។ ករណីទាំង ៣ នេះអាចជានិមិត្តរូបនៃរឿងរ៉ាវរបស់មនុស្សរាប់រយរាប់ពាន់នាក់ផ្សេងទៀត។

នៅក្នុងករណីរបស់អ្នកស្រី ប៊ុនណាត ពីដំបូងកូនប្រុសរបស់អ្នកស្រីត្រូវបានគេបញ្ជូនទៅព្យាបាលនៅប្រទេសថៃហើយទារកនោះបានទទួលការព្យាបាលនៅទីនោះប្រហែលមួយសប្តាហ៍ ក៏ត្រឡប់មកវិញហើយក្រោយមកមណ្ឌលកុមារកំព្រានិយាយថា ពួកគេនឹងបញ្ជូនកូនប្រុសរបស់អ្នកស្រីទៅសហរដ្ឋអាមេរិកដើម្បីទទួលការព្យាបាលបន្ត ហើយស្ត្រីជាម្តាយតែងតែរំពឹងថាកូនប្រុសរបស់ខ្លួននឹងវិលត្រលប់មកវិញ។

តាមការឃ្លាំមើលរបស់អង្គការលីកាដូ បង្ហាញថាពេលទារកនោះទៅដល់សហរដ្ឋអាមេរិក វាត្រូវបានគេដាក់ក្រោមការមើលថែរក្សាជាបណ្ដោះអាសន្នជាមួយគ្រួសារមួយ ក៏ប៉ុន្តែទំនងជាគ្រួសារនោះក្រោយមកបានទទួលយកទារកនោះទៅចិញ្ចឹម ហើយសកម្មភាពសុំកូននេះល្មើសនឹងបម្រាមរបស់សហរដ្ឋអាមេរិកនៅឆ្នាំ ២០០១។ របាយការណ៍របស់អង្គការលីកាដូបានបញ្ជាក់ថា ប៉ុន្មានឆ្នាំក្រោយមកបុគ្គលិកមណ្ឌលកុមារកំព្រាម្នាក់បានទៅផ្ទះរបស់អ្នកស្រី ប៊ុនណាត ហើយស្នើអ្នកស្រីឱ្យចុះហត្ថលេខាលើឯកសារចំនួន ២ ច្បាប់។ បុគ្គលិករូបនោះក៏បានប្រគល់ឲ្យអ្នកស្រីនូវសំបុត្រកំណើតរបស់កូនដែលមើលទៅហាក់ដូចជាផ្នែកមួយនៃការប៉ុនប៉ងបង្កើតឯកសារដើម្បីឲ្យការធ្វើដំណើរទៅសហរដ្ឋអាមេរិកមានភាពស្របច្បាប់ និងដើម្បីបញ្ជាក់ថាទារកនោះត្រូវបានឪពុកម្ដាយបោះបង់ចោល ដូច្នេះហើយបានជាកុមារនោះអាចត្រូវបានគេប្រគល់ឲ្យអ្នកដទៃយកទៅចិញ្ចឹមបាន។

សំឡេងរបស់អ្នកស្រី ប៊ុនណាត ហាក់បង្ហាញអំពីអារម្មណ៍រំជួលចិត្ត នៅពេលដែលអ្នកស្រីរៀបរាប់ពីការមើលថែទាំកូនប្រុសដ៏តូចរបស់អ្នកស្រីដែលមានជំងឺកាលជិត ២ ទសវត្សរ៍មុន។ អ្នកស្រីរៀបរាប់ថា៖ «ខ្ញុំមិនចង់បានអ្វីពីកូនប្រុសរបស់ខ្ញុំទេ។ ខ្ញុំគ្រាន់តែចង់ឃើញកូនរបស់ខ្ញុំ។ យ៉ាងហោចណាស់ឱ្យគាត់ដឹងថាខ្ញុំគឺជាម្ដាយរបស់គាត់»។

បងប្អូនស្រី ២ នាក់ម្នាក់ឈ្មោះ នាង ផល អាយុ ៣១ ឆ្នាំ និងម្នាក់ទៀតឈ្មោះ នាង យ៉ន អាយុ ៣៧ ឆ្នាំយល់អំពីអារម្មណ៍របស់អ្នកស្រី ប៊ុនណាត។ ក្នុងចំណោមពួកគេ កូនរបស់ពួកគេចំនួន ៧ នាក់ត្រូវបានបញ្ជូនទៅកាន់ប្រទេសអ៊ីតាលីដោយគ្មានការយល់ព្រមពីពួកគាត់ទេ។ ដោយសារតែការប្រកបរបរចិញ្ចឹមជីវិតជាកម្មករចម្ការកៅស៊ូ អ្នកស្រី យ៉ន បានយកកូនរបស់អ្នកស្រី ៤ នាក់ដែលកូនពៅទើបតែមានអាយុ ៧ ខែទៅដាក់ក្នុងមជ្ឈមណ្ឌលកុមារកំព្រាក្នុងឆ្នាំ ២០០៧ តាមការណែនាំរបស់អ្នកជិតខាងដែលបានក្លាយទៅជាឈ្មួញកណ្ដាលម្នាក់។ អ្នកស្រីថ្លែងថា៖ «ពួកយើងក្រីក្រខ្លាំងណាស់ហើយខ្ញុំសង្ឃឹមថាកូនៗរបស់ខ្ញុំនឹងអាចទទួលបានការអប់រំល្អ ប្រសិនបើពួកគេទៅរស់នៅទីនោះ»។ អ្នកស្រី ផល ដែលកូន ៣ នាក់របស់អ្នកស្រីត្រូវបានគេសុំយកទៅចិញ្ចឹមនៅប្រទេសអ៊ីតាលីនោះបានថ្លែងថាអ្នកស្រីដឹងថាកូនៗរបស់អ្នកស្រីនឹងត្រូវបានគេបញ្ជូនទៅក្រៅប្រទេស ប៉ុន្តែមិនត្រូវបានគេប្រាប់លម្អិតទេ។ គេបានប្រាប់បងប្អូនស្រីទាំង ២ ថាពួកគេនឹងផ្ញើរូបថតរបស់កូនគាត់មកឲ្យ និងប្រាប់អំពីស្ថានភាពរបស់កូនពួកគេរៀងរាល់ប្រាំមួយខែម្ដង ហើយកូនៗរបស់ពួកគេ អាចវិលត្រលប់មកលេងផ្ទះវិញបាន។ ប៉ុន្តែអ្វីដែលគេប្រាប់នោះមិនមែនជាការពិតទេ។ អ្នកស្រីថ្លែងថា៖ «ខ្ញុំមានអារម្មណ៍សោកស្ដាយខ្លាំងណាស់។ ខ្ញុំនៅតែនឹកពួកគេគ្រប់ពេលវេលាហើយខ្ញុំមិនដឹងទេថា តើខ្ញុំអាចជួបពួកគេម្ដងទៀតបានឬយ៉ាងណាទេ ប៉ុន្តែខ្ញុំសង្ឃឹមតិចតួចណាស់»។ «ខ្ញុំគិតអំពីកូនៗរបស់ខ្ញុំស្ទើរតែគ្រប់ពេលវេលា ហើយជួនកាលខ្ញុំសន្លប់»។

កំពុងមើលថែកូនពៅរបស់ខ្លួនដែលទើបតែមានអាយុ ៨ ខែជាកូនដែលកើតក្រោយពេលដែលកូន ៤ នាក់ត្រូវបានគេនាំទៅកាន់ប្រទេសអ៊ីតាលី អ្នកស្រី យ៉ន ថ្លែងថាអ្នកស្រីនឹកកូនរបស់អ្នកស្រីខ្លាំងណាស់ ពេលខ្លះអ្នកស្រីគិតចង់សម្លាប់ខ្លួន។ ប៉ុន្តែអ្នកស្រីគិតថា អ្នកស្រីត្រូវតែរស់ដើម្បីមើលថែកូនពៅរបស់អ្នកស្រី។ អ្នកស្រីបន្តថា៖ «ប្រសិនបើខ្ញុំចិញ្ចឹមពួកគេនៅក្នុងប្រទេសកម្ពុជា នោះខ្ញុំមិនចាំបាច់ព្រួយបារម្ភថា ខ្ញុំនឹងបាត់បង់ពួកគេទេ។ ទោះបីជាយើងមិនមានអាហារហូបគ្រប់គ្រាន់ក៏ដោយ ប៉ុន្តែយើងក៏អាចចែករំលែកគ្នាបានដែរ។ យើងនឹងរស់នៅកៃកាយជាមួយគ្នា ប៉ុន្តែពេលនេះខ្ញុំមិនប្រាកដទេថា តើខ្ញុំអាចឃើញមុខពួកគេបានទៀតឬអត់នោះ»។

របាយការណ៍របស់អង្គការលីកាដូបានគូសបញ្ជាក់អំពីករណីផ្សេងមួយទៀត ដែលស្ត្រីជាម្ដាយមានកូន ៤ នាក់ក៏ត្រូវបានគេបញ្ជូនទៅប្រទេសអ៊ីតាលីដែរ។ ឪពុកម្ដាយត្រូវបានបញ្ចុះបញ្ចូលដោយប្រធានមណ្ឌលកុមារកំព្រាថាវានឹងផ្ដល់ផលប្រយោជន៍ដល់កូនៗរបស់ពួកគេ បើទោះបីជាពួកគេមិនយល់អំពីវិសាលភាពនៃការសុំកូនពីបរទេសក្ដី។ ថ្វីបើពួកគេយល់ស្របពីដំបូង ប៉ុន្តែក្រោយមកពួកគេបានប្ដូរចិត្តទុកកូនៗ ឲ្យរស់នៅជាមួយពួកគេវិញ បន្ទាប់ពីពួកគេមកលេងក្នុងពិធីបុណ្យភ្ជុំបិណ្ឌ។ ប៉ុន្តែប្រធានមណ្ឌលកុមារកំព្រាបានមកយកកូនរបស់ពួកគេត្រឡប់ទៅវិញហើយពួកគេក៏បាន

យកកូនពៅទៅលាក់នៅក្នុងចម្ការកៅស៊ូ។ ប៉ុន្តែអ្នកជិតខាងបានប្រាប់ប្រធានមណ្ឌលកុមារពីកន្លែងដែលកូនគាត់លាក់ខ្លួន។ កូនរបស់គាត់កំពុងរត់លេងនៅមិនឆ្ងាយប៉ុន្មានពីគាត់ហើយពេលប្រធានមណ្ឌលបានមកដល់ គាត់បានចាប់លើកយកកូននោះហើយប្រធានមណ្ឌលបានប្រាប់ឲ្យប្រមូលកូនផ្សេងៗមក ពីព្រោះលិខិតស្នាមបានរៀបចំរួចរាល់អស់ហើយ។ ខណៈពេលដែលប្រទេសជាច្រើនបានផ្អាកសុំកូនពីប្រទេសកម្ពុជានៅដើមទសវត្សរ៍ឆ្នាំ ២០០០ ដោយសារតែការរកឃើញការក្លែងបន្លំអំពើពុករលួយក្នុងដំណើរការសុំកូននេះ ក៏ប៉ុន្តែនៅមានប្រទេសជាច្រើនទៀតនៅបន្តសកម្មភាពសុំកូនហើយអំឡុងពេលនោះកុមារច្រើនបំផុតគឺត្រូវបានគេសុំយកទៅចិញ្ចឹមនៅប្រទេសអ៊ីតាលី។ ក្រសួងការបរទេសអ៊ីតាលី និងស្ថានទូតអ៊ីតាលីនៅទីក្រុងបាងកក មិនបានឆ្លើយតបទៅនឹងសំណើសុំការបំភ្លឺទេ។

លោកស្រី Naly Pilorge នាយិកាអង្គការលីកាដូបានពណ៌នាករណីទាំងនេះថា ជារឿងដែល «គួរឱ្យខ្លាចផ្សា»។ លោកស្រីថ្លែងថា៖ «គ្រួសារដែលផ្តល់កំណើតដល់កុមារទាំងនោះត្រូវបានគេបោកបញ្ឆោតហើយឪពុកម្តាយដែលសុំកូននោះយកទៅចិញ្ចឹម ចាញ់ល្បិចកលគេ ចំណែកឯកុមារទាំងនោះត្រូវបានគេលួចអត្តសញ្ញាណពិតប្រាកដរបស់ពួកគេ។ ពួកគេទាំងអស់នោះគួរតែដឹងការពិតថា អ្វីដែលបានកើតឡើង និងគួរចាត់វិធានការលើអ្នកដែលពាក់ព័ន្ធឲ្យទទួលខុសត្រូវ»។ មិនមានករណីសុំកូនយកទៅចិញ្ចឹមនៅបរទេសទៀតទេ ចាប់តាំងពីប្រទេសកម្ពុជាបានសម្រេចដាក់បម្រាមរាល់សកម្មភាពសុំកូនទាំងអស់ក្នុងឆ្នាំ ២០០៩ ទោះបីមានរបាយការណ៍ផ្ទុយគ្នាដែលបង្ហាញថាការដាក់បម្រាមនេះត្រូវបានដកចេញក៏ដោយ។

លោក សូ គី ប្រធានគ្រប់គ្រងទិន្នន័យនៅរដ្ឋបាលសុំកូនអន្តរប្រទេសបានអះអាងថាការសុំកូនអន្តរប្រទេសបានដាក់ឲ្យស្របច្បាប់ឡើងវិញក្នុងឆ្នាំ ២០១៤ ប៉ុន្តែឯកសារឆ្នាំ ២០១៥ បង្ហាញថាក្រសួងសង្គមកិច្ចគ្រោងបើកការអនុវត្តឡើងវិញយឺតជាងនឹងបន្តិច។ លោកបញ្ជាក់ថា ការសុំកូនអន្តរប្រទេសឥឡូវនេះមានសុវត្ថិភាព ហើយគ្មានករណីសុំកូនណាមួយកើតឡើងទេ ពីព្រោះដំណើរការថ្មីមានលក្ខណៈតឹងរ៉ឹង។ លោកបន្តថា៖ «ជាមួយនឹងនីតិវិធីថ្មី គឺវាត្រូវចំណាយពេលច្រើនជាង ២០០ ថ្ងៃ ហើយការដាក់ពាក្យសុំកូនម្នាក់ត្រូវចំណាយ ៥ ពាន់ដុល្លារ ហើយប្រាក់ ៧០ ភាគរយបានទៅលើសុខុមាលភាពកុមារ»។ ក៏ប៉ុន្តែអនុសាសន៍របស់អង្គការលីកាដូបានលើកឡើងថា គ្មានសកម្មភាពសុំកូនអន្តរប្រទេសណាមួយកើតឡើងទៀតឡើយ លុះត្រាណាប្រព័ន្ធដោះស្រាយ និងការស៊ើបអង្កេតមួយត្រូវបានអនុវត្ត ហើយវិធានការសុវត្ថិភាព ត្រូវបានយកមកអនុវត្តដើម្បីធានាថាកំហុសអតីតកាលនឹងមិនអាចកើតមានឡើងវិញឡើយ។ ក្រុមសាស្ត្រាចារ្យយល់ស្រប និងបានអំពាវនាវឱ្យមានការទទួលស្គាល់ជាសាធារណៈអំពើកំហុសឆ្គងកាលពីអតីតកាលទាក់ទងទៅនឹងការសុំកូនអន្តរប្រទេសហើយត្រូវសុំទោសអ្នកដែលរងគ្រោះទាំងអស់ និងត្រូវចុះទៅដល់គ្រួសារដែលរងគ្រោះទាំងនោះដើម្បីឱ្យពួកគេរៀបរាប់រឿងរ៉ាវរបស់ពួកគេ ដើម្បីស្វែងរកដំណោះស្រាយ»។

លោក David Smolin ប្រធានមជ្ឈមណ្ឌលសម្រាប់កុមារ ច្បាប់ និងសីលធម៌ នៅសាកលវិទ្យាល័យ Samford University ថ្លែងថាប្រទេសដែលទទួលកុមារ ត្រូវតែចែករំលែកបន្ទុកនៃការស៊ើបអង្កេត និងការដោះស្រាយ ដើម្បីធ្វើឱ្យកុមារដែលគេសុំយកទៅចិញ្ចឹម ឪពុកម្តាយពួកគេ និងគ្រួសារដែលទទួលយកទៅចិញ្ចឹមមានឱកាសដើម្បីស្វែងរកការពិត និងដើម្បីភ្ជាប់ទំនាក់ទំនងជាមួយគ្រួសារឡើងវិញ...»។ លោកបានឱ្យដឹងតាមអ៊ីមែលថា៖ «ការរំលោភបំពាននេះធ្វើឱ្យកុមារទាំងនោះនៅដាច់ឆ្ងាយពីឪពុកម្តាយ និងគ្រួសាររបស់ពួកគេ ហើយអាចបំផ្លាញដល់ទំនាក់ទំនងរបស់គ្រួសារដែលសុំកូននោះផងដែរ។ ការរំលោភបំពានទាំងនេះក៏បំផ្លាញដល់ប្រព័ន្ធសុំកូនអន្តរប្រទេសផងដែរ ដែលជាកត្តាចម្បងធ្វើឲ្យការសុំកូន អន្តរប្រទេសនៅទូទាំងពិភពលោកធ្លាក់ចុះ»។

លោកស្រី Patrcia Fronek នៅសាកលវិទ្យាល័យ Griffith ដែលឯកទេសខាងសេវាពពោះជំនួស និងសុំកូនបានថ្លែងថា៖ «ករណីនៃការសុំកូនឆ្លងប្រទេសក្លែងបន្លំ និងការជួញដូរដែលត្រូវបានគេដឹងគឺគ្រាន់តែជាផ្នែកតូចមួយដែលអ្នកអាចឃើញក្នុងចំណោមផ្នែកដទៃទៀតដែលត្រូវបានលាក់បាំង»។ លោកស្រីថ្លែងតាមអ៊ីមែលថា៖ «ការសុំកូនឆ្លង

ប្រទេសមានផលវិបាកមួយជីវិត។ ម្តាយ ឪពុក និងគ្រួសាររងការឈឺចាប់ក្រៀមក្រំ និងផលវិបាក សុខភាពផ្លូវចិត្តជទៃៗទៀតជាពិសេសនៅពេលពួកគេមិនដឹងថាអ្វីកើតឡើងចំពោះកូនរបស់ខ្លួន»។ លោកស្រីបានថ្លែងថាសេវាតាមដាន និងជួបជុំគ្នាវិញត្រូវការឲ្យមានហើយបុគ្គលិកផ្នែកសង្គម និងប្រឹក្សាយោបល់ក៏ត្រូវការឲ្យមានផងដែរ ដើម្បីជួយពួកគេ។ លោកស្រីបន្តថាសូម្បីតែនៅពេលកុមារត្រូវបានចិញ្ចឹមនៅក្នុងគ្រួសារល្អមួយរបស់ឪពុកម្តាយដែលសុំក៏ដោយ ក៏ពួកគេនៅតែ «ឈឺចាប់អំពីបញ្ហាអត្តសញ្ញាណ និងការបែកបាក់ពីគ្រួសារ សហគមន៍ និងវប្បធម៌របស់ខ្លួនដែរ»។

ពិតណាស់អ្នកនាំពាក្យអង្គការ UNICEF លោកស្រី Iman Morooka ថ្លែងថា ការគ្រប់គ្រងសមស្របមួយគឺ «មានសារៈសំខាន់ខ្លាំងណាស់» ប្រសិនបើការសុំកូនអន្តរជាតិនឹងនៅតែបន្ត ហើយវាគួរតែកើតឡើង បន្ទាប់ពីការប្រើប្រាស់ជម្រើសនានាក្នុងស្រុក។ លោកស្រីថា៖ «បច្ចុប្បន្ននេះមានការខ្វះខាតបុគ្គលិកសង្គមធ្ងន់ធ្ងរក្នុងប្រទេសកម្ពុជា ហើយនេះជាអ្វីមួយដែលតម្រូវឲ្យមានការវិនិយោគជាបន្ទាន់ដោយរដ្ឋាភិបាល»។ លោកស្រី Fronek បានបន្តព្រមានថាកម្ពុជាមិនឲ្យយល់ស្របតាមប្រទេសនានា ដែលមានឥទ្ធិពលដែលជំរុញឲ្យមានការសុំកូនដើម្បីបំពេញតាមតម្រូវការរបស់ប្រជាពលរដ្ឋខ្លួនទេ។ «មានទីផ្សារសុំកូន។ កម្ពុជាមិនបំពាក់ដោយកម្មវិធីសុំកូនឆ្លងប្រទេស»។ បើសូម្បីតែមិនមានទីផ្សារសុំកូនអន្តរជាតិ ការកេងប្រវ័ញ្ចទាំងទៅលើកុមារ និងឪពុកម្តាយនៅតែកើតឡើង។ ភាគច្រើនបំផុតប្រហែល ៨០ ភាគរយនៃកុមារដែលរស់នៅមណ្ឌលកុមារកំព្រាកម្ពុជាយ៉ាងហោចណាស់មានម្តាយ ឬឪពុកដែលនៅរស់។ ពេលខ្លះឪពុកម្តាយត្រូវបានគេសន្យាមិនពិតថា កូនរបស់ពួកគេនឹងទទួលបានការអប់រំប្រសើរជាងការរស់នៅជាមួយពួកគេនៅផ្ទះ ហើយក្នុងករណីខ្លះគឺនៅមណ្ឌលកុមារកំព្រាដែលទទួលបានប្រយោជន៍ពីចំណូល។ លោកស្រីបានថ្លែងបន្តថា៖ «មិនមែនផ្ទះទាំងអស់របស់កុមារក្នុងប្រទេសកម្ពុជាត្រូវបានចុះពិនិត្យ ឬដាក់បញ្ញត្តិដោយរដ្ឋាភិបាលនោះទេ»។ «ទេសចរណ៍មណ្ឌលកុមារកំព្រានៅតែកើតមានហើយមានកុមារ និងគ្រួសារដែលមានហានិភ័យ និងងាយរងគ្រោះដល់មនុស្សជាច្រើនដែលនឹងយកប្រយោជន៍ពីពួកគេ»។

នៅក្នុងសេចក្តីថ្លែងការណ៍មួយស្ថានទូតអាមេរិកបានថ្លែងថារដ្ឋាភិបាលរបស់ខ្លួន «បន្តគាំទ្រ កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ខណៈខ្លួនកំពុងធ្វើការដើម្បីលើកកម្ពស់សុខុមាលភាពកុមារក្នុងប្រទេសកម្ពុជា ហើយបង្កើតដំណើរការសុំកូនឆ្លងប្រទេស ក្រោមអនុសញ្ញាសុំកូនទីក្រុងឡាអេ»។ «វាសំខាន់ណាស់ដែលកម្ពុជាត្រូវកសាងការការពារទាំងនេះពីមុនពេលសហរដ្ឋអាមេរិកអាចបន្តការសុំកូនឆ្លងប្រទេសនៅទីនោះ»។

មនុស្ស ២ នាក់ដែលជាប់ពាក់ព័ន្ធនឹងមណ្ឌលកុមារកំព្រាដែលកំណត់អត្តសញ្ញាណដោយម្តាយដែលត្រូវបានសម្ភាស ខណៈបញ្ជូនកូនរបស់ខ្លួនទៅបរទេសប្រឆាំងនឹងឆន្ទៈរបស់ឪពុកម្តាយបង្កើតរបស់ពួកគេបានផ្តាច់ខ្លួនចេញឆ្ងាយពីករណីមុនៗ។

លោកស្រី អ៊ុក ណារុំ នាយកប្រតិបត្តិនៃសមាគមអភិវឌ្ឍន៍គ្រួសារពលី និងកុមារកំព្រាបានថ្លែងថាលោកស្រីបាននៅមណ្ឌលដែលកុមារ ៤០ នាក់ត្រូវបានចិញ្ចឹមអស់រយៈពេល ៤ ឆ្នាំកន្លងមក និងបានសង្កត់ធ្ងន់ថាមិនមានការសុំកូនណាមួយកើតមានក្នុងអំឡុងពេលនោះទេ។ «ខ្ញុំគ្រាន់តែមើលថែក្មេងៗ។ សេចក្តីសម្រេចសម្រាប់ការផ្គូផ្គងជាមួយគ្រួសារក្រសួងជាអ្នកសម្រេច។ ខ្ញុំមិនមានសិទ្ធិធ្វើវាទេ»។ លោកស្រីបន្តថាមាន «ករណីតិចតួចណាស់» ដែលឪពុកម្តាយចិញ្ចឹមសួរសំណួរអំពីសាច់ញាតិរបស់កូនខ្លួន»។

នៅពេលបង្ហាញជាមួយការចោទប្រកាន់ថាមានការសុំកូនក្លែងបន្លំ ជាលក្ខណៈអន្តរជាតិទៅប្រទេសអ៊ីតាលី លោក មាស យុត អតីតប្រធានសមាគមសាមគ្គី ៧ មករាបានសង្កត់ធ្ងន់ថា លោកបានចូលនិវត្តន៍ពីមណ្ឌលកុមារកំព្រាកាលពី ៥ ឆ្នាំមុន។ លោកថ្លែងថា៖ «នៅពេលកុមារត្រូវបានសុំដោយឪពុកម្តាយបរទេស ហើយរស់នៅបរទេស វាគឺធ្វើឡើងតាមរយៈក្រសួងសង្គមកិច្ច។ យើងមិនដែលធ្វើវាដោយផ្ទាល់ទេ»។ «ឪពុកម្តាយសុំកូនផ្តល់ប្រាក់មួយចំនួនមកយើង វាកើតចេញពីទឹកចិត្តរបស់ពួកគេ»។ លោកបានបដិសេធថាកុមារមិនមែនសុំដោយការគិតជាតម្លៃប៉ុន្មាននោះទេ។

ប៉ុន្តែបញ្ហានៅតែកើតមានចំពោះស្ត្រីមួយចំនួន។ ស្ត្រីម្នាក់ក្នុងចំណោមស្ត្រីទាំងនោះគឺអ្នកស្រី អ៊ីន ម៉ាលី ដែលកាលពីឆ្នាំ ២០០៥ កូន ២ នាក់របស់អ្នកស្រី ត្រូវបានបញ្ជូនទៅប្រទេសអូទ្រីសដោយមិនមានការយល់ព្រមពីអ្នកស្រី។ ដូចមនុស្សជាច្រើនដទៃទៀតអ្នកស្រីមានអារម្មណ៍ត្រូវបានបង្ខំឲ្យដាក់កូនរបស់ខ្លួននៅក្នុងការមើលថែដោយមណ្ឌលកុមារកំព្រាដោយសារភាពក្រីក្រ និងប្តីមានជំងឺធ្ងន់ធ្ងរ។ នៅពេលអ្នកស្រីដឹងថាកូនស្រីរបស់អ្នកស្រីត្រូវបានបញ្ជូនចេញទៅអ្នកស្រីបានទៅប្រឈមមុខនឹងប្រធានមណ្ឌលកុមារកំព្រាដែលកាលពីមុនមិនពេញចិត្តនឹងអ្នកស្រី ម៉ាលី ដែលទៅលេងមណ្ឌលនេះញឹកញាប់ពេក។

លោកនាយកមណ្ឌលបានសួរថា៖ «ហេតុអ្វីអ្នកចង់ដឹង?»។ នៅពេលអ្នកស្រីទទួលបានពាក្យដែលគេប្រាប់ថាកូនប្រុសរបស់អ្នកស្រីកំពុងត្រូវបានរៀបចំសម្រាប់ការសុំកូនទៅបរទេស អ្នកស្រីបានចាប់ផ្តើមស្ទុះស្ទាទៅមណ្ឌលកុមារកំព្រា ប៉ុន្តែកូនរបស់អ្នកស្រីត្រូវបានគេបញ្ជូនចេញរួចជាស្រេចទៅហើយ។ អ្នកស្រីថ្លែងថា៖ «ក្នុងនាមជាម្តាយ ខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់»។ «ខ្ញុំមិនបានឃើញកូនរបស់ខ្ញុំសូម្បីតែម្តងមុនពេលចាកចេញ»៕ NS/PS

## ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៨

## មន្ត្រីព្រំដែនកំហិតទារលុយច្រើនពីពលករខ្មែរពេលឆ្លងដែនអំឡុងបុណ្យចូលឆ្នាំ

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 9 April, 2018

ប៉ោយប៉ែត ៖ ពលករខ្មែរធ្វើការងារនៅប្រទេសថៃ កំពុងសម្រុកចេញពីទឹកដីថៃ តាមច្រកអន្តរជាតិដូង ក្នុងស្រុកកំរៀង ដើម្បីត្រឡប់ទៅលេងស្រុកកំណើតថ្ងៃចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ខណៈដែលពលករត្អូញត្អែចោទប្រកាន់សមត្ថកិច្ចនៅមាត់ច្រកទ្វារទាំងភាគីថៃ និងខ្មែរទារប្រាក់ម្នាក់ៗអស់ជិត៤ម៉ឺនរៀល។ ពលករខ្មែរធ្វើការងារនៅក្នុងប្រទេសថៃរាប់ពាន់នាក់គេសង្កេតឃើញនៅព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៨ បាននាំគ្នាធ្វើដំណើរសម្រុកចាកចេញពីប្រទេសថៃតាមច្រកទ្វារព្រំដែនអន្តជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបងឈមនិងច្រកបានទ្បែម ស្រុកប៉ុងណាំរ៉ង ខេត្តច័ន្ទបុរី ប្រទេសថៃ បង្កឱ្យមានការកកស្ទះចរាចរណ៍ ដើម្បីមកលេងស្រុកកំណើត ក្នុងឱកាសថ្ងៃបុណ្យចូលឆ្នាំប្រពៃណីជាតិនៅសល់តែ៨ថ្ងៃទៀតប៉ុណ្ណោះនិងឈានមកដល់នោះ។ ខណៈដែលការចាកចេញតាមច្រកទ្វារអន្តរជាតិដូងស្រុកកំរៀង បែរជាពលករខ្មែរទាំងនោះមានការត្អូញត្អែ និងចោទប្រកាន់ថាសមត្ថកិច្ចកម្ពុជា និងសមត្ថកិច្ចថៃ ប្រចាំនៅច្រកទ្វារបានទារប្រាក់ពីពួកគាត់ក្នុងម្នាក់ៗ៣រយបាតប្រាក់ថៃស្មើនិងជិត៤ម៉ឺនរៀលប្រាក់ខ្មែរ។ការចោទប្រកាន់ថាមានយកប្រាក់ពីពលករខ្មែរធ្វើដំណើរមកលេងស្រុកកំណើតនៅថ្ងៃបុណ្យចូលឆ្នាំពីសមត្ថកិច្ចថៃនិងសមត្ថកិច្ចកម្ពុជានៅមាត់ច្រកទ្វារព្រំដែននោះត្រូវគេមើលឃើញថាសមត្ថកិច្ចទាំងនោះកំពុងអនុវត្តផ្ទុយពីសេចក្តីប្រកាសរួមរវាងរាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលថៃដែលបានឯកភាពគ្នាមិនឱ្យមានការយកប្រាក់ពីពលករខ្មែរ និងសម្របសម្រួលបង្កលក្ខណៈងាយស្រួលឱ្យដល់ពលករខ្មែរបានចាកចេញមកលេងស្រុកកំណើតនៅថ្ងៃបុណ្យចូលឆ្នាំឱ្យបានល្អផងដែរ។

បើតាមការបញ្ជាក់ឱ្យដឹងពីលករខ្មែរប្រាប់អ្នកសារព័ត៌មានឱ្យដឹងថា ពួកគាត់បានឆ្លងកាត់ច្រកទ្វារព្រំដែនអន្តរជាតិដូងស្រុកកំរៀងឈមនិងច្រកទ្វារព្រំដែនបានទ្បែម ស្រុកប៉ុងណាំរ៉ែន បានបង់ប្រាក់ទៅឱ្យសមត្ថកិច្ចកម្ពុជាក្នុងម្នាក់១រយបាតប្រាក់ថៃស្មើនិងជាង១ម៉ឺនរៀល បង់ប្រាក់ឱ្យសមត្ថកិច្ចថៃ២០០បាតប្រាក់ថៃស្មើនិងជាង២ម៉ឺនរៀលប្រាក់ខ្មែរទោះបីពួកគាត់មានឯកសារសម្រាប់ការឆ្លងដែនស្របច្បាប់ក៏គេតម្រូវឱ្យបង់ប្រាក់នោះផងដែរ។មិនតែប៉ុណ្ណោះចំណែកអីវ៉ាន់ខ្លះដែលពកខ្មែរទិញយកមកប្រើប្រាស់ក៏ត្រូវបង់ប្រាក់ម្នាក់ៗពី១រយបាតប្រាក់ថៃទៅ២រយបាត ផងនោះទៀត។ បញ្ហានេះបង្កឱ្យប៉ះពាល់សតិអារម្មណ៍និងធ្វើឱ្យពួកគាត់មិនសប្បាយចិត្តនោះឡើយ។ ពាក់ព័ន្ធនិងការយកប្រាក់ពីពលករខ្មែរហូតដល់៣បាតស្មើនិងជាង៤ម៉ឺនរៀលទាំងសត្ថកិច្ចថៃនិងសមត្ថកិច្ចកម្ពុជា បើតាមប្រភពព័ត៌មានពីមន្ត្រីសមត្ថកិច្ចខ្មែរប្រចាំច្រកទ្វារព្រំដែនអន្តរជាតិដូងបង្ហើបប្រាប់ថាការយកប្រាក់នោះគឺសមត្ថកិច្ចភាគីទាំង២សហការគ្នាប្រមូលប្រាក់ដើម្បីចែកភាគលាភគ្នា។

ជុំវិញបញ្ហានេះកាលពីរសៀលថ្ងៃទី៦ មេសា អ្នកយកព័ត៌មានយើងបានទំនាក់ទំនងទៅលោក ហម សំខាន់ ប្រធានកណៈកម្មការច្រកទ្វារព្រំដែនអន្តរជាតិដូងស្រុកកំរៀងសូមឱ្យជួយឆ្លើយបំភ្លឺនៃការចោទប្រកាន់ប៉ុន្តែទូរស័ព្ទលោកហៅចូល២ទៅ៣ដងគ្មានការទទួល។អ្នកយកព័ត៌មានយើងបានទំនាក់ទំនង អភិបាលខេត្តបាត់ដំបង លោក ងួន រតនៈ ដើម្បីបំភ្លឺនោះផងដែរលោកប្រាប់ថា កំពុងជាប់រវល់ប្រជុំគណៈអភិបាលខេត្ត។

ដោយឡែកលោកឧត្តមសេនីយ៍ត្រី សៅ ប៊ុនរិទ្ធ ប្រធានប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ច្រកទ្វារព្រំដែនអន្តរជាតិដូងបំភ្លឺឱ្យដឹងថា ថ្ងៃនេះពិតជាមានពលករខ្មែរចាកចេញមកលេងស្រុកកំណើតច្រើននោះមែន។តាមគោលការណ៍ថ្នាក់លើគឺមិនឱ្យសមត្ថកិច្ចនៅច្រកទ្វារព្រំដែនយកប្រាក់ពីពលករខ្មែរនោះឡើយ លោកអះអាងថាគ្មានករណីយកប្រាក់នោះទេ។ លោកបញ្ជាក់ឱ្យដឹងទៀតថា បើប៉ូលីសណាយកប្រាក់ពីពលករខ្មែរត្រូវកត់អត្តលេខនិងមើលឈ្មោះដើម្បីចាត់វិធានការ ប៉ុន្តែលោកឆ្ងល់បើដឹងថាមានសមត្ថកិច្ចយកប្រាក់ហេតុអីបានជាពួកគាត់មិនប្តឹង។

សូមបញ្ជាក់ថា សម្រាប់ពលករខ្មែរធ្វើការងារនៅប្រទេសថៃគេសង្កេតឃើញនៅថ្ងៃទី៦ ខែមេសា មិនត្រឹមតែចាកចេញតាមច្រកទ្វារព្រំដែនអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបងប្រឈមនិងច្រកបានឡែម ស្រុកប៉ុងណាំរ៉ង ខេត្តច័ន្ទបុរី ប្រទេសថៃប៉ុណ្ណោះទេ។ពួកគេក៏កំពុងធ្វើដំណើរចាកចេញពីប្រទេសថៃចូលមកកម្ពុជាតាមច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឈមនិងច្រកខ្លងទ្បឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ យ៉ាងសន្ធឹកសន្ធាប់នោះផងដែរ។ពលករខ្មែរអាចនិងបន្តធ្វើដំណើរជាបន្តបន្ទាប់ទៀតដើម្បីមកលេងស្រុកកំណើតក្នុងថ្ងៃបុណ្យចូលឆ្នាំប្រពៃណីខ្មែរនោះ គ្រាដែលមានសេចក្តីរាយការណ៍ឱ្យដឹងថារថយន្តរត់ឈ្នួលតូចៗក៏កំពុងតម្លើងថ្លៃឈ្នួលនៃការដឹកជញ្ជូននោះផងដែរ៕

## ពលករមកពី ថៃ រងគ្រោះដោយសារ នគរបាលអន្តោប្រវេសន៍ច្រកអន្តរជាតិដូង បញ្ជាឲ្យកូនចៅដេកចាំយកលុយ

http://peoplenews.asia/ ដោយ ៖ សុខ សាន្ត ថ្ងៃទី09 ខែ04 ឆ្នាំ2018 ម៉ោង 9:39 PM

ខេត្តបាត់ដំបង ៖ ពលករខ្មែរធ្វើការងារនៅប្រទេសថៃ បានវិលត្រឡប់មកស្រុកកំណើតវិញ ដើម្បីចូលរួមជួបជុំគ្រួសារ នាឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរ នៅតែបន្តរងគ្រោះ ដោយសារ លោក សៅ ប៊ុនណារិទ្ធ ប្រធានការិយាល័យនគរបាលអន្តោប្រវេសន៍ច្រកអន្តរជាតិដូង បញ្ជារឲ្យកូនចៅអង្គុយទាលុយពីពលករខ្មែរ ដែលធ្វើការនៅប្រទេសថៃចាប់តាំងពីដើមខែមេសា ដោយម្នាក់ៗត្រូវ ៣០០បាតជិតស្មើនិង៤០០០០រៀល ទៅអោយសមត្ថកិច្ចភាគីថៃ និងនគរបាលអន្តោប្រវេសន៍ច្រកអន្តរជាតិដូង។ នេះគឺជាសកម្មភាពនៃការប្រព្រឹត្តអំពើពុករលួយ ស្រណុកសុខស្រួល ជាមួយរដ្ឋវប្រមូលលុយ គ្រាន់តែដេក ក៏បានលុយចូលដោយងាយៗដែរ។ ទង្វើទាំងនេះ ធ្វើអោយប៉ះពាល់ដល់អារម្មណ៍ពលករខ្មែរ និងជះឥទ្ធិពលដ៏អាក្រក់ដល់ថ្នាក់លើ ខណៈបុគ្គលរូបនេះគិតផលប្រយោជន៍បុគ្គលធំជាងលើកកម្ពស់កិត្តិយសអង្គភាព និងស្វែងយល់ យន្តការនយោបាយ រដ្ឋាភិបាលបាននិងកំពុង គិតគូរពីពលករខ្មែរនោះ..?

នារដូវបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរយើងដែលនឹងឈានជិតមកដល់នាពេលដ៏ខ្លីខាងមុខនេះខាងរដ្ឋាភិបាលប្រទេសថៃដែលមានទំនាក់ទំនងដ៏ល្អជាមួយរដ្ឋាភិបាលកម្ពុជា គឺបានអោយតាមបណ្តាក្រុមហ៊ុន សហគ្រាសតូច-ធំក្នុងប្រទេសនេះត្រូវអនុញ្ញាតអោយបុគ្គលិក កម្មករ ពលករ ជនជាតិបរទេស ពិសេស ពលករខ្មែរបានឈប់សម្រាកពីការងារមួយរយៈ ដើម្បីមកលេងស្រុកកំណើត ជួបជុំបងប្អូនក្រុមគ្រួសារ ដើម្បីសប្បាយរីករាយ នារដូវចូលឆ្នាំថ្មីនេះ។ យ៉ាងតិចក្នុង១ថ្ងៃមានពលករខ្មែររាប់ពាន់នាក់បានឆ្លងតាមច្រកដូង។ មានពលខ្មែររាប់ម៉ឺននាក់បានចាកចេញពីប្រទេសថៃ តាមច្រកមួយចំនួនទាំងច្រកអន្តរជាតិ និងច្រកទ្វេភាគី ច្រករបៀងខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិនជាដើម ក្នុងមួយថ្ងៃៗរាប់ពាន់នាក់។ ប៉ុន្តែអ្វីដែលមិនគួរកើតត្រង់ថា មេនគរបាលអន្តោប្រវេសន៍ច្រកអន្តរជាតិដូង ស្ថិតក្នុងស្រុកកំរៀង ខេត្តបាត់ដំបង ឆក់ឱកាសអោយមន្ត្រីរបស់ខ្លួនយកលុយពីពលករខ្មែរ ក្នុងម្នាក់៣០០

បាតជិតស្មើនឹង៤០០០០រៀល ទៅអោយសមត្ថកិច្ចភាគីថៃ និងនគរបាលអន្តោប្រវេសន៍ច្រកអន្តរជាតិដូង។ផ្ទុយពីគោលការណ៍លើកទឹកចិត្តពីប្រមុខរាជរដ្ឋាភិបាលទៅលើពលករ កម្មករ កម្មការិនី ក្នុងក្របខណ្ឌទូទាំងប្រទេសនោះ។

ប្រជាពលរដ្ឋ ដែលជាពលករ បានចោទជាសំនួរថា តើការប្រព្រឹត្តរបស់លោក សៅ ប៊ុនណារិទ្ធ ប្រធានការិយាល័យនគរបាលអន្តោប្រវេសន៍ច្រកអន្តរជាតិដូង មានដឹងដែរឬទេ? ឬក៏ចាំបែងចែកផលប្រយោជន៍ជាមួយគ្នា។ គួរអោយអាសូរដល់ពលករដែលគ្នាខិតខំធ្វើការនៅប្រទេសគេហើយ ហើយពេលដល់ថ្ងៃត្រូវមកលេងក្រុមគ្រួសារ ត្រូវបានមន្ត្រីមួយចំនួន តាមច្រកទ្វារព្រំដែន តម្រូវអោយចំណាយលុយថែមទៀត វាហាក់ដូចជាកំពុងតែអាកក្តាមយកឈាមដូច្នេះដែរ។មិនងាចសុំការពន្យល់ពី លោក លោក សៅ ប៊ុនណារិទ្ធ ប្រធានការិយាល័យនគរបាលអន្តោប្រវេសន៍ច្រកអន្តរជាតិដូង បានទេ។

## សមត្ថកិច្ចថៃឃាត់ខ្លួនពលរដ្ឋខ្មែរ៣នាក់ ពីបទឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ

http://cambodiapolice.com/ 2:35 pm 9 មេសា 2018 56

ឧត្តរមានជ័យ ៖ នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៨ ព័ត៌មានពីក្រុមការងារទំនាក់ទំនងព្រំដែនប្រចាំច្រកជប់គគី ឲ្យដឹងថា នៅចំណុចក្បែរតម្រុយសីម៉ាលេខ២២៦B សមត្ថកិច្ចថៃបានចាប់ពលខ្មែរចំនួន០៣នាក់ ពីបទ ថាបានឆ្លងដែន និងរកសត្វព្រៃចូលក្នុងជ្រៅទឹកដីរបស់ថៃ កាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៨ វេលាម៉ោង១១និង០០នាទីថ្ងៃ ។ ប្រជាជនខ្មែរដែលចាប់ខ្លួនមានឈ្មោះ ៖ ១-ឈ្មោះ វ៉េវ វុត ភេទប្រុស អាយុ៣៦ឆ្នាំ , ២-ឈ្មោះ វ៉េវ ភេទប្រុស អាយុ២៥ឆ្នាំ និង៣-ឈ្មោះ ប៉េប ពាយ ភេទប្រុស អាយុ ៤១ឆ្នាំ ។ ទាំងបីនាក់មានទីលំនៅភូមិយ៉ក ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ។ បច្ចុប្បន្ន ពលរដ្ឋខ្មែរទាំង០៣នាក់ សមត្ថកិច្ចថៃបានត្រៀមបញ្ជូនទៅកាន់កន្លែងឃុំឃាំងនៅស្រុកនាំងរ៉ង ខេត្តប៊ុរីរ៉ាំ ៕

## ពលករធ្វើការនៅប្រទេសថៃចំនួនជិត3សែននាក់,មិនអាចវិលត្រឡប់ទៅលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំថ្មី បានដោយសារ.!

http://www.pheaktraprak.com/ April 10, 2018

យោងតាមបណ្តាញសារព័ត៌មានថៃបានចុះផ្សាយនៅថ្ងៃច័ន្ទទី09 ខែមេសា ឆ្នាំ2018 នេះអោយបានឲ្យដឹងថា ពលករបរទេសមានសញ្ជាតិខ្មែរ,ឡាវ,ភូមាចំនួនប្រមាណជិត 3សែននាក់ កំពុងធ្វើការរស់នៅក្នុងប្រទេសថៃ មិនអាចធ្វើដំណើរវិលឡប់ទៅលេងស្រុកកំណើតរបស់ខ្លួននៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិរបានដោយសារមូលហេតុគឺមិនបានធ្វើឡៀនប្រវត្តិរូចរាល់ ដូច្នេះហើយទើបមិនអាចធ្វើដំណើរចេញពីប្រទេសថៃទៅលេងស្រុកកំណើតរបស់ខ្លួនបាន ។ ហើយចំពោះពលករ ដែលកាន់កាប់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) នៅមានសុពលភាព និងពលករដែលកាន់លិខិតឆ្លងដែន លិខិតធ្វើដំណើរពលករកម្ពុជា ធ្វើការនៅបរទេស (TD) ដែលមានទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារនៅមានសុពលភាព ព្រមទាំងអ្នកនៅក្នុងបន្ទុក អាចធ្វើដំណើរចេញ ចូលប្រទេសថៃ-កម្ពុជាបានចាប់ពីថ្ងៃទី05រហូតថ្ងៃទី30 ខែមេសា ឆ្នាំ2018។

ចំពោះបងប្អូនពលករ កាន់កាប់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) ដែលមានបំណងធ្វើដំណើរត្រឡប់មកកម្ពុជាវិញ ក្នុងអំឡុងពេលនេះ ត្រូវស្នើសុំលិខិតអនុញ្ញាតពីមន្ទីរការងារថៃ ក្នុងខេត្តដែរខ្លួនកំពុងធ្វើការ។ ដោយឡែកចំពោះបងប្អូនពលករ ដែលកាន់កាប់លិខិតឆ្លងដែន លិខិតធ្វើដំណើរ (TD) ត្រូវទៅស្នើសុំទិដ្ឋាការចេញ ចូលនៅការិយាល័យអន្តោប្រវេសន៍ក្នុងខេត្ត ដែលខ្លួនធ្វើការ ឬច្រកព្រំដែនអន្តរជាតិ ដោយពុំមានបង់កម្រៃឡើយ។ ពលករទាំងអស់ត្រូវឆ្លងកាត់ តាមច្រកព្រំដែនអន្តរជាតិ ប្រសិនបើជាត្រឡប់មកកម្ពុជា តាមច្រកណាត្រូវត្រឡប់ទៅថៃវិញតាមច្រកនោះ។ ក៏ប៉ុន្តែពលករទាំងអស់នោះអាចនៅចូលរួមពិធី បុណ្យចូលឆ្នាំថ្មីនៅក្នុងប្រទេសថៃបាន ។

យោងតាមប្រសាសន៍ របស់ លោក អនុរ៉ាក់ ទុត្យារ៉ាក អគ្គនាយកកដ្ឋានក្រសួងការងារថៃ បានបញ្ជាក់ប្រាប់ថា ចំពោះពលករដែលមិនបានធ្វើតៀ្យតប្រវត្តិរួចរាល់នៅសូន្យ OSS, គឺពួកគាត់មិនអាចធ្វើដំណើរវិលត្រឡប់ទៅលេងស្រុកកំណើតបានដាច់ខាត់ ក៏ប៉ុន្តែពួកគាត់អាចនៅចូលលេងកម្សាន្តពិធីបុណ្យចូលឆ្នាំនៅក្នុងប្រទេសថៃបាន ហើយនៅក្រោយឱកាស បុណ្យចូលឆ្នាំថ្មី រួច ក្រសួងការងារថៃ នឹងប្រកាសជូនដំណឹងដល់និយោជកដែលបានចុះឈ្មោះ ពលករតាមប្រព័ន្ធអេឡិចត្រូនិក អោយមកធ្វើតៀ្យតប្រវត្តិអោយរួចរាល់នៅថ្ងៃទី30 ខែមេសា ឆ្នាំ2018នេះ។

## ស្របច្បាប់និងខុសច្បាប់ កំពុងសម្រុកចេញពីថៃមកលេងស្រុកថ្ងៃចូលឆ្នាំខ្មែរ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៨ ម៉ោង ១១:១៥ ប៊ុន ធឿន ,ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ រយៈពេល២ទៅ៣ថ្ងៃកន្លងមកហើយ ដែលពលករខ្មែរទៅធ្វើការឯប្រទេសថៃ បានសម្រុកចូលមកកម្ពុជាក្នុង១ថ្ងៃៗពី៤០០ទៅ៥០០នាក់ ចំណែកពលករចូលទៅប្រទេសថៃខុសច្បាប់ ក៏ត្រូវបានចាប់បញ្ជូនមកវិញពី១០០ ទៅ១៥០នាក់ដែរ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ។ លោកឧត្តមសេនីយ៍ត្រី ស៊ឹម សំអាត នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត បានប្រាប់កាលពីថ្ងៃទី៩ ខែមេសា ថា នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត រយៈពេល២ទៅ៣ថ្ងៃនេះ ពលករខ្មែរដែលត្រឡប់ចូលមកកម្ពុជាវិញក្នុង១ថ្ងៃៗប្រមាណជា៤០០ទៅ៥០០នាក់ គឺច្រើនជាងបើប្រៀបធៀបនឹងឆ្នាំមុន ដែលក្នុង១ថ្ងៃៗមានប្រមាណជា៣០០ទៅ៤០០នាក់ប៉ុណ្ណោះ ។ លោកបញ្ជាក់ថា ចំណែកពលករខ្មែរដែលត្រូវអាជ្ញាធរថៃចាប់បញ្ជូនមកវិញរយៈពេល២ទៅ៣នេះ ក្នុង១ថ្ងៃៗមានប្រមាណជា១០០ទៅ១៥០នាក់ បើប្រៀបធៀបនឹងសប្តាហ៍មុន១ថ្ងៃៗមានប្រមាណជិត១០០នាក់ ។ ភាគច្រើន ពួកគាត់ជាពលករខ្មែរដែលទៅធ្វើការដោយខុសច្បាប់នៅប្រទេសថៃតាមរយៈមេខ្យល់ ហើយត្រូវបានសមត្ថកិច្ចថៃចាប់បញ្ជូនមកវិញ ។ លោកឧត្តមសេនីយ៍ត្រី ស៊ឹម សំអាត ថ្លែងទៀតថា ប្រជាពលរដ្ឋខ្មែរដែលទៅធ្វើការនៅប្រទេសថៃដោយស្របច្បាប់ ហើយត្រឡប់មកស្រុកកំណើតវិញមុនថ្ងៃបុណ្យចូលឆ្នាំថ្មី គឺកើតមានរាល់ថ្ងៃរហូតជិតដល់ថ្ងៃចូលឆ្នាំទើបស្ងាត់ ។

លោកបានសំណូមពរ កុំឲ្យរថយន្តឈ្នួលឡើងថ្លៃ ព្រោះរៀងរាល់ឆ្នាំឲ្យតែជិតដល់ថ្ងៃបុណ្យចូលឆ្នាំថ្មី ប្រជាពលរដ្ឋខ្មែរសម្រុកចូលមកស្រុកកំណើតវិញ រថយន្តឈ្នួលឡើងថ្លៃណាស់ ។ស្របពេលដែលភាគីទាំង២ កម្ពុជា-ថៃ សម្រួលដល់ការធ្វើដំណើរចំពោះពលករស្នាក់នៅ និងធ្វើការនៅទឹកដីថៃ ឱ្យមានភាពងាយស្រួលក្នុងការវិលត្រឡប់មកស្រុកកំណើត ដើម្បីចូលរួមក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនាពេលខាងមុខដោយមិនយកប្រាក់ គេឃើញពលករនាំគ្នាសម្រុកមកកម្ពុជាវិញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតច្រើនខុសសព្វមួយដង សម្រាប់ថ្ងៃទី៨ ខែមេសា និងថ្ងៃ៩ ខែមេសា ។ ខណៈក្រុមពលករត្រឡប់ពីថៃច្រើន តាមដងផ្លូវជាតិលេខ៥នៅក្រុងប៉ោយប៉ែត ពិសេសតាមមុខសាខាលក់សំបុត្ររថយន្តក្រុង មានការកកស្ទះស្ទើរធ្វើដំណើរមិនចង់ទៅមុខ ព្រោះតែរទេះធំៗនិងម៉ូតូកង់បី ចតលើកដាក់អីវ៉ាន់ និងមានការលក់នំចំណី ផ្លែឈើច្រើន ធ្វើឱ្យសមត្ថកិច្ចឈឺក្បាល មិនតិចឡើយ ព្រោះដូចចាប់ក្តាមដាក់ចង្អេរ ។

រីឯរថយន្តក៏មានចំនួនកើនឡើងដែរ ដែលមួយចំនួនធំជារថយន្តតាក់ស៊ី តែមួយចំនួនទៀតមកពីតាមបណ្តាខេត្តជារថយន្តគ្រួសាររង់ចាំដឹកសាច់ញាតិវិលត្រឡប់ពីថៃ ។ សំបុត្ររថយន្តតូចធំតាមទីតាំងសាខាលក់សំបុត្រមួយចំនួន បានឡើងថ្លៃខុសពីមុន កន្លែងខ្លះរហូតម្នាក់៤០០បាត (ប្រាក់ថៃ) និងកន្លែងខ្លះរហូតដល់ទៅ៥០០បាត ប៉ុន្តែកន្លែងខ្លះក៏លក់ក្នុងតម្លៃធម្មតាព្រោះជាម៉ូយប្រចាំរបស់ពួកគេទាំងទៅទាំងមក ។ ពលករឆ្លងព្រំដែនពីថៃតាមច្រកទ្វារអន្តរជាតិខាងលើ សម្រាប់ថ្ងៃ៩ ខែមេសា ហាក់គគ្រឹកគគ្រេងណាស់ចំពោះអ្នកមកពីធ្វើការរោងចក្រពិសេសអ្នកប្រើប្រាស់ប័ណ្ណស៊ីជម្ពូ/លិខិតឆ្លងដែនការងារក្នុងលក្ខណៈជើងដំណើរធម្មតា ។ ដោយឡែក ពលករដែលប្រើប្រាស់ប័ណ្ណឆ្លងដែន Border Pass ធ្វើការតាមស្រុកក្នុងខេត្តជាប់ព្រំដែនដូចជា ស៊ីឈ្នួលធ្វើចម្ការកាប់អំពៅ ក៏វិលត្រឡប់ជាលក្ខណៈគ្រួសារ មានកូនចៅតូចៗ មកជាមួយ និងសម្ភារផ្ទាំងចានរបស់របរដឹកពេញៗរទេះតែម្តង ។

គេកត់សម្គាល់ឃើញថា ការឆ្លងព្រំដែនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតឆ្នាំនេះងាយស្រួលជាងឆ្នាំមុនៗ ។ នេះបើយោងតាមការសាកសួរផ្ទាល់ជាមួយក្រុមពលករ គឺអ្នកមានឯកសារច្បាប់ត្រឹមត្រូវ អាជ្ញាធរនិងសមត្ថកិច្ចប្រចាំនៅមាត់ច្រកទ្វារព្រំដែនប្រទេសទាំង២ មិនយកប្រាក់លើសេវាណាមួយឡើយ លើកលែងតែពលករដែលវិលត្រឡប់ដោយខុសច្បាប់ គឺត្រូវចំណាយប្រាក់ម្នាក់៥០០ទៅ៦០០បាត ឱ្យមេខ្យល់ដែលគេសង្ស័យថា អាចត្រូវរ៉ូវគ្នាជាមួយសមត្ថកិច្ចថៃទើបឆ្លងដែនបាន ។ជុំវិញករណីយកលុយពីពលករនេះ សមត្ថកិច្ចកម្ពុជានៅច្រកទ្វារអន្តរជាតិប៉ោយប៉ែតបដិសេធថាមិនបានដឹងទេ ព្រោះខាងកម្ពុជាបានបើកចំហមិនមានការត្រួតពិនិត្យអ្វីនោះឡើយ សូម្បីតែសេវាឯកសារផ្សេងៗក៏មិនយកប្រាក់ពីពលករដែរ ៕

## ថៃមិនគិតថ្លៃឆ្លងកាត់ព្រំដែនអំឡុងបុណ្យសង្ក្រាន្តសម្រាប់ពលករបរទេស

https://khmeread.com/ April 09, 2018 02:19PM

ប៉ូលិសអន្តោប្រវេសន៍ស្រុកតាក់មិនគិតថ្លៃឆ្លងកាត់តាមច្រកព្រំដែនត្រង់ចំណុច Mae Sot-Myawaddy នៅពេលដែលកម្មករអន្តោប្រវេសន៍ភូមារាប់ពាន់នាក់ត្រឡប់ទៅស្រុកកំណើតវិញក្នុងឱកាសបុណ្យមហាសង្ក្រាន។ អគ្គនាយកអន្តោប្រវេសន៍ប៉ូលិសលោកវរសេនីយ៍ឯក ម៉ាន់ រតនាព្រហូត បាននិយាយកាលពីថ្ងៃចន្ទថា ការឆ្លងកាត់តាមច្រកព្រំដែនតំបន់ Tha Sai Luad ឃើញមនុស្សរាប់ពាន់នាក់បានឆ្លងកាត់ ហើយបុគ្គលិកត្រូវបានបន្ថែមដើម្បីពន្លឿនដំណើរការការងារ។ អគ្គនាយកអន្តោប្រវេសន៍រូបនេះបានកត់សម្គាល់ថាគណៈរដ្ឋមន្ត្រីបានសម្រេចចិត្តរឿងនេះកាលពីថ្ងៃទី២៧ ខែមីនាមកម្ល៉េះ ដើម្បីលុបចោលការគិតថ្លៃឆ្លងកាត់សម្រាប់ពលករចំណាកស្រុកមកពីប្រទេសមីយ៉ាន់ម៉ា ឡាវ និងកម្ពុជាចាប់ពីថ្ងៃទី ៥ ដល់ថ្ងៃទី ៣០ ខែមេសាឆ្នាំនេះ។

ឯកឧត្តមអភិបាលខេត្ត តាច់វិនសានហ្គាណាត និងសមភាគីរបស់លោកនៅក្នុងទីក្រុងមីយ៉ាវ៉ាឌី លោកឡៅហ្គោយូ កាលពីព្រឹកថ្ងៃចន្ទបាននាំមន្ត្រី និងអ្នកស្ម័គ្រចិត្តចំនួន ១ ពាន់នាក់មកពីប្រទេសទាំងពីរដើម្បីសម្អាតស្ពានមិត្តភាពថៃ - មីយ៉ាន់ម៉ាលើកដំបូង ដើម្បីស្វាគមន៍បុណ្យឈប់សម្រាក មហាសង្ក្រាន្ត និងជំរុញទំនាក់ទំនងទ្វេភាគីផងដែរ។ ជាមួយនឹងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណី ដែលត្រូវបានគេស្គាល់ដោយសារការកកស្ទះចរាចរដោយសារតែអ្នកធ្វើដំណើរកម្សាន្តថ្ងៃឈប់សម្រាក កម្មករចំណាកស្រុកជាច្រើនបានចាប់ផ្តើមធ្វើដំណើរនៅថ្ងៃស្អែកនេះផងដែរ៕ ប្រភពៈថៃ

## ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៨

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សចុះMOU ជាមួយអង្គការក្រៅរដ្ឋាភិបាល ស្តីពីការការពារពលករខ្មែរ

http://bayontv.com.kh/ 10/04/2018

ភ្នំពេញ៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចុះហត្ថលេខាអនុស្សរណៈនៃការយោគយល់គ្នា ជាមួយអង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិលដែលហៅកាត់ថាGVC ដើម្បីការពារ និងការតស៊ូមតិលើសិទ្ធពលករទេសន្តប្រវេសក៍ក្នុងប្រទេសថៃ។ ការចុះអនុស្សរណៈលើការពារពលករនេះ ធ្វើឡើងនៅរសៀលថ្ងៃទី០៩ ខែមេសានៅអគ្គនាយកដ្ឋានជួញដូរមនុស្សក្រុងភ្នំពេញ។

ថ្លែងប្រាប់ដល់អ្នកសារព័ត៌មានក្រោយពីចុះអនុស្សរណៈនោះ រដ្ឋលេខាធិការក្រសួងមហាផ្ទៃលោកជំទាវ ជូ ប៊ុនអេង បានឲ្យដឹងថា ការចុះអនុស្សរណៈជាមួយអង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិល"GVC"នេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ដើម្បីសហការគ្នាជួយដល់បងប្អូនពលករខ្មែរដែលធ្វើការនៅប្រទេសថៃនៅពេលពួកគេមានបញ្ហាអ្វីមួយកើតឡើង។ លោកជំទាវបន្តថា អង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិល "GVC"មានស្នាក់ការនៅក្នុងក្រុងសៀមរាប ជាប់ជាយដែនកម្ពុ

ជា-ថៃ។ អង្គការនេះមានបណ្តាញច្រើននៅក្នុងប្រទេសថៃ។ ដូច្នេះពេលដែលពលករខ្មែរមានបញ្ហាអ្វីកើតឡើងគឺអង្គការនេះបានដឹង និងអាចរាយការណ៍បន្តឱ្យគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ក្រុមការងាររបស់ក្រសួងនឹងចុះដើម្បីជួយ និងអន្តរាគមន៍ដល់បងប្អូនពលករទាំងនោះតែម្តងនៅពេលទទួលបានសេចក្តីរាយការណ៍ផ្សេងៗ។ លោកជំទាវជូ ប៊ុនអេងបានអះអាងថា នាពេលខាងមុខរាជរដ្ឋាភិបាលដែលមានក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទានឹងធ្វើកន្លែងស្នាក់នៅបណ្តោះអាសន្ននៅ ច្រកក្រុងប៉ោយប៉ែត។ ការធ្វើកន្លែងស្នាក់នៅបណ្តោះអាសន្ននេះដើម្បីជួយដល់បងប្អូនពលករខ្មែរដែលត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនមកវិញ។ ហើយស្របពេលដែលគេបញ្ជូនមកវិញនោះក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនឹងធ្វើការសាកសួរដល់ពួកគេអំពីមូលហេតុដែលកើតមានឡើងលើពួកគេ៕

## នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ថាប្រជាពលរដ្ឋខ្មែរធ្វើការនៅប្រទេសថៃសម្រុកចូលកម្ពុជាតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមួយថ្ងៃជាងមួយពាន់នាក់

http://cambodiapolice.com/ 5:04 pm 10 មេសា 2018

**បន្ទាយមានជ័យ ៖** ប្រជាពលរដ្ឋខ្មែរធ្វើការនៅប្រទេសថៃសម្រុកចូលកម្ពុជាតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមួយថ្ងៃ ជាងមួយពាន់នាក់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨។ លោកឧត្តមសេនីយ៍ត្រី ស៊ឹម សំអាត នាយប៉ុស្តិ៍នគរអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតបានប្រាប់ឲ្យដឹងថា រយៈពេល២ទៅ៣ថ្ងៃនេះឃើញមានប្រជាពលរដ្ឋខ្មែរដែលធ្វើការនៅប្រទេសថៃបាននាំសម្រុកចូលមកកម្ពុជាវិញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យកាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨ មានប្រមាណ៤០០ទៅ៥០០នាក់ តែនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ មានប្រមាណជាង១.០០០នាក់។ លោកបានបញ្ជាក់ថា សម្រាប់នៅថ្ងៃបន្តអាចច្រើនជាងនេះព្រោះប្រជាពលរដ្ឋខ្មែរដែលធ្វើការនៅប្រទេសថៃបាននាំគ្នាត្រឡប់មកស្រុកកំណើតដើម្បីមកលេងថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរខាងនេះ ហើយកម្លាំងនគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតបានខិតខំការពារសុវត្ថិភាពជូនបងប្អូនប្រជាពលរដ្ឋ។ លោកឧត្តមសេនីយ៍ត្រី ស៊ឹម សំអាត បានបញ្ជាក់ថា ក្រោយពេលប្រជាពលរដ្ឋខ្មែរសម្រុកត្រឡប់មកស្រុកកំណើរវិញទទួលព័ត៌មានថាមានរថយន្តក្រុមហ៊ុនដឹកអ្នកដំណើរឬរថយន្តតាក់ស៊ីបានឡើងថ្លៃមួយទ្វេរពីរ។ បានសំណូមពរសុំអោយក្រុមហ៊ុនរថយន្តដឹកអ្នកដំណើរ និងរថយន្តតាក់ស៊ីមិនត្រូវឆ្លៀតឱកាសពេលដែលប្រជាពលរដ្ឋខ្មែរសម្រុកចូលមកកម្ពុជាវិញនៅថ្ងៃបុណ្យសុំតម្លៃដូចធម្មតាវិញ។ លោកបានបញ្ជាក់ថា ក្រោយថ្ងៃចូលឆ្នាំប្រពៃណីហើយប្រជាពលរដ្ឋដែលធ្វើការនៅប្រទេសថៃអាចថាសម្រុកចេញទៅវិញដើម្បីរកការងារធ្វើនៅប្រទេសថៃកាលពីឆ្នាំមុនមួយថ្ងៃមិនតិចជាងមួយពាន់នាក់៕ដោយៈ ចន្ត្រា

## កុងស៊ុលខ្មែរ និងអាជ្ញាធរថៃ រៀបចំបែបបទ ឲ្យពលករខ្មែរ ត្រឡប់មកលេង ថ្ងៃចូលឆ្នាំ

https://www.dap-news.com/kh/ ថ្ងៃពុធ, ១១ មេសា ២០១៨ 10:44 ដោយ: ដើមអម្ពិល ID:112

ភ្នំពេញ ៖ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តសាកែវ ប្រទេសថៃ បានសហប្រតិបត្តិការ ជាមួយស្នងការនគរបាលអន្តោប្រវេសន៍ខេត្តសាកែវ និងស្ថាប័នពាក់ព័ន្ធ ដើម្បីសម្រួល បែបបទ ដល់ពលករកម្ពុជា ដែលអញ្ជើញវិលត្រឡប់ ទៅចូលរួមពិធីចូលឆ្នាំថ្មី ប្រពៃណីជាតិ នៅស្រុកកំណើត ។ បើតាមមន្ត្រីនគរបាល នៅតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្នុង១ថ្ងៃៗ មានពលករខ្មែរ ត្រឡប់មកចូលរួមបុណ្យឆ្នាំថ្មី ប្រមាណជា៥០០នាក់។ យោងតាមហ្វេសប៊ុក របស់ស្ថានអគ្គកុងស៊ុលខ្មែរ ប្រចាំខេត្តស្រះកែវ បានឲ្យដឹងថា នៅថ្ងៃ ទី១១ ខែមេសា ឆ្នាំ២០១៨នេះ ភាគីទាំងបានជួយសម្រួល ឯកសារនានា ដើម្បីបង្កការងាយ ស្រួលឲ្យពលករខ្មែរ ត្រឡប់មកស្រុកកំណើតវិញ។ ស្ថានអគ្គកុងស៊ុល ក៏បានថ្លែងអំណរគុណ ដ៏ស្មោះចំពោះកងកម្លាំង នគរបាលអន្តោប្រវេសន៍ ថៃ នៅតាមច្រកទ្វារអន្តរជាតិកម្ពុជា-ថៃ ដែលខិតខំរៀបចំសម្រួល បែបបទដល់ពលករកម្ពុជា បានយ៉ាងឆាប់រហ័ស មិនរង់ចាំយូរហួសហេតុ៕

## ច្រកទ្វារព្រំដែនអន្តរជាតិខេត្តប៉ៃលិន មិនសូវមានពលករឆ្លងកាត់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៨ ម៉ោង ២២:២០ នីយ៉ា

ខេត្តប៉ៃលិន ៖ គេសង្កេតឃើញថា នៅកៀកចូលឆ្នាំខ្មែរប្រពៃណីជាតិឆ្នាំ២០១៨នេះ ក៏ដូចជារៀងរាល់ឆ្នាំដែរ ច្រកទ្វារអន្តរជាតិខេត្តប៉ៃលិន ស្ថិតនៅក្នុងភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន មិនសូវមានពលករឆ្លងកាត់ចូលមកលេងទឹកដីខ្មែរដូចជានៅច្រកទ្វារខេត្តផ្សេងៗនោះទេ។ ខណៈច្រកទ្វារទ្បែម ក្នុងភូមិដូង ឃុំដូង ស្រុកកំរៀង ខេត្តបាត់ដំបង មានពលករឆ្លងដែនចូលមកលេងស្រុកកំណើតនាឱកាសបុ ណ្យចូលឆ្នាំខ្មែរនេះយ៉ាងគគ្រឹកគគ្រេង ។ ជាក់ស្តែងកាលពីប៉ុន្មានថ្ងៃកន្លងទៅនេះ គេសង្កេតឃើញថា នៅច្រកទ្វារអន្តរជាតិព្រំស្វាត់ អត់សូវឃើញមានពលករឆ្លងចូលមកលេងស្រុកកំណើតតាមបណ្តាខេត្តនានាប៉ុន្មានោះទេ។

ប្រភពព័ត៌មានពីអ្នករត់ម៉ូតូឌុបម្នាក់ ឈ្មោះ សុខ លាង អាយុ៤៥ឆ្នាំ ស្នាក់នៅក្នុងភូមិខាងលើបានរៀបរាប់ឱ្យដឹងថា គាត់មិនឃើញមានសកម្មភាពអ្វីខុសប្លែកនោះទេ ទោះជាថ្ងៃធម្មតាក៏ដូចជាថ្ងៃបុណ្យទាន ភ្ជុំបិណ្ឌ ឬបុណ្យចូលឆ្នាំដែរ ប្រជាពលរដ្ឋដែលចេញចូលតាម ច្រកទ្វារអន្តរជាតិ មានតិចតួច មិនដូចជានៅច្រកទ្វារផ្សេងៗនោះទេ។ គាត់បន្តទៀតថា ណាមួយប្រហែលជាដោយសារតែច្រកទ្វារ អន្តរជាតិផ្សេងបង្កភាពងាយស្រួលជាង ព្រោះផ្លូវដើរឆ្លងកាត់ក្បែរទឹកដីថៃជាងច្រកទ្វារខេត្តប៉ៃលិន។ ម្យ៉ាងទៀត ច្រកទ្វារផ្សេងមានភាពធំទូលាយជាង មានសមត្ថកិច្ចប្រចាំច្រករួសរាយរាក់ជាងក៏មិនដឹងដែរ ព្រោះតាមច្រកនីមួយៗ មិនមានការយកលុយយកាក់ពីប្រជាពលរដ្ឋ និងពលករដូចគ្នាដែរ។

ចំណែកការធ្វើដំណើរតាមច្រកទ្វារព្រំដែនខេត្តប៉ៃលិន ទៅធ្វើការងារនៅប្រទេសថៃ ក៏អត់សូវមានប្រជាពលរដ្ឋឆ្លងដែនច្រើនប៉ុន្មានដែរ ខណៈច្រកទ្វារអន្តរជាតិទ្បែម ភូមិដូង មានពលករចេញចូលទៅមករាប់សិបនាក់ឯនោះក្នុង១ថ្ងៃៗ។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ ខាងមន្រ្តីនគរបាលអន្តោប្រវេសន៍ ច្រកទ្វារព្រំដែនខេត្តប៉ៃលិន ធ្លាប់ឱ្យភ្នាក់ងារយើងដឹងដែរថា មូលហេតុដែលពលករអត់សូវឆ្លងកាត់តាមច្រកទ្វារមួយនេះ ដោយសារតែផ្លូវចូលពីទឹកដីថៃចូលមកខ្មែរមានរយៈចម្ងាយជាងច្រកទ្វារអន្តរជាតិដូងខេត្តបាត់ដំបង ហើយខាង សមត្ថកិច្ចថៃនៅខាងខេត្តប៉ៃលិនមានការតឹងរ៉ឹងជាងច្រកផ្សេង ដូច្នេះហើយប្រជាពលរដ្ឋមិនសូវចូលមកនោះទេ។ ម្យ៉ាងវិញទៀត ផ្លូវចូលពីថៃមកខេត្តប៉ៃលិន និងផ្លូវចូលពីថៃមកតាមខេត្តបាត់ដំបងជា ផ្លូវតែមួយ ហើយផ្លូវគេមានលក្ខណៈងាយស្រួលជាង៕

## ពលករខ្មែរធ្វើការនៅថៃ សម្រុកវិលមកស្រុកកំណើតឱកាសបុណ្យចូលឆ្នាំថ្មីច្រើនជាងរាល់ឆ្នាំ

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 11 April, 2018

ប៉ោយប៉ែត ៖ ពលករខ្មែរជាច្រើនកំពុងតែវិលត្រឡប់ពីប្រទេសថៃចូលមកប្រទេសរបស់ខ្លួនវិញតាមច្រកទ្វារព្រំដែនអន្តជាតិប៉ោយប៉ែតដើម្បីទៅជួបជុំបងប្អូននៅរដូវសង្រ្កានឆ្នាំថ្មីខាងមុខនេះ។ នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត នៅព្រឹកថ្ងៃទី១០ខែមេសាឆ្នាំ២០១៨នេះ គេសង្កេតឃើញថា ចាប់ពីគល់ស្ពានមិត្តកម្ពុជា ថៃ ឃើញមានពលករខ្មែរជាច្រើននៅទឹកដីថៃ ឈរជាជួរដើម្បី បំពេញបែបបទឆ្លងចូលប្រទេសកម្ពុជាវិញមានចំនួនច្រើនជាងបណ្តាឆ្នាំមុនៗក្នុងមួយថ្ងៃមិនក្រោម១.០០០នាក់ទេ ស្របពេលសេចក្តីប្រកាសរួមរវាងរាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលថៃដែលបានឯកភាពគ្នាមិនឱ្យមានការយកប្រាក់ពីពលករខ្មែរ និងសម្របសម្រួលបង្កលក្ខណៈងាយស្រួលឱ្យដល់ពលករខ្មែរបានចាកចេញមកលេងស្រុកកំណើតនៅថ្ងៃបុណ្យចូលឆ្នាំឱ្យបានល្អផងដែរ។ចាប់តាំងពីថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៨ មកនេះ មានការកកស្ទះជាខ្លាំង ដោយសារតែរថយន្តតាក់ស៊ី រទេះលក់ផ្លែឈើ រទេះដឹកឥវ៉ាន់ពលករ និងរថយន្តដែលនៅតាមបណ្តាខេត្តមកចតតាមចិញ្ចើមផ្លូវដើម្បីរងចាំដឹកសាច់ញ្ញាតផងដែរ ទើបមានការកកស្ទះ ទោះមានការរៀបចំពីសំណាក់អាជ្ញាធរក្រុងនិងកម្លាំងសមត្ថកិច្ចក៏ដោយ ។

ម្យ៉ាងទៀតបើទោះមានសេចក្តីប្រកាស់រួមគ្នារវាង រាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលថៃ ដែលបានឯកភាពគ្នាមិនឱ្យមានការយកប្រាក់ពីពលករខ្មែរ និងសម្របសម្រួលបង្កលក្ខណៈងាយស្រួលឱ្យដល់ពលករយ៉ាងណាក៏ដោយ

មានពលករមួយចំនួនតូចនៅតែចាញ់បោកមេខ្យល់អូរទាញនាំចូលមកកម្ពុជាវិញតាមច្រករបៀងដើម១០០ ឋិតក្នុងភូមិបន្ទាយមានរិទ្ធ ឃុំគោរមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចំងាយពីច្រកតំបន់បឹងត្រកួនប្រហែល១០០ម៉ែត្រជាថ្នូរនឹងការយកលុយដដែល។

ដោយឡែកកម្មករអូរទេះម្នាក់នៅច្រកទ្វារប៉ោយប៉ែតឈ្មោះ យឿន សួ ភេទប្រុស អាយុ៤២ឆ្នាំ បានរៀបរាប់ឲ្យដឹងថា ចូលឆ្នាំៗនេះមានពលករខ្មែរ វិលត្រឡប់មកស្រុកយ៉ាងច្រើនធ្វើឲ្យកម្មករអូសរទេះ ស៊ីឈ្នួលដឹកសម្ភារៈផ្សេងៗរកចំណូលបានក្នុងមួយថ្ងៃ រហូតជាង១០០០បាត ជឿថាមុននឹងចប់ចូលឆ្នាំ ក្រុមកម្មករអូសរទេះ អាចរកចំណូលបានច្រើនបង្គួរ។

កម្មករអូររទេះបានលើកឡើងថា ពួកគាត់បានរកប្រាក់ចំណូលបានច្រើនរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះព្រោះថា ការរកចំណូលបាននេះដោយសារតែពួកគាត់ដឹកឥវ៉ាន់របស់ពលករខ្មែរយើងដែលវិលពីប្រទេសថៃ មកតាមច្រកទ្វារអន្តជាតិឆ្នាំនេះ មានការកើនឡើងជាងរាល់ឆ្នាំ។

ជុំវិញការពលករខ្មែរដែលវិលត្រលប់ពីប្រទេសជិតខាងក្នុងរដូវសង្ក្រានចូលឆ្នាំខាងមុខនេះលោក ស៊ឹម សំអាត ប្រធានស្នាក់ការអន្តោប្រវេសន៍ប្រចាំច្រកទ្វារព្រំដែនអន្តជាតិប៉ោយប៉ែត មិនអាចសុំការអធិប្បាយបានទេ ទូរសព្ទ័របស់លោកចុចចូលគ្មានអ្នកទទួល៕

## ទិដ្ឋភាពពលករខ្មែរសម្រុកមកស្រុកកំណើត ណែនណន់នៅព្រលានយន្តហោះភ្នំពេញយប់មិញ

http://news.sabay.com.kh/ ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៨ ម៉ោង 10:25

ពលករខ្មែរនៅកូរ៉េរាប់រយនាក់ សម្រុកមកលេងស្រុកកំណើតរបស់ខ្លួន ក្រោយកន្លែងការងារបានអនុញ្ញាតឲ្យសម្រាករយៈពេលយូររហូតដល់មួយខែពេញ ដើម្បីជួបជុំគ្រួសារនាឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរខាងមុខ ។ នៅយប់ថ្ងៃទី ១០ មេសា វេលាម៉ោង ១១ ក្រុមគ្រួសារបានឈររង់ចាំបងប្អូនពលករខ្មែរនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដោយទឹកមុខញញឹមពព្រាយ ខ្លះយំផង អោបផង ទម្រាំបានជួបសាច់ញាតិម្តងៗ។

គួររំឭកថា ពលករខ្មែរស្របច្បាប់ និងមិនស្របច្បាប់ ធ្វើការនៅកូរ៉េទទួលបានប្រាក់ខែយ៉ាងតិច ១ ២០០ដុល្លារក្នុង១ខែ ហើយពួកគាត់តែងតែផ្ញើប្រាក់ទាំងនេះមកស្រុកកំណើតវិញ ក្នុងម្នាក់ៗ មិនតិចជាង៨០០ ទៅ ១០០០ដុល្លារឡើយ។ បើគិតពីតួលេខនេះ ចំនួនទឹកប្រាក់ដែលពលករខ្មែរត្រូវផ្ញើមកស្រុកកំណើត មានប្រមាណជាង ៣០០លានដុល្លារក្នុងមួយឆ្នាំ៕ អត្ថបទ៖ ស៊ិន សារ៉េត

## ១សប្តាហ៍ ពលករចេញពីថៃ តាមច្រកទ្វារអន្តរជាតិដូង មកលេងបុណ្យចូលឆ្នាំ ជាង ៣ម៉ឺននាក់

https://www.dap-news.com/kh/ ព្រហស្បតិ៍, ១២ មេសា ២០១៨ 10:08 ដោយ: រិទ្ធិ ជ័យ ID:112

បាត់ដំបង៖ លោក មិន លីដាហ្សាណូ នាយរងប៉ុស្តិ៍ច្រកទ្វារអន្តរជាតិដូង (ឡែម) ស្ថិតនៅស្រុក កំរៀង ខេត្តបាត់ដំបង បានឲ្យដឹងនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ថា មានពលករខ្មែរ ចេញតាម ច្រកនេះ ក្នុងមួយថ្ងៃប្រមាណជាង ២០០០នាក់ និងថ្ងៃខ្លះឡើងដល់ជាង៦០០០នាក់ ដោយចាប់ពីថ្ងៃទី៥ ដល់ទី១១ ខែមេសា មានពលករចេញតាមច្រកទ្វារអន្តរជាតិដូងចំនួន ៣៤ ៩២១នាក់ បើធៀបនឹងឆ្នាំមុនមានចំនួនច្រើនជាង ។ លោកនាយរងប៉ុស្តិ៍បានបន្តថា "ការចេញពីថៃមកខ្មែរច្រើន តាមច្រកទ្វារអន្តរជាតិដូង ដោយសារសមត្ថកិច្ចប្រចាំច្រកនេះទាំងអស់ បានជួយសម្រួលឲ្យពួកគាត់ ចេញទៅផ្ទះស្រួល ដូចជាការបំពេញបែបបទជាដើមបានលឿន ណាមួយពួកគាត់រកប្រាក់បានច្រើនហើយក៏នាំគ្នាសម្រុកមកលេងពេលបុណ្យចូលឆ្នាំតែម្តង" ។

គួរបញ្ជាក់ថា ច្រកទ្វារអន្តរជាតិដូង ជាច្រកព្រំដែនជាប់នឹងប្រទេសថៃ ដោយច្រកនេះ ជាមធ្យមក្នុងមួយថ្ងៃៗមានប្រជាពលរដ្ឋខ្មែរ និងបរទេសរាប់រយនាក់ឆ្លងកាត់ក្នុងគោលបំណងទៅរកការងារធ្វើ ធ្វើពាណិជ្ជកម្ម និងទេសចរណ៍

ជាដើម។ សម្រាប់ឆ្នាំ២០១៧កន្លងទៅ តាមច្រកព្រំដែននីមួយៗកម្ពុជា ថៃ មានប្រជាពលរដ្ឋខ្មែរ និងបរទេសបានឆ្លងកាត់ជាង ៥លាននាក់ ៕

**អាជ្ញាធរឥណ្ឌូណេស៊ី កំពុងស៊ើបអង្កេត ករណីទូកនេសាទមួយ ដែលមានប្រើប្រាស់ទង់ជាតិកម្ពុជា**

https://www.rfa.org/khmer/news/ ដោយ ម៉ៅ សុជានី 2018-04-11

អាជ្ញាធរឥណ្ឌូណេស៊ីកំពុងស៊ើបអង្កេតករណីទូកនេសាទមួយ ដែលមានផ្ទុកទាសករនេសាទឥណ្ឌូណេស៊ី ចំនួន ១៤នាក់ កាលពីសប្តាហ៍មុន ដែលមានប្រើប្រាស់ទង់ជាតិកម្ពុជា។ រដ្ឋមន្ត្រីក្រសួងនាវាចរណ៍ និងនេសាទ អ្នកស្រី សូស៊ី ពុដហ្ស៊ីអាស ទុយទី (Susi Pudjiastuti) ត្រូវបានភ្នាក់ងារពត៌មាន អេភី ដកស្រង់សំដីថា កងនាវាឥណ្ឌូណេស៊ី បានស្ទាក់ចាប់ទូកនេសាទនេះ នៅចម្ងាយ ៦០គីឡូម៉ែត្រពីកោះ វេ (Weh) ក្នុងខេត្តអាចេះ (Aceh) កាលពីថ្ងៃសុក្រសប្តាហ៍មុន។ អ្នកស្រី Susi បន្តថា ក្នុងទូកនេសាទខុសច្បាប់នេះ គេបានរកឃើញជនជាតិរុស្ស៊ី ៦នាក់ ក្នុងនោះនាយនាវិកម្នាក់ និង ១៤នាក់ផ្សេងទៀតជាជនជាតិឥណ្ឌូណេស៊ី ដែលគេជឿជាក់ថា ពួកគេត្រូវបានជួញដូរពលកម្មរាប់សិបឆ្នាំមកហើយ ដោយពុំទទួលបានប្រាក់កម្រៃ។ សមត្ថកិច្ចឥណ្ឌូណេស៊ី ឲ្យដឹងថា ម្ចាស់ទូកនេសាទនេះ ពុំមានលិខិតសំគាល់ខ្លួនត្រឹមត្រូវឡើយ និងបានប្រើប្រាស់ទង់ជាតិក្លែងក្លាយពីប្រទេសជាច្រើន ក្នុងនោះរួមមាន ទង់ជាតិកម្ពុជា ឥណ្ឌូណេស៊ី ជប៉ុន កូរ៉េខាងត្បូង និងសេរ៉ាឡេអូន ជាដើម៕

**ថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០១៨**

**ស្ថានតំណាងកម្ពុជា អន្តរាគមន៍ជួយពលរដ្ឋខ្មែរ ៣០នាក់**

https://www.dap-news.com/kh/ ព្រហស្បតិ៍, ១២ មេសា ២០១៨ 14:53 ដោយ: ដើមអម្ពិល ID:119

**ភ្នំពេញ៖** ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅប្រទេសចំនួន៣ ក្នុងមានម៉ាឡេស៊ី វៀតណាម និងថៃ បានអន្តរាគមន៍ ជួយពលរដ្ឋខ្មែរចំនួន ៣០នាក់ ឲ្យបានវិលត្រឡប់មកស្រុកកំណើតវិញ ។ យោងតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រសួងការបរទេសខ្មែរ នៅថ្ងៃទី១២ មេសានេះ បានឲ្យដឹងថា ស្ថានទូតដែលបានអន្តរាគមន៍ ជួយពលរដ្ឋខ្មែររួមមាន៖

ទី១. ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី បានសហការ ជាមួយអាជ្ញាធរ មានសមត្ថកិច្ច របស់ ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំ មាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ ចំនួន១២នាក់ ក្នុងនោះពលករ មានចំនួន៣នាក់ និងពលការិនី៧នាក់ ដែល បានទៅ ធ្វើការ ដោយខុសច្បាប់ នៅប្រទេសម៉ាឡេស៊ី និង២នាក់ ទៀតជាកុមារ។ ពលរដ្ឋទាំង១២នាក់ នោះបានមកដល់កម្ពុជា វិញ ជាបន្តបន្ទាប់ ចន្លោះ ពីថ្ងៃទី៣១ ខែមីនា ដល់ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៨ ។

ទី២. ស្ថានអគ្គ កុងស៊ុល កម្ពុជា ប្រចាំទីក្រុងហូជីមិញ បានសហការជាមួយ អាជ្ញាធរ វៀតណាម រៀបចំ មាតុភូមិ និវត្តន៍របស់ ពលរដ្ឋខ្មែរ១៤នាក់ (ក្នុងនោះកុមារ មានចំនួន១១នាក់) មានអាយុចន្លោះ ពី២ឆ្នាំ ដល់ ៦៧ឆ្នាំ មកពីខេត្ត ស្វាយរៀង ដែលចូល ទៅស្នាក់នៅនិង ប្រកប របរ លក់ ឆ្នោតដោយខុសច្បាប់ នៅក្នុង ប្រទេសវៀតណាម។ អាជ្ញាធរ វៀតណាម បានរៀបចំ អោយពលរដ្ឋខ្មែរ ស្នាក់ នៅ បណ្តោះ អាសន្ន ក្នុង មជ្ឈម ណ្ឌល គាំពារ សង្គមក្នុង ទីក្រុង ហូជីមិញ មុនពេលបញ្ជូនមក ស្ថាន អគ្គកុងស៊ុល។ ស្ថានអគ្គកុងស៊ុល បានជូនពលរដ្ឋទាំង១៤នាក់ មកកម្ពុជាវិញ នៅថ្ងៃទី ៩ ខែមេសា ឆ្នាំ២០១៨ តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត ដើម្បី ប្រគល់ ជូនអាជ្ញាធរកម្ពុជា ចាត់ចែង បញ្ជូនបន្ត ទៅស្រុកកំណើត។

ទី៣. ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំ ប្រទេសថៃ រួមនឹងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ បានសហការជាមួយ អាជ្ញាធរថៃ រៀបចំបញ្ជូនកុមារីចំនួន៤នាក់ មានអាយុចន្លោះពី៣ឆ្នាំដល់១៣ឆ្នាំ ដែល ទទួល រងគ្រោះ ដោយការ ជួញដូរ មនុស្ស ត្រឡប់មកកម្ពុជាវិញតាមច្រកអន្តរជាតិប៉ោយប៉ែត កាលពីថ្ងៃទី២២ ខែ មីនា ឆ្នាំ ២០១៨។

ផ្អែកតាមអនុស្សរណៈរវាងរាជរដ្ឋាភិបាលប្រទេសទាំងពីរ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងការ ប្រឆាំងនឹងការជួញដូរកុមារនិងស្ត្រី ហើយនិងការជួយដល់ជនរងគ្រោះដោយការជួញដូរ ក្រសួងអភិវឌ្ឍន៍ សង្គមនិងសន្តិសុខមនុស្សរបស់ថៃ បានជួយកុមារទាំង៤នាក់នេះ ដែលរងគ្រោះដោយការជួញដូរ និងបាន រក្សាទុកនៅមជ្ឈមណ្ឌលគាំពារសុខុមាលភាពសម្រាប់ជនរងគ្រោះដោយការជួញដូរ ហើយបានជូនព័ត៌មាន ទៅស្ថានទូតកម្ពុជានៅទីក្រុងបាងកកដើម្បីរៀបចំមាតុភូមិនិវត្តន៍ ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
-------

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
-------

**ស្ថានតំណាងកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរ៣០នាក់**

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន**១២នាក់** ក្នុងនោះពលករមានចំនួន៣នាក់ និងពលការិនី៧នាក់ ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី និង២នាក់ទៀតជាកុមារ។ ពលរដ្ឋទាំង១២នាក់នោះ បានមកដល់កម្ពុជាវិញ ជាបន្តបន្ទាប់ ចន្លោះពីថ្ងៃទី**៣១ ខែមីនា** ដល់ថ្ងៃទី**០៩** ខែ **មេសា ឆ្នាំ២០១៨** ។

២. ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុង**ហូជីមិញ** បានសហការជាមួយអាជ្ញាធរវៀតណាម រៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ**១៤នាក់** (ក្នុងនោះកុមារមានចំនួន១១នាក់) មានអាយុចន្លោះពី២ឆ្នាំដល់៦៧ឆ្នាំ មកពីខេត្តស្វាយរៀង ដែលចូលទៅស្នាក់នៅនិងប្រកបរបរលក់ឆ្នោតដោយខុសច្បាប់នៅក្នុងប្រទេសវៀតណាម។ អាជ្ញាធរវៀតណាម បានរៀបចំអោយពលរដ្ឋខ្មែរស្នាក់នៅបណ្តោះអាសន្នក្នុងមជ្ឈមណ្ឌលគាំពារសង្គមក្នុងទីក្រុងហូជីមិញ មុនពេលបញ្ជូនមកស្ថានអគ្គកុងស៊ុល។

ស្ថានអគ្គកុងស៊ុល បានជូនពលរដ្ឋទាំង១៤នាក់ មកកម្ពុជាវិញ នៅថ្ងៃទី**០៩** ខែ **មេសា ឆ្នាំ ២០១៨** តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត ដើម្បីប្រគល់ជូនអាជ្ញាធរកម្ពុជា ចាត់ចែងបញ្ជូនបន្តទៅស្រុកកំណើត។

៣. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ថៃ** រួមនឹងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ បានសហការជាមួយអាជ្ញាធរថៃ រៀបចំបញ្ជូនកុមារីចំនួន**៤នាក់** មានអាយុចន្លោះពី៣ឆ្នាំដល់១៣ឆ្នាំ ដែលទទួលរងគ្រោះដោយការជួញដូរមនុស្ស ត្រឡប់មកកម្ពុជាវិញតាមច្រកអន្តរជាតិប៉ោយប៉ែត កាលពីថ្ងៃទី**២២** ខែ **មីនា ឆ្នាំ២០១៨**។

ផ្អែកតាមអនុស្សរណៈរវាងរាជរដ្ឋាភិបាលប្រទេសទាំងពីរ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងការប្រឆាំងនឹងការជួញដូរកុមារនិងស្ត្រី ហើយនិងការជួយដល់ជនរងគ្រោះដោយការជួញដូរ ក្រសួងអភិវឌ្ឍន៍សង្គមនិងសន្តិសុខមនុស្សរបស់ថៃ បានជួយកុមារទាំង៤នាក់នេះ ដែលរងគ្រោះដោយការជួញដូរ និងបានរក្សាទុកនៅមជ្ឈមណ្ឌលគាំពារសុខុមាលភាពសម្រាប់ជនរងគ្រោះដោយការជួញដូរ ហើយបានជូនព័ត៌មានទៅស្ថានទូតកម្ពុជានៅទីក្រុងបាងកក ដើម្បីរៀបចំមាតុភូមិនិវត្តន៍។

ថ្ងៃ ព្រហស្បតិ៍ ១២រោច ខែ ចេត្រ ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១
ភ្នំពេញ, ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៨
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ក្រសួងការងារ ប្រកាស ចាត់វិធានការតាមផ្លូវច្បាប់ចំពោះ ក្រុមហ៊ុន១ ដែល ជ្រើសរើសពលករដោយខុសច្បាប់

http://peoplenews.asia/ ដោយ ៖ សុខ សាន្ត ថ្ងៃទី14 ខែ04 ឆ្នាំ2018 ម៉ោង 8:23 AM

ភ្នំពេញ៖ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រកាសថាខ្លួននិងសហការជាមួយ អាជ្ញាធរមានសមត្ថកិច្ច រៀបចំសំណុំឯកសារប្តឹងក្រុមហ៊ុន ស៊ី ជេ លេប័រ ស៊ីបផ្លាយ (CJ LABOUR SUPPLY CO., LTD)ដើម្បីចាត់វិធានការទៅតាមនីតិវិធីច្បាប់ជាធរមាន បន្ទាប់ពី ក្រុមហ៊ុន ស៊ី ជេ លេប័រ ស៊ីបផ្លាយបាននិងកំពុងឆបោកសាធារណជន ដោយក្លែងបន្លំប្រកាសអនុញ្ញាតរបស់ក្រសួងការងារ ដើម្បីធ្វើជាទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់។

យោងតាមសេចក្តីប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី១២មេសា បានឲ្យដឹងថា ក្រុមហ៊ុន ស៊ី ជេ លេប័រ ស៊ីបផ្លាយ (CJ LABOUR SUPPLY CO., LTD) បាននិងកំពុងឆបោកសាធារណជន ដោយក្លែង

បន្លំប្រកាសអនុញ្ញាតរបស់ក្រសួងការងារ ដើម្បីធ្វើជាទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់។ក្នុងសេចក្តីប្រកាសដដែល បញ្ជាក់ថា ក្រសួងមិនបានផ្តល់អាជ្ញាប័ណ្ណ និងអនុញ្ញាតឲ្យក្រុមហ៊ុនខាងលើ ជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ថៃ គូវ៉ែត តំបន់រដ្ឋបាលពិសេសហុងកុង និងជប៉ុននោះទេ។ ពាក់ព័ន្ធនឹងករណីនេះ ក្រសួងបាននិងកំពុងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច រៀបចំសំណុំឯកសារប្តឹងទៅតុលាការ ដើម្បីចាត់វិធានការទៅតាមនីតិវិធីច្បាប់ជាធរមាន។ ក្រុមហ៊ុន ស៊ី ជេ លេប័រ សឹបផ្លាយ (CJ LABOUR SUPPLY CO., LTD) មានទីតាំងស្ថិតនៅអគារលេខ១៣ ផ្លូវលេខ២៧១ ក្រុមទី៧ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ករណីឆបោករបស់ក្រុមហ៊ុន ស៊ី ជេ លេប័រ សឹបផ្លាយ**
(CJ LABOUR SUPPLY CO.,LTD)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា ក្រសួងមិនបានផ្តល់អាជ្ញាប័ណ្ណ និងអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី ជេ លេប័រ សឹបផ្លាយ(CJ LABOUR SUPPLY CO., LTD) ដែលមានទីស្នាក់ការ អគារលេខ១៣ ផ្លូវលេខ២៧១ ក្រុមទី៧ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ព្រះរាជាណាចក្រថៃឡង់ដ៍ ប្រទេសគូវ៉ែត តំបន់រដ្ឋបាលពិសេសហុងកុង និងទៅធ្វើកម្មសិក្សាការីនៅប្រទេសជប៉ុននោះទេ។

ក្រុមហ៊ុន ស៊ី ជេ លេប័រ សឹបផ្លាយ(CJ LABOUR SUPPLY CO., LTD) បាននិងកំពុងឆបោកសាធារណជន ដោយបានក្លែងបន្លំប្រកាសអនុញ្ញាតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើជាទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ ដោយបានធ្វើការជ្រើសរើសពលករឱ្យទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុង។ ក្នុងករណីនេះ ក្រសួងបាននិងកំពុងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច រៀបចំសំណុំឯកសារប្តឹងទៅតុលាការ ដើម្បីចាត់វិធានការទៅតាមនីតិវិធីច្បាប់ជាធរមាន។

ក្រសួង សូមធ្វើការក្រើនរំលឹកដល់សាធារណជន ដែលមានបំណងទៅធ្វើការនៅក្រៅប្រទេសឱ្យមានការប្រុងប្រយ័ត្នខ្ពស់ មុនពេលសម្រេចចិត្តចុះឈ្មោះទៅធ្វើការតាមរយៈក្រុមហ៊ុនណាមួយ ត្រូវពិនិត្យលើបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ដែលអនុញ្ញាតដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សម្រាប់ព័ត៌មានបន្ថែម សូមមេត្តាទំនាក់ទំនងតាមទូរស័ព្ទលេខ ០២៣ ៨៨០ ៤៧៤ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំង២៥ រាជធានី-ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ ឬពិនិត្យមើលបញ្ជីឈ្មោះក្រុមហ៊ុន ដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨

## គ្រឡាប់រថយន្តឈ្នួល,ដឹកពលករខ្មែរវិលត្រឡប់ទៅស្រុកកំណើត បណ្តាលមនុស្ស04នាក់របួស

http://www.pheaktraprak.com April 12, 2018

មានករណីគ្រោះថ្នាក់ក្រឡាប់រថយន្តឈ្នួលដឹកពលករខ្មែរចំនួន13នាក់ វិលត្រឡប់ទៅលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំថ្មីបណ្តាលមានមនុស្សចំនួន 04នាក់ រងរបួសធ្ងន់។ ហេតុការណ៍នេះបានកើតឡើងកាលពីវេលាម៉ោង03ទៀបភ្លឺនាថ្ងៃព្រហស្បតិ៍ ទី12 ខែមេសា ឆ្នាំ2018 នៅត្រង់ចំណុចផ្លូវជាតិ(បានបឹង-ក្លែង) ស្ថិតនៅក្នុងស្រុកវាំងចាន់ ខេត្តរ៉ាក់យ៉ង ប្រទេសថៃ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នេះ បណ្តាលឲ្យមានមនុស្សចំនួន 04នាក់ រងរបួសធ្ងន់ ក្នុងនោះមានស្ត្រីពោះធំ ៦ខែរងរបួសផងផងដែរ បច្ចុប្បន្នជនរងគ្រោះទាំងអស់ត្រូវបានសមត្ថកិច្ចថៃបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យវាំងចាន់ ខេត្តរ៉ាក់យ៉ង។ យោងតាមប្រភពពីអ្នកបើកបររថយន្តកើតហេតុបានរៀបរាប់ប្រាប់អោយដឹងថា រថយន្តខាងលើបានដឹកពលករកម្ពុជាចំនួន13នាក់ ចេញដំណើរមកពីខេត្តសាមុតសាខន ឆ្ពោះដំណើរទៅកាន់ច្រកព្រំដែនបានទ្បែមខេត្តចាន់បុរី ដើម្បីវិលត្រឡប់ទៅលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ក៏ប៉ុន្តែមកដល់ត្រង់ចំណុចកើតហេតុបាន វ៉ាក់អើរជាមួយរថយន្ត(សិបឡរ)កំពុងឈប់ក្បែរចិញ្ចើមផ្លូវ អ្នកបើកបររថយន្តបានកាច់ចង្កូតគេចធ្វើឲ្យរថយន្តក្រឡាប់តែម្តង។

## ថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៨
## មកតាមណាប្រាកដជាទៅតាមនោះវិញ

https://www.facebook.com/matemohachunnews/ **សារព័ត៌មាន មតិមហាជន 16/04/2018**

បន្ទាយមានជ័យ៖ មុនពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីយ៍ជាតិពលករវិលត្រឡប់ពីថៃរាប់ម៉ឺននាក់តាមបណ្តាច្រកទ្វារអន្តរជាតិសំខាន់ៗ តាមខេត្តជាប់ព្រំដែននៃទិសពាយ័ព្យ។ ប៉ុន្តែគេក៏សង្កេតឃើញដែរថាពលករមួយចំនួនតូចក៏បានលួចឆ្លងដែនត្រឡប់មកវិញតាមច្រករបៀងខុសច្បាប់ ដោយសារតែចាញ់ឃោសនាអូសទាញរបស់មេខ្យល់ដែរបើទោះជារាជរដ្ឋាភិបាលនៃប្រទេសទាំង2 កម្ពុជា-ថៃ សហការណ៍គ្នាសម្រួលដល់ពួកគេឲ្យវិលត្រឡប់តាមច្រកទ្វារអន្តរជាតិដោយមិនឲ្យយកប្រាក់កំដោយ។ ពលករខ្លះខ្វះឯកសារច្បាប់តែឆ្លងព្រំដែនអន្តរជាតិបានដោយគ្រាន់តែបង់លុយម្នាក់500 ទៅ600បាត ឲ្យពួកមេខ្យល់ដែលត្រូវរ៉ូវគ្នាជាមួយភាគីថៃ។ ដោយឡែកពលករខ្លះវិលតាមច្រករបៀងជ្រោកក្រោមរូបភាពអ្នកចេញចូលទិញឥវ៉ាន់នៅផ្សារណាត់លើទឹកដីថៃ ដោយគ្រាន់តែបង់ថ្លៃផ្លូវឆ្លងកាត់ឲ្យសមត្ថកិច្ចខ្មែរថៃ និងមេខ្យល់។ ច្រករបៀងចំបក់ឃុំបឹងបេង ស្រុកម៉ាឡៃ ក៏មិនតិចតួចដែរក្នុងមួយថ្ងៃៗរាប់រយនាក់។ ចំណែកច្រករបៀងខាងជើងច្រកតំបន់បឹងត្រកួនប្រហែលជាង100ម៉ែត្រ ក្នុងភូមិបន្ទាយមានឫទ្ធីឃុំគោករមៀត ស្រុកថ្មពួក សមត្ថកិច្ចបើកចំហរឲ្យចេញចូលយ៉ាងសេរី។ ករណីខាងលើនេះត្រូវបានអ្នកស្រុកយល់ថា ក្រោយពិធីបុណ្យចូលឆ្នាំថ្មីរួចពលករវិលត្រឡប់ទៅថៃវិញប្រាកដជាអ្នកមកស្របច្បាប់ និងទៅវិញតាមលក្ខណៈស្របច្បាប់ហើយ អ្នកវិលមកខុសច្បាប់តាមច្រករបៀងប្រាកដជានិងត្រឡប់ទៅវិញតាមច្រករបៀងត្រូវប៉ាន់អស់លោកសមត្ថកិច្ចមួយចំនួនជាក់ជាមិនខាន៕ ដោយមតិមហាជន

## ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី បានជំនួបពិភាក្សាការងារ និងចុះកិច្ចព្រមព្រៀងជាមួយលោកជំទាវ Kim Young Joo រដ្ឋមន្ត្រីក្រសួងមុខរបរនិងការងារ

http://mlvt.gov.kh/index. Monday, 16 April 2018 16:46 | Written by MLVT

នារសៀលថ្ងៃចន្ទ ២កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៨ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជំនួបពិភាក្សាការងារ និងចុះកិច្ចព្រម

ព្រៀងជាមួយលោកជំទាវ Kim Young Joo រដ្ឋមន្ត្រីក្រសួងមុខរបរនិងការងារ នៅទីស្តីការក្រសួងមុខរបរ និងការងារសាធារណរដ្ឋកូរ៉េ។

ក្នុងជំនួបនេះភាគីទាំងពីរបានសម្តែងនូវការរីករាយចំពោះកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរ ជាពិសេសកិច្ចសហការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបានពិភាក្សាគ្នាលើកិច្ចព្រមព្រៀងសម្រាប់កិច្ចសហប្រតិបត្តិការ(Arrangement for Cooperation) រវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា និងក្រសួងមុខរបរនិងការងារកូរ៉េ សម្រាប់គម្រោងស្តីពី "ការអភិវឌ្ឍប្រព័ន្ធសេវាការងារ និងព័ត៌មានទីផ្សារការងារនៅកម្ពុជា តាមអ៊ីនធើណេត-WorkNet" ដែលនឹងត្រូវអនុវត្តដោយទីភ្នាក់ងារជាតិ មុខរបរនិងការងារ(NEA) នៃព្រះរាជាណាចក្រកម្ពុជា និងភ្នាក់ងារសេវាព័ត៌មានការងារកូរ៉េ (KEIS) នៃសាធារណរដ្ឋកូរ៉េ។

គម្រោងនេះមានរយៈពេល ៤ឆ្នាំ និងមានគម្រោងថវិកាចំនួន ៣លាន ១សែនដុល្លារអាមេរិក ដោយអនុវត្តជា៣ដំណាក់កាល រួមមានៈ

-ទី១ ឆ្នាំ២០១៨ ការសិក្សាទៅវិញទៅមក អំពីប្រព័ន្ធផ្តល់សេវាការងារសាធារណៈនៅប្រទេសកម្ពុជា និងសាធារណរដ្ឋកូរ៉េ ថវិកា ២សែនដុល្លារ។

-ទី២ (២០១៩-២០២០) ការបំពាក់សម្ភារបរិក្ខាបច្ចេកទេស និងSoftware ដើម្បីបង្កើត ប្រព័ន្ធសេវាការងារ និងព័ត៌មានទីផ្សារ ការងារតាមអ៊ីនធើណេត-WorkNet ថវិកា ២លាន ៧សែនដុល្លារ។

-ទី៣ ឆ្នាំ២០២១ ការផ្ទេរចំណេះដឹងបច្ចេកទេស ការតាមដាន និងវាយតម្លៃ ថវិកា ២សែនដុល្លារ។ បន្ទាប់មកភាគីទាំងពីរក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការសម្រាប់គម្រោងស្តីពី "ការអភិវឌ្ឍប្រព័ន្ធសេវាការងារ និងព័ត៌មានទីផ្សារការងារនៅកម្ពុជា តាមអ៊ីនធើណេត-WorkNet" ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។

## ពលករឈប់សម្រាក់ការងារគ្មានមូលហេតុ,អាចនឹងត្រូវថៅកែបណ្តេញចេញពីការងារដោយមិនចាំបាច់បង់ប្រាក់សំណង.

http://www.pheaktraprak.com April 15, 2018

តើបងប្អូនពលករមានដឹងទេថា ក្នុងករណីឈប់សម្រាកអត់ធ្វើការបីថ្ងៃជាប់ៗគ្នា ដោយគ្មានមូលហេតុថៅកែអាចបញ្ឈប់ការងារ បងប្អូនបានដោយមិនចាំបាច់ចាយប្រាក់សំណងអ្វីទាំងអស់ដល់បងប្អូន។ យោងតាមព្រះរាជក្រឹត្យច្បាប់គាំពារពលករ ឆ្នាំ(ពស ២៥៤១) បានកំណត់ថា ក្នុងករណីពលករឈប់សម្រាកឬបោះបង់ការងាររយៈពេលបីថ្ងៃជាប់គ្នាទោះជាថ្ងៃឈប់សម្រាកឬក៏មិនមែនថ្ងៃឈប់សម្រាក ដោយគ្មានហេតុផលសមរម្យនោះ និយោជិតអាចមានសិទ្ធិបញ្ឈប់ការងារពលកររូបនោះអោយឈប់ធ្វើការបាន ដោយមិនចាំបាច់បង់ប្រាក់សំណង់អ្វីទាំងអស់។ "พระราชบัญญัติคุ้มครองแรงงาน พ.ศ.2541 ได้กำหนดกรณีลูกจ้างละทิ้งหน้าเป็นเวลา 3 วันทำงานติดต่อกันไม่ว่าจะมีวันหยุดคั่นหรือไม่ก็ตาม โดยไม่มีเหตุอันสมควรนายจ้างสามารถเลิกจ้างได้โดยไม่ต้องจ่ายค่าชดเชย"។

ដូច្នេះហើយសូមបងប្អូនពលករទាំងអស់មេត្តា អនុវត្តទៅតាមលក្ខខណ្ឌច្បាប់ការងារអោយបានត្រឹមត្រូវ។ ដូច្នេះហើយក្នុងថ្ងៃឈប់សម្រាកនាឱកាសថ្ងៃបុណ្យចូលឆ្នាំថ្មីនេះ សូមបងប្អូនពលករទាំងអស់ មេត្តាឈប់សម្រាក់ទៅតាមការកំណត់របស់ច្បាប់ការងារដែលថៅកែខ្លួនបានកំណត់ដើម្បីកុំឲ្យកើតមានបញ្ហាដូចដែលច្បាប់ខាងលើបានចែងប្រាប់។

## ពលករចាប់ផ្តើមសម្រុកនៅថៃវិញ នោះស្តៀងនៅតែបន្តធ្លាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៨ ម៉ោង ១២:២៥ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ បើតាមសេចក្តីរាយការណ៍បឋមបានឱ្យដឹងថា ខណៈពេលពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិមិនទាន់ទាំងចប់ស្រួលបួលផង ដោយកន្លែងខ្លះនៅបន្តលេងយ៉ាងសប្បាយរីករាយនោះ ចំណែកពលករខ្មែរចាប់

ផ្ដើមវិលត្រឡប់ទៅថៃវិញជាហូរហែតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត កាលពីនៅព្រឹកថ្ងៃទី17 ខែមេសានេះ។ ជាមួយគ្នានេះផងដែរ ព្រះភិរុណក៏បានបង្អុរមិនទាន់ឈប់ ស្ថិតលើភូមិសាស្ត្រក្រុងប៉ោយប៉ែត ប៉ុន្តែពុំមានខ្យល់កន្ត្រាក់ ដូចកាលពីរសៀលថ្ងៃទី15 មេសា ដែលកន្លងមកបានបំផ្លាញផ្ទះប្រជាពលរដ្ឋក្នុងស្រុក-ក្រុងចំនួន៣ ដូចជាក្រុងប៉ោយប៉ែត ស្រុកអូរជ្រៅ ស្រុកម៉ាឡៃ បណ្ដាលឱ្យខូចខាតអស់ផ្ទះប្រជាពលរដ្ឋ៥៧ខ្នងនោះទេ៕

## ប្រទេសអូស្ត្រាលីប្ដេជ្ញាប្រយុទ្ធប្រឆាំងទេសចរណ៍រូបភាពមណ្ឌលកុមារកំព្រា

https://www.rfa.org/khmer/ ដោយ មួង ណារ៉េត 2018-04-18

អ៊ីម៉ែលប្រទេសអូស្ត្រាលី ប្ដេជ្ញាប្រយុទ្ធប្រឆាំង ការជួញដូរតាមរបៀបទេសចរណ៍មណ្ឌលកុមារកំព្រា ដើម្បីទប់ស្កាត់ការជួយជួរកុមារ នៅប្រទេសអាស៊ីអាគ្នេយ៍។ តាមប្រភពសារព័ត៌មានអង់គ្លេស រ៉យទ័រ (Reuters) ដកស្រង់អង្គការសប្បុរសធម៌ឈ្មោះ លូម៉ូស៍ (Lumos) ដែលរកឃើញថា កុមារនៅប្រទេសជាច្រើន ដូចជាប្រទេសកម្ពុជា ត្រូវគេយកចេញពីផ្ទះ ដើម្បីឲ្យមកនៅមណ្ឌលកុមារកំព្រា គ្រាន់តែដើម្បីទាក់ទាញការបរិច្ចាគ និងឧបត្ថម្ភពីអ្នកស្ម័គ្រចិត្ត ពីប្រទេសអូស្ត្រាលី។ តាមប្រភពដដែល ការយកក្មេង មកដាក់មណ្ឌលកុមារកំព្រា ដើម្បីលុយបរិច្ចាគនេះ ត្រូវបានអង្គការសហប្រជាជាតិ និងក្រុមអង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គ្រោះកុមារផង (Save the Children) ផងព្រមានថា ជារូបភាពនៃទេសចរណ៍មណ្ឌលកុមារកំព្រា ដែលសកម្មជនសិទ្ធិកុមារ ចាត់ទុកថា ជាទម្រង់នៃទាសភាពសម័យទំនើប។

រដ្ឋមន្ត្រីការបរទេសអូស្ត្រាលី អ្នកស្រី ជូលី ប៊ីហ្សប (Julie Bishop) លើកឡើងថា អ្នកស្ម័គ្រចិត្តជាជនជាតិអូស្ត្រាលី ដែលភាគច្រើនជាយុវជន និងសិស្សសាលា បានផុងខ្លួនក្នុងការចូលរួម ក្នុងអំពើជួញដូរមនុស្ស ដោយមិនដឹងខ្លួន ព្រោះពួកគាត់ត្រូវចំណាយប្រាក់រហូតដល់ ២.០០០ ដុល្លារ ដើម្បីចូលរួមក្នុងការបរិច្ចាគ និងឧបត្ថម្ភមណ្ឌលកុមារកំព្រាទាំងនេះ។ អ្នកស្រី ជូលី ប៊ីហ្សប បញ្ជាក់បន្ថែមថា ប្រទេសអូស្ត្រាលី ត្រូវតែចាត់ការលុបបំបាត់បញ្ហានេះ។

អង្គការសហប្រជាជាតិ បានរកឃើញថា មណ្ឌលកុមារកំព្រានៅកម្ពុជា កើនចំនួនយ៉ាងច្រើន និង ក្លាយជាកន្លែងទាក់ទាញបំផុត សម្រាប់ទេសចរណ៍មណ្ឌលកុមារកំព្រា។ ប៉ុន្តែ កុមារដែលយកដាក់នៅមណ្ឌលទាំងនោះ ស្ទើរតែទាំងអស់ ជាក្មេងដែលនៅមានម្ដាយ ឬឪពុកនៅរស់នៅឡើយ។

ប្រទេសអូស្ត្រាលី ជាប្រទេសដែលមានអ្នកផ្ដល់ប្រាក់បរិច្ចាគ និងឧបត្ថម្ភច្រើនជាងគេ ទៅដល់មណ្ឌលកុមារកំព្រា ដែលគេយកមកធ្វើជាកន្លែងទេសចរណ៍បែបនេះ៕

## ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨

## ពលករនៅតែសម្រុកឆ្លងដែន តាមច្រករបៀងខុសច្បាប់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៨ ម៉ោង ២៣:៣៦ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរសម្រុកឆ្លងដែនទៅប្រទេសថៃតាមច្រករបៀងដោយខុសច្បាប់ ក្រោយពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ នាយប់ថ្ងៃទី១៨ មេសា២០១៨។ ច្រករបៀងដែលមានពលករ លួចឆ្លងដែនខាងលើស្ថិតក្នុងភូមិអូរល្ងា ឃុំបឹងបេង ស្រុកម៉ាឡៃ។ ពលករម្នាក់និយាយថា ការឆ្លងដែនតាមច្រករបៀងខុសច្បាប់ព្រោះ តែទៅតាមរយៈក្រុមហ៊ុនធ្វើលិខិតឆ្លងដែនមានការយឺតយ៉ាវ ទើបបង្ខំចិត្តឆ្លងដែនតាមច្រករបៀង។

ក្រុមពលករប្រាប់ថា ទៅប្រទេសថៃធ្វើការផ្សេងៗគ្នា ខ្លះធ្វើការរោងចក្រ និងភាគច្រើនទៅធ្វើជាកម្មករសំណង់ ហើយថាថ្លៃផ្លូវពីកម្ពុជាដល់គោលដៅម្នាក់ ២៥០០បាត(ប្រាក់ថៃ)នេះមិនទាន់គិតដល់សេវាជជុះនៅមាត់អូរព្រំដែនខ្មែរថៃនៅឡើយ។ គិតទៅពិបាកដែររាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ(កម្ពុជា-ថៃ) បានសម្របសម្រួលជើងធ្វើដំណើរ តាមច្រកទ្វារព្រំដែនអន្តរជាតិនានាមិនយកប្រាក់ក្ដី ក៏ពលករមួយចំនួននៅតែលួចឆ្លងដែនខុសច្បាប់ ដដែល ដោយសារចាញ់បោកការអូសទាញរបស់ពួកមេខ្យល់ឬ?៕

# ករណីសុំកូនៈឪពុកម្ដាយស្វែងរកជួបមុខកូនបន្ទាប់ពីបែកគ្នាជិត២០ឆ្នាំ

https://wmc.org.kh/ ថ្ងៃពុធ ទី១៨ ខែមេសា ឆ្នាំ២០១៨ ធូ វីរៈ

ភ្នំពេញៈឪពុកម្ដាយស្វះស្វែងរកពីអង្គការសង្គមស៊ីវិល ដើម្បីជួយអន្តរាគមន៍សុំជួបមុខកូនៗរបស់ពួកគាត់ក្រោយជនបរទេសសុំយកទៅចិញ្ចឹមរយៈពេលជិត២០ឆ្នាំ។ យ៉ាងតិចឪពុកម្ដាយប្រាំគ្រួសារបានមកស្វះស្វែងអន្តរាគមន៍ពីអង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ ដើម្បីឲ្យអន្តរាគមន៍អោយបានជួបមុខកូនដែលត្រូវបានជនបរទេសសុំយកទៅចិញ្ចឹមជាកូនចិញ្ចឹមកាលពី១៨ឆ្នាំមុន។ នេះបើយោងតាមសេចក្ដីថ្លែងការណ៍លីកាដូចេញផ្សាយនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៨នេះ។ សេចក្ដីថ្លែងការណ៍ដដែលបញ្ជាក់ថាឪពុកម្ដាយមានជីវភាពក្រីក្រទាំងនោះបានយកកូនរបស់ពួកគាត់មានអាយុចន្លោះពី៣ឆ្នាំ ទៅ ៩ឆ្នាំ ឲ្យរស់នៅក្នុងមណ្ឌលកុមារកំព្រាកាលពីឆ្នាំ២០០០។ ការសម្រេចចិត្តផ្ញើកូននៅមណ្ឌលកុមារកំព្រាដោយសារពួកគាត់ចង់ឲ្យកូនៗទទួលបានការសិក្សាល្អនិងព្យាបាលជំងឺឲ្យបានទៀតទាត់។

អ្នកស្រី នាង យន់ ជាគ្រួសារមួយក្នុងចំណោមគ្រួសារផ្សេងទៀតបានស្នើសុំ ជួបមុខកូនក្រោយពីបែកគ្នាអស់រយៈពេលជាង១០ឆ្នាំមកហើយ។ អ្នកស្រី នាង យន់ ឲ្យដឹងថាកូនច្បងរបស់អ្នកស្រីមានអាយុ១៨ឆ្នាំហើយគិតចាប់ពីឪពុកម្ដាយចិញ្ចឹមជាជនបរទេសយកទៅចិញ្ចឹមកាលពីឆ្នាំ ២០០៨។ អ្នកស្រី នាង យន់៖*«ចង់បានឲ្យតែជួបមុខកូន ឲ្យបានដំណឹងកូនវិញ ហើយឲ្យបានដឹកសុខទុក្ខកូនយ៉ាងណាហើយ។ ចង់ផ្ញើកូនថាកូនអើយដឹងដំណឹងម្ដាយឲ្យសូមឲ្យកូននឹងស្គាល់មុខម្ដាយផង មើលមុខម្ដាយផង។ម្ដាយកំពុងពិបាក នឹកកូនខ្លាំងអញ្ចឹងទៅ។សូមឲ្យកូនតបតជាមួយម្ដាយវិញខ្លះ ព្រោះខ្ញុំបៀមទុកយូហើយ។»*

របាយការណ៍អង្គការលីកាដូលើកឡើងថាឪពុកម្ដាយទាំងនោះមិនបានព្រមព្រៀងក្នុងការដំណើរការសុំកូនទេ។ ប៉ុន្តែនាយកមណ្ឌលកុមារកំព្រា និងអាជ្ញាធរក្នុងតំបន់ធ្វើឯកសារមិនពិតដោយអះអាងថាកុមារទាំងនោះកំព្រាឬឪពុកម្ដាយបោះបង់ចោល។

កាលពីឆ្នាំ ២០០៩ រាជរដ្ឋាភិបាលសម្រេចផ្អាកដំណើរការសុំកូនយកទៅចិញ្ចឹមពីប្រទេសកម្ពុជាហើយប្រទេសជាច្រើនក៏សម្រេចផ្អាកការសុំកូនពីកម្ពុជា ដោយសារភស្តុតាងជាច្រើនបានបង្ហាញថា កុមារកម្ពុជារស់នៅក្នុងមណ្ឌលកុមារកំព្រាមិនមែនជាកុមារកំព្រាទេ ប៉ុន្តែកុមារទាំងនោះត្រូវបានឪពុកម្ដាយយកទៅផ្ញើនៅមណ្ឌលកុមារកំព្រាឲ្យជួយចិញ្ចឹមដោយសារស្ថានភាពគ្រួសារក្រីក្រពេក។

លោក អំ សំអាត អ្នកគ្រប់គ្រងកម្មវិធីឃ្លាំមើលនិងការពារសិទ្ធិមនុស្សអង្គការលីកាដូ ឲ្យដឹងថាយ៉ាងតិចកុមារ១៤នាក់នៃ៥គ្រួសារមកស្នើសុំឲ្យអង្គការលីកាដូជួយអន្តរាគមន៍ជួបកូនៗរបស់ពួកគាត់។ក្នុងចំណោមកុមារទាំងអស់នេះត្រូវបានឪពុកម្ដាយចិញ្ចឹមយកទៅចិញ្ចឹមនៅសហរដ្ឋអាមេរិក ប្រទេសអូទ្រីស និងប្រទេសអ៊ីតាលី។ លោក អំ សំអាត បន្ថែមថា អង្គការរបស់លោកនឹងខិតខំប្រឹងប្រែងអន្តរាគមន៍ដើម្បីឲ្យឪពុកម្ដាយបង្កើនអាចជួបមុខកូន។លោក អំ សំអាត ៖*«វាពិបាកក្នុងការទំនាក់ទំនងការរកយន្តការឬវិធីសាស្ត្រឲ្យម្ដាយឪពុកនឹងកូនជួបគ្នា។ក៏ប៉ុន្តែអង្គការលីកាដូយើងនៅតែព្យាយាមទាក់ទងទៅប្រទេសទទួលក្មេងនិងហើយនិងអាជ្ញាធរកម្ពុជាធ្វើយ៉ាងណាឲ្យមានការទំនាក់ទំនងរវាងឪពុកម្ដាយនិងកូន។»*

បើយោងតាមទិន្នន័យរាជរដ្ឋាភិបាលកម្ពុជា កុមារខ្មែរមានចំនួន៣៦៩៦នាក់ ត្រូវបានឪពុកម្ដាយចិញ្ចឹមទទួលយកទៅរស់នៅក្រៅប្រទេសមុនពេលផ្អាកការសុំកូនចាប់ឆ្នាំ២០០៩។ យោងតាមទិន្នន័យរបស់រាជរដ្ឋាភិបាលកម្ពុជាកុមារចំនួន ៣៦៩៦នាក់ ត្រូវបានបញ្ជូនទៅរស់នៅបរទេស មុនពេលមានការផ្អាកដំណើរការសុំកូននេះ នៅឆ្នាំ២០០៩។ ចាប់តាំងពីការផ្អាកការសុំកូនរហូតមកដល់ពេលនេះអាជ្ញាធរកម្ពុជាមិនទាន់ចាត់វិធានការចំពោះអ្នកក្លែងឯកសារ ដើម្បីផ្ដន្ទាទោសនៅឡើយទេ។ ជនរងគ្រោះក៏ពុំទាន់ទទួលបានសំណងខូចខាតអ្វីដែរ។

អង្គការនេះសំណូមពរដោយទទូចឲ្យអាជ្ញាធរកម្ពុជា និងរដ្ឋាភិបាលបរទេសពាក់ព័ន្ធធ្វើការសុំទោសអ្នករងគ្រោះដោយដំណើរការសុំកូនបែបបទក្លែងបន្លំកាលពីអតីតកាល។អង្គការនេះសង្ឃឹមថារាជរដ្ឋាភិបាលនឹងមិនអនុញ្ញាតឲ្យមានការសុំកូនអន្តរប្រទេសជាថ្មីម្តងទៀតទេ៕

## ពលករខ្មែរសម្រុកចេញទៅប្រទេសថៃវិញក្រោយពិធីបុណ្យចូលឆ្នាំបញ្ចប់

http://www.ppd-news.net/ 18-April-2018 / **ដោយ ៖ ម៉ាសុភាព**

**ខេត្តបន្ទាយមានជ័យ ៖** ក្រោយពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរឆ្នាំ២០១៨ ដែលមានរយៈពេល៣ថ្ងៃ ត្រូវបានបញ្ចប់ មានពលករខ្មែររាប់សិបនាក់ បាននិងកំពុងសម្រុកចេញទៅប្រទេសថៃវិញ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។លោក ពៅ ថាវុធ នាយរងការិយាល័យនគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត បានឲ្យដឹងកាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨ នេះថា ក្រោយថ្ងៃបុណ្យចូលឆ្នាំខ្មែរ បានបញ្ចប់ មានពលករខ្មែរស្របច្បាប់ជាច្រើននាក់ បានសម្រុកចេញ ទៅធ្វើការងារនៅប្រទេសថៃវិញ តាមរយៈការបែបបទដោយស្របច្បាប់ ហើយការធ្វើបែបបទចេញពីប្រទេសនេះ គឺមិនមានការបង់ប្រាក់កាក់អ្វីនោះទេ ពោលគឺបើកឲ្យប្រជាពលរដ្ឋទូរទៅមានឱកាសបំពេញឯកសារ ឫសំណុំបែបបទស្នើសុំផ្សេងៗ ដោយខ្លួនឯង ដែលវាខុសពី ពេលមុន ៗ ដោយមានជនខិលខូចមួយចំនួន បានលួចយកលុយក្រៅសេវា ជាថ្នូរនិងការបំពេញបែបបទ រត់ការឯកសារ ឬប្រថាប់ត្រា ដើម្បីបានលឿននិងរហ័សជាដើម ។ ហើយការលុបបំបាត់ ការយកលុយក្រៅសេវានេះ លោកបានចាប់ផ្តើមរឹតបន្តឹងតាំងមុនថ្ងៃចូលឆ្នាំមកម្លះយ៉ាងណាមិញ លោកនិងក្រុមមន្ត្រីរបស់លោកនឹងខិតខំបន្តសកម្មភាពនេះជាបន្តទៀត ។

គួរបញ្ជាក់ថា មូលហេតុដែលពលករខ្មែរទាំងនោះសម្រុកចេញទៅ ទាំងគង់ហុគបែបនេះ គឺដោយសារពួកគាត់ត្រូវប្រញាប់ទៅឲ្យទាន់ ពេលវេលាដែលគាត់បានសុំច្បាប់អនុញ្ញាត ពីថៅកែថៃ ហើយប្រសិនបើគាត់ទៅមិនទាន់តាមការកំណត់របស់ថៅកែថៃទេនោះ នោះពួកគាត់នឹងត្រូវកាត់លុយជាក់ជាមិនខាន ។ ដោយឡែក បើយោងតាមសេចក្តីរាយការណ៍ពីបន្ទាត់ព្រំដែន កម្ពុជាថៃ បានឲ្យដឹងថា ក្រៅពីការចេញដោយស្របច្បាប់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតនេះ ក៏មានពលករខ្មែររាប់សិបនាក់ផ្សេងទៀត បានលួចចេញពីកម្ពុជាទៅថៃ ដោយខុសច្បាប់ តាមច្រករបៀងនានាក្នុងភូមិសាស្ត្រនៃខេត្តបន្ទាយមានជ័យ ដោយមានការបើកដៃ ឃុបឃិតជាមួយកងកម្លាំងការពារព្រំដែនកម្ពុជាថៃ ៕

## ពលរដ្ឋខ្មែររាប់រយនាក់ សម្រុកធ្វើប័ណ្ណព្រំដែន ដើម្បីចេញទៅធ្វើការនៅប្រទេសថៃ

http://www.ann.com.kh/ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៨

ខេត្តបាត់ដំបង៖ ក្រោយពីថ្ងៃបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ បានបញ្ចប់ហើយនោះ នៅព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨នេះ មានពលរដ្ឋរាប់រយនាក់ បាននាំគ្នាសម្រុកមកធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃ នៅក្នុងបរិវេណសាលាខេត្តបាត់ដំបង ដើម្បីត្រលប់ទៅធ្វើការនៅប្រទេសថៃវិញ។

អ្នកនាង លី ហ្វា អាយុ៣៤ឆ្នាំ ដែលជាពលករខ្មែរម្នាក់ រស់នៅស្រុកឯកភ្នំ ខេត្តបាត់ដំបង បានប្រាប់ថា អ្នកនាងជាពលករខ្មែរម្នាក់ ដែលចេញចូលធ្វើការងារនៅប្រទេសថៃយូរឆ្នាំហើយ អ្នកនាងមកសាលាខេត្តថ្ងៃនេះ គឺដើម្បីទទួលយកប័ណ្ណព្រំដែនកម្ពុជា-ថៃ ដើម្បីចូលទៅធ្វើការងារបន្តនៅប្រទេសថៃវិញ ដោយស្របច្បាប់។ អ្នកនាងបន្តថា ការធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃ នេះ ខាងសាលាខេត្តតម្រូវអោយយក អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ សំបុត្រកំណើត និងរូបថត៤x៦ ចំនួន២សន្លឹក និងបង់ប្រាក់តែ២ម៉ឺនរៀលប៉ុណ្ណោះ ដែលមានសុពលភាពរយៈពេល២ឆ្នាំ និងអាចចេញចូលបានបីខេត្តជាប់ព្រំដែន រួមមាន៖ ខេត្តច័ន្ទបុរី ខេត្តត្រាត និងខេត្តស្រះកែង។

លោក សឿម ប៊ុនរិទ្ធី អភិបាលរងខេត្តបាត់ដំបង បានបញ្ជាក់ថា ចាប់ពីដើមខែមករា ថ្ងៃធ្វើដំបូងរហូតមកដល់ត្រឹមថ្ងៃទី១៩ ខែមេសា នេះ មានប្រជាពលរដ្ឋជាង៦ពាន់នាក់ហើយ ដែលបាននាំគ្នាមកធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃ នៅសាលាខេត្តបាត់ដំបង។ លោកបន្តថា ការធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃ នេះ ខាងសាលាខេត្តទទួលធ្វើចំពោះតែពលរដ្ឋរស់

នៅក្នុងខេត្តបាត់ដំបងតែប៉ុណ្ណោះ ដោយឡែកចំពោះពលរដ្ឋរស់នៅក្នុងខេត្តផ្សេងៗ ដែលអាចមកធ្វើបានលុះត្រាតែមានទីសំណាក់បញ្ជាក់ដោយអាជ្ញាធរមូលដ្ឋានជាមុនសិន៕ ដោយ៖ រៀម សាលី

## ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

## បម្រុងឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសជិតខាង សមត្ថកិច្ចឃាត់ជាង១០នាក់

http://nokorwatnews.com/ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៨

ប៉ោយប៉ែត៖ ពលករប្រុស ស្រីជាង១០នាក់បម្រុងឆ្លងដែនទៅនៅប្រទេសថៃខុសច្បាប់ត្រូវកម្លាំងនគរបាលការពារព្រំដែនគោក៨១៥ សហការជាមួយកម្លាំងយោធាសីករង ស្រុកម៉ាឡៃទប់ស្កាត់អប់រំឲ្យវិលត្រឡប់ទៅផ្ទះវិញកាលពីរសៀលថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨ នៅតាមបន្ទាត់ព្រំដែនកម្ពុជា ថៃ ឋិតក្នុងភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

នៅក្នុងប្រតិបត្តិការទប់ស្កាត់ពលករបម្រុងឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនោះ ដឹកនាំកម្លាំងដោយលោកអនុសេនីយ៍ទោ ប៊ុន គុន នាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោក៨១៥ រួមសហការកម្លាំងយោធាសីករង ស្រុកម៉ាឡៃចំនួន៧នាក់ ។ លោកអនុសេនីយ៍ទោ ប៊ុន គុន នាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោកបានប្រាប់ថា ដោយមានសេចក្តីរាយការពីពលរដ្ឋថា មានពលករប្រុស ស្រីចំនួន១២នាក់ក្នុងនោះ ស្រី២នាក់ ដែលពួកគាត់មកពីខេត្តបន្ទាយមានជ័ចំនួន៣នាក់ ខេត្តបាត់ដំបង២នាក់ និង ខេត្តព្រៃវែង ៧នាក់ បានដើរបម្រុងឆ្លងដែនពីភូមិខាងលើបម្រុងឆ្លងអូរព្រំដែនទៅប្រទេដថៃ ទើបលោកសហការជាមួយកម្លាំងយោធា ហៅពួកគាត់មកវិញដើម្បីធ្វើកំណត់ហេតុ និងណែនាំពីការឆ្លងដែនខុសច្បាប់ ។ លោកថា ការឆ្លងដែនតាមរយះមេខ្យចំពោះពលករទាំងអស់នោះ វាឈមទៅនឹងកត្តាច្រើនយ៉ាង ទី១គ្រោះថ្នាក់ដោយចាញ់បោករបស់មេខ្យល់ ដែលយកពួកគាត់ទៅលក់កម្លាំងឲ្យថៅកែ, ទី២ជិះរថយន្តពីព្រំដែនទៅកន្លែងធ្វើការនោះ មានផលលំបាក និងប្រកបដោយគ្រោះថ្នាក់ ព្រោះដេកពីលើគ្នា ពេលជិះរថយន្ត។ ព្រោះថាខុសច្បាប់មិនងាយស្រួលដូចស្របច្បាប់ ដូច្នេះគួរតែបងប្អូនងាកទៅរកឆ្លងដែនស្របច្បាប់ទើបមានលក្ខណៈល្អ ពេលមានបញ្ហាសមត្ថកិច្ចជំនាញងាយស្រួលស្រាវជ្រាវរកមុខសញ្ញា។

សមត្ថកិច្ចជួរមុខចំណុចកើតហេតុប្រាប់ថា ពលករប្រុស ស្រីជាង១០នាក់ ខាងលើ ក្រោយពីអប់រំបានឲ្យពួកគេធ្វើកិច្ចសន្យាបញ្ឈប់ឆ្លងដែនខុសច្បាប់ ព្រោះវាអាចប្រឈម បញ្ហាជាយថាហេតុគ្រប់ពេល បន្ទាប់មកបានឲ្យពលករទាំងនេះវិលត្រឡប់ទៅលំនៅឋានវិញរៀងៗខ្លួន ៕ វណ្ណា

## អាជ្ញាធរខេត្តបាត់ដំបង នឹងបើកទីតាំងធ្វើប័ណ្ណ ព្រំដែន កម្ពុជា-ថៃ ១កន្លែងទៀត

https://www.dap-news.com/kh/ ថ្ងៃសុក្រ, ២០ មេសា ២០១៨ 12:26 ដោយ: រិទ្ធិ ជ័យ ID:115

បាត់ដំបង៖ រដ្ឋបាលនៃសាលាខេត្តបាត់ដំបង នឹងបើកទីតាំងធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃ (ហ្វត់ឌីផាស់) ១កន្លែងទៀត នៅក្នុងស្រុកសំពៅលូន ដើម្បីបំពេញតម្រូវការពលរដ្ឋ ខណៈពួកគាត់កំពុងសម្រុក ទៅធ្វើនៅសាលាខេត្ត កាន់តែមានចំនួន ច្រើនឡើងនិងមានការកកស្ទះ ។

លោក សឿម ប៊ុនរិទ្ធិ អភិបាលរងខេត្តបាត់ដំបង បានមានប្រសាសន៍ថា ទីតាំងគ្រោងបើកបន្ថែម នៅស្រុកសំពៅលូននោះ ធ្វើនៅការិយាល័យច្រកចេញចូលតែមួយ ហើយបង្កភាពងាយស្រួលដល់ពលរដ្ឋ អាចទៅធ្វើនៅទីនោះបាន មិនចាំបាច់មកធ្វើដល់សាលាខេត្តទេ ។ លោកបន្តថា គម្រោងនេះ នឹងបើកនាពេលឆាប់ៗខាងមុខ ដោយបច្ចុប្បន្នរដ្ឋបាលខេត្តកំពុងរៀបចំឲ្យមន្ត្រីជំនាញ ទៅបណ្តុះបណ្តាលមន្ត្រីនៅស្រុកសំពៅលូនជាមុនសិន ទើបចូលធ្វើការងារនេះបាន ដោយមន្ត្រីទាំងអស់នោះ ត្រូវធ្វើការតាមប្រព័ន្ធកុំព្យូទ័រ ។ បន្ថែមពីលើនេះទៀត អភិបាលរងខេត្តថា មុននឹងអាចធ្វើប័ណ្ណនេះបាន ទាល់តែមានឯកសារ៣ គឺអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ និងសំបុត្រកំណើត ហើយចំណាយ ២០០០០រៀល ទើបអាចចូលទៅថៃ ត្រឹមខេត្តត្រាត ខេត្តច័ន្ទបុរី និងខេត្តស្រះកែវ មានសុពលភាពត្រឹម៧ថ្ងៃ ពេលតមិន

ចាំបាច់មកដល់សាលាខេត្តនោះទេអាចធ្វើតាមព្រំដែនបាន ហើយអាចប្រើប្រាស់បានចំនួន២ឆ្នាំ ។ លោក សឿម ប៊ុនរិទ្ធិ បានបញ្ជាក់ថា ប័ណ្ណព្រំដែនកម្ពុជា-ថៃនេះ ប្រើប្រាស់ខុសពីលិខិតឆ្លងដែន ព្រោះបើចូលតាមច្រកណា ត្រូវចេញមកវិញតាមច្រកនោះ មិនដូចលិខិតឆ្លងដែន បើជិះយន្តហោះទៅហើយអាចជិះរថយន្តចេញ តាមច្រកណាមួយក៏បាន ។

បើតាមប្រជាពលរដ្ឋ ដែលមកធ្វើប័ណ្ណនេះ បានលើកឡើងថាពួកគាត់សប្បាយចិត្ត ដែលរាជរដ្ឋាភិបាល បានសម្រួលឲ្យពួកគាត់ធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃនេះចំណាយថវិកាអស់តិចទោះបីជាមានរយៈពេលខ្លី និងអាចប្រើបានតាមខេត្តរបស់ប្រទេសថៃបានអនុញ្ញាត តែក៏បានជួយពួកគាត់ច្រើនដែរ ក្នុងការចូលទៅថៃ រកការងារ ឬធ្វើជំនួញអ្វីមួយ ។ គួរបញ្ជាក់ថា ពីថ្ងៃទី៧ ខែមករា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី១៩ ខែមេសា មានពលរដ្ឋមកធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃ ចំនួន ៦៤៥១នាក់ ៕

## ថៃចេញច្បាប់តម្រូវឲ្យទូកនេសាទមានលេខសំគាល់ ព្រោះហេតុផលពិសេសមួយ

http://news.sabay.com.kh/article/ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១៨ ម៉ោង 15:52

នាយកដ្ឋានជលផលថៃ បានតម្រូវឲ្យទូកនេសាទទាំងអស់លាបលេខកូតសំគាល់នៅចំហៀងទូកនីមួយៗឲ្យបានមុនបំណាច់ខែ ឧសភានេះ។ ប្រធាននាយកដ្ឋានជលផល លោក Adisorn Promthep និយាយថាច្បាប់នេះបានចូលជាធរមានកាលពីថ្ងៃទី ១មេសាក្រោយត្រូវបានផ្សព្វផ្សាយដោយ Royal Gazette។ ចំណាត់ការនេះ ធ្វើឡើងក្រោមហេតុផលដោះស្រាយបញ្ហានេសាទដោយខុសច្បាប់នានា។ លើសពីនេះទៀតវានឹងជួយឲ្យអាជ្ញាធរងាយស្រួលក្នុងការកំណត់មុខសញ្ញាទូកដែលអាចជាប់ពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្សផងដែរ។

គួរឲ្យដឹងថា លេខកូតសំគាល់នេះមានសំណុំតួអក្សរ និងលេខចំនួនបួន ហើយត្រូវលាបនៅចំហៀងទូកដើម្បីងាយស្រួលមើល។ ឧទាហរណ៍ដូចជាលេខកូត "T-M-245-B" ដោយអក្សរ T មានន័យថាទូកនេះត្រូវនេសាទតែក្នុងឈូងសមុទ្រថៃប៉ុណ្ណោះ ខណៈអក្សរ Mមានន័យថាទូកត្រូវមានទម្ងន់យ៉ាងតិច ៣០ តោន ប៉ុន្តែមិនត្រូវលើស ៦០ តោន ចំណែកឯលេខ 245 គឺជាលេខចុះបញ្ជីទូក ហើយអក្សរ Bមានន័យថាទូកនេះមានអួនផងដែរ៕

## ក្រសួងការងារ បិទក្រុមហ៊ុនជ្រើសរើសពលករគ្មានអាជ្ញាប័ណ្ណមួយ

https://www.postkhmer.com/ យន់ ស៊ីនាត and Daphne Chen | Publication date 20 April 2018 | 14:43 ICT

**ភ្នំពេញៈ** ក្រសួងការងារ បានបិទទីភ្នាក់ងារជ្រើសរើសពលករគ្មានអាជ្ញាប័ណ្ណមួយ ដែលកុហកថា ទទួលបានអាជ្ញាប័ណ្ណក្នុងការបញ្ជូនពលករទៅធ្វើការនៅប្រទេស ម៉ាឡេស៊ី ថៃ ហុងកុង និងប្រទេសជប៉ុន។ នៅក្នុងសេចក្ដីប្រកាសមួយ កាលពីថ្ងៃទី ១៩ ខែមេសាឆ្នាំ ២០១៨ ក្រសួងបានថ្លែងថា ក្រុមហ៊ុន CJ Labour Supply Co, Ltd បាន «កុហកនិងបោកប្រាស់សាធារណជន» នៅក្នុងការប្រកាសថា ក្រុមហ៊ុន ទទួលបានអាជ្ញាប័ណ្ណជ្រើសរើសពលករចំណាកស្រុកពីក្រសួង។ មានសេចក្ដីលម្អិតតិចតួចប៉ុណ្ណោះ អំពីទីភ្នាក់ងារនេះ ដែលមិនត្រូវបានបញ្ចូលនៅក្នុងបញ្ជីថ្មីៗ របស់ក្រសួងដែលមានទីភ្នាក់ងារជ្រើសរើសពលករចំនួន ៩៣ ដែលត្រូវបានអនុញ្ញាត ឬនៅក្នុងទិន្នន័យ ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម។

អ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ មិនបានឆ្លើយតបនឹងសារអំពីទីភ្នាក់ងារនេះទេ កាលពីថ្ងៃទី ១៩ ខែមេសា។

រូបថតនៃវិញ្ញាបនបត្រពន្ធដារ ដែលប្រើដោយក្រុមហ៊ុន CJ Labour Supply ដែលឃើញនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមកាលពីសប្ដាហ៍មុន បានកំណត់អត្តសញ្ញាណបុរសម្នាក់ឈ្មោះ ស៊ុន សីហា ថា ជាម្ចាស់ក្រុមហ៊ុននេះ ប៉ុន្តែនៅពេលទាក់ទងកាលពីថ្ងៃទី១៩ ខែមេសា លោក សីហា បានបដិសេធថា លោកមិនបានដឹង អំពីក្រុមហ៊ុននេះទេ។

លោកបានថ្លែងតាមសារថា៖ «ខ្ញុំមិនមែនជាម្ចាស់ក្រុមហ៊ុននេះទេ»។ «វាជាឈ្មោះរបស់ខ្ញុំ និងរូបរបស់ខ្ញុំ ប៉ុន្តែខុសក្រុមហ៊ុន។ ប្រសិនបើអ្នកចង់ទទួលបានការបញ្ជាក់ សូមទៅប៉ុស្តិ៍នគរបាលជាមួយខ្ញុំ ដើម្បីសួរបញ្ជាក់»។

អ្នកតស៊ូមតិ ដើម្បីសិទ្ធិការងារ ធ្លាប់បានរិះគន់កំណត់ត្រារបស់រដ្ឋាភិបាល ស្តីពីការអនុវត្តច្បាប់ទៅលើទីភ្នាក់ងារជ្រើសរើសពលករ ដែលមិនល្អ។ លោក មឿន តុលា នាយកប្រតិបត្តិនៃអង្គការ Central បានថ្លែងថា លោកពិបាកនិយាយ ថាតើទង្វើនេះវិជ្ជមានឬអត់។ លោកថ្លែងថា៖ «ពួកគេតែងតែស៊ីត្រីតូច ហើយទុកត្រីធំ បំពានសិទ្ធិកម្មករនិងច្បាប់»។

កាលពីដើមខែមេសានេះ ក្រសួងការងារ បានផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារជ្រើសរើសពលករថ្មីមួយ ដែលដឹកនាំដោយបុរសម្នាក់ ដែលកាលពីមុនធ្លាប់រត់គេចចេញពីប្រទេស បន្ទាប់ពីរដ្ឋាភិបាល រកឃើញថា គាត់បានជ្រើសរើសស្ត្រីបម្រើការងារតាមផ្ទះមិនទាន់គ្រប់អាយុ និងឃុំខ្លួនពួកគេដោយខុសច្បាប់ នៅក្នុងមណ្ឌលបណ្តុះបណ្តាលដែលមានលក្ខណៈដូចគុក៕ PS

## ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨

## ពលករខ្មែររាប់រយនាក់ សម្រុកចេញទៅធ្វើការប្រទេសថៃ តាមច្រកព្រំដែនខេត្តបន្ទាយមានជ័យ

https://www.rfa.org/khmer/ ដោយ មួង ណារ៉េត 2018-04-21

ក្រោយបុណ្យចូលឆ្នាំប្រពៃណីខ្មែររួមភ្លាម ពលករខ្មែរជាច្រើនរាយនាក់បាននាំគ្នាសម្រុកឆ្លងដែន ដើម្បីទៅស្វែងរកការងារធ្វើនៅប្រទេសថៃតាមច្រកព្រំដែនខេត្តបន្ទាយមានជ័យ។ មន្ត្រីសង្គមស៊ីវិលនិងពលរដ្ឋនៅព្រំដែនខេត្តបន្ទាយមានជ័យ អះអាងថា ពលករភាគច្រើនទៅតាមរយៈមេខ្យល់ នាំឆ្លងដែនទៅធ្វើការដោយខុសច្បាប់ ហើយប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិត។

ប្រជាពលរដ្ឋនៅព្រំដែនស្រុកអូរជ្រៅលោក ចក់ ចាន់ ឲ្យដឹងនៅថ្ងៃទី២១មេសាថា ពលករជាច្រើននាក់ ដោយអ្នកខ្លះធ្វើដំណើរតាមឡានឈ្នួលចំណុះ៦នាក់និងខ្លះទៀតឡានចំណុះ២០នាក់ត្រូវបានមេខ្យល់ដឹកយកទៅទម្លាក់ចោលនៅតាមព្រំដែន ដើម្បីឆ្លងដែនទៅធ្វើការងារនៅប្រទេសថៃ ខុសច្បាប់ ជាពិសេសច្រករបៀងព្រំដែនស្រុកអូរជ្រៅ និងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ៖ «ហើយបើទៅដល់ព្រំដែនម៉ាឡេស៊ី ដូចជានៅខេត្តស៊ុងខ្លា និងខេត្តប៉ាតានីជាដើម ម្នាក់ ១ម៉ឺនបាតក៏មានដែរ ហើយភាគច្រើនអ្នកមកខេត្តឆ្ងាយៗ ដូចខេត្តតាកែវ និងខេត្តព្រៃវែង កំពង់ចាមជាដើម។ ចំពោះអ្នកនៅជាប់ព្រំដែនមិនសូវមានទៅទេ ភាគច្រើនគេរកស៊ីតាមព្រំដែន ហើយត្រឡប់មកផ្ទះវិញពេលល្ងាច។ ពីម្សិលមិញគ្រាន់តែខ្ញុំឈរមួយភ្លែតប្រហែល ១០ឡាន ហើយគ្រាន់តែគេដឹកកាត់មុខ ដឹកតកន្ទុយគ្នា ចុះទម្រាំមួយថ្ងៃពេញមិនដឹងប៉ុន្មានទៅ»។ ពលរដ្ឋរូបនេះបន្ថែមទៀតថា ទម្រាំបានឆ្លងដែនទៅប្រទេសថៃពលករខ្លះដេកតាមគុម្ពោតព្រៃរកេតរកូតនៅច្រកព្រំដែនប្រមាណពី ៣ ទៅ ៥ថ្ងៃក៏មាន ហើយពលករខ្លះត្រូវចំណាយប្រាក់ឲ្យមេខ្យល់ពី ២.០០០ទៅ ២.៥០០បាត ឬស្មើជាង ៣០ម៉ឺនរៀលក្នុងម្នាក់ក្នុងការឆ្លងដែននេះ។

មន្ត្រីទាហានប្រចាំការនៅច្រករបៀងទំនប់ដាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ លោក រ័ត្ន វាសនា មានប្រសាសន៍ថា នៅព្រំដែនដែលលោកប្រចាំការមិនសូវមានពលករឆ្លងដែនដូចនៅច្រកផ្សេងនោះទេ ព្រោះខាងភាគីថៃបានដាក់ទាហានឈុតខ្មៅការពារតឹងរ៉ឹង ហើយមិនអនុញ្ញាតឲ្យពលករខុសច្បាប់ឆ្លងដែនច្រកមួយនេះបាននោះឡើយ។ លោក រ័ត្ន វាសនា អះអាងទៀតថា ចាប់តាំងពីរួចបុណ្យចូលឆ្នាំប្រពៃណីខ្មែរមក គឺមានពលករស្របច្បាប់ ដែលកាន់លិខិតឆ្លងដែន និងប័ណ្ណធ្វើការងារស៊ីជម្ពូឆ្លងដែនប្រមាណ ១០នាក់ក្នុងមួយថ្ងៃ បានឆ្លងដែនទៅប្រទេសថៃតាមច្រកមួយនេះ៖ «បាទតិចៗ ហើយតែអ្នកដែលមានលិខិតឆ្លងដែនទេ។ បើកន្លែងផ្សេងៗ គេទៅបានតិចៗ អីចឹង កន្លែងនេះគេបិទអត់អោយចេញ ទាល់តែមានប័ណ្ណការងារបានគេអោយទៅ ដែលអ្នកខ្លះគាត់ទៅផ្លូវវៀម ហើយអត់បានវៃចេញ ដល់ពេលចូលវិញគាត់មកតាមច្រករបៀង។ ការដែលតឹងរ៉ឹងនេះ ដោយសារគេដូរពីប៉ូលិសមកដាក់ទាហានឈុតខ្មៅ»។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្ស អាដហុក (Adhoc) ខេត្តបន្ទាយមានជ័យលោក ស៊ុំ ច័ន្ទតា អះអាងថា ពលករសម្រុកឆ្លងដែនស្ទើរគ្រប់ច្រករបៀងព្រំដែនក្នុងខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង។ លោកបន្ថែមទៀតថា ពលករឆ្លងដែនតាមច្រករបៀងភាគច្រើន ជាពលករទៅធ្វើការខុសច្បាប់ ហើយពួកគេប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិត។ ប៉ុន្តែដោយសារពួកគេគ្មានការងារធ្វើនៅឯស្រុកកំណើត ដើម្បីរកប្រាក់ចិញ្ចឹមជីវិត ទើបពួកគេសម្រេចចិត្តឆ្លងដែនទាំងប្រថុយប្រថាន៖ «ប្រឈមមុខទី១ ពួកគាត់ត្រូវបានគេជួញដូរកម្លាំងពលកម្ម។ ទី២ ការយកទៅធ្វើការឲ្យទៅប្រព្រឹត្តល្មើសនៅប្រទេសគេ ដូចជា ទៅកាប់ឈើក្រញូងទៅកាប់អីចឹង ប្រាប់ថា ទៅកាប់ដើមអាកាសស្បាហើយទៅកាប់ដើមក្រញូងនឹងត្រូវបានគេដេញបាញ់ចង់ងាប់ ហើយអ្នកក៏មានជីវិតរស់មកវិញ ហើយខ្លះទៅត្រូវរងគ្រោះស្លាប់ និងខ្លះត្រូវគេចាប់ដាក់គុក»។

ប្រជាពលរដ្ឋ និងលោក ស៊ុំ ច័ន្ទតារ អះអាងទៀតថា ចំណុចដែលពលករឆ្លងដែន គឺមាននៅច្រកណងចាន់ អូរបីជាន់ក្នុងស្រុកអូរជ្រៅ ច្រកបឹងត្រកួន និងច្រកមួយចំនួនទៀត នៅស្រុកស្វាយចេក។

បច្ចុប្បន្នពលករខ្មែរដែលធ្វើការនៅប្រទេសថៃមានប្រមាណ ១លាននាក់ ហើយក្នុងចំណោមនោះមួយចំនួនធំពួកគេឆ្លងដែនតាមច្រករបៀងទៅធ្វើការដោយខុសច្បាប់៕

## អាជ្ញាធរថៃត្រៀមបើកដំណើរច្រកចេញចូលតែមួយចំនួន ៨០កន្លែង សម្រាប់ធ្វើប័ណ្ណការងារស្របច្បាប់ដល់ពលករបរទេស

https://www.rfa.org/khmer/ ដោយ មួង ណារ៉េត 2018-04-21

ស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកក ប្រទេសថៃ ជូនដំណឹងថា ពលករខ្មែរ ដែលបានចុះបញ្ជីធ្វើការងារជាមួយអាជ្ញាធរថៃរួចហើយ ប៉ុន្តែមិនទាន់បានប័ណ្ណនោះ អាជ្ញាធរថៃនឹងបើកដំណើរការិយាល័យច្រកចេញចូលតែមួយចំនួន ៨០កន្លែងនៅទូទាំងប្រទេសថៃ ដើម្បីផ្តល់ប័ណ្ណការងារនេះ។

ការិយាល័យច្រកចេញចូលតែមួយចំនួន ៨០កន្លែង គឺមាននៅទីក្រុងបាងកក ៤កន្លែង និងតាមខេត្តចំនួន ៧៤ទីតាំង ហើយប័ណ្ណការងារដែលនឹងផ្តល់ឲ្យពលករនេះ ជាប័ណ្ណមិនមែនសញ្ជាតិថៃ ឬហៅប័ណ្ណពណ៌ស៊ីជម្ពូ ហើយដែលពលករបានបញ្ជាក់អត្តសញ្ញាណរួចហើយ។ ប័ណ្ណពណ៌ស៊ីជម្ពូថ្មី ដែលមានសុពលភាពត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ នឹងត្រូវផ្តល់ឲ្យពលករដែលបានចុះបញ្ជីរួច និងផ្តល់ទិដ្ឋាការស្នាក់នៅ ព្រមទាំងប័ណ្ណអនុញ្ញាតការងារដល់ពលករ ដែលមានលិខិតឆ្លងដែន (Passport) លិខិតធ្វើដំណើរ (TD) និងប័ណ្ណពលករកម្ពុជា ដែលទៅធ្វើការងារក្រៅប្រទេស (CCWC)។

ការិយាល័យច្រកចេញតែមួយទាំងអស់នោះ នឹងចាប់ដំណើរការចាប់ពីថ្ងៃទី២៣ មេសាដល់ថ្ងៃទី៣០ មិថុនា ឆ្នាំ២០១៨។ ពលករទាំងអស់ត្រូវប្រញាប់ទៅអនុវត្តន៍នីតិវិធីបន្តនៅច្រកចេញចូលតែមួយ (OSS) ដែលមានទីតាំងនៅជិតទីកន្លែងធ្វើការរបស់ខ្លួនឲ្យបានគ្រប់គ្នា។ ប្រសិនបើពលករណាមានចម្ងល់ អាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក តាមលេខ ០២ ៩៥៧ ៥៨៥២ ឬ ០៨៦ ៧៩៩ ៩៩៥៧ និង ០៩៤ ០៩២៥៩០៥ ជាដើម៕

## ទាហានថៃបិទច្រកមិនឲ្យរថយន្តតាក់ស៊ីខ្មែរចូលទៅប្រទេសថៃដឹកភ្ញៀវ

http://www.ppd-news.net/ 23-April-2018 / ព័ត៌មានជាតិ

**ខេត្តឧត្តរមានជ័យ ៖** ភាគីថៃបានបិទមិនឱ្យរថយន្តតាក់ស៊ីខ្មែរ ដែលធ្លាប់ដឹកភ្ញៀវ មិនឱ្យចូលទៅប្រទេសថៃ តាមទ្វារព្រំដែនអន្តរជាតិអូរស្មាច់-ឆងចម ដោយមូលហេតុ ភាគីថៃ បានចោទប្រកាន់ថា រថយន្តតាក់ស៊ីដឹកភ្ញៀវ ទាំងនោះបានលួចដឹកមនុស្សឆ្លងដែនខុសច្បាប់ បន្លំ ជាមួយអ្នកជំងឺ ទៅព្យាបាលជំងឺនៅប្រទេសថៃ នឹងបន្លំលួចដឹកឈើ គ្រញូង

ពីប្រទេសថៃ ចូលមកកម្ពុជា។ ករណីនេះកើតឡើងនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៨ នៅវេលាម៉ោង០៧ និង៣០នាទី។

ជាមួយគ្នានោះនៅវេលាម៉ោង០៩ និង២០នាទី ថ្ងៃខែឆ្នាំដដែលក្រុមអ្នករត់តាក់ស៊ីខ្មែរ បានមកប្រមូលផ្តុំគ្នា នៅមុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ដើម្បីទប់ស្កាត់មិនឱ្យរថយន្តថៃ ឆ្លងដែនចូលមកកម្ពុជាដូចគ្នាដែលភាគីថៃបានបិទ ។ បន្ទាប់មកអាជ្ញាធរមូលដ្ឋាន(សង្កាត់) បានជួយអន្តរាគមន៍ឲ្យរថយន្តថៃចរាចរធម្មតាឡើងវិញ និងបានឱ្យអ្នករត់តាក់ស៊ីមកជួបជុំគ្នានៅសាលាសង្កាត់អូរស្មាច់ ដើម្បីដោះស្រាយតាមសន្តិវិធី៕

## ពលករនៅថៃមួយចំនួនតូចនៅចាញ់បោកមេខ្យល់ឆ្លងដែនតាមច្រករបៀង

http://nokorwatnews.com/ ថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០១៨

ប៉ោយប៉ែត ៖ បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរឆ្នាំ២០១៨ បានកន្លងផុតទៅ ចំណែកពលករខ្មែរប្រុស ស្រីជាច្រើនរយនាក់កំពុងធ្វើដំណើរចេញពីកម្ពុជាទៅប្រទេសថៃវិញ ដើម្បីចូលបម្រើការនៅកន្លែងរៀងៗខ្លួន តាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

នាយរងការិយាល័យនគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតលោក ពៅ ថារុធ បានឲ្យដឹងថា ក្រោយថ្ងៃបុណ្យចូលឆ្នាំខ្មែរ បានបញ្ចប់ ពលករខ្មែរស្របច្បាប់ជាច្រើននាក់ បានចេញ ទៅធ្វើការងារនៅប្រទេសថៃវិញ តាមរយៈការធ្វើបែបបទដោយស្របច្បាប់ មិនមានការបង់ប្រាក់កាសអ្វីឡើយ។ លោកបញ្ជាក់ថា: ក្រុមការងារជំនាញបានបើកឲ្យប្រជាពលរដ្ឋទូទៅមានឱកាសបំពេញឯកសារបែបបទស្នើសុំផ្សេងៗ ដោយខ្លួនឯង ដែលវាខុសពីពេលមុនៗ មានជនខិលខូចមួយចំនួន បានលួចយកប្រាក់ក្រៅសេវា ជាថ្នូរនឹងការបំពេញបែបបទ រត់ការឯកសារ ឬប្រថាប់ត្រា ដើម្បីបានលឿន និងរហ័សជាដើម ហើយការលុបបំបាត់ ការយកលុយក្រៅសេវានេះ លោកបានចាប់ផ្តើមរឹតបន្តឹងតាំងមុនថ្ងៃចូលឆ្នាំមក ។ លោកនិងក្រុមមន្ត្រីរបស់លោកនឹងខិតខំបន្តសកម្មភាពនេះជាបន្តទៀត ។

តាមការឲ្យដឹងពីពលករដែលកំពុងធ្វើបែបបទ មូលហេតុដែលពលករខ្មែរទាំងនោះសម្រុកចេញទៅ បែបនេះ គឺដោយសារពួកគាត់ត្រូវប្រញាប់ទៅឲ្យទាន់ពេលវេលាដែលគាត់បានសុំច្បាប់អនុញ្ញាត ពីថៅកែថៃ ហើយប្រសិនបើគាត់ទៅមិនទាន់តាមការកំណត់របស់ថៅកែថៃ ពួកគាត់នឹងត្រូវកាត់ប្រាក់ខែតាមការកំណត់របស់ថៅកែ។

ដោយឡែក: តាមសេចក្តីរាយការណ៍ពីបន្ទាត់ព្រំដែន កម្ពុជា ថៃ ប្រាប់ថា ក្រៅពីការចេញដោយស្របច្បាប់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ក៏មានពលករខ្មែរច្រើននាក់ទៀតត្រូវបានគេដឹកជញ្ជូនតាមរយៈរថយន្ត តាមច្រករបៀងដែលពួកគាត់ ចាញ់បោកមេខ្យល់លួចចេញពីកម្ពុជា ទៅថៃ ដោយខុសច្បាប់ មួយចំនួនក្នុងភូមិសាស្ត្រនៃខេត្តបន្ទាយមានជ័យ ដូចជាច្រករបៀងក្លឹបថ្ម គ្រប់គ្រងដោយយោធាតំបន់អតិវឌ្ឍន៍ភ្នំឆត្រ ឋិតក្នុងភូមិក្លិបថ្ម ឃុំគោករមៀត ស្រុកថ្មពួក គ្មានការទប់ស្កាត់ បើទោះជារាជរដ្ឋាភិបាលទាំងពីរមានការយកចិត្តទុកដាក់លើបញ្ហាពលករក៏ដោយ ប្រឈមទៅនឹងគ្រោះថ្នាក់ដល់ពួកគាត់ ព្រោះកន្លងមក ពលករឆ្លងដែនខុសច្បាប់ ធ្លាប់ជួបគ្រោះថ្នាក់ខ្លះបាត់បង់ជីវិត និងខ្លះទៀតពិការផងដែរ ៕ វណ្ណា

## កម្លាំងសមត្ថកិច្ចថៃព័ទ្ធស្ទាក់ចាប់ពលករខ្មែរ ចំនួន៣២នាក់ ក្នុងព្រៃព្រំដែន នៅតាប្រាយ៉ា

http://www.cen.com.kh/ April 22, 2018

បន្ទាយមានជ័យ ៖ ខណៈពលករខ្មែរសម្រុកវិលទៅថៃវិញ កងកម្លាំងសមត្ថកិច្ចថៃបានព័ទ្ធស្ទាក់ចាប់ក្នុងព្រៃរបោះព្រំដែន ។ ការព័ទ្ធចាប់នោះធ្វើឡើងកាលពីយប់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨ ហើយព្រឹកបន្ទាប់ទើបកម្លាំងសមត្ថកិច្ចថៃនាំយកឡានទ្រុងមកដឹកពលករចេញទៅ។

ប្រភពព័ត៌មានពីព្រំដែនបានឲ្យដឹងថា ៖ ពលករខ្មែរ ចំនួន៣២នាក់ (ប្រុស-ស្រី) ត្រូវបានកម្លាំងយោធា និងសមត្ថកិច្ចនគរបាលថៃខាងការពារព្រំដែននិងខេត្តស្រះកែវ ធ្វើការហ៊ុំព័ទ្ធព្រៃមួយកន្លែងក្នុងស្រុកតាប់ប្រាយ៉ា ខេត្តស្រះកែវ ទល់មុខភ្នំប្រាក់ ភូមិក្លឹបថ្ម ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ទីនោះគ្រប់គ្រងដោយយោធាតំបន់

អភិវឌ្ឍន៍ឃោធភូមិភាគ៥-ភ្នំធំត្រ ហើយបានបណ្តោយឲ្យមានពលករខ្មែរលួចឆ្លងដែនខុសច្បាប់ ។ ពលករម្នាក់ៗត្រូវបង់លុយឲ្យមេខ្យល់ចំនួនពី២.០០០ទក (២.៥០០បាតប្រាក់ថៃ)។ មកទល់ថ្ងៃទី២២មេសានេះ ពលករទាំងនោះ មិនទាន់ត្រូវបានបញ្ជូនមកប្រទេសកំណើតវិញនៅឡើយទេ។

លោកស្រី ស៊ិន ណាំយ៉ុង មេភូមិប៉ោយប៉ែត និងជាមន្ត្រីនៅមណ្ឌលទទួលពលករច្រកទ្វារព្រំដែនប៉ោយប៉ែត (ផ្សារមង្គល) នៅភូមិ-សង្កាត់-ក្រុងប៉ោយប៉ែត បានបញ្ជាក់ប្រាប់សារព័ត៌មាននៅថ្ងៃទី២២ ខែមេសានេះ ៕ ដោយ ៖ បន្ទាយ

## ពួកមេខ្លោងនៅពីក្រោយក្រុមធ្វើជំនួញអាជីវកម្មពេស្យាចារក្មេងស្រីសិស្សសាលាថៃត្រូវបានកាត់ទោសឱ្យជាប់គុកចាប់ពីជាង១៥០ឆ្នាំដល់ជាង៣០០ឆ្នាំ

http://www.rasmeinews.com/ April 20, 2018, 3:12 PM

សេវាកម្មដ៏ទាក់ទាញដែលផ្តល់សេវាកម្មក្មេងស្រីជំទង់នៅប្រទេសថៃ ដែលគេហៅថា ″ បង្អែម ״នោះត្រូវបានគ្រប់គ្រងដោយក្រុមមន្ត្រីជាន់ខ្ពស់រួមទាំងមន្ត្រីប៉ូលីសថ្នាក់ខ្ពស់ម្នាក់ដែល ត្រូវបានដាក់ទោសឱ្យជាប់គុករយៈពេល៣២០ឆ្នាំ កាលពីថ្ងៃពុធទី១៨មេសា។ មេក្រុមពេស្យាចារដែលប្រតិបត្តិការនៅខេត្តMae Hong Son នៅភាគពាយព្យនៃប្រទេសថៃត្រូវបានចាប់ខ្លួនកាលពីឆ្នាំ២០១៧ ។ ប៉ុន្តែនៅពេលដែល វាត្រូវបានដំណើរការនោះស្ត្រីវ័យក្មេងៗ ត្រូវបានសម្គាល់ដោយការចាក់សាក់រូបសត្វទីទុយ ហើយស្ត្រីក្មេងៗទាំងនោះត្រូវបានគេផ្តល់ដល់ក្រុមភ្ញៀវពិសេសៗ។

កាសែត Bangkok Post បានរាយការណ៍ថា តុលាការឧក្រិដ្ឋកម្មក្រុងបាងកក បានកាត់ទោសលោក Yutthachai Thongchai មន្ត្រីប៉ូលីសថ្នាក់ខ្ពស់នេះឱ្យជាប់គុក៣២០ឆ្នាំ ហើយមនុស្ស២នាក់ក្នុងចំណោមមនុស្សជំនិតច្រើននាក់របស់គាត់ ត្រូវបានកាត់ទោសឱ្យជាប់គុកម្នាក់ៗ ជាង១៥០ឆ្នាំ ។

លោក Piyathat Papthiensuwan និងលោក Piyawan Sookmak ត្រូវបានកាត់ទោសឱ្យជាប់គុក១៧៦ឆ្នាំនិង១៦៧ឆ្នាំតែរៀងៗខ្លួន បើទោះបីជាច្បាប់ឧក្រិដ្ឋកម្មរបស់ថៃ មានទោសជាប់ពន្ធនាគារច្រើនបំផុតនោះ គឺរយៈពេល៥០ឆ្នាំក៏ដោយ។

អ្នកសារព័ត៌មានថៃម្នាក់បានប្រាប់សារព័ត៌មាន AFP ថាមេក្រុមស្រីរកស៊ីផ្លូវភេទនេះបានចាត់ទុកស្ត្រីវ័យក្មេងទាំងនេះ ជាអ្វីមួយ ដែលអាចត្រូវបានទិញក្នុងតម្លៃសមរម្យ។ សារព័ត៌មាន Straits Times បានរាយការណ៍ថាស្ត្រីវ័យក្មេង៣នាក់ត្រូវបានបង្ខិតបង្ខំឱ្យរួមភេទជាមួយពួកបុរសៗឱ្យបាន១០ដងក្នុងមួយសប្តាហ៍ក្នុងតម្លៃ ៤០,៥០ដុល្លារក្នុងមួយលើក។ ក្មេងស្រីម្នាក់ត្រូវបាន គេបង្ខំឱ្យរួមភេទជាមួយគ្រូបង្រៀន មកពីសាលារៀនរបស់នាង។ កាសែតនេះបានរាយការណ៍ថាក្មេងស្រីទាំងនេះត្រូវបានផ្លាស់ប្តូរចេញពីខេត្តដែលត្រូវបានគេស្គាល់ថាជាកន្លែងដែលមានការសប្បាយបំផុតនៅប្រទេសថៃ ហើយអតិថិជនដែលប្រើប្រាស់សេវានេះរួមទាំងពួកមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់៕

## រាជរដ្ឋាភិបាលកម្ពុជាកំពុងយកចិត្តទុកដាក់ពីការលំបាកកម្មករកម្មការិនីធ្វើការនៅម៉ាឡេស៊ី

http://nokorwatnews.com/ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៨

ម៉ាឡេស៊ី៖ លោក អូស្មាន ហាស្សាន់ បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាកំពុងយកចិត្តទុកដាក់ពីការលំបាករបស់បងប្អូន កម្មករ កម្មការិនីដែលធ្វើការងារនៅប្រទេសម៉ាឡេស៊ី និងនៅតាមបណ្តាប្រទេសផ្សេងៗ ជាច្រើនទៀត។ រាជរដ្ឋាភិបាលកម្ពុជាបានគិតគូរិះរកគ្រប់មធ្យោបាយទំនាក់ទំនង ផ្នែកការទូតជាមួយប្រទេសដែលបងប្អូនមកធ្វើការដើម្បីឲ្យថ្នាក់ដឹកនាំប្រទេសនោះ គេទទួលស្គាល់ និងឲ្យតម្លៃការងារបងប្អូនបានល្អ។ លោក អូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយក រដ្ឋមន្ត្រី បានបញ្ជាក់បែបនេះ ខណៈលោកដឹកនាំគណៈ ប្រតិភូកម្ពុជាអញ្ជើញចុះសាកសួរសុខទុក្ខសំណេះសំណាលជាមួយបងប្អូន ពលករ ពលការិនី និងពលរដ្ឋខ្មែរអ៊ិស្លាមប្រមាណ៣០០នាក់ នៅប្រទេសម៉ាឡេស៊ី

ក្នុងរដ្ឋ Johor Baharu ដោយមានវត្តមានលោកស្រី វ័ត្ន ម៉ានី ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី និងសហការីអមដំណើរពរូបផងដែរ។

ជំនួបនេះ ធ្វើឡើងនៅឯតំបន់ Ulutiram កាលពីព្រឹកថ្ងៃអាទិត្យ ៨កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៨ ដោយមានតំណាង និងបងប្អូនខ្មែរមកពីបណ្តាភូមិ តំបន់ជុំវិញ រដ្ឋ Johor Baharu ដែលអ្នកខ្លះបានមករស់នៅរួមរស់តាំងពីទសវត្ស៧០ ទសវត្ស៨០ និងជាបន្តបន្ទាប់។ រដ្ឋ Johor Baharu ជារដ្ឋដែលមានចម្ងាយប្រមាណ ជិត៤០០គីឡូម៉ែត្រ ពីរដ្ឋធានីគូឡាឡាំពួរ ដោយក្តីអបអរសាទរ និងរីករាយជាទីបំផុត។

លោកស្រី វ័ត្ន ម៉ានី ក្នុងនាមជាឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅម៉ាឡេស៊ី លើកឡើងពីគោលជំហ និងតួនាទីរបស់ខ្លួន នឹងឈរលើឆន្ទៈបម្រើប្រជាជនខ្មែរដែលនៅប្រទេសម៉ាឡេស៊ី ស្វាគមន៍ជានិច្ចនូវ រាល់បញ្ហាផ្សេងៗ ដែលពលរដ្ឋជួបប្រទះ ដោយមិនបង្កការប៉ះពាល់ដល់ច្បាប់នៃប្រទេសម៉ាឡេស៊ី ។

លោក អូស្មាន ហាស្សាន់ បានជម្រាបពីភាពរីកចម្រើនគ្រប់បែបយ៉ាង របស់កម្ពុជា ក្រោមគោលនយោបាយដឹកនាំដ៏ត្រឹមត្រូវ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បើគ្មានការដឹកនាំប្រកបដោយឆន្ទៈមុះមត់ ស្មារតីលះបង់ខ្ពស់ គិតគូរអំពីផលប្រយោជន៍ជាតិជាធំទេ របស់ប្រមុខដឹកនាំទេ គឺកម្ពុជាមិនមែនសម្រេចបានដោយជោគជ័យ ក្លាយទៅជាប្រទេសដែលមានសុខសន្តិភាព សុខដុមបនីយកម្ម និងការអភិវឌ្ឍ សេដ្ឋកិច្ចរីកចម្រើនបានល្អប្រសើរដូចសព្វថ្ងៃនោះទេ។ លោកបានកោតសរសើរដល់ពលករ ពលការិនី និងពលរដ្ឋខ្មែរអ៊ិស្លាមទាំងអស់អ្នក ដែលទទួលបានសញ្ជាតិ និងអ្នកដែលនៅបំពេញការងារ គឺបានសាមគ្គី រួមរស់នៅ ប្រកបដោយសេចក្តីសុខសប្បាយ មិនដែលឮជួបនូវបញ្ហាបង្កការលំបាក នាំភាពខ្វល់ខ្វាយដល់រដ្ឋាភិបាលម៉ាឡេស៊ី ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាខ្លួនឯងនោះដែរ គឺជាកសាងកេរ្តិ៍ឈ្មោះមួយយ៉ាងល្អប្រសើរ ជូនប្រជាជាតិកម្ពុជាទាំងមូល។

ជាមួយគ្នានេះដែរ លោក អូស្មាន ហាស្សាន់ និងគណៈ ប្រតិភូ ក្រោយពីបញ្ចប់កម្មវិធី ជួបសំណេះសំណាលរួចក៏បានបន្តដំណើរទៅតបន់ Sungai Boluh រដ្ឋ Selangor ប្រទេសម៉ាឡេស៊ី ដែលមានចម្ងាយប្រមាណជាង ៤០០ គីឡូម៉ែត្រ ពីរដ្ឋ Johor Baharu ដើម្បីបន្តជួបសំណេះសំណាលជាមួយបងប្អូនកម្មករ កម្មការិនី និងប្រជាពលរដ្ឋខ្មែរដែលកំពុងប្រកបអាជីវកម្ម និងធ្វើការងារនៅតាមបណ្តាសហគ្រាសធន់តូចមធ្យម និងធំប្រមាណជាង៥០០នាក់ នៅតំបន់នោះផងដែរ៕ សំរិត

## ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨

## អគ្គកុងស៊ុលខ្មែរ ប្រចាំខេត្តជីនបុរី បញ្ជូនពលករខ្មែរ ជួបគ្រោះថ្នាក់ចរាចរណ៍ មកវិញ

https://www.dap-news.com/kh/ អង្គារ, ២៤ មេសា ២០១៨ 09:19 ដោយ: ដើមអម្ពិល ID:118

**ភ្នំពេញ៖** ស្ថានអគ្គកុងស៊ុលខ្មែរ បានអន្តរាគមន៍បញ្ជូនពលករខ្មែរ ខុសច្បាប់១៤នាក់ ដែលជួបគ្រោះថ្នាក់ចរាចរណ៍ ហើយរងរបួសស្រាល នៅស្រុកមឿងប្រាជីនបុរី ខេត្តប្រាជីនបុរី ត្រឡប់មកវិញ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨។ បើតាមហ្វេសប៊ុក របស់អគ្គកុងស៊ុលខ្មែរ ពួកគេបានជួបគ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៨។ ចំណែកអ្នករងរបួសធ្ងន់ តែមិនប៉ះពាល់ដល់ជីវិត កំពុងសម្រាកព្យាបាល របួសនៅមន្ទីរពេទ្យបង្អែក ខេត្តប្រាជីនបុរី និងអ្នកថែទាំ ចំនួន៧ នាក់ទៀត ស្ថានអគ្គកុងស៊ុលនឹងសហការ ជាមួយអាជ្ញាធរពាក់ព័ន្ធថៃ មាតុភូមិនិវត្តន៍ពួកគាត់ បន្ទាប់របួសជាសះស្បើយ៕

## ថៃ បង្ហាញពិធីជប់លៀងសិច ដែលមានទាំងខ្មែរនិងជាតិសាសន៍ផ្សេងៗ នៅប៉ាតាយ៉ា

http://kleykley.sabay.com.kh/ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៨ ម៉ោង 16:57

សមត្ថកិច្ចថៃ កាលពីថ្ងៃសៅរ៍សប្តាហ៍មុន បានចុះបង្ក្រាបពិធីជប់លៀងសិច នៅសណ្ឋាគារ ឈ្មោះ Ban Tulip នៅតំបន់ Phra Tamnak ក្រុងប៉ាតាយ៉ា ដោយឃាត់ខ្លួនជនបរទេសសរុប ២៥នាក់ (ប្រុស ១១នាក់ និងស្ត្រី ១៤នាក់) ក្នុងនោះមានទាំងជនជាតិខ្មែរផងដែរ។ ចំពោះចំនួនជនជាតិខ្មែរ ដែលត្រូវឃាត់ខ្លួន មិនត្រូវបានបញ្ជាក់នោះទេ។ ជនបរទេស និងស្ត្រីជនជាតិថៃ មួយចំនួន ត្រូវសមត្ថកិច្ចថៃចាប់ខ្លួន នៅសណ្ឋាគារ Ban Tulip (រូបភាព៖ news.com.au) ប៉ូលិសបានរកឃើញថា ទីតាំងខាងលើបានរៀបចំពិធីជប់លៀងសិចខុសច្បាប់ ដែលអ្នកចូលរួមបានរួមភេទផ្លាស់គ្នា។ សណ្ឋាគារនេះ មានម្ចាស់ជាជនជាតិចិន ឈ្មោះ Xeng-Chai Yang វ័យ៥៣ឆ្នាំ ដែលត្រូវបានឃាត់ខ្លួនពីបទបើកសណ្ឋាគារដោយគ្មានអាជ្ញាប័ណ្ណ។ ជារួម ប៉ូលិសឃាត់ខ្លួនបានជនជាតិ អាមេរិក កាណាដា ចិន ម៉ាឡេស៊ី សិង្ហបុរី អាល្លឺម៉ង់ ថៃ កម្ពុជា ឥណ្ឌា និងអ៊ុយក្រែន។

លោក Naris Niramaiwong មេប៉ុស្តិ៍សង្កាត់ Bang Lamung បាននិយាយថា ប្រជាពលរដ្ឋក្នុងតំបន់បានដាក់ពាក្យបណ្តឹងចំពោះសណ្ឋាគារខាងលើ ដែលតែងតែរៀបចំពិធីជប់លៀងសិចនេះ។ លោកបន្តថា អ្នកចូលរួមពិធីនេះបានចុះឈ្មោះតាមរយៈវេបសាយមួយ ដោយម្នាក់ត្រូវចំណាយ ១៥០០បាត ឬជិត ៥០ដុល្លារអាមេរិក។ សូមបញ្ជាក់ថា ថៃទទួលបានភ្ញៀវទេសចរអន្តរជាតិជាង ៣៥លាននាក់ កាលពីឆ្នាំ២០១៧។ ហើយទេសចរ ទៅកម្សាន្តនៅក្រុងប៉ាតាយ៉ាមានចំនួនរាប់ពាន់នាក់ ដើម្បីស្វែងរកសេវាកម្មផ្លូវភេទ៕ ប្រភព៖ Bangkokpost ប្រែសម្រួល៖ លាភ.

## ហ្វីលីពីន កាត់ទោសបុរសម្នាក់ឲ្យជាប់គុកជាង ៣០០ឆ្នាំ

http://kleykley.sabay.com.kh/ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៨ ម៉ោង 14:57

បុរសសញ្ជាតិអាមេរិកម្នាក់ឈ្មោះ David Lynch ត្រូវបានតុលាការហ្វីលីពីនសម្រេចកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ៣៣០ឆ្នាំ ពីបទបំពានផ្លូវភេទអនីតិជន។ David បានធ្វើទេសចរណ៍សិចទៅកាន់ប្រទេសហ្វីលីពីន ហើយបានបង្ហោះវីដេអូរួមភេទជាមួយកុមារជាច្រើននាក់ កាលពីឆ្នាំ២០០៥។ សមត្ថកិច្ចហ្វីលីពីន ប្រាប់ថា ក្នុងចំណោមជនរងគ្រោះដែល David បានប្រព្រឹត្តបទល្មើសលើនោះ មានកុមារខ្លះអាយុត្រឹមតែ ៦ឆ្នាំប៉ុណ្ណោះ។ David ត្រូវបានប៉ូលិសក្រុង Veniceប្រទេសអ៊ីតាលីចាប់ខ្លួននៅអំឡុងឆ្នាំ២០១៦ខណៈដែលលោកបម្រុងហោះទៅកាន់ប្រទេសហ្វីលីពីនម្តងទៀត។ ព្រះរាជអាជ្ញា បានបញ្ជាក់ថា ក្នុងដំណើរកម្សាន្តសិចរបស់ David យ៉ាងហោចណាស់មានម្តងត្រូវបានរៀបចំឡើងដោយម្តាយរបស់កុមារជនរងគ្រោះ។ ព្រះរាជអាជ្ញា ប្រាប់បន្តថា សព្វថ្ងៃ David មានកូនចំនួន ២នាក់ កំពុងរស់នៅប្រទេសហ្វីលីពីន។ សូមបញ្ជាក់ថា David ត្រូវបានតុលាការចោទប្រកាន់កាលពីចុងឆ្នាំ២០១៧ ហើយទើបត្រូវកាត់ទោសកាលពីសប្តាហ៍មុន។ បន្ថែមពីទោសត្រូវជាប់គុករាប់រយឆ្នាំ David ក៏ត្រូវតុលាការរឹបអូសផ្ទះមួយខ្នងផងដែរ៕ ប្រភព៖ nytimes ប្រែសម្រួល៖ ឈាង.

## ប្រទេសពីរ ក្លាយជាគោលដៅថ្មីរបស់ ពលករហ្វីលីពីន

http://kleykley.sabay.com.kh/ ថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០១៨ ម៉ោង 11:19

ពលករហ្វីលីពីន ត្រូវគេរំពឹងថា នឹងស្វែងរកការងារនៅប្រទេសរុស្ស៊ី និងចិន ស្របពេលដែលប្រទេសហ្វីលីពីនគ្រោងនឹងកាត់ផ្តាច់ទំនាក់ទំនងជាមួយប្រទេសនៅមជ្ឈិមបូព៌ា។ ក្នុងឆ្នាំ២០១៨នេះ រុស្ស៊ីបានជួលបុគ្គលិកហ្វីលីពីនដែលមានជំនាញ ដើម្បីបម្រើការងារនៅផ្នែកសំណង់ និងសេវាកម្ម ខណៈចិន ត្រូវការជនជាតិហ្វីលីពីនជាង ២ពាន់នាក់ ដើម្បីធ្វើជាគ្រូបង្រៀនភាសាអង់គ្លេស។ នេះជាការអះអាងរបស់លោក Bernard Olalia ប្រធានរដ្ឋបាលការងារក្រៅប្រទេសរបស់ហ្វីលីពីន កាលពីពេលថ្មីៗកន្លងទៅ។

ទឹកប្រាក់ដែលពលករហ្វីលីពីន ផ្ញើមកប្រទេសកំណើតរបស់ពួកគេ មានចំនួនរាប់ពាន់លានដុល្លារអាមេរិក ដែលបានរួមចំណែកជួយដល់សេដ្ឋកិច្ចរបស់ហ្វីលីពីន។ យោងតាមធនាគារពិភពលោក បានឲ្យដឹងថា ពលករហ្វីលីពីន ផ្ញើប្រាក់ចំនួន ៣៣ពាន់លានដុល្លារអាមេរិក កាលពីឆ្នាំ២០១៧។ ទោះជាយ៉ាងនេះក្តី មជ្ឈិមបូព៌ា នៅតែជាគោលដៅធំរបស់ពលករហ្វីលីពីន។ កាលពីឆ្នាំ២០១៦ ពលករហ្វីលីពីន មាននៅមជ្ឈិមបូព៌ា ច្រើនជាង ១លាននាក់ ឬ ៦៣% នៃចំនួនពលករសរុប។ ក៏ប៉ុន្តែ ករណីឃាតកម្មលើពលករហ្វីលីពីនម្នាក់នៅប្រទេសគុយវ៉ែត ធ្វើឲ្យប្រធានាធិបតីហ្វីលីពីន Rodrigo Duterte ចេញបម្រាមមិនឲ្យមានការចេញទៅធ្វើការនៅប្រទេសនានាក្នុងតំបន់អារ៉ាប់ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០១៨៕ ប្រភព៖ Straits Times ប្រែសម្រួល៖ លាភ.

## ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨

### កម្លាំងទីបញ្ជាការជួរមុខកម្ពុជា និងកងទ័ពជើងទឹកថៃ រួមគ្នាទប់ស្កាត់បទល្មើសជួញដូរមនុស្ស

http://www.cen.com.kh/ April 25, 2018

ខេត្តព្រះសីហនុ៖ កម្លាំងទីបញ្ជាការជួរមុខ និងមន្ត្រីស្ថាប័នគន្លឹះចំនួន ២០រូប ដឹកនាំដោយ លោកឧត្តមនាវីឯក ទៀ សុខា មេបញ្ជាការរងកងទ័ពជើងទឹក និងជាមេបញ្ជាការទីបញ្ជាការជួរមុខ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ បានអញ្ជើញទទួលស្វាគមន៍គណៈប្រតិភូយោធភូមិភាគទី១ នៃកងទ័ពជើងទឹកភូមិន្ទថៃចំនួន ២២រូប ដឹកនាំដោយ លោកឧត្តមនាវីឯក BANJOB POEDAENG មេបញ្ជាការយោធភូមិភាគទី១ នៃកងទ័ពជើងទឹកភូមិន្ទថៃ ចូលរួមកិច្ចប្រជុំលើកទី៨ ស្តីពីកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មានលើផ្ទៃសមុទ្រ ដើម្បីឈានទៅសហការទប់ស្កាត់ បង្ក្រាបការជួញដូរមនុស្ស ការរុករក និងជួយសង្គ្រោះគ្រោះមហន្តរាយរួមគ្នាឲ្យមានប្រសិទ្ធភាព។ កិច្ចប្រជុំនេះបានរៀបចំ កាលពីរសៀលថ្ងៃអង្គារ ទី២៤ ខែមេសា ឆ្នាំ២០១៨ នៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ៕ ដែន សីមា

### ក្រសួងការបរទេសកម្ពុជា សម្រេចបញ្ជូនពលករខ្មែរខុសច្បាប់ ហើយជួបគ្រោះថ្នាក់ចរាចរណ៍នៅប្រទេសថៃ វិលមកកម្ពុជាវិញ

http://www.cen.com.kh/ April 24, 2018

ភ្នំពេញ៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានឲ្យដឹងថា បន្ទាប់ពីមានករណីពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ២១នាក់ បានជួបគ្រោះថ្នាក់ចរាចរណ៍នៅខេត្តប្រាជីនបុរី ប្រទេសថៃរួចមក គឺស្ថានកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ បានចុះទៅពិនិត្យស្ថានភាព របស់ពលករខ្មែរទាំងនោះដល់មន្ទីរពេទ្យ និងបានសហការជាមួយអាជ្ញាធរពាក់ព័ន្ធប្រទេសថៃ ដើម្បីសម្រមសម្រួលរឿងនេះ។ យោងតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ញប្រកាសនៅថ្ងៃអង្គារ ទី២៤ ខែមេសា ឆ្នាំ២០១៨ បានបង្ហាញថា អាជ្ញាធរខ្មែរ សម្រេចបញ្ជូនពលករខ្មែរ ដែលរងរបួសសរុបមានគ្នាចំនួន ១៤នាក់ ឲ្យត្រឡប់មកកម្ពុជាវិញ តាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត កាលពីរសៀលថ្ងៃចន្ទ ទី២៣ ខែមេសា ឆ្នាំ២០១៨។

គ្រោះថ្នាក់ចរាចរណ៍ខាងលើនេះ បានកើតឡើងកាលពីព្រឹកថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៨ នៅឃុំខុងឡេក ស្រុកមឿងប្រាជីនបុរី ដោយរថយន្តភីកអាប់ ១គ្រឿង ដឹកពលករខ្មែរខុសច្បាប់ចំនួន ២១នាក់ (ស្រី៥នាក់) ចេញពីច្រកព្រំដែនបឹងត្រកួន–ណងចាន់ ខេត្តបន្ទាយមានជ័យ ជាប់ខេត្តសាកែវ ឆ្ពោះទៅខេត្តឈុនបុរី ប្រទេសថៃ។ ប្រភពបានឲ្យដឹងថា ពេលរថយន្តកំពុងបើកបរ ក៏បានរេចង្កូតបុករថយន្តដឹកទឹកកកពីក្រោយ បណ្តាលឲ្យពលករខ្មែរជិះនៅលើរថយន្តភីកអាប់នោះ រងរបួសធ្ងន់ស្រាលជាច្រើននាក់ ហើយត្រូវបានអាជ្ញាធរថៃ ដឹកបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យក្នុងទឹកដីថៃ។ ប្រភពដដែលបានឲ្យដឹងទៀតថា ពលករខ្មែរឆ្លងដែនខុសច្បាប់ចូលទៅប្រទេសថៃទាំង ២១នាក់នោះមានឈ្មោះ៖ ទី១.ឈ្មោះ វ៉េត ចាន់ធឿន ភេទស្រី អាយុ២៨ឆ្នាំ រស់នៅឃុំព្រែកតូច ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ទី២.ឈ្មោះ ស្តើង ស្រីនិច ភេទស្រី អាយុ ១៨ឆ្នាំ រស់នៅឃុំឈូក ស្រុកឈូក ខេត្តកំពត។ ទី៣.ឈ្មោះ វ៉ាន់ សុភី ភេទស្រី អាយុ ២៨

ឆ្នាំ។ ទី៤.ឈ្មោះ ង៉ែត សុគីម ភេទស្រី អាយុ ១៨ឆ្នាំ។ ទី៥.ឈ្មោះ ស្តើង សុខ ភេទប្រុស អាយុ២៧ឆ្នាំ។ អ្នកទាំង ៣នាក់ នេះ រស់នៅឃុំប្រាសាទ ស្រុកសំបូរព្រៃគុក ខេត្តកំពង់ធំ។ ទី៦.ឈ្មោះ ណៃ នី ភេទប្រុស អាយុ ២៩ឆ្នាំ រស់នៅឃុំព្រៃតូច ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ទី៧.ឈ្មោះ អឿ សី ភេទប្រុស អាយុ ២០ឆ្នាំ រស់នៅឃុំ-ស្រុកជីក្រែង ខេត្តសៀមរាប។ ទី៨.ឈ្មោះ ស៊ឹម រស់ ភេទប្រុស អាយុ ២៩ឆ្នាំ រស់នៅឃុំ–ស្រុកក្រឡាញ់ ខេត្តសៀមរាប។ ទី៩.ឈ្មោះ ម៉ន ស្នា ភេទប្រុស អាយុ៣០ឆ្នាំ រស់នៅឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប។ ទី១០.ឈ្មោះ រ៉េត ចំរ៉ុង ភេទប្រុស អាយុ ២៣ឆ្នាំ រស់នៅឃុំព្រៃតូច ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ទី១១.ឈ្មោះ សូ ពិន ភេទប្រុស អាយុ ១៨ឆ្នាំ រស់នៅឃុំកំពង់ស្នោ ស្រុកជីក្រែង ខេត្តសៀមរាប ។ ទី១២.ឈ្មោះ ហី ផាយ ភេទប្រុស អាយុ ១៨ឆ្នាំ រស់នៅឃុំភ្នំលេប ស្រុកព្រះនេត្រ ខេត្តបន្ទាយមានជ័យ។ ទី១៣.ឈ្មោះ វ៉ាន់ ឌីណា ភេទប្រុស អាយុ ២១ឆ្នាំ រស់នៅឃុំគោល ស្រុកប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ។ ទី១៤.ឈ្មោះ សឿម តុញ ភេទប្រុស អាយុ ២៦ឆ្នាំ រស់នៅឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប។ ទី១៥.ឈ្មោះ យន់ លី ភេទប្រុសអាយុ ២៦ឆ្នាំ រស់នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ទី១៦.ឈ្មោះ ពេញ ថៃ ភេទប្រុស អាយុ ២០ឆ្នាំ រស់នៅស្រុកស្ទោង ខេត្តកំពង់ធំ។ ទី១៧.ឈ្មោះ ចេក វិចិត្រ ភេទប្រុស អាយុ ៣១ឆ្នាំ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ទី១៨.ឈ្មោះ ហី អ៊ិល ភេទប្រុស អាយុ ២៧ឆ្នាំ រស់នៅស្រុកព្រះនេត្រ ខេត្តបន្ទាយមានជ័យ។ ទី១៩.ឈ្មោះ រី រ៉ុម ភេទប្រុស អាយុ ៣០ឆ្នាំរស់នៅស្រុកមោងឫស្សី។ ទី២០.ឈ្មោះ ចេ រ៉ា ភេទស្រី អាយុ ២៨ឆ្នាំ រស់នៅស្រុកមោងឫស្សី និងទី២១.ឈ្មោះ ហី ផាត់ ភេទប្រុស អាយុ ២០ឆ្នាំ រស់នៅស្រុកព្រះនេត្រ ខេត្តបន្ទាយមានជ័យ៕ ដែន សីមា

## មជ្ឈមណ្ឌលសេវាកម្ម One stop service មួយបានបើកទ្វារដល់កម្មករចំណាកស្រុក

http://www.kohthmey.com/ 2018-4-24 14:58| sky | vietnamplus

ក្រសួងការងាររបស់ថៃបានបើកមជ្ឈមណ្ឌលសេវាកម្ម One stop service (OSS) នៅទូទាំងប្រទេសដើម្បីដំណើរការឯកសាររបស់ពលករចំណាកស្រុក។ នៅទីក្រុងបាងកកមជ្ឈមណ្ឌល OSS បានបើកទ្វាររបស់ខ្លួននៅតាមក្រសួងការងារ មន្ទីរពេទ្យ Tang Hua Seng មន្ទីរពេទ្យ Sirindhorn និងនៅតាមសួនឧទ្យាន Holland។ បច្ចុប្បន្ននេះមានពលករចំណាក ស្រុកចំនួន ១៥៨.០១១ នាក់នៅក្នុងទីក្រុងបាងកក។ នៅក្នុងតួលេខនេះ ១២០.៦៩២ នាក់បានបញ្ជាក់ពីសញ្ជាតិរបស់ពួកគេ ហើយ ៣៧.៣១៩ នាក់ទៀតនឹងធ្វើតាមបង្គាប់។ អ្នកដែលបានបញ្ចប់ដំណើរការត្រួតពិនិត្យនីតិសម្បទា ហើយបានទទួលការពិនិត្យសុខភាពរួចហើយរហូតមកដល់ចុងខែឧសភា ដើម្បីទទួលបានលិខិតអនុញ្ញាតការងារនៅមជ្ឈមណ្ឌល OSS ។

កម្មករអន្តោប្រវេសន៍ ដែលមានសញ្ជាតិនិងស្ថានភាពសុខភាព មិនទាន់ត្រូវបានពិនិត្យរហូតដល់ចុងខែមិថុនា ដើម្បីឆ្លងកាត់នីតិវិធីទាំងអស់។ មជ្ឈមណ្ឌល OSS នីមួយៗអាចដំណើរការរហូតដល់ ១.០០០ នាក់ក្នុងមួយថ្ងៃ។ កម្មករក្រៅស្រុកនៅក្រៅក្រុងបាងកក ត្រូវបានគេរំពឹងថានឹងមានថ្ងៃកំណត់ដដែល។ ទន្ទឹមនឹងនេះដែរ រដ្ឋមន្ត្រីក្រសួងការងារ លោកឧត្តមសេនីយ៍ Adul Saengsingkaew បានស្នើសុំឱ្យមន្ត្រីកណ្តាលរបស់ OSS ជួយកម្មករចំណាកស្រុកនៅក្នុងដំណើរការនេះ៕ ប្រែសម្រួល៖ sky

## ស្រណោះណាស់! ជីវិតកម្មករឆ្លងដែន ចូលឆ្នាំរួចត្រឡប់ទៅធ្វើការវិញ

https://www. Sabay News Tube .com/ 25-04-2018

នេះហើយផ្លូវកាត់ បីថ្ងៃពីរយប់ ដេកនៅក្នុងព្រៃ ហាលក្ដៅហាលភ្លៀង ហាលខ្យល់ហាលថ្ងៃ ម្នាក់ៗញ័រភ័យ ហារស្ដីមិនចេញ. ចាំគេមកយក ក្នុងចិត្តទួញសោក ដេកគិតដេកភ័យ បានបាយខ្វះទឹក បានព្រឹកខ្វះថ្ងៃ នឹកឡើង អាល័យអាណិតខ្លួនឯង .រីឯឡានវិញ ញាត់មនុស្សឡើងពេញ ម្នាក់ៗស្ទើស្លាប់ ទាហ៊ានតាមបាញ់ ឡានបើកប្រញ៉ាប់ បើសិនក្រឡាប់ នឹងស្លាប់ទាំងអស់.( សំពៅលូន ថ្ងៃទី២០-២៣ .០៤.២០១៨.ចាំគ្មានថ្ងៃភ្លេច) FB : Sor Cheang

**កម្លាំងសមត្ថកិច្ច ចុះបិទផ្ទះបននៅខណ្ឌដូនពេញ ឃាត់ខ្លួនជនសង្ស័យ ជនជាតិវៀតណាម ៣នាក់**

https://www.dap-news.com/kh/ ថ្ងៃពុធ, ២៥ មេសា ២០១៨ 13:25 ដោយ: ខា ដា ID:114

ភ្នំពេញ៖ កម្លាំងសមត្ថកិច្ច នៅព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨នេះ បានចុះឆែកឆេរ និងបិទទីតាំងផ្ទះបនមួយកន្លែង ស្ថិតនៅផ្ទះលេខ៧២ E0 ផ្លូវលេខ១២៦ ភូមិ២ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ ឃាត់ខ្លួនជនសង្ស័យជា ជនជាតិវៀតណាម ៣នាក់ ។

ប្រតិបត្តិការចុះបិទ ទីតាំងខាងលើនេះ គឺមានការចូលរួមពីលោកវរសេនីយទោ តាន់ វណ្ណារិទ្ធ អនុប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន លោកវរសេនីយឯក ជាន វុធ នាយកការិយាល័យប្រឆាំងការជួញដូរមនុស្ស ក្នុងប្រទេស និងមានការដឹកនាំដោយ លោក កុល បុន ព្រះរាជអាជ្ញារង នៃអយក្យការអមសាលាដំបូង រាជធានីភ្នំពេញ ។ សមត្ថកិច្ចបានឲ្យដឹងថា ជនសង្ស័យទាំង ៣នាក់មានឈ្មោះ៖ ទី១-ង្វៀង ហ៊ីអ៊ិក ភេទស្រី អាយុ៥៨ឆ្នាំ ជនជាតិវៀតណាម, ទី២-ង្វៀង មែន ភេទស្រី អាយុ២៨ឆ្នាំ ជនជាតិវៀតណាម និងទី៣-ង្វៀង ធូវ ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិវៀតណាម ។ រីឯជនរងគ្រោះឈ្មោះ ង្វៀង ត្រាវ ភេទស្រី អាយុ១៥ឆ្នាំ ជនជាតិវៀតណាម និងម្នាក់ទៀតឈ្មោះ ង្វៀង ធីលីង ភេទស្រី អាយុ១៩ឆ្នាំ ជនជាតិវៀតណាម ។ សមត្ថកិច្ចបន្តថា វត្ថុតាងដែលរឹបអូសបានរួមមាន៖ ក្នុងបន្ទប់លេខ១ ស្រោមមិនទាន់ប្រើចំនួន ១២, បន្ទប់លេខ២ ស្រោមមិនទាន់ប្រើចំនួន១ និងប្រើរួចចំនួន ១, បន្ទប់លេខ៣ ស្រោមមិនទាន់ប្រើចំនួន២, ក្នុងផ្ទះបាយ មានស្រោមប្រើរួចចំនួន ២, បន្ទប់ផ្ទាល់ដី មានសៀវភៅកត់ត្រា ៤ក្បាល ស្រោមមួយចំនួនធំ និងឧបករណ៍ប្រើប្រាស់ចំនួន ២ផងដែរ ។

បច្ចុប្បន្ន ជនសង្ស័យ និងជនរងគ្រោះ ត្រូវបានកម្លាំងសមត្ថកិច្ច កសាងសំណុំរឿងបញ្ជូន ទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីសាកសួរបំភ្លឺ ៕

## ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨

## យ៉ាងយូរដំណាច់ខែមិថុនា ពលករខ្មែរ ធ្វើការនៅថៃទាំងអស់ នឹងទទួលបានទិដ្ឋាការ ស្នាក់នៅ និងប័ណ្ណការងារស្របច្បាប់

https://www.dap-news.com/kh/ ថ្ងៃពុធ, ២៥ មេសា ២០១៨ 16:18 ដោយ: ដើមអម្ពិល ID:11

ភ្នំពេញ៖ កម្ពុជា-ថៃនឹងរួមគ្នាធ្វើយ៉ាងណាផ្ដល់ទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារ ដល់ពលករ ខ្មែរឱ្យរួចរាល់នៅដំណាច់ខែមិថុនាខាងមុខនេះ ដើម្បីឱ្យពលករទាំងនោះទទួលភាពស្របច្បាប់។ លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានបញ្ជាក់ឱ្យដឹង នៅថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៨នេះថា រាជរដ្ឋាភិបាលកម្ពុជាសហការជាមួយភាគីថៃ នឹងផ្ដល់ឯកសារស្រប ច្បាប់ជូនដល់ពលករខ្មែរ ដែលនៅមិនទាន់ស្របច្បាប់ប្រមាណ១២ម៉ឺន នាក់ទៀត ដែលកំពុងធ្វើការនៅ ប្រទេសថៃ ឱ្យបានរួចរាល់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ខាងមុខ។ លោកបានបន្តថា ដើម្បីសម្រេចតាមគោលដៅនេះ ភាគីទាំងពីរបានរៀបចំ កំណត់ទីតាំងបញ្ជីឈ្មោះ ពលករកម្ពុជា និងផ្ដល់ទិដ្ឋាការស្នាក់នៅ និងទិដ្ឋាការការងារជូនដល់ ពលករកម្ពុជា ដែលរៀបចំក្រុម ការងារចល័តនិងមជ្ឈមណ្ឌលធ្វើឯកសារលិខិតធ្វើដំណើរ និងប័ណ្ណអនុវត្តការងារដល់ពលករខ្មែរបន្ថែមទៀត ដើម្បីបង្កើនផ្ដល់ភាពស្រប ច្បាប់ដល់ពលករ។

សូមជម្រាបថាកាលពីពេលថ្មីៗនេះ ភាគីថៃបានបើកដំណើរការច្រកចេញចូលតែ ចំនួន៨០កន្លែង បន្ថែមទៀតនៅទូទាំងប្រទេស ក្នុងនោះមាន៤កន្លែង នៅទីក្រុងបាងកកនិង៧៦កន្លែងទៀត នៅតាម បណ្ដាខេត្តដើម្បីផ្ដល់ប័ណ្ណ

មិនមែនសញ្ជាតិថៃ ឬប័ណ្ណស៊ីជម្ពូ ដល់ ពលករខ្មែរដែលបានចុះបញ្ជី ឬបញ្ជាក់អត្តសញ្ញាណរួច ផ្តល់ទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារដល់ពលករដែលមានលិខិត ធ្វើដំណើរនិងលិខិតឆ្លងដែនផងដែរ។

លោក ហេងសួរបានស្វាគមន៍ ចំពោះភាគីថៃដែលបានពង្រីកសេវា ច្រកចេញចូលតែមួយនេះ ព្រោះ ជួយឱ្យការផ្តល់ឯកសារស្របច្បាប់ ដល់ពលករកម្ពុជាកាន់តែលឿនជាងមុន។ ជាក់ស្តែងគណៈកម្មការ ផ្តល់ភាពស្របច្បាប់របស់កម្ពុជាអាចទទួលពលករខ្មែរ មកធ្វើឯកសារបញ្ជាក់ សញ្ជាតិ និងប័ណ្ណពលករ កម្ពុជាប្រមាណ៧ម៉ឺននាក់ក្នុង១ខែ។ លោក ហេង សួរ ក៏បានអំពាវនាវដល់ពលករខ្មែរ ដែលនៅមិនទាន់មានភាពស្រប ច្បាប់ត្រូវរួសរាន់ ទៅធ្វើឯកសារស្របច្បាប់ឱ្យ បានទាន់ពេលវេលានៅតាមមជ្ឈមណ្ឌលធ្វើឯកសារលិខិតធ្វើដំណើរ និង ប័ណ្ណពលករ តាមក្រុមចល័តនានា ចៀសវាងការកេងប្រវ័ញ្ចយកផលប្រយោជន៍ ពិន័យ និងជាប់ទោស ជាដើម។

គួរបញ្ជាក់ថា បច្ចុប្បន្ននេះ មានពលករខ្មែរកំពុងធ្វើការនៅប្រទេសថៃ ប្រមាណ១.០៥០.០០០នាក់ ក្នុងនោះនៅសល់ពលករប្រមាណ១២ម៉ឺននាក់ទៀត នៅមិនទាន់ស្របច្បាប់។ នេះបើយោង តាមការចុះ ផ្សាយរបស់ទីភ្នាក់ងារសារព័ត៌មានកម្ពុជា( AKP)៕

## ពលករចំណាកស្រុកខុសច្បាប់ដេកតាមព្រៃដើម្បីចាំឡានមេខ្យល់មកយកទៅធ្វើការនៅប្រទេសថៃតាមច្រករបៀងដើមអំពិល

http://cambodiapolice.com/policekh/ 8:53 pm 25 មេសា 2018 187

**បន្ទាយមានជ័យ ៖** ក្រោយបុណ្យចូលឆ្នាំថ្មីហើយគេឃើញពលករចំណាកស្រុកខុសច្បាប់សម្រុកចេញតាមច្រករបៀងខុសច្បាប់ នឹងកំពុងដេករងចាំរថយន្តមេខ្យល់ថៃមកទទួលយកទៅធ្វើការសកម្មភាពនេះនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ ស្ថិតច្រករបៀងខុសច្បាប់ដើមអំពិល ក្នុងភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ។ ពលករចំណាកដោយខុសច្បាប់ទៅតាមរយៈមេខ្យល់បានសម្រុកចេញតាមច្រករបៀង ខុសច្បាប់ (ដើមអំពិល) ដែលគ្រប់គ្រងដោយកម្លាំងយោធាតំបន់ប្រតិបត្តការស្រុកម៉ាឡៃ ពលករចំណាកស្រុក កំពុងដេកតាមព្រៃចំការប្រមាណជិត១០០នាក់ ដែលរងចាំរថយន្តមេខខ្យល់ថៃមកទទួលពេលយប់ចេញទៅរកការងារធ្វើនៅទីក្រុងបាងកកប្រទេសថៃ។

ជាក់ស្តែងក្រោយថ្ងៃបុណ្យឆ្នាំថ្មីហើយរយៈពេលប៉ុន្មានថ្ងៃនេះឃើញមានប្រជាពលរដ្ឋខ្មែរជាពលករចំណាក់ស្រុកខុសច្បាប់តាមរយៈមេខ្យល់ឃើញសកម្មដេកកណ្តាលព្រៃប្រឈមគ្រោះថ្នាក់ចេញរាល់ថ្ងៃយប់តាមច្រករបៀងល្មើសច្បាប់(ដើមអំពិល)ដែលគ្រប់គ្រងដោយកម្លាំងយោធាខេត្ត។

សូមបញ្ជាក់ថា៖ខេត្តបន្ទាយមានជ័យមានព្រំដែនកម្ពុជា-ថៃ ប្រវែងជាង១៥៣គីឡូម៉ែត្រ ហើយមានជាប់៥ស្រុកក្រុងមួយ រួមមាន: ១.ស្រុកម៉ាឡៃ ២.ស្រុកអូរជ្រៅ ៣.ក្រុងប៉ោយប៉ែត ៤.ស្រុកស្វាយចេក ៥.ស្រុកថ្មពួក។ ហើយបើតាមរបាយការណ៍អភិបាលខេត្តបន្ទាយមានជ័យចាស់ ច្រករបៀងខុសច្បាប់ក្នុងខេត្តបន្ទាយមានជ័យមានចំនួន៦៣កន្លែង៕ ដោយ៖ចន្ទ្រា

## ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨
## ច្រករបៀងដើមអម្ពិលបើកឲ្យពលករចូលទៅធ្វើការនៅប្រទេសថៃខុសច្បាប់

http://nokorwatnews.com/ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៧

ខេត្តបន្ទាយមានជ័យ ៖ ក្រោយបុណ្យចូលឆ្នាំថ្មីហើយគេឃើញពលករចំណាកស្រុកខុសច្បាប់សម្រុកចេញតាមច្រករបៀងនិងកំពុងដេករង់ចាំរថយន្តមេខ្យល់ថៃមកទទួលយកទៅធ្វើការកាលពីថ្ងៃ១០កើត ខែ ពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវ នឹងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ស្ថិត ច្រករបៀងខុសច្បាប់ដើមអម្ពិល ក្នុងភូមិ សង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ។ ពលករចំណាកស្រុកដោយខុសច្បាប់ ទៅតាមរយៈមេខ្យល់បានសម្រុកចេញតាមច្រករបៀងខុសច្បាប់

(ដើមអម្ពិល) ដែលគ្រប់គ្រងដោយកម្លាំងយោធាតំបន់ប្រតិបត្តិការស្រុកម៉ាឡៃ ពលករចំណាក ស្រុកកំពុងដេកតាមព្រៃចម្ការប្រមាណជិត១០០នាក់ ដែលរង់ចាំរថយន្តមេខ្យល់ថៃ មកទទួលពេលយប់ចេញទៅរកការងារធ្វើនៅទីក្រុងបាងកក ប្រទេសថៃ។

ការលួចបើកច្រករបៀងខុសច្បាប់មិនគោរពតាមបទបញ្ជាសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ដែលបានដាក់វិធានការដល់អាជ្ញាធរខេត្ត ក៏ដូចជាកងកម្លាំងដែលឈរជើងតាមបន្ទាត់ព្រំដែនចូលលុបបំបាត់ច្រករបៀងល្មើស ច្បាប់បើមានលួចបើកអនាធិបតេយ្យតំបន់ ណាតំបន់នោះទទួលខុសត្រូវចំពោះមុខ ច្បាប់។ ជាក់ស្តែងក្រោយថ្ងៃបុណ្យឆ្នាំថ្មីហើយ រយៈពេលប៉ុន្មានថ្ងៃនេះឃើញមានប្រជា ពលរដ្ឋខ្មែរជាពលករចំណាកស្រុកខុសច្បាប់តាមរយៈមេខ្យល់ឃើញសកម្មដេក កណ្តាលព្រៃប្រឈមគ្រោះថ្នាក់ចេញរាល់ថ្ងៃយប់តាមច្រករបៀងល្មើសច្បាប់ ដែល គ្រប់គ្រងដោយកម្លាំងយោធាខេត្ត ។

សូមបញ្ជាក់ថា ខេត្តបន្ទាយមានជ័យ មានព្រំដែនកម្ពុជា-ថៃ ប្រវែងជាង១៥៣ គីឡូម៉ែត្រ ហើយមានជាប់៥ស្រុក ក្រុង មួយរួមមាន: ១.ស្រុកម៉ាឡៃ ២.ស្រុកអូរ ជ្រៅ ៣.ក្រុងប៉ោយប៉ែត ៤.ស្រុកស្វាយ ចេក ៥.ស្រុកថ្មពួក។ បើតាមរបាយការណ៍អភិបាលខេត្តបន្ទាយមានជ័យចាស់ ច្រក របៀងខុសច្បាប់ក្នុងខេត្តបន្ទាយមានជ័យមានចំនួន៦៣កន្លែង៕ ហេង នរិន្ទ្រ

## លោក ឡុង ឌីម៉ង់៖ ប្រទេសភាគច្រើន បញ្ជូនពលករទៅកូរ៉េ តម្រូវឲ្យតម្កល់ប្រាក់កក់ ៥ ពាន់ដុល្លារ តែកម្ពុជា មិនជ្រើសវិធានការនេះទេ

https://www.dap-news.com/kh/ សុក្រ, ២៧ មេសា ២០១៨ 08:25 ដោយ: ស៊ាន កុសល ID:119

ភ្នំពេញ៖ ឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ លោក ឡុង ឌីម៉ង់ បានអះអាងថា បណ្តាប្រទេសភាគច្រើន ដែលបានបញ្ជូនពលករ មកធ្វើការនៅប្រទេសកូរ៉េ គឺភាគច្រើន តម្រូវឲ្យតម្កល់ប្រាក់កក់ ៥០០០ដុល្លារ ប៉ុន្តែសម្រាប់កម្ពុជាវិញ គឺមិនជ្រើសរើសយក វិធានការណ៍នេះទេ។ ការអះអាងរបស់លោក ឡុង ឌីម៉ង់ បែបនេះគឺធ្វើឡើង ខណៈដែលបណ្តាទូត នៃប្រទេសបញ្ជូនពលករ មកកូរ៉េបានជួបប្រជុំគ្នា ជាមួយទីភ្នាក់ងារ អភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីដកស្រង់ពិសោធន៍ ពីគ្នាទៅវិញទៅមក ក្នុងការងារគ្រប់គ្រងពលករ ដោះស្រាយបញ្ហា ប្រឈមនានា របស់ពលករ ធ្វើឲ្យលក្ខ័ណ្ឌការងារ ក៏ដូចជាការរស់នៅរបស់បងប្អូនព លករឲ្យមានការគាំពារ យ៉ាងគត់មត់ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១៨។ លោក ឡុង ឌីម៉ង់ បានមានប្រសាសន៍ថា "ចំនុចមួយដែលខ្ញុំចាប់អារម្មណ៍ ពាក់ព័ន្ធនឹងវិធានការណ៍ កាត់បន្ថយពលករខុសច្បាប់នៅកូរ៉េ ប្រទេសភាគច្រើនគេ ឲ្យពលករតំកល់ប្រាក់កក់ ដល់ទៅ៥០០០$ មុននឹងចេញទៅកូរ៉េ រីឯកម្ពុជាវិញ យើងអត់ជ្រើសរើស វិធានការណ៍បែបនេះទេ យើងមានការបណ្តុះបណ្តាល បន្ថែមពេលបងប្អូន ចប់អាណត្តិ ហើយតម្រង់ទិស ទៅចូលទីផ្សារការងារ ដែលបងប្អូនមានជំនាញ ស្រាប់ហើយមាន ប្រាក់ខែខ្ពស់ទៀត"៕

## ពលករជិត១០០នាក់ រង់ចាំមេខ្យល់មកទទួលទៅធ្វើការនៅថៃ ដោយខុសច្បាប់នៅច្រករបៀង ត្រូវកម្លាំងមន្ត្រីជំនាញខេត្តបន្ទាយមានជ័យ អប់រំណែនាំ និងឲ្យទៅផ្ទះវិញ

http://freshnewsasia.com/ 2018-04-26

**(បន្ទាយមានជ័យ)៖** ពលករប្រុសស្រី ក្មេងចាស់ប្រមាណជិត១០០នាក់ បានមកសម្រាកក្បែរច្រករបៀងខុសច្បាប់ រង់ចាំរថយន្តមេខ្យល់មកទទួលទៅធ្វើការ នៅប្រទេសថៃ ដោយខុសច្បាប់ ត្រូវបានលោក សួន បវរ អភិបាលខេត្ត សហការជាមួយកម្លាំងមន្ត្រីជំនាញ ដែលឈរជើងនៅតំបន់នោះ ទៅពិនិត្យមើលជាក់ស្តែង និងប្រមូលផ្តុំពួកគាត់ ដើម្បីធ្វើការអប់រំណែនាំ និងឲ្យទៅផ្ទះវិញ។

ហេតុការណ៍នេះដែរ លោក សួន បវរ អភិបាលខេត្តបន្ទាយមានជ័យ បានឲ្យសារព័ត៌មានដឹងនៅ ព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨នេះថា លោកនឹងឲ្យស្នងការខេត្តសហការជាមួយកម្លាំងវរៈព្រំដែន ដែលឈរជើងនៅតំបន់នោះ ត្រូវ

ពិនិត្យមើលឯកសារ ធ្វើយ៉ាងណាឲ្យស្របច្បាប់ឲ្យពួកគាត់ ដែលស្ថិតនៅស្រុកម៉ាឡៃ និងស្រុកអូរជ្រៅ ដើម្បីបានទៅធ្វើការនៅប្រទេសថៃដោយស្របច្បាប់ផងដែរ។ លោកបានបន្តថា ពលករចំណាកដោយខុសច្បាប់ទៅតាមរយៈមេខ្យល់បានសម្រុកចេញតាមច្រករបៀងខុសច្បាប់ (ដើមអំពិល) ដែលគ្រប់គ្រងដោយកម្លាំងយោធាតំបន់ប្រតិបត្តការស្រុកម៉ាឡៃ ពលករចំណាកស្រុក កំពុងដេកតាមព្រៃចំការប្រមាណជិត១០០នាក់ ដែលរង់ចាំរថយន្តមេខ្យល់ថៃមកទទួល ដើម្បីពេលយប់ចេញទៅរកការងារធ្វើ នៅទីក្រុងបាងកក ប្រទេសថៃ។ លោកបានលើកឡើងទៀតថា តាមតំបន់ណាដែលលួចបើកច្រករបៀងខុសច្បាប់ មិនគោរពតាមបទបញ្ជាសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋ មន្ត្រីក្រសួងមហាផ្ទៃ ដែលបានដាក់វិធានការដល់អាជ្ញាធរខេត្ត ក៏ដូចជាកងកម្លាំងដែលឈរជើងតាមបន្ទាត់ព្រំដែន ចូលលុបបំបាត់ច្រករបៀងល្មើសច្បាប់ បើមានលួចបើកអាណាធិបតេយ្យតំបន់ណាតំបន់នោះ ទទួលខុសត្រូវចំពោះមុខច្បាប់។

ជាក់ស្តែងបន្ទាប់ពីបុណ្យចូលឆ្នាំថ្មីមក ពលករចំណាកស្រុកខុសច្បាប់សម្រុកចេញ តាមច្រករបៀងខុសច្បាប់នឹងកំពុងដេករង់ចាំរថយន្តមេខ្យល់ថៃ មកទទួលយកទៅធ្វើការដែលសកម្មភាពនេះ បានកើតឡើងកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ ស្ថិតច្រករបៀងខុសច្បាប់ (ដើមអំពិល) ស្រុកម៉ាឡៃ និងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ៕ ។

សូមបញ្ជាក់ផងដែរ ថាខេត្តបន្ទាយមានជ័យមានព្រំដែនកម្ពុជា-ថៃ ប្រវែងជាង១៥៣គីឡូម៉ែត្រ ហើយមានជាប់ក្រុងមួយ និងស្រុក៥ ដែលក្នុងនោះរួមមាន៖ ១.ស្រុកម៉ាឡៃ ២.ស្រុកអូរជ្រៅ ៣.ស្រុកថ្មពួក ៤.ស្រុកស្វាយចេក និងទី៥.ក្រុងប៉ោយប៉ែត។ តែបើតាមរបាយការណ៍អភិបាលខេត្តបន្ទាយមានជ័យចាស់ ច្រករបៀងខុសច្បាប់ក្នុងខេត្តបន្ទាយមានជ័យមានចំនួន៦៣កន្លែងផងដែរ៕

## ជម្លោះជុំវិញពលករបំរើតាមផ្ទះហ្វីលីពីននៅគុយវ៉ែត នាំដល់ការបណ្តេញនិងចាប់មន្ត្រីទូត

http://www.rasmeinews.com/ April 27, 2018, 4:48 AM

ជម្លោះរវាងគុយវ៉ែតនិងហ្វីលីពីនអំពីរបាយការណ៍ស្តីការរំលោភពលករហ្វីលីពីន បានប្រែជាអាក្រក់ឡើងកាលពីថ្ងៃព្រហស្បតិ៍ ទី២៦ មេសា ដោយហ្វីលីពីនបានសម្តែងការមិនសប្បាយចិត្តខ្លាំងចំពោះការដែលគុយវ៉ែតបណ្តេញឯកអគ្គរដ្ឋទូតរបស់ខ្លួន។ ជម្លោះនេះបានកើតមានបីខែមកហើយ បង្កឡើងដោយរបាយការណ៍ថា ជនហ្វីលីពីនជាច្រើនត្រូវបង្ខំធ្វើអត្តឃាតដោយសារតែការរំលោភពីនិយោជក (ថៅកែ) គុយវ៉េត។ ប្រទេសទាំងពីរបាន និងកំពុងធ្វើកិច្ចព្រមព្រៀងមួយដើម្បីការពារពលករកម្មករចំណាកស្រុក បន្ទាប់ពីហ្វីលីពីនហាមមិនអោយពលករខ្លួនបន្តទៅធ្វើការនៅគុយវ៉ែត។ តែកាលពីថ្ងៃពុធ គុយវ៉ែតបានបញ្ជាអោយឯកអគ្គរដ្ឋទូតហ្វីលីពីនចាកចេញក្នុងរង្វង់មួយសប្តាហ៍និងក៏បានកោះហៅតំណាងកុងស៊ុលរបស់ខ្លួន ក្រោយពីបុគ្គលិកស្ថានទូតបានព្យាយាមជួយសង្គ្រោះពលករបំរើការតាមផ្ទះនៅគុយវ៉ែតកាលពីចុងសប្តាហ៍។

ជម្លោះទំនងជាដល់ចំណុចកំពូល បន្ទាប់ពីសប្តាហ៍មុនវីដេអូបង្ហាញបុគ្គលិកទូតហ្វីលីពីនជួយសង្គ្រោះពលករហ្វីលីពីនដែលត្រូវបានគេចោទថាត្រូវថៅកែរំលោភ។ គុយវ៉ែត ថ្កោលទោសអំពើនេះដោយចាត់ទុកវាជាការរំលោភច្បាប់របស់ខ្លួនហើយក៏ប្រាប់អោយឯកអគ្គរដ្ឋទូតចាកចេញ។ ហ្វីលីពីនបានធ្វើការសុំទោស តែបានបញ្ជាក់ថា ស្ថានទូតចាត់វិធានការតាមការអំពាវនាវសុំជំនួយពីជនជាតិហ្វីលីពីនដែលមានបញ្ហា។

សូមរំលឹកថា កាលពីថ្ងៃសៅរ៍មុន ក្រសួងការបរទេសហ្វីលីពីនបានចេញវីដេអូពីរបង្ហាញក្រុមមកពីស្ថានទូតនៅគុយវ៉ែតជួយសង្គ្រោះពលករបំរើការតាមផ្ទះដោយវីដេអូមួយ បង្ហាញស្ត្រីម្នាក់រត់ចេញពីប្លុកអាគារនិងត្រូវគេជួយចូលក្នុងរថយន្ត។ ជនជាតិហ្វីលីពីន៤នាក់ដែលស្ថានទូតជួលមកជួយធ្វើការក៏ត្រូវប៉ូលិសគុយវ៉ែតចាប់ខ្លួន និងដីកាចាប់ខ្លួនក៏ត្រូវបានចេញសំរាប់បុគ្គលិកទូត៣នាក់។ ហ្វីលីពីននិយាយថា ខ្លួនប្រឆាំងជំទាស់អំពីការឃុំខ្លួនជនជាតិខ្លួន៤នាក់ ដែលបំរើការនៅស្ថានទូតរបស់ខ្លួននៅគុយវ៉ែត និងការចេញដីកាចាប់ខ្លួនបុគ្គលិកទូតបីនាក់ទៀត។ ឯកអគ្គរដ្ឋទូតបានជួប រដ្ឋមន្ត្រីការបរទេសហ្វីលីពីនកាលពីថ្ងៃអង្គារ ដើម្បីដោះស្រាយជម្លោះនិងបានយល់ព្រមលើវិធានការរារាំងកុំអោយមានឧបទ្ទវហេតុដូចនេះកើតមានជាថ្មីទៀត។

ក្រសួងការបរទេសហ្វីលីពីន កាលពីថ្ងៃព្រហស្បតិ៍បានកោះហៅឯកអគ្គរដ្ឋទូតគុយវ៉ែតមកទាមទារផ្តល់ការពន្យល់បកស្រាយថាហេតុអីបានជាគុយវ៉ែតចាត់វិធានការដូច្នេះ តែត្រូវបានគេប្រាប់ថាតំណាងគុយវ៉ែតបានចាកចេញពីហ្វីលីពីនតាំងពីថ្ងៃពុធមកម្ល៉េះ។ ក្រសួងការបរទេសហ្វីលីពីនបានបញ្ជូនកំណត់ហេតុការទូតមួយទៅស្ថានទូតគុយវ៉ែតដោយបង្ហាញការភ្ញាក់ផ្អើលនិងការមិនសប្បាយចិត្តជាខ្លាំងអំពីការប្រកាសថាឯកអគ្គរដ្ឋទូតRenato Pedro Villaជាបុគ្គលមិនត្រូវបានស្វាគមន៍"។ ពលករបំរើការតាមផ្ទះតំណាងអោយជាង៦៥ភាគរយនៃជនជាតិហ្វីលីពីនជាង២៦០.០០០នាក់ដែលធ្វើការនៅគុយវ៉ែត។ កាលពីខែកុម្ភៈ ប្រធានាធិបតីហ្វីលីពីន លោក រ៉ូឌ្រីហ្គោ ឌុយទែតេ បានអំពាវនាវអោយពលករហ្វីលីពីននៅគុយវ៉ែតវិលមកស្រុកវិញ ក្រោយការរកឃើញសាកសពរបស់ពលករបំរើការតាមផ្ទះម្នាក់ស្ថិតនៅក្នុងទូក្លាស្សេក្នុងផ្ទះដែលគេបោះបង់ចោលមួយ។ ពលករកម្មករហ្វីលីពីន នៅប្រទេសឈូងសមុទ្រជាច្រើនត្រូវបានជួលក្រោមប្រព័ន្ធស្ពនស័រមួយដែលអនុញ្ញាតអោយថៅកែរក្សាទុកលិខិតឆ្លងដែនរបស់គេនិងត្រួតត្រាពេញលេញលើការស្នាក់នៅរបស់ពួកគេ។

អង្គការសិទ្ធិមនុស្សមួយចំនួនបានត្អូញត្អែរជាយូរមកហើយថា បណ្តារដ្ឋឈូងសមុទ្រមិនមានលក្ខខណ្ឌការងារត្រឹមត្រូវទេសំរាប់កម្មករនិងពលករបំរើការតាមផ្ទះកំរៃទាប៕ ដោយៈ*វាសនា*

## សមត្ថកិច្ចបញ្ជូនខ្លួន ស្ត្រីជនជាតិវៀតណាម នៅតុលាការ ពាក់ព័ន្ធរឿងបើកហាងម៉ាស្សាបង្កប់សេវាផ្លូវភេទ

http://www.ann.com.kh/ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨

រាជធានីភ្នំពេញ៖ កម្លាំងសមត្ថកិច្ចនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ នៅព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨នេះ បានបញ្ជូនខ្លួនស្ត្រីជនជាតិវៀតណាមចំនួន ២នាក់ ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការបន្តតាមច្បាប់ ពាក់ព័ន្ធករណីបើកហាងម៉ាស្សា ផ្តល់សេវា រួមភេទ ដោយខុសច្បាប់។

យោងតាមការបញ្ជាក់ពីសមត្ថកិច្ច ជនសង្ស័យទី ១.ឈ្មោះ ង្វៀង ធីអ៊ុក ភេទស្រី អាយុ៥៨ឆ្នាំ និងទី២.ឈ្មោះ ង្វៀង ធីមាំង ភេទស្រី អាយុ២៨ឆ្នាំ។ សមត្ថកិច្ចឲ្យដឹងថា សំណុំរឿងនេះស្ថិតក្រោមចំណាត់ការរបស់លោកព្រះរាជអាជ្ញារង ស៊ិន វិរៈ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

គួររំលឹកថា ជនសង្ស័យទាំង ២នាក់ខាងលើត្រូវបាន កម្លាំងនគរបាល នាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ ឃាត់ខ្លួន កាលពីព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨កន្លងទៅ នៅចំណុចហាងម៉ាស្សាមួយកន្លែង នៅផ្ទះលេខ៧២ E0 ផ្លូវលេខ១២៦ ភូមិ២ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ។ នៅពេលចុះបង្ក្រាបសមត្ថកិច្ចបាន ជួយសង្គ្រោះជនរងគ្រោះ ជាក្មេងស្រីៗ ជនជាតិវៀតណាម ចំនួន ០២នាក់ និងដកបានស្រោមអនាម័យជាច្រើន មានទាំងប្រើរួច និងមិនទាន់ប្រើមួយចំនួនធំ៕ ដោយ៖ ឡុក សំរិត

## តុលាការឃុំខ្លួនស្ត្រីថៅកែហាងម៉ាស្សាបង្កប់បម្រើសេវាផ្លូវភេទពីរនាក់

http://www.rasmeinews.com/ April 27, 2018, 3:05 PM

*ដោយៈសរិទ្ធ/ភ្នំពេញ*.ស្ត្រីជនជាតិវៀតណាម២នាក់ជាថៅកែហាងម៉ាស្សាបង្កប់បម្រើសេវាផ្លូវភេទត្រូវចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញសម្រេចឃុំខ្លួនដាក់ពន្ធនាគារនៅល្ងាចថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨នេះក្រោមការចោទប្រកាន់ពីបទសញ្ចារកម្ម ។ ស្ត្រី២នាក់នេះឈ្មោះ ង្វៀង ធីអ៊ុក អាយុ៥៨ឆ្នាំ និងឈ្មោះ ង្វៀង ធីមាំង អាយុ២៨ឆ្នាំត្រូវនគបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ បានបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញកាលពីព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨ដើម្បីចាត់ការតាមនីតិវិធីពាក់ព័ន្ធ ករណីបើកហាងម៉ាស្សាផ្តល់សេវា រួមភេទដោយខុសច្បាប់។

គួររំលឹកថា ជនសង្ស័យទាំង ២នាក់ខាងលើត្រូវបាន កម្លាំងនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ ឃាត់ខ្លួនកាលពីព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨កន្លងទៅ នៅចំណុចហាងម៉ាស្សាមួយកន្លែង នៅផ្ទះលេខ៧២ E0 ផ្លូវលេខ១២៦ ភូមិ២ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ។នៅពេលចុះបង្ក្រាបសមត្ថកិច្ចបាន ជួយសង្គ្រោះជនរងគ្រោះ ជាក្មេងស្រីៗ ជនជាតិវៀតណាម ចំនួន ០២នាក់ និងដកបានស្រោមអនាម័យជាច្រើនមានទាំងប្រើរួច និងមិនទាន់ប្រើមួយចំនួនធំ។ទS/

## ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨
## ស៊ើបចេកគ្នាមើល ទែករកេមុខឃើញហើយជនកំណាចចាប់ក្មេងជះក្រលៀនលក់

http://tvonlines.club/ By Admin On Apr 29, 2018

ភ្នំពេញ៖ រឿងក្តីទិញ លក់ក្រលៀនឆ្លងដែន ដែលបានធ្វើអោយល្បីកក្រើកកាលពីចុងខែមេសា ឆ្នាំ២០១៨កន្លងទៅ ខណៈជនជាប់ចោទ២នាក់ កំពុងជាប់ឃុំឃាំងក្នុងពន្ធនាគារពីបទជួញដូរសរីរាង្គមនុស្សដោយខុសច្បាប់នោះ ឥឡូវនេះត្រូវបានសមត្ថកិច្ចចាប់ខ្លួនជនទី៣ម្នាក់ទៀតហើយ បញ្ជូនមកតុលាការដើម្បីសាកសួរ ។ មន្ត្រីនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញបានអោយដឹងថា ជនសង្ស័យទី៣ដែលត្រូវឃាត់ខ្លួននេះឈ្មោះ ជឿន ធី ហៅ ធីក្បាលធំ ភេទប្រុសអាយុ៣៨ឆ្នាំ មានមុខរបរជាកម្មករ និងជាអ្នករត់ ការឯកសារបញ្ជូនមនុស្សឆ្លងដែនទៅប្រទេសឥណ្ឌា ដើម្បីវះកាត់ដូរសរីរាង្គ ( ដូរក្រលៀន ) ។ នៅក្នុងសំណុំរឿងទិញ-លក់ក្រលៀន ដែលសមត្ថកិច្ចបានបង្ក្រាបកាលពីថ្ងៃទី ២៧មេសា ឆ្នាំ២០១៨កន្លងទៅនោះ ឈ្មោះ ជឿន ធី គឺជាអ្នករត់ការឯកសារអោយជនរងគ្រោះ និងជាអ្នកនាំជនរងគ្រោះមកជួប ឡាច ម៉េងហុង និង អឿ ឡាត ។ ប៉ុន្តែក្រោយចាប់ខ្លួនជនសង្ស័យ២នាក់នេះ ឈ្មោះ ជឿន ធី បានរត់គេចខ្លួនបាត់រហូតមកដល់ថ្ងៃចាប់ខ្លួនកាលពីថ្ងៃទី២៨មេសា ឆ្នាំ២០១៨នេះ ។ ឥឡូវនេះឈ្មោះ ជឿន ធី ត្រូវបានបញ្ជូនមកអោយលោក ខៀវ ផល្លា ព្រះរាជអាជ្ញារងកំពុងធ្វើការសាកសួរនាំព្រឹកថ្ងៃទី២៧មេសានេះ ។

គួររំលឹកថាចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ២៨មេសា ២០១៨ នេះបានសម្រេចចេញដីការឃុំខ្លួន ជនសង្ស័យប្រុសស្រី២នាក់ពាក់ពន្ធករណីជួញដូរក្រលៀន ដាក់ពន្ធនាគារជាបណ្តោះអាសន្ន ក្រោមការចោទប្រកាន់ពីបទជួញដូរមនុស្សឆ្លងដែនដោយខុសច្បាប់ (ដកហូតសរីរាង្គ) តាមមាត្រា១០ និងមាត្រា១៥ នៃច្បាប់ស្តីពីអំពើប្រឆាំងការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ។ ជនជាប់ចោទដែលតុលាការឃុំខ្លួនឈ្មោះ ឡាច ម៉េងហុង ភេទប្រុស អាយុ៣៤ឆ្នាំ មានអាស័យដ្ឋាននៅភូមិព្រែកឯក សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ( ជាមេខ្យល់ ) និងម្នាក់ឈ្មោះ អើ ឡាត ភេទស្រី អាយុ៣៨ឆ្នាំ ស្នាក់នៅផ្ទះជួលក្នុងសង្កាត់ចោមចៅ រាជធានីភ្នំពេញ ។

គួបញ្ជាក់ថា ជនសង្ស័យប្រុសស្រី ២នាក់ ម្នាក់ជាមេខ្យល់ និងម្នាក់ជាអ្នកគួកជេរ(រកមនុស្ស) ក្នុងករណីជួញដូរក្រលៀន កាលពីថ្ងៃទី២៨ មេសា ត្រូវបានសមត្ថកិច្ចនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជនរាជធានីភ្នំពេញធ្វើការស្រាវជ្រាវ រហូតឈានដល់ការឃាត់ខ្លួន ជនសង្ស័យម្នាក់ឈ្មោះ ឡាច ម៉េងហុង ភេទប្រុស អាយុ៣៤ឆ្នាំ មានអាស័យដ្ឋាននៅភូមិព្រែកឯក សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ(ជាមេខ្យល់) និងម្នាក់ឈ្មោះ អើ ឡាត ភេទស្រី អាយុ៣៨ឆ្នាំ ស្នាក់នៅផ្ទះជួលក្នុងសង្កាត់ចោមចៅ រាជធានីភ្នំពេញ ។ ទាក់ទិន និង ការឃាត់ខ្លួនសង្ស័យទាំង២នាក់ខាងលើនេះត្រូវបានលោកវរៈសេនីយ៍ឯក កែវ ជា ប្រធានការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងកាពារអនិតិជន រាជធានីភ្នំពេញឲ្យដឹងថា កន្លងទៅការិយាល័យធ្លាប់បានទទួលព័ត៌មាន និងពាក្យបណ្តឹងជាញឹកញ៉ាប់ ពីករណីមានជនល្មើសមួយក្រុមរកស៊ីជួញដូរក្រលៀន ក្នុងរូបភាពនាំមនុស្សពីស្រុកខ្មែរទៅវះដោះដូរនៅប្រទេសឥណ្ឌា ។

ក្រោយពីទទួលបានព័ត៌មាននោះសមត្ថកិច្ចជំនាញ បានធ្វើការស្រាវជ្រាវ រហូតដល់សៀលថ្ងៃទី២៨ មេសាឈានដល់ការឃាត់ខ្លួនស្ត្រីម្នាក់ នៅខាងក្រោយផ្សារឯករាជ្យ២ តាមផ្លូវវេងស្រេង សង្កាត់ចោមចៅ ខណ្ឌពោធិសែនជ័យរាជធានីភ្នំពេញ លុះវេលាម៉ោងជាព្យប់ថ្ងៃដដែលចាប់បានបុរសម្នាក់ទៀតជាមេក្លោង នៅម្តុំស្តុបបូកគោ សង្កាត់ទន្លេបា

សាក់ ខណ្ឌចំការមន ។ លោកវរៈសេនីយ៍ឯក កែវ ធា បន្តថា ក្រោយពេលចាប់ខ្លួនជនសង្ស័យបានសារភាពថា ពួកគេគឺជាមុខសញ្ញាជួញដូរក្រលៀនពិតប្រាកដមែន និងធ្លាប់បានធ្វើសកម្មភាពជាង១ឆ្នាំហើយ និងធ្វើបានជាង១០នាក់ ដែលនាំមនុស្សយកទៅវះកាត់ដោះដូរក្រលៀន នៅប្រទេសឥណ្ឌា ដែលមានទីតាំងនៅទីក្រុងញូដាលី ។ តាមចម្លើយជនសង្ស័យបានប្រាប់សមត្ថកិច្ចទៀតថា ជាមួយឆ្នាំនេះបុរសឈ្មោះ ឡាច ម៉េងហុង បានទាក់ទងធ្វើសកម្មភាពប្រើមនុស្សឲ្យដើររកអ្នកជម្ងឺដែលត្រូវការក្រលៀន ហើយក៏គេត្រូវការរកមនុស្ស ឬជនក្រីក្រត្រូវការប្រាក់ដើម្បីទ្រទ្រង់ជីវភាព(លក់ក្រលៀន) ។

ក្នុងនោះជនសង្ស័យបានប្រើល្បិចខ្ពស់ តាមរូបភាពពីរ១.ដំបូងត្រូវការពិនិត្យឈាមជនរងគ្រោះអ្នកលក់ក្រលៀនឲ្យត្រូវគ្នាជាមួយអ្នកជម្ងឺត្រូវដោះដូរក្រលៀន ២.ត្រូវការកែឆ្នៃឯកសារជនរងគ្រោះ(អ្នកលក់ក្រលៀន)ធ្វើជាសាច់ញាតិអ្នកដែលត្រូវការ(ទិញក្រលៀន)ប៉ុន្តែជាអ្នកដ៏ទៃទេ ដើម្បីងាយស្រួលគេរៀបចំធ្វើឯកសារជាលក្ខណៈធ្វើមនុស្សធម៌ ក្នុងការនាំចេញទៅដោះដូរនៅប្រទេសឥណ្ឌានោះ ។ ចម្លើយបញ្ជាក់ថា ក្រលៀនមួយឈ្មោះ ឡាច ម៉េងហុង យកពីអ្នកជម្ងឺតម្លៃជាង ៤ម៉ឺនដុល្លារអាមេរិក តែក្នុងតម្លៃជាង៤ម៉ឺនដុល្លារនោះ គេបានយកទៅចំណាយលើការកែឆ្នៃឯកសារ ដើម្បីដាក់ចូលស្ថានទូតឥណ្ឌាសម្រាប់នាំមនុស្សចេញ និងថ្លៃយន្តហោះ ការហូបចុក និងការស្នាក់នៅ ។ ដូច្នោះខ្លួននៅសល់ប្រាក់ពីការចំណាយត្រឹម៥ ៨០០ ដុល្លារក្នុងម្នាក់តែប៉ុណ្ណោះ ។

ចំណែកចម្លើយស្ត្រីដែលជាជនសង្ស័យឈ្មោះ អ៊ើ ឡាត បានសារភាពប្រាប់សមត្ថកិច្ចថា ខ្លួនទើបតែចូលរួមធ្វើសកម្មភាពជាមួយឈ្មោះ ឡាច ម៉េងហុង ២ដងទេ និងដើររកបានមនុស្ស២នាក់ប្រគល់ឲ្យ ម៉េងហុង នាំទៅវះកាត់ដោះដូរក្រលៀននៅប្រទេសឥណ្ឌានោះ ។ ជនសង្ស័យបន្តថា មនុស្ស២នាក់នោះ ត្រូវបានឈ្មោះ ម៉េងហុង ឲ្យសេវាម្នាក់៤០០ទៅ៥០០ដុល្លារអាមេរិក តែក៏បានកុម្មុយស្បងពីអ្នកលក់ក្រលៀន និងអ្នកជម្ងឺត្រូវការទិញក្រលៀនខ្លះទៀតដែរ ។ បានជាមានការរៀបចំ និងរកមនុស្ស(អ្នកលក់ និងអ្នកទិញក្រលៀន) ទៅធ្វើការវះកាត់ ដោះដូរនៅប្រទេសឥណ្ឌានោះ ព្រោះវេជ្ជបណ្ឌិតនៅទីនោះយកតម្លៃថោក ពោលគឺធ្វើការវះកាត់ដោះដូរក្រលៀនមនុស្សម្នាក់អស់តែ១៥.០០០ ទៅ ១៧.០០០ដុល្លារអាមេរិក(ថ្លៃកាំបិត) មិនមែនថ្លៃក្រលៀនទេ ថ្លៃក្រលៀន៥.៨០០ដុល្លារផ្សេង ។ លោក កែវ ធា បន្តថា ជនសង្ស័យជាមេខ្យល់ឈ្មោះ ឡាច ម៉េងហុង គេមានបណ្ដាញទំនាក់ទំនងនៅក្នុងស្រុកហួតដល់ប្រទេសឥណ្ឌា រីឯស្ត្រីម្នាក់នោះគ្រាន់តែជាមនុស្សដែលឈ្មោះ ឡាច ម៉េងហុង ប្រើ និងឲ្យដើរអូសទាញជនក្រីក្រត្រូវការប្រាក់(លក់ក្រលៀន) ប៉ុណ្ណោះ ៕

## **អាវុធហត្ថរាជធានីភ្នំពេញ បង្ក្រាបករណីជួញដូរមនុស្ស ក្រោមរូបភាពយកប្ដីចិន ជាថ្មីទៀតហើយ!**

https://www.dap-news.com/kh/ សៅរ៍, ២៨ មេសា ២០១៨ 18:07 ដោយ: ID:027

នៅព្រឹកថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨នេះ សមត្ថកិច្ចអាវុធហត្ថរាជធានីភ្នំពេញ បានបញ្ជូនបុរសជនជាតិចិន ០៣នាក់ និងនារីខ្មែរ ០១នាក់ ទៅតុលាការពាក់ព័ន្ធករណីជួញដូរមនុស្សឆ្លងដែន ទៅប្រទេសចិនក្រោមរូបភាពសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និង រំដោះនារីរងគ្រោះបាន០២នាក់។ ហើយរូបភាពជួញដូរបែបនេះអាវុធហត្ថរាជធានីភ្នំពេញ ក៏ធ្លាប់បានបង្ក្រាបដូចគ្នា កាលពីចុងឆ្នាំ ២០១៧ និង ដើមឆ្នាំ ២០១៨ និងធ្លាប់បានសង្គ្រោះនារីរងគ្រោះ០២នាក់ ឃាត់ខ្លួនមេខ្យល់០២នាក់ផងដែរ ដែលកាលនោះក្នុង ចំណោមនារីរងគ្រោះទាំង០២នាក់ មានម្នាក់ជាអនិតិជន(អាយុក្រោម១៨ឆ្នាំ) ត្រូវបានមេខ្យល់នាំឆ្លងដែនទៅចិន តាមប្រទេស វៀតណាម និងត្រូវបានមេខ្យល់វៀតណាម រំលោភតាមផ្លូវភេទ ហើយ ទើបប្រគល់ឱ្យមេខ្យល់ចិន លក់បន្តទៅបុរសចិន ០៣នាក់ទៀត ដើម្បីបម្រើផ្លូវភេទជាបន្តបន្ទាប់ ហួតដល់អាវុធហត្ថរាជធានីភ្នំពេញរំដោះបានត្រលប់មកស្រុក កំណើតវិញក្នុងខែកុម្ភៈឆ្នាំ២០១៨។

ដោយឡែកចំពោះករណីជួញដូរមនុស្សឆ្លងដែនថ្មីនេះ ត្រូវបានសមត្ថកិច្ចអាវុធហត្ថរាជធានីភ្នំពេញធ្វើការបង្ក្រាបបានតាមរយៈ ការសហការណ៍ផ្ដល់ព័ត៌មានពីអង្គការមេត្រីភាព អន្តរជាតិ ហៅកាត់ថា AIM SWAT នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ ដោយអង្គការ AIM SWAT បានរាយការណ៍មកសមត្ថកិច្ចអាវុធហត្ថថា បានឃើញសកម្មភាពមនុស្សមួយក្រុម មានគ្នា០៧នាក់ មានស្ត្រី០៣នាក់ ជាជនជាតិខ្មែរ និងបុរស ០៣នាក់ជាជនជាតិចិន និងប្រុសម្នាក់

ទៀតប្រហែលជនជាតិខ្មែរ បានកំពុងពិភាក្សាគ្នា រៀបចំឯកសារ ចេញទៅប្រទេសចិន ក្រោមរូបភាពរៀបអាពិហ៍ពិពាហ៍ នៅចំណុចហាងកាហ្វេឈ្មោះ ប៉ូណា ផ្លូវលេខ៥៣BT សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ដោយខាងអង្គការAIM SWAT មានការសង្ស័យថាជាអំពើជួញដូរមនុស្ស ទើបស្នើសុំជំនួយមក បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ ដើម្បីជួយអន្តរាគមន៍រំដោះជនរងគ្រោះ។ ក្រោយពេលទទួលបានរបាយការណ៍របស់អង្គការ AIM SWAT លោកវរសេនីយ៍ត្រី សេន កូម៉ុន នាយការិយាល័យបទល្មើស ជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានធ្វើការស្រាវជ្រាវ រកឃើញមនុស្ស០៦នាក់ នៅក្នុងផ្ទះសំណាក់ម្កុដមាស ក្បែរផ្សារទំនើបស្ទឹងមានជ័យ។

តាមរយៈវិធានការជំនាញរបស់អាវុធហត្ថរាជធានីភ្នំពេញ ជនសង្ស័យបានសារភាពថា៖ ឈ្មោះ JI JIAXIN ជនជាតិចិន និងប្រពន្ធឈ្មោះ តែម អឿន ជនជាតិខ្មែរ គឺជាមេខ្យល់ កន្លងមកអ្នកទាំងពីរធ្លាប់បាននាំនារីខ្មែរឱ្យទៅរៀបការយកប្តីចិន បានចំនួន០៣នាក់មកហើយ១.ឈ្មោះ ស្រីថន អាយុ ២២ឆ្នាំ, ២.ឈ្មោះ យ៉ុន ចាន់នី អាយុ២០ឆ្នាំ និង៣.ឈ្មោះ អារីម អាយុ២១ឆ្នាំ តែបច្ចុប្បន្នពុំមានដំណឹងពីពួកនាងទេ (សមត្ថកិច្ចកំពុងស្រាវជ្រាវរកដំណឹងពួកនាងទាំង០៣នាក់)។ ហើយករណីថ្មីនេះពួកគេទាំងពីរនាក់ប្តីប្រពន្ធ បានណែនាំឱ្យនារីរងគ្រោះពីរនាក់ផ្សេងទៀត ឈ្មោះ គ.ព អាយុ ២៤ឆ្នាំ កំព្រាឪពុក រស់នៅខេត្តតាកែវ និង ជនរងគ្រោះឈ្មោះ ថ.រ អាយុ២៧ឆ្នាំ កំព្រាទាំងឪពុកនិងម្តាយ រស់នៅខេត្តតាកែវ ឱ្យរៀបការយកប្តីចិន ដោយសន្យាថាបានទទួលថ្លៃទឹកដោះ ម្នាក់៤,០០០ដុល្លារ។

ក្រោយមកមេខ្យល់០២នាក់ប្តីប្រពន្ធ បាននាំបុរសជនជាតិចិន០២នាក់ឈ្មោះ ZHANG LIANG អាយុ២៧ឆ្នាំ និងឈ្មោះ YAN FAN អាយុ២៨ឆ្នាំ ឲ្យមកជួបជាមួយក្រុមគ្រួសារជនរងគ្រោះ និងបានធ្វើពិធីភ្ជាប់ពាក្យរវាង ឈ្មោះ ZHANG LIANG ជាមួយនារីរងគ្រោះ ឈ្មោះ គ.ព រួចរាល់ក្នុងថ្ងៃទី២២.០៤.២០១៨ បន្ទាប់មកនៅថ្ងៃទី២៣.០៤.២០១៨ មេខ្យល់ពីរនាក់ប្តីប្រពន្ធ និងបុរសជនជាតិចិន ០២នាក់ទៀត រួមជាមួយជនរងគ្រោះទាំង០២នាក់ បាននាំគ្នាឡើងមកភ្នំពេញដើម្បីធ្វើឯកសារឆ្លងដែនទៅប្រទេសចិន ក្រោមរូបភាព រៀបអាពាហ៍ពិពាហ៍។ លុះដល់យប់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ មនុស្សទាំង០៦នាក់ខាងលើនេះ បាននាំគ្នាចូលសម្រាក នៅផ្ទះ សំណាក់ម្កុដមាស ដោយបំបែកបន្ទប់គ្នា មួយបន្ទប់មួយគូរៗ ក៏ត្រូវអាវុធហត្ថរាជធានីភ្នំពេញ ស្រាវជ្រាវរកឃើញ និងធ្វើការឃាត់ខ្លួន កសាងសំណុំរឿងបញ្ជូនមេខ្យល់និងជនជាប់ពាក់ព័ន្ធសរុប០៤នាក់ទៅតុលាការដើម្បីផ្តន្ទាទោស រីឯនារីរងគ្រោះ០២នាក់ត្រូវបាន មន្ទីរសង្គមកិច្ចនិងអង្គការ AIM SWAT ប្រឹក្សាផ្តល់សេវាការងារមានប្រាក់បៀវត្សសមរម្យឲ្យ ពួកនាងនិងក្រុមគ្រួសា បានស្ម័គ្រចិត្ត ទទួលសេវាការងារតាមការ ប្រឹក្សានិងសម្តែងការសប្បាយចិត្ត ត្រេកអរជាអនេក។

## សមត្ថកិច្ចថៃបង្ក្រាបទីតាំង ទទួលធ្វើប័ត្រស៊ីជម្ពូ ក្លែងក្លាយនិងប័ណ្ណបើកបរក្លែងក្លាយ

http://www.khaokhmer.com/ By Khao Khmer April 30, 2018

កាលពីពេលថ្មីកន្លងទៅនេះ កម្លាំងសមត្ថកិច្ចតំរួតទីក្រុងបាងកក ប្រទេសថៃ បានធ្វើការបង្ក្រាបទីតាំងផលិតប័ត្រស៊ីជម្ពូ របស់ពលករបរទេស ក្លែងក្លាយ មួយកន្លែងស្ថិតនៅសង្កាត់(មីនបុរី) នាទីក្រុងបាងកក ប្រទេសថៃ ។ ក្នុងការបង្ក្រាបទីតាំងផលិត ប័ត្រស៊ីជម្ពូ ក្លែងក្លាយខាងលើនេះ កម្លាំងសមត្ថកិច្ច តម្រួតថៃ បានរឹបអូស បានប័ត្រស៊ីជម្ពូ ក្លែងក្លាយ និងប័ណ្ណបើកបររថយន្ត ក្លែងក្លាយចំនួនជាច្រើនសន្លឹកផងដែរ។